ពន្លឺ

# សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង



ភិក្ខុ ថាច់ ប្រីជា គឿន (សុធម្មប្បញ្ញោ)

ព. ស. ២៥៦៤ គ. ស. ២០២០

# ពន្លឺ

# សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង

ភិក្ខុ ចាច់ ប្រីជា គឿន (សុធម្មប្បញ្ញោ)

ព. ស. ២៥៦៤ គ. ស. ២០២០

**ពន្លឺសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង**
និពន្ធដោយ ភិក្ខុ ថាច់ ប្រីជា គឿន (សុធម្មប្បញ្ញោ)
បោះពុម្ពលើកទី ១ ចំនួន ១០០០ ក្បាល នៅប្រទេសកម្ពុជា
ឧបត្ថម្ភបោះពុម្ពដោយ ព្រះតេជព្រះគុណ សឹង យ៉ឹង រតនា (សុវណ្ណប្បញ្ញោ)
អ៊ីម៉ែល៖ thachpreicheakoeun@gmail.com
គេហទំព័រ៖ www.preicheakoeun.com
ISBN-13: 978-9924-9321-1-6
9 789924 932116 >

# មាតិកា


**អារម្ភកថា** ៧

**វគ្គទី ១ សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង** ១០

- អំពី សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង ១១
- ជនជាតិដើមខ្មែរក្រោម និងសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង ២៤
- តារាងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិរបស់ អ.ស.ប. ២៩
- លក្ខណសម្បត្តិជា «ប្រទេស» មួយ នៅក្នុងច្បាប់អន្តរជាតិ ៣៨
- នីតិវិធីក្នុងការបង្កើតជា «ប្រទេស» មួយ ៤២

**វគ្គទី ២ កម្ពុជាក្រោម** ៥១

- តារាងកម្ពុជាក្រោមនៅក្នុងរបបគ្រប់គ្រងនីមួយៗ ៥៤

■ **អំពី កម្ពុជាក្រោម** ៥៥

- កម្ពុជាក្រោមក្នុងសម័យអាណានិគមបារាំង (១៨៥៩-១៩៥៩) ៦១
- ការកសាងវិមាននរោត្តម ៦៤
- កម្ពុជាក្រោមចូលជាសហភាពឥណ្ឌូចិន ៦៥
- ការបែងចែកខេត្តខ័ណ្ឌនៅកម្ពុជាក្រោមក្នុងសម័យបារាំង ៦៧

■ **កម្ពុជាក្រោម ពីឆ្នាំ ១៩៤១ ដល់ ១៩៧៥** ៧៣

- ជប៉ុនចូលដណ្តើមអំណាចពីបារាំង ជំរុញឲ្យ បាវ ដាយ ប្រកាសឯករាជ្យ ឆ្នាំ ១៩៤៥ ៧៤
- យៀក មិញ ដណ្តើមអំណាច បង្ខំឲ្យ បាវ ដាយ ដាក់រាជ្យ ឆ្នាំ ១៩៤៥ ៧៦
- ហូ ជី មិញ ប្រកាសឯករាជ្យ បាវ ដាយ ចុះចូលជាមួយនឹង យៀក មិញ ៧៧
- បាវ ដាយ ផ្តាច់ខ្លួនចេញពី ហូ ជី មិញ ហើយនិរទេសទៅហុងកុង ៧៨
- កម្ពុជាក្រោមក្នុងសម័យ «សាធារណរដ្ឋស្វយ័តកូស័ងស៊ីន» (១៩៤៦-១៩៤៨) ៧៩
- កម្ពុជាក្រោមក្នុងសម័យ «រដ្ឋាភិបាលបណ្តោះអាសន្នវៀតណាម» ៨៣
- បារាំងបង្កើតផែនការ «ដំណោះស្រាយ បាវ ដាយ» ដើម្បីប្រឆាំង យៀក មិញ ៨៦
- សន្ធិសញ្ញាសមុទ្រហាឡុង ឆ្នាំ ១៩៤៨ ៨៨
- ហូ ជី មិញ ថ្កោលទោស បាវ ដាយ និង បារាំង ៨៩
- កិច្ចព្រមព្រៀងរវាង វ៉ាំងសង់ អូរីយ៉ូល និង បាវ ដាយ មុនពេលបារាំងផ្ទេរកម្ពុជាក្រោមទៅយួន ៩១
- បារាំងប្រគល់ដែនដីកម្ពុជាក្រោម ឲ្យទៅ បាវ ដាយ ឆ្នាំ ១៩៤៦ ៩៦
- នីតិវិធីនៃការប្រគល់ទឹកដីកម្ពុជាក្រោម ឲ្យទៅ បាវ ដាយ ៩៧
- ការបង្កើតសភាកូស័ងស៊ីន ៩៨
- គម្រោងច្បាប់ភ្ជាប់ទឹកដីកម្ពុជាក្រោមទៅវៀតណាម ១០២
- បារាំងប្រកាសច្បាប់ភ្ជាប់ទឹកដីកម្ពុជាក្រោមទៅជាមួយនឹងវៀតណាម ១០៥

- ច្បាប់លេខ ៤៩-៧៣៣ ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ១៩៤៩ កែប្រែលក្ខន្តិកៈកូស័ងស៊ីន ១០៧

■ **៧០ ឆ្នាំ កម្ពុជាក្រោម បន្តនៅក្រោមអាណានិគមយួន ១៩៤៩ - ២០១៩** ១០៨

- កម្ពុជាក្រោមក្នុងសម័យ «រដ្ឋវៀតណាម» ១៩៤៩ - ១៩៥៥ ១០៨
- សន្និសីទទីក្រុងហ្សឺណែវ ឆ្នាំ ១៩៥៤ ពុះប្រទេសវៀតណាមចេញជាពីរ ១១០
- កិច្ចព្រមព្រៀងស្តីពីបទឈប់បាញ់គ្នា ១១២
- សេចក្តីប្រកាសចុងក្រោយ នៃសន្និសីទទីក្រុងហ្សឺណែវស្តីពីឥណ្ឌូចិន ១១៣
- បារាំងដកអាណានិគមទាំងស្រុងចេញពីកម្ពុជាក្រោម ឆ្នាំ ១៩៥៦ ១១៨

■ **កម្ពុជាក្រោមក្នុងសម័យសាធារណរដ្ឋវៀតណាម ១៩៥៥ - ១៩៧៥** ១១៩

- កម្ពុជាក្រោមក្នុងរបបផ្តាច់ការ ងោ ឌិញ យេម ១៩៥៥ - ១៩៦៣ ១២១
- ការតស៊ូរបស់ព្រះសង្ឃខ្មែរក្រោមឲ្យគោរពសិទ្ធិពុទ្ធសាសនា ឆ្នាំ ១៩៦៣ ១២៣
- កម្ពុជាក្រោមក្នុងរបប ង្វៀង វ៉ាំង ទេវ (១៩៦៧ - ១៩៧៥) ១២៧
- ការតស៊ូដើម្បីរក្សានូវនាទីជាជនជាតិភាគតិច ឆ្នាំ ១៩៦៩ ១២៨
- បាតុកម្មប្រឆាំងនឹងការចាប់ព្រះសង្ឃផ្សឹកឲ្យទៅធ្វើជាទាហាន ១៣២
- របបសាធារណរដ្ឋវៀតណាមត្រូវដួលរលំ ឆ្នាំ ១៩៧៥ ១៣៦

■ **៤៥ ឆ្នាំ កម្ពុជាក្រោមនៅក្រោមរបបយួនកុម្មុយនីស្ត ពីឆ្នាំ ១៩៧៥ ដល់ បច្ចុប្បន្ន** ១៣៧

- ព្រឹត្តិការណ៍ ១៦ វិច្ឆិកា ១៩៧៦ ១៤០
- ករណីកាសេហាសិប (KC-50) ១៤៥
- ករណីរណសិរ្សតស៊ូខ្មែរកម្ពុជាក្រោមនៅខេត្តទឹកខ្មៅ ១៤៩
- ករណី ភិក្ខុ ថាច់ លីភោ នៅខេត្តព្រះត្រពាំង ឆ្នាំ ២០០៥ ១៥០
- ចលនាសម្ព័ន្ធជាតិនិយមខ្មែរកម្ពុជាក្រោម ១៥១
- ករណី ភិក្ខុ គឹម ស៊ីសំណា ឆ្នាំ ២០០៦ ១៥៣
- ករណី ភិក្ខុ ស៊ឺន ចែងចើន, ភិក្ខុ ថាច់ ធន, ភិក្ខុ សឺន លំអាន ឆ្នាំ ២០០៧ ១៥៤
- ព្រឹត្តិការណ៍ ៨ កុម្ភៈ ឆ្នាំ ២០០៧ ១៥៧
- បាតុកម្មរបស់ខ្មែរក្រោមនៅក្រៅប្រទេសថ្កោលទោសរបបយួន ១៥៨
- ករណី ភិក្ខុ អៀង សុខធឿន នៅប្រទេសកម្ពុជា ឆ្នាំ ២០០៧ ១៥៩
- ករណី ព្រះតេជព្រះគុណ ទឹម សាខន ឆ្នាំ ២០០៧ ១៦១
- ករណី លោក វិញ បា នៅខេត្តឃ្លាំង ឆ្នាំ ២០១០ ១៦៣
- ករណី លោក ចៅ ហេន នៅខេត្តមាត់ជ្រូក ឆ្នាំ ២០១០ ១៦៤
- ករណី ភិក្ខុ លី ចិន្តា ត្រូវយួនច្រកចូលបាវធ្វើទារុណកម្ម ឆ្នាំ ២០១៣ ១៦៥
- ករណី ភិក្ខុ ថាច់ ធឿន និង ភិក្ខុ លីវ នី នៅវត្តសិរីតាសេក ខេត្តឃ្លាំង ឆ្នាំ ២០១៣ ១៦៥
- ករណីដណ្តើមដីធ្លីនៅខេត្តក្រមួនស ឆ្នាំ ២០២០ ១៦៧

- តារាងឈ្មោះខេត្ត ក្រុង កោះ នៅដែនដីកម្ពុជាក្រោម ឆ្នាំ ២០២០ ១៦៩

**វគ្គទី ៣ ប្រជុំអត្ថបទ ស្តីពី ដែនដីកម្ពុជាក្រោម** ១៧១

- អត្ថន័យនៃសញ្ញា «រាហូចាប់ចន្ទ» នៅក្នុងសង្គមខ្មែរក្រោម ១៧២
- ប្រវត្តិទង់ជាតិកម្ពុជាក្រោម ១៧៥
- ជំនោរសេរីភាព ១៨០
- ខ្ញុំមានសុបិនមួយសម្រាប់ខ្មែរក្រោម ១៨៤
- ចង់បានសិទ្ធិម្ចាស់ការលើទឹកដី ត្រូវមានសិទ្ធិម្ចាស់ការលើទឹកចិត្តជាមុន ១៨៧
- ១៦ វិច្ឆិកា បង្ហាញពីទឹកចិត្តខ្មែរក្រោម «រស់ព្រោះហ៊ានស្លាប់» ១៩០
- សេរីភាព និង សុភមង្គលគ្មានទេ បើគ្មានសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង ១៩៤
- ការចាប់ លោក ថៅ ហេន ដាក់គុក ជាចន្លុះដុតបេះដូងខ្មែរក្រោម ១៩៦
- វៀតណាមមិនអាចបិទបាំងនូវអំពើរើសអើងពូជសាសន៍មកលើខ្មែរក្រោមបានទៀតទេ ១៩៩
- វៀតណាម សិទ្ធិជនជាតិដើមបែបជើងជាប់ខ្នោះ ១០២
- របបកុម្មុយនីស្តយួននឹងត្រូវដួលរលំ ដោយសារចលនាជនជាតិដើម និងលទ្ធិប្រជាធិបតេយ្យ ២០៤
- ធ្វើយ៉ាងណាទើបដឹងថា នរណាជាខ្មែរក្រោម នរណាជាយួន ១០៩
- មើលទង់ពុទ្ធសាសនា ឃើញទង់ជាតិកម្ពុជាក្រោម ២១៣
- កូស័ងស៊ីន មិនមែនមានន័យថា «នាងទី ៩ សុំ» ទេ ២១៨

# អារម្ភកថា

សៀវភៅ **«ពន្លឺសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង»** ដែលលោកអ្នកកំពុងតែអាននោះ ជាកម្រងឯកសារមួយស្ដីអំពី «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ដែលមានចែងនៅក្នុងច្បាប់អន្តរជាតិ កាលប្បវត្តិនៃដែនដីកម្ពុជាក្រោម នៅក្នុងរបបគ្រប់គ្រងនីមួយៗតាំងពីសម័យដើមរហូតដល់បច្ចុប្បន្ន និងអត្ថបទផ្សេងៗដើម្បីដាស់ស្មារតីឲ្យពលរដ្ឋខ្មែរក្រោមចេះប្រើប្រាស់នូវសិទ្ធិរបស់ខ្លួន ក្នុងការអនុវត្តនូវ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ក្នុងនាមជាជនជាតិដើម នៃដែនដីកម្ពុជាក្រោម ។

គោលបំណងនៃការសរសេរជាសៀវភៅនេះ ដោយសារ ខ្ញុំព្រះករុណា អាត្មាភាព ចង់នាំយកពន្លឺនៃសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯងនេះ ទៅអុជបំភ្លឺឲ្យភ្លឺសព្វសាយទូទាំងដែនដីកម្ពុជាក្រោម ទីដែលពលរដ្ឋខ្មែរក្រោមរាប់លាននាក់កំពុងតែរស់នៅក្នុងទីងងឹតនៃគុកឥតជញ្ជាំងរបស់របបអាណានិគមយួន សព្វថ្ងៃ ។ តាមរយៈការអាននូវសៀវភៅនេះ ពលរដ្ឋខ្មែរក្រោមនឹងបានយល់នូវសិទ្ធិជាមូលដ្ឋានរបស់ខ្លួន និងបានដឹងនូវពង្សាវតាររបស់ខ្លួនជាជនជាតិដើមនៃដែនដីកម្ពុជាក្រោម ហើយមានសេចក្ដីក្លាហានក្នុងការអនុវត្តនូវ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» នៅលើទឹកដីកំណើតរបស់ខ្លួនយោងតាមច្បាប់អន្តរជាតិ ។

វគ្គទីមួយនៃសៀវភៅនេះ និយាយអំពី «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង»ក្នុងនោះ មានបញ្ជាក់អំពីនិយមន័យ គោលការណ៍ ប្រវត្តិ និងច្បាប់អន្តរជាតិនានា ដែលជាប់ទាក់ទងនឹងសិទ្ធិដ៏សំខាន់មួយនេះ ។ ក្នុងវគ្គនេះ ក៏មាននិយាយអំពីគោលការណ៍ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» របស់ប្រជាជាតិខ្មែរក្រោម ដែលបានកំណត់ដោយ សហព័ន្ធខ្មែរកម្ពុជាក្រោម ផងដែរ ។ តាមរយៈការតស៊ូជានិរន្តរ៍របស់ សហព័ន្ធខ្មែរកម្ពុជាក្រោម ដើម្បីទាមទារនូវសិទ្ធិនេះ ពលរដ្ឋខ្មែរក្រោមនឹងទទួលបានលទ្ធផលបីយ៉ាង គឺ ទីមួយ **«រួមរស់»** ជាមួយគ្នានៅក្នុងប្រទេសមួយដែលមានចម្រុះជាតិសាសន៍ តែត្រូវមានការគោរពសិទ្ធិឲ្យបានពេញលេញក្នុងនាមខ្មែរក្រោមជាជនជាតិដើម, ទីពីរ **«ស្វ័យភាព»** ដែនដីកម្ពុជាក្រោមនឹងក្លាយទៅជាតំបន់ស្វយ័ត ឬមានរដ្ឋាភិបាលស្វ័យ

គ្រប់គ្រងរបស់ខ្លួនមួយ យោងតាមមាត្រាទី ៤ នៃសេចក្តីប្រកាសរបស់ អ.ស.ប. ស្តីពីសិទ្ធិជនជាតិដើម ដែលបានចែងថា ជនជាតិដើមមានសិទ្ធិស្វយ័ត (Autonomy) ឬស្វ័យគ្រប់គ្រងដោយខ្លួនឯង (Self-Government) លើបញ្ហាទាំងឡាយដែលទាក់ទងនឹងកិច្ចការផ្ទៃក្នុង និងកិច្ចការនៅតាមមូលដ្ឋានរបស់ខ្លួន, និងទីបី **«ឯករាជ្យ»** ដែលមានអធិបតេយ្យភាពពេញលេញនៅលើទឹកដីរបស់ខ្លួន ។ ការអនុវត្តនូវសិទ្ធិនេះ នៅពេលដែលរបបអាណានិគមយួននៅតែបន្តជិះជាន់ និងរារាំងនូវដំណើរការអនុវត្តនូវសិទ្ធិផ្សេងៗជាមូលដ្ឋានរបស់ខ្មែរក្រោមនៅដែនដីកម្ពុជាក្រោម ព្រោះថា **«ទីណាមានការគាបសង្កត់ ទីនោះមានការរើបម្រះ»** ។ ក្រៅពីនេះ ក៏មាននិយាយអំពីលក្ខណសម្បត្តិជាប្រទេសមួយ និងនីតិវិធីក្នុងការបង្កើតជាប្រទេសមួយតាមច្បាប់អន្តរជាតិ ផងដែរ ។

វគ្គទីពីរ និយាយអំពីកាលប្បវត្តិ នៃដែនដីកម្ពុជាក្រោម តាំងពីសម័យដើមរហូតដល់សម័យបច្ចុប្បន្ន ។ ក្នុងនោះ មានសម័យកម្ពុជាក្រោមនៅក្នុងអាណាចក្រខ្មែរ, សម័យយួនចូលវាតទី និងឈ្លានពានទឹកដីខ្មែរ, សម័យអាណានិគមបារាំង, របបសាធារណរដ្ឋវៀតណាម និងរបបយួនកុម្មុយនីស្តសព្វថ្ងៃ ។

ចុងក្រោយ វគ្គទីបី ជាអត្ថបទផ្សេងៗដែលខ្ញុំព្រះករុណា អាត្មាភាព បានសរសេរ និងបានចុះផ្សាយនៅលើទំព័រ កាសែត ព្រៃនគរ និង គេហទំព័រ វិទ្យុសំឡេងកម្ពុជាក្រោម (VOKK) នាពេលកន្លងមក ហើយបានប្រមូលមកចងក្រងនៅក្នុងសៀវភៅនេះ ។ នេះជាអត្ថបទស្តីពីរឿងរ៉ាវផ្សេងៗនៅដែនដីកម្ពុជាក្រោម ដែលមានបញ្ចូលនូវទស្សនៈខ្លះៗដើម្បីដាស់ស្មារតីឲ្យពលរដ្ឋខ្មែរក្រោម ចេះប្រើនូវសិទ្ធិជាមូលដ្ឋានរបស់ខ្លួនក្នុងនាមជាម្ចាស់ស្រុកនៃដែនដីកម្ពុជាក្រោម ។

អ្វីដែលមាននៅក្នុងសៀវភៅនេះ គ្រាន់តែជាចំណែកដ៏តូចមួយ នៃការស្រាវជ្រាវរបស់ខ្ញុំព្រះករុណា អាត្មាភាព តែប៉ុណ្ណោះ វាត្រូវការសិក្សា និងស្រាវជ្រាវបន្ថែមទៀតដើម្បីឲ្យខ្លឹមសារនៃប្រធានបទនេះ មានអត្ថន័យទូលំទូលាយ និងគ្រប់ជ្រុងជ្រោយ ។ម្យ៉ាងទៀត ខ្ញុំព្រះករុណា អាត្មាភាព ក៏សូមអភ័យទោសទុកជាមុន ផងដែរ ចំពោះកំហុសឆ្គងទាំងឡាយដោយអចេតនា ដែលបានកើតឡើងនៅក្នុងសៀវភៅនេះ និង

ប្រសិនបើមានចំណុចណាមួយលើសលស់ខ្វះខាត ក៏សូមលោកអ្នកជួយផ្ដល់យោបល់កែលម្អដាក់ទានផង ដើម្បីការបោះលើកក្រោយបានល្អប្រសើរជាងមុន ។

ដោយអំណាចនៃវិរិយភាពដែលកើតចេញពីការនិពន្ធ និងរៀបរៀងជាសៀវភៅនេះ សូមឲ្យប្រជាជាតិខ្មែរក្រោមគ្រប់រូប ឆាប់បានទទួលសិទ្ធិសេរីភាពជាមូលដ្ឋានរបស់ខ្លួន និងបានទទួលនូវ **«ពន្លឺសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង»** នៅលើទឹកដីកម្ពុជាក្រោម ដូចជាជាតិសាសន៍នានាក្នុងពិភពលោក ក្នុងពេលឆាប់ៗខាងមុខកុំបីខាន ។

វត្តខេមររង្សី ទីក្រុង San Jose រដ្ឋ California សហរដ្ឋអាមេរិក
ថ្ងៃព្រហស្បតិ៍ ២ រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព. ស. ២៥៦៤
ត្រូវនឹងថ្ងៃទី ៣១ ខែធ្នូ គ. ស. ២០២០

**ភិក្ខុ ថាច់ ប្រីជា គឿន (សុធម្មបញ្ញោ)**

# វគ្គទី ១
# សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង

# អំពី
# សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង

**«សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង»** ជាពាក្យដែល សហព័ន្ធខ្មែរកម្ពុជាក្រោម បានបង្កើតឡើងដើម្បីធ្វើជាមាគ៌ាតស៊ូរបស់ខ្លួន ក្នុងការទាមទារឲ្យមានការ **«រួមរស់»** ប្រកបដោយការគោរពសិទ្ធិសេរីភាពឲ្យបានពេញលេញ, **«ស្វ័យភាព»** និង **«ឯករាជ្យ»** នៅលើទឹកដីកម្ពុជាក្រោម ក្នុងនាមខ្មែរក្រោមជាជនជាតិដើម ។ ពាក្យនេះ កើតមកពីពាក្យ «The Right to Self–Determination» ដែលអង្គការសហប្រជាជាតិ បានចែងនៅក្នុងធម្មនុញ្ញរបស់ខ្លួន និងនៅក្នុងច្បាប់អន្តរជាតិផ្សេងៗទៀត ដោយចាប់បង្ខំឲ្យប្រទេសហត្ថលេខីនានាក្នុងពិភពលោកត្រូវតែអនុវត្តតាម ។ ពាក្យនេះ ក៏មានចែងនៅក្នុង «សេចក្ដីប្រកាសរបស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិជនជាតិដើម» ដែលបានអនុម័តកាលពីឆ្នាំ ២០០៧ ផងដែរ ។

ពាក្យ **«Self-Determination»** នៅក្នុងភាសាអង់គ្លេស ជាពាក្យដែលបង្កប់ដោយអត្ថន័យរួម សំដៅលើ **«ភាពម្ចាស់ការលើខ្លួនឯង»** ឬ **«ការកំណត់ការគ្រប់គ្រងដោយខ្លួនឯង»** ឬ **«ការសម្រេចចិត្តដោយខ្លួនឯង»** ឬក៏ **«ការសម្រេចវាសនាដោយខ្លួនឯង»** ដោយមិនមានការជ្រៀតជ្រែក ឬបង្គាប់បញ្ជាពីភាគីខាងក្រៅ ។

វចនានុក្រម Merriam-Webster បានពន្យល់ពាក្យ «Self-Determination» នៅក្នុងភាសាអង់គ្លេសមានអត្ថន័យ ២ យ៉ាងគឺ៖

*“ ១. សេរីភាពក្នុងការសម្រេចចិត្តជ្រើសរើសនូវសកម្មភាព និងឋានៈរបស់ខ្លួន ដោយមិនចាំបាច់មានការបង្ខិតបង្ខំពីខាងក្រៅ ។*

*២. ការកំណត់ ឬការសម្រេចចិត្តដោយប្រជាជននៃដែនដីមួយអំពីឋានៈនយោបាយអនាគតផ្ទាល់ខ្លួនរបស់ពួកគេ” ។* [1]

ស្រដៀងគ្នានេះដែរ វចនានុក្រម Oxford Learner's Dictionaries បានពន្យល់

[1] ‘Self-determination.’ Merriam-Webster.com Dictionary, Merriam-Webster, (ស្រង់ប្រភព៖ ២៣ ធ្នូ ២០២០), https://www.merriam-webster.com/dictionary/self-determination ។ អត្ថន័យដើមជាភាសាអង់គ្លេស៖ 1: free choice of one's own acts or states without external compulsion. 2: determination by the people of a territorial unit of their own future political status.

ពាក្យ «Self-Determination» មានអត្ថន័យ ២ យ៉ាងគឺៈ

*" ១. សិទ្ធិរបស់ប្រជាជន នៃប្រទេស ឬតំបន់ណាមួយក្នុងការទទួលបាននូវឯករាជ្យ និងជ្រើសរើសនូវរដ្ឋាភិបាល និងប្រព័ន្ធនយោបាយរបស់ពួកគេដោយខ្លួនឯង ។ ឧទាហរណ៏ៈ ប្រជាជាតិទាំងអស់ ត្រូវមានសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង ។ ដែនដីកំពុងតែស្វែងរកសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯងខាងនយោបាយ ។ សទិសន័យ ឬន័យដូចគ្នានឹងពាក្យ «ឯករាជ្យ» ។*

*២. សិទ្ធិ ឬសមត្ថភាពរបស់មនុស្សម្នាក់ក្នុងការគ្រប់គ្រងនូវជោគវាសនាដោយខ្លួនឯងរបស់ពួកគេ ។* [2]

ដូច្នេះ **«សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង»** ជាការកំណត់ការគ្រប់គ្រងដោយខ្លួនឯង ដោយមិនមានការជ្រៀតជ្រែក ឬបង្ខិតបង្ខំពីភាគីខាងក្រៅឡើយ ។ យោងតាមសិទ្ធិនេះ ជាតិសាសន៍នីមួយៗអាចបង្កើតជាប្រទេសជាតិ «ឯករាជ្យ» ដាច់ដោយឡែករបស់ខ្លួនមួយ ឬរួមជាមួយនឹងជាតិសាសន៍ផ្សេងៗទៀត បង្កើតទៅជាប្រទេសជាតិមួយដែលមានចម្រុះជាតិសាសន៏ ផ្អែកលើគោលការណ៏សមភាព និងគោរពសិទ្ធិគ្នាជាមូលដ្ឋាន ។

សព្វថ្ងៃ សហព័ន្ធខ្មែរកម្ពុជាក្រោម (KKF) ដែលមានមូលដ្ឋាននៅក្រៅប្រទេសកំពុងតែធ្វើចលនាតស៊ូដោយសន្តិវិធី និងអហិង្សានៅលើឆាកអន្តរជាតិ ដើម្បីជំរុញឲ្យខ្មែរក្រោមបានទទួលនូវ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ក្នុងនាមជាជនជាតិដើមនៅលើទឹកដីកម្ពុជាក្រោម ដោយផ្អែកលើច្បាប់អន្តរជាតិ និង «សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើម» (UNDRIP) ដែលបានអនុម័តកាលពីថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០០៧ ថាៈ

[2] "Self-determination." Oxford Learner's Dictionaries, (ស្រង់ប្រភពៈ ២៣ ធ្នូ ២០២០), https://is.gd/pjEGjp
អត្ថន័យដើមជាភាសាអង់គ្លេសៈ 1. the right of a country or a region and its people to be independent and to choose their own government and political system. *All nations have the right to self-determination. The territory is seeking political self-determination.* SYNONYM **independence**. 2. the right or ability of a person to control their own fate.

*“ជនជាតិដើមមានសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង ។ យោងតាមស្មារតីនៃសិទ្ធិនេះ ពួកគេកំណត់នូវឋានៈនយោបាយរបស់ខ្លួនដោយសេរី និងធ្វើការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ខ្លួនដោយសេរី”* ។ [3]

សហព័ន្ធខ្មែរកម្ពុជាក្រោម បានបញ្ជាក់ថា ដោយផ្អែកលើស្មារតីនៃការតស៊ូជានិរន្តរ៍ក្នុងការទាមទារសិទ្ធិនេះ និងយោងតាមកាលៈទេសៈ ប្រជាជាតិខ្មែរក្រោមនឹងទទួលបានលទ្ធផល ៣ យ៉ាងគឺ៖

*“១/ **រួមរស់** ក្នុងរដ្ឋអំណាចអាណានិគម ដោយមានការគោរពសិទ្ធិសេរីភាពពេញលេញ គោរពយុត្តិធម៌ និងកិត្តិយសពូជសាសន៍ នៃជនជាតិដើម ។ តួយ៉ាងដូចស្ថានភាព នៃជនជាតិដើមឥណ្ឌាន [4] នៅសហរដ្ឋអាមេរិក ។*

*២/ **ស្វ័យភាព** ក្នុងនោះ ជនជាតិដើមមានរដ្ឋាភិបាលដោយខ្លួនឯង ប៉ុន្តែឋិតនៅក្រោមលក្ខខណ្ឌរបស់រដ្ឋអំណាចសហភាព (Federation ឬ Union) ។ តួយ៉ាងដូចស្ថានភាពនៃតំបន់នូណាវុត (Nunavut) នៅប្រទេសកាណាដា ។*

*៣/ **ឯករាជ្យ** ក្នុងនោះ ជនជាតិដើម មានរដ្ឋាភិបាលគ្រប់គ្រងដោយខ្លួនឯង ដោយម្ចាស់ការពេញទីលើដែនដីរបស់ខ្លួន ។ តួយ៉ាងដូចស្ថានភាពនៃ កូសូវ៉ូ នៅប្រទេសយូហ្គូស្លាវី (Yugoslavia)”* ។ [5]

ចាប់តាំងពីទ្រឹស្តី «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» បានបង្កើតឡើងរហូតមកទល់ពេលនេះ អត្ថន័យទ្រឹស្តីនេះ ត្រូវបានគេយកទៅអនុវត្តអនុលោមតាមគោលការណ៍ និងទិសដៅរៀងៗខ្លួន ។

---

[3] មាត្រា ៣ នៃសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើម (UNDRIP), (ស្រង់ប្រភព៖ ២៣ ធ្នូ ២០២០), https://is.gd/uKKEoG

[4] «ឥណ្ឌាន» ជាជនជាតិដើមនៅសហរដ្ឋអាមេរិក ដែលគេស្គាល់ឈ្មោះជាទូទៅថា American Indians, Native Americans, First Americans, Indigenous Americans ។

[5] KKF, (២០០៩), សៀវភៅមគ្គុទ្ទេសក៍ ផ្លូវទៅយកសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង, ទំព័រ ១៣ - ១៤

នៅឆ្នាំ ១៩១៨ ទ្រឹស្តីនេះ ត្រូវបានអ្នកនយោបាយពីររូបដែលមានគំនិតផ្ទុយពីគ្នាយកទៅឃោសនាដើម្បីបម្រើគោលដៅរបស់ខ្លួន ។ ប្រធានាធិបតីសហរដ្ឋអាមេរិក វូតរ៉ូ វិលសុិន (Woodrow Wilson) បានយកទ្រឹស្តីនេះទៅប្រើក្នុងគោលបំណងរំសាយនូវការឈ្លានពានរបស់ប្រទេសមហាអំណាចមួយចំនួន ដូចជា ចក្រភព អូទ្រីស-ហុងគ្រី, អាល្លឺម៉ង់ និង ចក្រភព អូតូម៉ង់ ដែលចាញ់សង្គ្រាមនៅក្នុងសង្គ្រាមលោកលើកទី ១ ។ បន្ទាប់ពីបានថ្លែងសេចក្តីប្រកាសនូវគោលការណ៍សន្តិភាព «១៤ ចំណុច» (Fourteen Points) [6] ដើម្បីបញ្ចប់សង្គ្រាមលោកលើកទី ១ នៅថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ១៩១៨ ប្រធានាធិបតី វិលសុិន បានថ្លែងស្តីពី «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ថា៖

> *"វាល់គោលបំណងរបស់ប្រទេសជាតិត្រូវតែបានគេគោរព ។ ឥឡូវនេះ ប្រជាជនអាចត្រូវគេត្រួតត្រា និងគ្រប់គ្រងដោយការយល់ព្រមរបស់ខ្លួនគេផ្ទាល់ ។ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» មិនមែនគ្រាន់តែជាពាក្យមួយឃ្លានោះទេ វាជាគោលការណ៍ចាំបាច់ត្រូវឲ្យមានសកម្មភាព"* ។ [7]

ស្របពេលជាមួយគ្នានោះដែរ វ្លាឌីមៀរ អុីលីច លេនីន (Vladimir Ilyich Lenin) ជាមេដឹកនាំបដិវត្តរុស្ស៊ី ឆ្នាំ ១៩១៧ បានយកគោលការណ៍ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ដើម្បីឃោសនាប្រឆាំងនឹងអ្វីមួយដែលលទ្ធិកុម្មុយនីស្តរបស់គាត់ហៅថា «អាណានិគមនិយម» និង «ចក្រពត្តិនិយម»។ គោលការណ៍នេះ ត្រូវបានអន្តរជាតិទទួលស្គាល់យ៉ាងទូលំទូលាយ នៅក្នុងរយៈពេលមួយដែលដំណើរការលុបបំបាត់របបអាណានិគមនិយមកាន់តែកើនឡើងនៅលើពិភពលោក ។

នៅក្នុងសង្គ្រាមលោកលើកទី ២ គោលការណ៍ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ត្រូវបានដាក់បញ្ចូលទៅក្នុង «ធម្មនុញ្ញអាត្លង់ទិក» (Atlantic Charter) ដែល

---

[6] United States, "Address of the President of the United States, Delivered at a Joint Session of the Two Houses of Congress, January 8, 1918." HathiTrust Digital Library, (ស្រង់ប្រភព៖ ២៣ ធ្នូ ២០២០), https://is.gd/43eljb

[7] United States, "President Wilson's Address to Congress, Analyzing German and Austrian Peace Utterances (Delivered to Congress in Joint Session on February 11, 1918)", www.gwpda.org, (ស្រង់ប្រភព៖ ២៣ ធ្នូ ២០២០), http://www.gwpda.org/1918/wilpeace.html

បានចុះហត្ថលេខានៅថ្ងៃទី ១៤ ខែសីហា ឆ្នាំ ១៩៤១ ដោយប្រធានាធិបតីសហរដ្ឋអាមេរិក Franklin D. Roosevelt និង នាយករដ្ឋមន្ត្រីអង់គ្លេស Winston Churchill ជាអ្នកដែលបានសន្យាលើចំណុចសំខាន់ទាំង ៨ នៃធម្មនុញ្ញនេះ ។ ធម្មនុញ្ញនេះ ត្រូវបានគេទទួលស្គាល់ថាជាសិទ្ធិស្របច្បាប់អន្តរជាតិមួយ បន្ទាប់ពីវាត្រូវបានគេចុះបញ្ជីយ៉ាងច្បាស់ថាជាសិទ្ធិមួយនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ ។ នៅក្នុងកថាខណ្ឌទី ៣ នៃធម្មនុញ្ញអាត្លង់ទិក បានបញ្ជាក់ថា៖

*"ទីបី ពួកគេគោរពនូវសិទ្ធិរបស់ប្រជាជនទាំងអស់ក្នុងការជ្រើសរើសនូវទម្រង់រដ្ឋាភិបាលដែលពួកគេនឹងរស់នៅ ។ ហើយពួកគេមានបំណងចង់ឃើញនូវសិទ្ធិអធិបតេយ្យ និងរដ្ឋាភិបាលខ្លួនឯងត្រូវបានបង្កើតឡើងវិញ ចំពោះអ្នកដែលត្រូវគេដកហូតដោយបង្ខំ"* ។ [8]

បន្ទាប់មក កថាខណ្ឌនេះបានក្លាយជាចំណុចសំខាន់មួយក្នុងចំណោមចំណុចសំខាន់ទាំង ៨ នៃ ធម្មនុញ្ញអាត្លង់ទិក ដែលបានចែងថា *"ប្រជាជនទាំងអស់មានសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង"*(*All people had a right to self-determination*) ។ [9]

ក្រោយមក គោលការណ៍ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ត្រូវបានទទួលស្គាល់នៅក្នុងកតិកាសញ្ញាអន្តរជាតិនានា ក្នុងនោះ គោលការណ៍នេះ បានទទួលស្គាល់ជាលើកដំបូងនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ (UN Charters) នាឆ្នាំ ១៩៤៥ ។

នៅក្នុងកថាខណ្ឌទី ២ ប្រការទី ១ ជំពូកទី ១ ស្ដីពីវត្ថុបំណង និងគោលច្បាប់របស់ធម្មនុញ្ញនៃអង្គការសហប្រជាជាតិបានចែងថា៖

*"អភិវឌ្ឍទំនាក់ទំនងមិត្តភាពក្នុងចំណោមប្រជាជាតិនានាដោយផ្អែកលើការគោរពគោលការណ៍សិទ្ធិស្មើភាព និងការសម្រេចវាសនាខ្លួនដោយខ្លួនឯងរបស់ប្រជាជន និងចាត់វិធានការសមស្របផ្សេងទៀត ដើម្បីពង្រឹងសន្តិភាពជាសកល"* ។ [10]

---

[8] Nato, 'The Atlantic Charter' - Declaration of Principles Issued by the President of the United States and the Prime Minister of the United Kingdom.' NATO, (ស្រង់ប្រភព៖ ២៣ ធ្នូ ២០២០), https://is.gd/ig9HJS

[9] Atlantic Charter, (២២ ធ្នូ ២០២០), Wikipedia, https://en.wikipedia.org/wiki/Atlantic_Charter

[10] កថាខណ្ឌទី ២ ប្រការ ១ នៃ ធម្មនុញ្ញ អ.ស.ប. ឆ្នាំ ១៩៤៥, UN, www.un.org/en/charter-united-nations/index.html

ក្រោយឆ្នាំ ១៩៤៥ គោលការណ៍ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» មានការរីកចម្រើន ពេលដែលការអនុវត្តជាក់ស្តែងនូវផែនការលុបបំបាត់របបអាណានិគមនៅក្នុងក្របខណ្ឌនៃអង្គការសហប្រជាជាតិ ។ បន្ទាប់ពី មហាសន្និបាត អ.ស.ប. បានចេញសេចក្តីសម្រេចលេខ 1514 (XV) ថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ១៩៦០ ស្តីពី «ការប្រកាសប្រគល់នូវឯករាជ្យជូនប្រទេស និងប្រជាជនដែលនៅក្រោមអាណានិគម» នោះមកអត្ថន័យនៃគោលការណ៍នេះ ត្រូវបានគេទទួលស្គាល់កាន់តែខ្លាំងជាងមុន ។ ប្រការទី ២ នៃសេចក្តីប្រកាសនេះ បានចែងថា៖

> *"ប្រជាជនទាំងអស់មានសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង ។ យោងតាមស្មារតីនៃសិទ្ធិនេះ ពួកគេកំណត់នូវឋានៈនយោបាយរបស់ខ្លួនដោយសេរី និងធ្វើការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ខ្លួនដោយសេរី"* ។ [11]

សេចក្តីសម្រេចលេខ 1514 (XV) បានក្លាយជាមូលដ្ឋានដំបូងក្នុងការចាប់ផ្តើមការលុបបំបាត់នូវអាណានិគមនិយមនៅក្នុងក្របខណ្ឌ អ.ស.ប. ចាប់តាំងពីឆ្នាំ ១៩៦០ ។ តាំងពីពេលនោះមក មានប្រទេសជាច្រើនបានទទួលឯករាជ្យជាបន្តបន្ទាប់ ។

នៅឆ្នាំ ១៩៦៦ គោលការណ៍ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ត្រូវបានគេទទួលស្គាល់ និងដាក់បញ្ចូលទៅក្នុងកតិកាសញ្ញាអន្តរជាតិជាលើកដំបូង ក្នុងនោះមាន «កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិស៊ីវិល និងនយោបាយ» (ICCPR) [12] និង «កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌» (ICESCR) [13] ។ ប្រការ ១ មាត្រា ១ នៃកតិកាសញ្ញាអន្តរជាតិទាំងពីរនេះ សុទ្ធតែបានចែងដូចគ្នានឹងប្រការទី ២ នៃសេចក្តីសម្រេចលេខ 1514 (XV) ខាងលើដែរ ។

[11] សេចក្តីសម្រេចលេខ 1514 (XV) របស់អង្គការសហប្រជាជាតិ, (ថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ១៩៦០), (ស្រង់ប្រភព៖ ២៣ ធ្នូ ២០២០), https://undocs.org/A/Res/1514(XV)

[12] United Nations, (1967), "International Covenant on Civil and Political Rights", ទំព័រ ១, (ស្រង់ប្រភព៖ ២៣ ធ្នូ ២០២០), https://is.gd/Podcy3

[13] United Nations, (1967), "International Covenant on Economic, Social and Cultural Rights", ទំព័រ ១, (ស្រង់ប្រភព៖ ២៣ ធ្នូ ២០២០), https://is.gd/16sYR9 ។ ប្រការ ១ មាត្រា ១ នៃ ICCPR និង ICESCR ជាភាសាអង់គ្លេសចែងថា៖

*"All peoples have the right of self-determination. By virtue of that right they freely determine their political status and freely pursue their economic, social and cultural development."*

តុលាការយុត្តិធម៌អន្តរជាតិ (ICJ) បានទទួលស្គាល់នូវគោលការណ៍ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ថាជាសិទ្ធិស្របច្បាប់មួយនៅក្នុងច្បាប់អន្តរជាតិ ។ នៅឆ្នាំ ១៩៧៥ នៅក្នុងគំនិតផ្តល់យោបល់ដល់ករណីសាហារ៉ាខាងលិច (Western Sahara) តុលាការ ICJ បានចាត់ទុកនូវ «គោលការណ៍សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯងថាជាសិទ្ធិរបស់ប្រជាជនទាំងអស់» ។ ករណីក្តី ទីម័រខាងកើត (East Timor) ឆ្នាំ ១៩៩៥ តុលាការបានបញ្ជាក់ថា សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង ជា «គោលការណ៍មួយដ៏សំខាន់នៅក្នុងច្បាប់អន្តរជាតិក្នុងសហសម័យ» ដែលមានលក្ខណៈ Erga omnes គឺវាមានសុពលភាពសម្រាប់គ្រប់ប្រទេសទាំងអស់ ។ [14]

នៅក្នុងសេចក្តីប្រកាសស្តីពីគោលការណ៍ច្បាប់អន្តរជាតិ ដែលបានអនុម័តនៅក្នុងសេចក្តីសម្រេចលេខ 2625 (XXX) នៃមហាសន្និបាត អ.ស.ប. ឆ្នាំ ១៩៧០ បានទទួលស្គាល់នូវចំណុចជាក់ស្តែងជាច្រើននៃគោលការណ៍ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ។ ចំណុចទាំងនោះ រួមមាន៖

- ប្រជាជនទាំងអស់មានសិទ្ធិសេរីភាពក្នុងការកំណត់នូវរបបនយោបាយ អភិវឌ្ឍសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដោយមិនមានការជ្រៀតជ្រែកពីភាគីខាងក្រៅ ។
- គ្រប់ប្រទេសទាំងអស់ មានកាតព្វកិច្ចគោរពនូវសិទ្ធិនេះ ជំរុញឲ្យមានការអនុវត្តនូវសិទ្ធិនេះ និងគាំទ្រ អ.ស.ប. ក្នុងការបញ្ចប់នូវរបបអាណានិគម ។
- ការបង្ខំ និងកេងប្រវ័ញ្ចលើប្រជាជន គឺជាការបំពានលើគោលការណ៍នេះ ដែលវាផ្ទុយពីសិទ្ធិមនុស្សជាមូលដ្ឋាន និងធម្មនុញ្ញ ។
- ប្រទេសទាំងអស់មានកាតព្វកិច្ចលើកកម្ពស់ការអនុវត្ត និងការគោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ។
- ប្រជាជនទាំងអស់មានសេរីភាពក្នុងការបង្កើតជាប្រទេសឯករាជ្យមួយ ឬប្រទេសសមាគម ឬធ្វើសមាហរណកម្មសេរីជាមួយនឹងប្រទេសឯករាជ្យ

[14] ICJ, (1995),"East Timor (Portugal v. Australia)", (ស្រង់ប្រភព៖ ២៣ ធ្នូ ២០២០), https://www.icj-cij.org/en/case/84

ផ្សេងទៀត ឬក៏បង្កើតជារបបនយោបាយផ្សេងៗពីនេះ ។

- ប្រទេសទាំងអស់មានកាតព្វកិច្ចមិនធ្វើសកម្មភាពដោយប្រើអំពើហិង្សា រារាំងមិនឲ្យប្រជាជនអនុវត្តសិទ្ធិនេះ ។
- ទឹកដីដែលនៅក្រោមអាណានិគម ឬដែនដីដែលមិនមានការគ្រប់គ្រង (Non-Governing Territory) មានសិទ្ធិផ្តាច់ខ្លួនចេញពីទឹកដីនៃប្រទេសដែលកាន់កាប់ រហូតដល់ប្រជាជននៃដែនដីអាណានិគម ឬទឹកដីនោះមានលទ្ធភាពអនុវត្តនូវ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ។
- គ្មានន័យណាមួយនៅទីនេះ អនុញ្ញាតឲ្យបកស្រាយតាមរបៀបមួយដែលអនុញ្ញាត ឬលើកទឹកចិត្តដល់សកម្មភាពដើម្បីធ្វើឲ្យបែកបាក់ ឬបំផ្លាញទាំងមូល ឬក៏ផ្នែកណាមួយនៃបូរណភាពដែនដី និងឯកភាពនយោបាយនៃប្រទេសឯករាជ្យឡើយ ។ សម្រាប់ប្រទេសនានាដែលកំពុងតែអនុវត្តនូវ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ដូចរៀបរាប់ខាងលើ ត្រូវមានរដ្ឋាភិបាលមួយដែលតំណាងប្រជាជនទាំងអស់ដែលរស់នៅក្នុងទឹកដីនោះ ដោយមិនមានការប្រកាន់ពូជសាសន៍ សាសនា និងព័ណ៌សម្បុរឡើយ ។
- ប្រទេសទាំងអស់មិនត្រូវធ្វើសកម្មភាពដើម្បីធ្វើឲ្យបែកបាក់សាមគ្គីភាពជាតិ និងបូរណភាពទឹកដីរបស់ប្រទេសមួយផ្សេងទៀតឡើយ ។ [15]

សរុបសេចក្តីមក គោលការណ៍ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ផ្តោតលើ ៣ ចំណុចសំខាន់ៗ គឺ៖

**ចំណុចទីមួយ** ប្រជាជនទាំងអស់ (Peoples) មានសិទ្ធិសេរីភាពក្នុងការកំណត់នូវរបបនយោបាយ សេដ្ឋកិច្ច វប្បធម៌ និងសង្គមរបស់ខ្លួន ដោយមិនមានការជ្រៀតជ្រែកពីប្រទេសក្រៅ ។ នៅក្នុងអត្ថន័យនេះ ត្រូវរាប់បញ្ចូលទាំងគោលការណ៍ហាមជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់ប្រទេសដទៃ គោលការណ៍សិទ្ធិស្មើគ្នាលើដែន

[15] UN, (1970),"Declaration on Principles of International Law concerning Friendly Relations and Co-operation among States in accordance with the Charter of the United Nations", (ស្រង់ប្រភព៖ ២៣ ធ្នូ ២០២០), https://is.gd/xYbUMR

អធិបតេយ្យ និងគោលការណ៍ហាមឃាត់ការគំរាមកំហែង និងប្រើអំពើហិង្សា ។ អនាគតនៃប្រជាជននីមួយៗ ត្រូវតែប្រជាជនទាំងនោះជាអ្នកសម្រេច ។ ទោះបីយ៉ាងនេះក្តី ការអនុវត្តនូវ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» គេតម្រូវឲ្យ «មានរដ្ឋាភិបាលមួយសម្រាប់តំណាងប្រជាជនទាំងមូលនៅលើដែនដីនោះ ដោយផ្អែកលើគោលការណ៍មិនប្រកាន់ពូជសាសន៍ សាសនា និងព័ណ៌សម្បុរ» ។ ក្រៅពីនេះ គេបានកំណត់នូវ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ចេញជាពីរសណ្ឋានទៀត គឺ៖

- ទីមួយ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង**ខាងក្នុង**» (Internal) ។
- ទីពីរ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង**ខាងក្រៅ**» (External) ។

«សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯងខាងក្នុង» (Internal Self-determination) គឺជា «*សិទ្ធិរបស់ប្រជាជនទាំងអស់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ពួកគេដោយសេរីដោយគ្មានការជ្រៀតជ្រែកពីខាងក្រៅ ។ ក្នុងន័យនេះ [សិទ្ធិនេះ] ត្រូវផ្សារភ្ជាប់ជាមួយសិទ្ធិរបស់ប្រជាពលរដ្ឋគ្រប់រូប ក្នុងការចូលរួមកិច្ចការសាធារណៈនៅគ្រប់កម្រិត ។ នេះបើយោងតាមមាត្រា 5(c) នៃអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ ។ អាស្រ័យហេតុនេះ រដ្ឋាភិបាលនានា ត្រូវតែតំណាងឲ្យប្រជាជនទាំងមូលដោយគ្មានការបែងចែកពូជសាសន៍ ពណ៌សម្បុរ ដើមកំណើត ឬសញ្ជាតិ ឬក៏ជនជាតិដើម*» ។ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯងខាងក្រៅ» (External Self-determination) មានន័យថា «*ប្រជាជនទាំងអស់មានសិទ្ធិកំណត់ឋានៈនយោបាយ និងតួនាទីរបស់ពួកគេនៅក្នុងសហគមន៍អន្តរជាតិដោយសេរីដោយផ្អែកលើគោលការណ៍នៃសិទ្ធិស្មើគ្នា និងបង្ហាញឲ្យឃើញនូវឥស្សរភាពរបស់ប្រជាជនពីអាណានិគមនិយម និងដោយការរារាំងមិនឲ្យប្រជាជនរស់នៅក្រោមអំណាចត្រួតត្រា ការជិះជាន់ និងការកេងប្រវ័ញ្ចពីបរទេស* » ។ [16]

អត្ថន័យមួយទៀត ដែលអ្នកសិក្សា និងប្រទេសមួយចំនួនបានលើកឡើងថា «សិទ្ធិ

[16] គណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍ (CERD), អនុសាសន៍រួម លេខ ២១ (សម័យប្រជុំលើកទី ៤៨, ឆ្នាំ ១៩៩៦), សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង, (CERD, General Recommendation 21, The right to self-determination (Forty-eighth session, 1996), U.N. Doc. A/51/18, annex VIII at 125 (1996), Human Rights Library, University of Minnesota, (ស្រង់ប្រភព៖ ២៧ ធ្នូ ២០២០), https://is.gd/rX3DlO

សម្រេចវាសនាខ្លួនដោយខ្លួនឯងខាងក្រៅ» ត្រូវរាប់បញ្ចូលទាំងសិទ្ធិក្នុងការផ្តាច់ខ្លួន ឬបំបែកទឹកដីចេញពីប្រទេសមួយ ខណៈដែលករណីនេះជាដំណោះស្រាយចុងក្រោយដើម្បីឲ្យប្រជាជន ឬជនជាតិមួយបានចៀសផុតពីស្ថានភាពនៃការបង្ក្រាបពីផ្ទៃខាងក្នុងនៃរដ្ឋាភិបាលណាមួយ ។

> *“ស្របពេលដែលច្បាប់អន្តរជាតិប្រកាន់ខ្ជាប់នូវគោលការណ៍ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ដោយមិនបានរាប់បញ្ចូលនូវសិទ្ធិក្នុងការផ្តាច់ខ្លួន ។ វាអាចកើតឡើងបានចំពោះតែករណីលើកលែងនៅក្នុងច្បាប់អន្តរជាតិតែប៉ុណ្ណោះ ដែលអនុញ្ញាតឲ្យមានការផ្តាច់ខ្លួននៅក្នុង «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯងខាងក្រៅ» ទីដែលប្រជាជនត្រូវគេធ្វើអាណានិគម ឬត្រូវគេជិះជាន់ (ដូចជាករណីកូសូវ៉ូ)។ ក្រៅពីនេះទៀត ការផ្តាច់ខ្លួន [17] ត្រូវហាមឃាត់ដោយច្បាប់អន្តរជាតិ ប្រសិនបើក្រុមផ្តាច់ខ្លួនប៉ុនប៉ងបំបែកខ្លួនដោយរំលោភលើបទដ្ឋានគ្រឹះនៃច្បាប់អន្តរជាតិ ដូចជាការហាមឃាត់ការប្រើប្រាស់កម្លាំង (ដូចជាក្នុងករណី Northern Cyprus) ។ ផ្ទុយទៅវិញ ក្នុងករណីផ្សេងមួយទៀតនៃការប៉ុនប៉ងផ្តាច់ខ្លួនដែលប្រជាជនពាក់ព័ន្ធមិនត្រូវបានគេជិះជាន់វិញ ដូចជាករណីរដ្ឋកេបិច (Quebec) ឬ ស្កុតឡែន (Scotland) គឺច្បាប់អន្តរជាតិនៅជាអព្យាក្រឹតចំពោះការផ្តាច់ខ្លួន ដោយច្បាប់មិនគាំទ្រនូវសិទ្ធិក្នុងការផ្តាច់ខ្លួន ហើយក៏មិនហាមឃាត់ដល់ការផ្តាច់ខ្លួនដែរ ។ ដូច្នេះជម្លោះក្នុងការផ្តាច់ខ្លួន ត្រូវប្រគល់ឲ្យច្បាប់ក្នុងស្រុកជាអ្នកដោះស្រាយ និងការចរចានយោបាយមួយរវាងប្រទេសអធិករណ៍ និងភាគីផ្តាច់ខ្លួន”* ។[18]

ហេតុផលនៃការគាំទ្រទ្រឹស្តី «ផ្តាច់ខ្លួន» នោះ ដោយគេយោងតាមមូលដ្ឋាន «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ស្រង់ចេញពី «សេចក្តីសម្រេចឆ្នាំ ១៩៩៨» របស់

[17] «ការផ្តាច់ខ្លួន» (Secession) មានន័យថា ការបំបែករដ្ឋចេញពីប្រទេសសហព័ន្ធ ឬការបំបែកទឹកដីចេញពីប្រទេសណាមួយ ឬក៏ការប្រកាសឯករាជ្យចេញពីអាណានិគមនៃបរទេសណាមួយ ។

[18] Milena Sterio, (៥ មករា ២០១៨), ‘Self-Determination and Secession Under International Law: The Cases of Kurdistan and Catalonia’, The American Society of International Law, (ស្រង់ប្រភព៖ ២៧ ធ្នូ ២០២០), https://is.gd/xu8xo9

តុលាការជាន់ខ្ពស់ប្រទេសកាណាដា ក្នុងករណីក្តីរដ្ឋកេបិច (Quebec) ផ្តាច់ខ្លួនចេញពីកាណាដា ។ តុលាការនេះបានលើកឡើងថា៖

> *"ពេលណាដែលប្រជាជនមួយត្រូវគេរារាំងមិនឲ្យអនុវត្តនូវ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯងខាងក្នុង» គឺប្រជាជននោះ ត្រូវមាន «សិទ្ធិសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ដោយការផ្តាច់ខ្លួនជាដំណោះស្រាយចុងក្រោយ"* ។ [19]

នៅក្នុងសេចក្តីសម្រេចនេះដដែល តុលាការកំពូលរបស់ប្រទេសកាណាដា បានបញ្ជាក់អំពីទំហំនៃ «សិទ្ធិ» របស់ប្រជាជនក្នុងការទទួលបាននូវ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ថា វាមានវិសាលភាពទូលំទូលាយជាងអនុសញ្ញា ដែលមានចែងនៅក្នុងគោលការណ៍ច្បាប់អន្តរជាតិទៅទៀត ។

> *"អត្ថិភាពនៃសិទ្ធិរបស់ប្រជាជនក្នុងការសម្រេចវាសនាខ្លួនដោយខ្លួនឯង ត្រូវបានគេទទួលស្គាល់យ៉ាងទូលំទូលាយនៅក្នុងអនុសញ្ញាអន្តរជាតិដែលគោលការណ៍នេះ បានទទួលឋានៈលើសពី «អនុសញ្ញា» ហើយត្រូវបានគេចាត់ទុកថាជាគោលការណ៍ទូទៅនៃច្បាប់អន្តរជាតិ"* ។ [20]

**ចំណុចទីពីរ** ប្រទេសទាំងអស់ត្រូវមានកាតព្វកិច្ចគោរពនូវ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» របស់ប្រជាជនទាំងអស់ ដោយមិនត្រូវធ្វើសកម្មភាពរារាំងនូវការអនុវត្តសិទ្ធិនេះ និងត្រូវគាំទ្រ និងជួយដល់ប្រជាជន និង អ.ស.ប. ក្នុងការបញ្ចប់នូវរបបអាណានិគម ។ ប្រទេសទាំងអស់ ក៏មិនត្រូវកេងប្រវ័ញ្ចលើសិទ្ធិនេះ ដើម្បីបំផ្លិចបំផ្លាញនូវបូរណភាពដែនដី និងឯកភាពនយោបាយរបស់ប្រទេសដទៃឡើយ ដូចជាញុះញង់ និងផ្តល់ជំនួយដល់កងកម្លាំងដើម្បីផ្តាច់ខ្លួន ។

**ចំណុចទីបី** «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» មិនអនុញ្ញាតឲ្យមានរបបអាណានិគមបន្តគង់វង្សឡើយ មិនអនុញ្ញាតឲ្យប្រទេសមួយគាបសង្កត់ កេងប្រវ័ញ្ច

[19][20] Supreme Court of Canada, (1998), 'Reference re Secession of Quebec', SCC, (ស្រង់ប្រភព៖ ២៧ ធ្នូ ២០២០), https://is.gd/RGTI21

និងជិះជាន់លើប្រជាជនផ្សេងទៀតទេ ។ ចំពោះប្រជាជនទាំងអស់ដែលនៅក្រោមអាណានិគម និងទឹកដីដែលមិនបានគ្រប់គ្រងដោយខ្លួនឯង (Non-Self-Governing Territories) អង្គការសហប្រជាជាតិនឹងជួយប្រជាជនទាំងនេះ ក្នុងការអនុវត្តនូវ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ។ សេចក្ដីសម្រេចលេខ 1541 (XV) ឆ្នាំ ១៩៦០ បានដាក់ចេញនូវជម្រើស ៣ យ៉ាង សម្រាប់ប្រជាជនដែលនៅក្រោមអាណានិគម ។

ទីមួយ៖ **បង្កើតជាប្រទេសឯករាជ្យមួយដែលមានអធិបតេយ្យរបស់ខ្លួន** ។

ទីពីរ៖ **ចូលរួមដោយសេរីជាមួយនឹងប្រទេសឯករាជ្យមួយផ្សេងទៀត** ។ ឬ

ទីបី៖ **ធ្វើសមាហរណកម្មជាមួយនឹងប្រទេសឯករាជ្យមួយ** ។ [21]

**អត្ថន័យពាក្យ (Peoples) នៅក្នុងភាសាអង់គ្លេស៖**

គោលការណ៍ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» មិនបានផ្ដល់សិទ្ធិផ្ដាច់មុខទៅឱ្យ «ប្រទេស» នោះទេ ។ ម្ចាស់ដែលត្រូវទទួលបាននូវសិទ្ធិនោះគឺ «ប្រជាជន» ឬ «ជនជាតិ» ទាំងអស់ ។ ប៉ុន្តែគេនៅមិនទាន់បានឃើញមានការបញ្ជាក់ណាមួយឱ្យបានច្បាស់លាស់នៅឡើយអំពីអត្ថន័យនៃពាក្យ «Peoples» នៅក្នុងគោលការណ៍ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ។ វចនានុក្រម Oxford English Dictionary បានពន្យល់ពាក្យ «People» ថា ពាក្យនេះ ទោះបីជាឯកវចនៈ ឬពហុវចនៈក្ដី មានន័យថា «*សមាជិកជាក់លាក់នៃប្រទេសមួយ, សហគមន៍ ឬក្រុមជនជាតិមួយ*» ។ [22]

ដូច្នេះ ពាក្យ «Peoples» នៅក្នុងគោលការណ៍ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» អាចសំដៅលើន័យ ៣ យ៉ាង គឺ ប្រជាជន, ជនជាតិ និង សហគមន៍ ។

- **ប្រជាជន** មានន័យថា ពួកជនចំណុះប្រទេស ឬពលរដ្ឋនៃប្រទេសមួយ ។ ឧទាហរណ៍៖ ប្រជាជននៃសហរដ្ឋអាមេរិក ហៅកាត់ថា ពលរដ្ឋអាមេរិក, ប្រជាជននៃប្រទេសកម្ពុជា ហៅកាត់ថា ពលរដ្ឋ ឬ ប្រជាជនកម្ពុជា និង ប្រជាជននៃប្រទេសវៀតណាម ហៅកាត់ថា ពលរដ្ឋវៀតណាម ជាដើម ។

---

[21] UN, (Dec 15, 1960), 'General Assembly resolution 1541 (XV), Annex, Principle VI', (ស្រង់ប្រភព៖ ២៨ ធ្នូ ២០២០), https://undocs.org/en/A/RES/1541(XV)

[22] 'People', Oxford English Dictionary, (ស្រង់ប្រភព៖ ១០ តុលា ២០១៨), https://is.gd/zNiq80 ពាក្យដើមនៅក្នុងវចនានុក្រម «The members of a particular nation, community, or ethnic group» ។

♦**ជនជាតិ** មានន័យថា ជាតិនៃមនុស្សដែលមានវង្សត្រកូល និងភាសា ជាមួយគ្នា ។ ឧទាហរណ៍ៈ ជនជាតិខ្មែរ, ជនជាតិយួន, ជនជាតិចិន និងជនជាតិ ដើមខ្មែរក្រោម ជាដើម ។

♦**សហគមន៍** មានន័យថា ការទៅជាមួយ ឬដំណើរជាមួយគ្នា ឬក៏ដូចគ្នា ។ ឧទាហរណ៍ៈ សហគមន៍ពុទ្ធសាសនា, សហគមន៍គ្រឹស្តបរិស័ទ ឬសហគមន៍ អ្នកភូមិបឹងកក់ ជាដើម ។

សរុបសេចក្តីមក ការអនុវត្តនូវគោលការណ៍ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» នោះ ប្រសិនបើពាក្យ «Peoples» គេសំដៅលើ «ប្រជាជន» ឬ «ពលរដ្ឋ» មានន័យថា ការផ្តាច់ខ្លួន ឬការប្រកាសឯករាជ្យ គឺជាការសម្រេចចិត្តរបស់ប្រជាជនទាំងអស់នៅក្នុងប្រទេសមួយ ។ តែប្រសិនបើគេសំដៅលើ «ជនជាតិ» វិញ មានន័យថា ជាតិសាសន៍ ឬជនជាតិនីមួយៗនឹងប្រកាសឯករាជ្យ ឬផ្តាច់ខ្លួនចេញពីប្រទេសមួយ ដើម្បីរំដោះខ្លួនចេញពីនឹមអាណានិគមនៃជាតិសាសន៍ផ្សេងមួយទៀត ។

ដូច្នេះ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» មិនមែនជាសិទ្ធិផ្តាច់មុខសម្រាប់តែប្រទេសជាសមាជិកនៃ អ.ស.ប. នោះទេ តែវាជាសិទ្ធិសម្រាប់គ្រប់ «ប្រជាជន» និង «ជនជាតិ» ទាំងអស់នៅក្នុងពិភពលោក ដោយពួកគេមានសិទ្ធិក្នុងការកំណត់នូវប្រព័ន្ធនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ខ្លួនដោយសេរី ។ ការលើកឡើងដូច្នេះ ដោយសារយើងមើលឃើញថា នៅពេលដែល អ.ស.ប. បានបង្កើតឡើងនៅឆ្នាំ ១៩៤៥ នោះ មានប្រទេសតែ ៥០ ប៉ុណ្ណោះ ដែលបានចុះហត្ថលេខាលើធម្មនុញ្ញរបស់ខ្លួន តែមកដល់ពេលនេះ សមាជិក អ.ស.ប. បានកើនឡើងដល់ ១៩៣ ប្រទេស ហើយ បន្ទាប់ពីប្រទេសទាំងនោះបានអនុវត្ត «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ប្រកាសឯករាជ្យចេញពីអាណានិគមជាបន្តបន្ទាប់ ។ ប្រទេសដែលបានទទួលឯករាជ្យ និងចូលជាសមាជិក អ.ស.ប. នៅពេលថ្មីៗនេះ រួមមាន ទីម័រខាងកើត នៅឆ្នាំ ២០០២ ម៉ុនតេនេក្រូ ឆ្នាំ ២០០៦ និងស៊ូដង់ខាងត្បូង ឆ្នាំ ២០១១ ។ [23]

[23] UN News, (១៤ កក្កដា ២០១១), 'UN welcomes South Sudan as 193rd Member State', www.news.un.org, (ស្រង់ប្រភពៈ ២៩ ធ្នូ ២០២០), https://is.gd/aAxPjL

## ជនជាតិដើមខ្មែរក្រោម និង សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង៖

សតវត្សរ៍ទី ២០ ជាយុគសម័យដែលប្រទេស និងជនជាតិនានាក្នុងពិភពលោក បានក្រោកឡើង ដើម្បីរំដោះខ្លួនចេញពីអាណានិគមនៃប្រទេសមហាអំណាច ប៉ុន្តែនៅក្នុងសតវត្សរ៍ទី ២១ នេះ ជាយុគសម័យមួយទៀត សម្រាប់ជនជាតិដើមនៅជុំវិញពិភពលោក ប្រមាណ ៤៧៦ លាននាក់ [24] ក្នុងនោះ ក៏មានខ្មែរក្រោមជាង ៧ លាននាក់ [25] នៅកម្ពុជាក្រោម ផងដែរ កំពុងតែតស៊ូមតិដើម្បី «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» នៅលើទឹកដីកេរដូនតារបស់ខ្លួន ។

ខ្មែរក្រោមជាជនជាតិដើម (Indigenous Peoples) នៃដែនដីកម្ពុជាក្រោម [26] និងត្រូវបានអង្គការសហប្រជាជាតិអនុញ្ញាតឲ្យ «សហព័ន្ធខ្មែរកម្ពុជាក្រោម» (KKF) ចូលប្រជុំនៅក្នុងវេទិកាអចិន្ត្រៃយ៍ស្ដីពីបញ្ហាជនជាតិដើម (UNPFII) នៅការិយាល័យកណ្ដាលរបស់ អ.ស.ប. នាទីក្រុង New York សហរដ្ឋអាមេរិក ជារៀងរាល់ឆ្នាំ ចាប់តាំងពីឆ្នាំ ២០០៤ មក បន្ទាប់ពីវេទិកានេះបានបង្កើតឡើងនៅឆ្នាំ ២000 តាមសេចក្ដីសម្រេចលេខ ២000/២២ (Resolution 2000/22) ដើម្បីដោះស្រាយនូវបញ្ហាផ្សេងៗរបស់ជនជាតិដើមក្នុងពិភពលោក ទាក់ទងនឹងការអភិវឌ្ឍសេដ្ឋកិច្ច, សង្គម, វប្បធម៌, បរិស្ថាន, អប់រំ, សុខភាព និងសិទ្ធិមនុស្ស ។ [27] ប្រជាជនខ្មែរក្រោម នៅដែនដីកម្ពុជាក្រោមផ្ទាល់មិនបានចូលប្រជុំនៅក្នុង អ.ស.ប. ទេ ដោយសាររដ្ឋាភិបាលរបបយួនកុម្មុយនីស្តរារាំង តែ «សហព័ន្ធខ្មែរកម្ពុជាក្រោម» ដែលមានមូលដ្ឋាននៅក្រៅស្រុកធ្វើជាតំណាងប្រជាជនខ្មែរក្រោមវិញ ។ សហព័ន្ធខ្មែរកម្ពុជាក្រោម ចាត់ទុកវត្តមានរបស់ខ្លួននៅក្នុងវេទិកា UNPFII ថាជាព្រឹត្តិការណ៍មិនធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្រនៃប្រជាជាតិខ្មែរក្រោម ។ [28] សហព័ន្ធខ្មែរកម្ពុជាក្រោម បានលើកយកករណីទាំងឡាយដែលរបបយួនកុម្មុយនីស្ត បានរំលោភសិទ្ធិមនុស្សលើប្រជាជាតិ

[24] The World Bank, (១ តុលា ២០២០), ‘INDIGENOUS PEOPLES’, (ស្រង់ប្រភព៖ ២៩ ធ្នូ ២០២០), https://is.gd/Alp5fL

[25] សូមមើលចំនួនខ្មែរក្រោម នៅទំព័រ ៥៥ - ៥៧ ។

[26] សូមអានលេខយោង [1] ស្ដីអំពីទឡ្ហីករណ៍បង្ហាញនូវលក្ខណៈខ្មែរក្រោមជាជនជាតិដើម នៅទំព័រ ៥៥ ។

[27] UN, ‘The United Nations Permanent Forum on Indigenous Issues (UNPFII)’, un.org, (ស្រង់ប្រភព៖ ៣០ ធ្នូ ២០២០), https://is.gd/jRFXuO

[28] KKF, (2009), ‘The Khmer-Krom Journey to Self-Determination’, (សហព័ន្ធខ្មែរកម្ពុជាក្រោម - ស.ខ.ក.ក.), ទំព័រ ២៧៦

ខ្មែរក្រោមទៅថ្លែងការណ៍ជាបន្តបន្ទាប់នៅក្នុងវេទិកានេះ ឲ្យសហគមន៍អន្តរជាតិបានជ្រាប ។ ក្រៅពីនេះ សហព័ន្ធខ្មែរកម្ពុជាក្រោម ក៏បានចូលជាសមាជិកនៃ «អង្គការប្រជាជាតិ និងប្រជាជនមិនមានតំណាង» ហៅកាត់ថា «យូអិនភីអូ» (UNPO) នៅថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០១ ដើម្បីទាមទារឲ្យរបបអាណានិគមយួនទទួលស្គាល់នូវ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» នៃជនជាតិដើមខ្មែរក្រោមនៅកម្ពុជាក្រោម ដោយអនុលោមតាម «សេចក្ដីប្រកាសរបស់ អ.ស.ប. ស្ដីពីសិទ្ធិជនជាតិដើម» ដែល អ.ស.ប. បានប្រកាសកាលពីឆ្នាំ ២០០៧ ។ ត្រង់ចំណុចនេះ យូអិនភីអូ បានបញ្ជាក់នៅលើគេហទំព័ររបស់ខ្លួនថា៖

> *“ទិសដៅរបស់ សហព័ន្ធខ្មែរកម្ពុជាក្រោម គឺធ្វើចលនាផ្ដោតលើគោលការណ៍អហិង្សា ដើម្បីឲ្យមានការទទួលស្គាល់សិទ្ធិជនជាតិដើម នៃប្រជាជននៅដែនដីកម្ពុជាក្រោម ស្របតាមអនុសញ្ញាអន្តរជាតិ”* ។[29]

សូមបញ្ជាក់ថា យូអិនភីអូ ជាអង្គការអន្តរជាតិមួយ ដែលប្រមូលផ្ដុំដោយអង្គការអន្តរជាតិទាំងឡាយជាសមាជិក បង្កើតឡើងដើម្បីផ្ដល់អំណាចសំឡេងដល់ប្រជាជននៅក្នុងពិភពលោកដែលគ្មានតំណាង និងត្រូវគេបោះបង់ចោល និងតស៊ូដើម្បីការពារនូវសិទ្ធិមនុស្សជាមូលដ្ឋានរបស់ពួកគេ ។ UNPO បានបង្កើតជាផ្លូវការនៅឆ្នាំ ១៩៩១ នៅវិមានសន្តិភាព នាទីក្រុងឡាអេ ប្រទេសហុល្លង់ ។ សមាជិកនៃអង្គការនេះប្រមូលផ្ដុំដោយក្រុមជនជាតិដើម ជនជាតិភាគតិច និងទឹកដីដែលគេមិនទទួលស្គាល់ ឬដែនដីដែលត្រូវគេជណ្ដើមកាន់កាប់ ។ UNPO ធ្វើសកម្មភាពដើម្បីអភិវឌ្ឍការយល់ដឹង និងគោរពនូវសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង ដោយផ្ដល់ជាយោបល់ និងជួយដោះស្រាយនូវចម្ងល់ផ្សេងៗទាក់ទងនឹងកិច្ចការអន្តរជាតិ និងស្វ័យភាពខាងនយោបាយ បណ្ដុះបណ្ដាលដល់ក្រុមអំពីរបៀបធ្វើចលនា ដើម្បីបុព្វហេតុនៃការតស៊ូរបស់ពួកគេឲ្យមានប្រសិទ្ធភាព និងគាំទ្រដោយផ្ទាល់ក្នុងការធ្វើប្រតិកម្មជាលក្ខណៈអន្តរជាតិលើករណីរំលោភសិទ្ធិមនុស្សដល់ក្រុមសមាជិករបស់ UNPO ។ អតីតសមាជិកមួយចំនួនដែលបានទទួលឯករាជ្យ និងបានចូលជាសមាជិកនៃអង្គការសហប្រជាជាតិ នាពេល

[29] UNPO, (៣០ មករា ២០១៨), ‘Khmer-Krom’, unpo.org, (ស្រង់ប្រភព៖ ៣០ ធ្នូ ២០២០), www.unpo.org/members/7887

កន្លងមក រួមមានអាមេនៀ (Armenia) ឆ្នាំ ១៩៩២, ទីម័រខាងកើត (East Timor) ឆ្នាំ ២០០២, អេស្តូនៀ (Estonia) ឆ្នាំ ១៩៩១, ចរ័ចៀ (Georgia) ឆ្នាំ ១៩៩១, ល័តវៀ (Latvia) ឆ្នាំ ១៩៩១ និង ប៉ាឡូ (Palau) ឆ្នាំ ១៩៩៤ ។ [30] តាំងពីពេលបង្កើតរហូតមកដល់ពេលនេះ សមាជិក UNPO ជាច្រើនបានសម្រេចនូវគោលដៅរបស់ខ្លួន នៅក្នុងចលនាតស៊ូដើម្បីស្វែងរកឋានៈពិតប្រាកដជូនប្រជាជនរបស់គេ នៅក្នុងក្របខណ្ឌជាតិ ឬអន្តរជាតិ ហើយបានដាច់នូវសមាជិកភាពពី UNPO ដោយសារប្រជាជាតិរបស់គេមិនត្រូវគេចាត់ទុកថា «គ្មានតំណាង» តទៅទៀត ។ សព្វថ្ងៃ UNPO មានសមាជិកទាំងអស់ចំនួន ៤៥ ជនជាតិ តំណាងប្រជាជនជាង ៣០០ លាននាក់ នៅជុំវិញពិភពលោកដែលគ្មានតំណាងរបស់ខ្លួននៅក្នុងវេទិកាផ្សេងៗនៅក្នុងប្រទេស និងអន្តរជាតិ ។[31]

និយាយអំពី សហព័ន្ធខ្មែរកម្ពុជាក្រោម វិញ ចាប់តាំងពីបានចូលជាសមាជិក UNPO រហូតមកដល់ពេលនេះ មានរយៈពេលពីរទសវត្សរ៍ហើយ ដែលបានធ្វើសកម្មភាពតស៊ូមតិនៅលើឆាកអន្តរជាតិឥតឈប់ឈរ ដើម្បីទូងស្គរឲ្យពិភពលោកបានឮនូវសំឡេងដង្ហោយហៅរកយុត្តិធម៌របស់ជនជាតិដើមខ្មែរក្រោម ដែលត្រូវរបបយួនជិះជាន់គ្រប់ជំនាន់ ។ សកម្មភាពជាលក្ខណៈអន្តរជាតិ ដែលសហព័ន្ធខ្មែរកម្ពុជាក្រោម បានធ្វើក្នុងបុព្វហេតុ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» នោះ មានដូចជា ធ្វើសន្និសីទអន្តរជាតិ, សិក្ខាសាលា, ចូលប្រជុំនៅក្នុងមហាសន្និបាតនៃអង្គការសហប្រជាជាតិ, ធ្វើរបាយការណ៍ទៅក្រសួងការបរទេសប្រទេសមហាអំណាច និងអង្គការអន្តរជាតិនានា, ធ្វើបាតុកម្មនៅជុំវិញពិភពលោក និងបង្កើតជាស្ថាប័នព័ត៌មានដើម្បីផ្សព្វផ្សាយឯកសារ និងដំណឹងស្តីពីកម្ពុជាក្រោម ជាដើម ។

ការតស៊ូមតិនៅក្នុង អ.ស.ប. របស់ សហព័ន្ធខ្មែរកម្ពុជាក្រោម និងក្រុមជនជាតិដើមផ្សេងៗទៀតមកពីប្រទេសនានាក្នុងពិភពលោកនាពេលកន្លងមក បានធ្វើឲ្យពិភពលោកមានការផ្លាស់ប្តូរគួរឲ្យកត់សម្គាល់ ដោយអង្គការសហប្រជាជាតិបានអនុម័តនូវសេចក្តីប្រកាស និងឯកសារច្បាប់ជាច្រើនក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស

[30] Unrepresented Nations and Peoples Organization, (១៦ ធ្នូ ២០២០), https://is.gd/rspXl7

[31] UNPO, 'About UNPO', unpo.org, (ស្រង់ប្រភព៖ ២០ ធ្នូ ២០២០), https://unpo.org/section/2

ជាមូលដ្ឋានរបស់ជនជាតិដើម ។ អ្វីដែលយើងមើលឃើញនោះ ក្នុងអំឡុង ២០ ឆ្នាំចុងក្រោយនេះ សិទ្ធិរបស់ជនជាតិដើមត្រូវបាន អ.ស.ប. ទទួលស្គាល់តាមរយៈការអនុម័តលើឯកសារច្បាប់ និងយន្តការអន្តរជាតិជាច្រើន ដូចជា «សេចក្តីប្រកាសរបស់ អ.ស.ប. ស្តីពីសិទ្ធិជនជាតិដើម» (UNDRIP) នៅឆ្នាំ ២០០៧, សេចក្តីប្រកាសអាមេរិកស្តីពីសិទ្ធិជនជាតិដើម (ADRIP) នៅឆ្នាំ ២០១៦, ការផ្តល់សច្ចាប័នចំនួន ២៣ លើអនុសញ្ញាជនជាតិដើម និងកុលសម្ព័ន្ធ ពីឆ្នាំ ១៩៩១, ការបង្កើត វេទិកាអចិន្ត្រៃយ៍របស់អង្គការសហប្រជាជាតិស្តីពីបញ្ហាជនជាតិដើម (UNPFII) ពីឆ្នាំ ២០០០, យន្តការអ្នកជំនាញស្តីពីសិទ្ធិជនជាតិដើម (EMRIP) និងអ្នករាយការណ៍ពិសេសរបស់ អ.ស.ប. ទទួលបន្ទុកសិទ្ធិជនជាតិដើម (UNSR) ជាដើម ។

សព្វថ្ងៃ ខ្មែរក្រោមនៅកម្ពុជាក្រោម ដែលកំពុងតែរស់នៅក្រោមនឹមត្រួតត្រារបស់អាណានិគមយួននោះ គ្មានសិទ្ធិសេរីភាពអ្វីទាំងអស់ បើទោះបីរដ្ឋាភិបាលយួនបានចុះហត្ថលេខាទទួលស្គាល់ និងផ្តល់សច្ចាប័នលើឯកសារច្បាប់អន្តរជាតិជាច្រើន ដោយបានសន្យាថា នឹងគោរពនូវការអនុវត្តគោលការណ៍ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» របស់ជនជាតិដើម និងប្រជាជនទាំងអស់យ៉ាងណាក៏ដោយ ។ ប្រទេសមួយដែលមានឈ្មោះថា «សាធារណរដ្ឋសង្គមនិយមវៀតណាម» នោះ ជាប្រទេសសម្រាប់បម្រើផលប្រយោជន៍ផ្តាច់មុខចំពោះតែជនជាតិយួនតែមួយប៉ុណ្ណោះ មិនមែនសម្រាប់គ្រប់ជនជាតិទាំង ៥៤ ដូចអ្វីដែលរបបយួនបានឃោសនានោះទេ ។ បញ្ហាជាក់ស្តែងដែលគេមើលឃើញគ្រប់គ្នានោះគឺ ជនជាតិយួនមានសិទ្ធិគ្រប់បែបយ៉ាង តែជនជាតិទាំង ៥៣ ផ្សេងទៀត ក្នុងនោះមានខ្មែរក្រោមផងដែរ មិនទទួលបានសិទ្ធិសេរីភាពអ្វីទាំងអស់ ។ ពួកគាត់គ្មានសិទ្ធិទេ ក្នុងការបង្កើតគណបក្សនយោបាយ ដើម្បីកំណត់នូវឋានៈនយោបាយរបស់ខ្លួន, គ្មានសិទ្ធិក្នុងការបង្កើតជាសមាគមដើម្បីការពារសិទ្ធិខ្លួន គ្មានសិទ្ធិបង្កើតស្ថាប័នព័ត៌មានឯករាជ្យ ដើម្បីផ្សព្វផ្សាយដំណឹងពិតឲ្យពលរដ្ឋបានជ្រាប គ្មានសិទ្ធិបើកកិច្ចប្រជុំដើម្បីពិភាក្សាអំពីបញ្ហាទូទៅរបស់ជាតិ និងគ្មានសាលារៀនអក្សរខ្មែរសម្រាប់កូនចៅខ្មែរក្រោមបានរៀនសូត្រឲ្យបានទូលំទូលាយនៅ

សាលាសាធារណៈ ជាដើម ។

ទោះបីរបបយួនកុម្មុយនីស្តខំប្រឹងលុបបំបាត់ពូជសាសន៍ខ្មែរក្រោមឲ្យរលាយយ៉ាងណាក៏ដោយ តែគេសង្កេតឃើញខ្មែរក្រោមក្នុងសម័យនេះ បានងើបឡើងតវ៉ាដើម្បីសិទ្ធិសេរីភាពរបស់ខ្លួនជាបន្តបន្ទាប់ ហើយត្រូវរបបយួនកុម្មុយនីស្តបង្ក្រាបដោយការចាប់ព្រះសង្ឃផ្សឹកយកទៅធ្វើទារុណកម្មនៅក្នុងគុក និងគំរាមកំហែងដោយការហៅទៅសួរចម្លើយ ជាដើម ។[32] នេះជាទង្វើដែលរបបអាណានិគមយួនកំពុងតែរំលោភបំពានយ៉ាងព្រៃផ្សៃលើសិទ្ធិជាមូលដ្ឋានរបស់ជនជាតិដើមខ្មែរក្រោម និងបានរំលោភបំពានលើសន្ធិសញ្ញាអន្តរជាតិទាំងស្រុងដែលខ្លួនបានចុះហត្ថលេខា និងផ្ដល់សច្ចាប័នទទួលស្គាល់ ។ សព្វថ្ងៃ របបយួនកុម្មុយនីស្តបានចុះហត្ថលេខា និងផ្ដល់សច្ចាប័នលើ «សន្ធិសញ្ញា» (Treaty) អន្តរជាតិចំនួនប្រាំពីរ និង «សេចក្ដីប្រកាស» (Declaration) សំខាន់ៗចំនួនពីរ ជាមួយនឹង អ.ស.ប. ស្ដីពីការគោរពសិទ្ធិមនុស្ស និងសិទ្ធិជនជាតិដើមជាមូលដ្ឋាន ដែលក្នុងសន្ធិសញ្ញាទាំងនោះ តម្រូវឲ្យមានការគោរពនូវ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» របស់ប្រជាជន និងជនជាតិដើមទាំងអស់ នៅក្នុងប្រទេសវៀតណាម ។

ពាក្យ «Treaty» ឬ «សន្ធិសញ្ញា» គឺជាកិច្ចព្រមព្រៀងអន្តរជាតិដែលធ្វើឡើងរវាងរដ្ឋ និងរដ្ឋនៅក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ ហើយស្ថិតនៅក្រោមច្បាប់អន្តរជាតិ ។ វាជាកិច្ចព្រមព្រៀងរវាងភាគីពីរឬច្រើន ដែលជាប្រធាននៃនីតិអន្តរជាតិសំដៅបង្កើតឲ្យមានឥទ្ធិពលខាងផ្លូវច្បាប់និងស្ថិតនៅក្រោច្បាប់អន្តរជាតិ ។ សន្ធិសញ្ញាត្រូវធ្វើឡើងដោយស្ម័គ្រចិត្តពីភាគីទាំងអស់ ដែលក្នុងន័យនេះ សន្ធិសញ្ញាអាចត្រូវបានចាត់ទុកជាកិច្ចសន្យាគតិយុត្តិ ដែលមានអានុភាពអនុវត្តតាមផ្លូវច្បាប់ជាលក្ខណៈបង្ខំចំពោះគ្រប់ភាគីទាំងអស់ហើយ ដែលមានភាពខុសប្លែកពីសេចក្ដីប្រកាសធម្មតា ។[33]

សន្ធិសញ្ញាដែលវៀតណាមបានចុះហត្ថលេខា និងធ្វើសច្ចាប័ននោះ រួមមានៈ

[32] សូមមើលករណីរបបយួនរំលោភសិទ្ធិលើខ្មែរក្រោមនៅចំណុច «៤៥ ឆ្នាំ ក្រោមរបបយួនកុម្មុយនីស្ត (១៩៧៥ - បច្ចុប្បន្ន» ចាប់ពីទំព័រ ១៣៧ ដល់ ១៦៨ ។

[33] រាជបណ្ឌិតសភាកម្ពុជា, (២០១៤), ‘សទ្ទានុក្រមវិទ្យាសាស្ត្រនយោបាយ និងការទូត’, (ក្រុមប្រឹក្សាជាតិភាសាខ្មែរ), ទំព័រ ៥៤

| សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិរបស់អង្គការសហប្រជាជាតិ [34] | | | |
|---|---|---|---|
| ល.រ. | អក្សរកាត់ | អត្ថន័យពេញ | ថ្ងៃខែឆ្នាំ<br>ចុះហត្ថលេខា (A)<br>ធ្វើសច្ចាប័ន (B) |
| ១ | CAT | អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និង ការប្រព្រឹត្តមកលើខ្លួន ឬ ទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប | ៧ វិច្ឆិកា ២០១៣ (A)<br>៥ កុម្ភៈ ២០១៥ (B) |
| ២ | OP-CAT | ពិធីសារបន្ថែម នៃអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប បង្ការទារុណកម្ម និងការធ្វើបាប | ៧ វិច្ឆិកា ២០១៣ (A)<br>៥ កុម្ភៈ ២០១៥ (B) |
| ៣ | ICCPR | កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ | ២៤ កញ្ញា ១៩៨២ (A) |
| ៤ | CEDAW | អនុសញ្ញាស្តីពីការបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី | ២៩ កក្កដា ១៩៨០ (A)<br>១៧ កុម្ភៈ ១៩៨២ (B) |
| ៥ | ICERD | អនុសញ្ញាអន្តរជាតិ ស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ | ៩ មិថុនា ១៩៨២ (B) |
| ៦ | ICESCR | កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ២៤ កញ្ញា ១៩៨២ (B) |

| | | | |
|---|---|---|---|
| ៧ | CRP | អនុសញ្ញាស្តីពីសិទ្ធិកុមារ | ២៦ មករា ១៩៩០ (A)<br>២៨ កុម្ភៈ ១៩៩០ (B) |
| ៨ | CRC<br>- OP<br>- AC | ពិធីសារស្រេចចិត្ត នៃអនុសញ្ញា ស្តីពី សិទ្ធិកុមារ ស្តីពីការចូលរួមរបស់កុមារ ក្នុងជម្លោះប្រដាប់អាវុធ | ៨ កញ្ញា ២០០០ (A)<br>២០ ធ្នូ ២០០១ (B) |
| ៩ | CRC<br>- OP<br>- SC | ពិធីសារស្រេចចិត្តនៃអនុសញ្ញា ស្តីពី សិទ្ធិកុមារ ស្តីពីការលក់ពេស្យាចារកុមារ និងរូបភាពអាសអាភាសកុមារ | ៨ កញ្ញា ២០០០ (A)<br>២០ ធ្នូ ២០០១ (B) |
| ១០ | CRPD | អនុសញ្ញាស្តីពីសិទ្ធិជនពិការ | ២២ តុលា ២០០៧ (A)<br>៥ កុម្ភៈ ២០១៥ (B) |
| **សេចក្តីប្រកាសស្តីពីសិទ្ធិមនុស្ស និង សិទ្ធិជនជាតិដើម របស់ អ.ស.ប.** | | | |
| ១១ | UDHR | សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស | **ថ្ងៃខែឆ្នាំអនុម័ត**<br>១០ ធ្នូ ១៩៤៨ |
| ១២ | UNDRIP | សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើម | ១៣ កញ្ញា ២០០៧ |
| **ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ** | | | |
| ១៣ | ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ (Charter of the United Nations) ឬ (UN Charter) | | ២៦ មិថុនា ១៩៤៥ |

[34] UN, ‘UN Treaty Body Database’, ohchr.org , (ស្រង់ប្រភព៖ ២០ ធ្នូ ២០២០), https://is.gd/bg91aG

តាមរយៈការទទួលយកសន្ធិសញ្ញាទាំងនេះ របបយួនកុម្មុយនីស្តបានសន្យាភ្ជាប់នូវកាតព្វកិច្ចតាមផ្លូវច្បាប់ក្នុងការអនុវត្តសិទ្ធិទាំងឡាយ ដែលមានចែងនៅក្នុងសន្ធិសញ្ញា ដើម្បីជាប្រយោជន៍ដល់ពលរដ្ឋគ្រប់រូបនៅក្នុងប្រទេសវៀតណាម និងជនជាតិដើមខ្មែរក្រោមនៅដែនដីកម្ពុជាក្រោម ដែលរបបយួនកំពុងតែធ្វើអាណានិគម សព្វថ្ងៃ ។

ប្រទេសជាភាគី នៃសន្ធិសញ្ញាសិទ្ធិមនុស្សដែលបានចុះហត្ថលេខា និងធ្វើសច្ចាប័ន ត្រូវតែដាក់បញ្ជូននូវរបាយការណ៍ជាទៀងទាត់ទៅ អ.ស.ប. ស្តីពីរបៀបអនុវត្តសិទ្ធិក្នុងសន្ធិសញ្ញានេះ ។ របាយការណ៍ទាំងនេះ ត្រូវបានពិនិត្យឡើងវិញដោយគណៈកម្មាធិការជំនាញឯករាជ្យ ដែលគេហៅថាជា «ស្ថាប័នសន្ធិសញ្ញា» ។ គណៈកម្មាធិការនេះ ពិនិត្យរបាយការណ៍នីមួយៗ និងដោះស្រាយកង្វល់ដែលមានក្នុងរបាយការណ៍ ហើយដាក់ចេញជាអនុសាសន៍ផ្សេងៗ ជូនទៅរដ្ឋភាគីក្នុងរូបភាពជា «សេចក្តីសន្និដ្ឋានចុងក្រោយ» ។ គោលបំណងនៃដំណើរការនេះ មិនមែនដើម្បីរិះគន់រដ្ឋាភិបាលនោះទេ ប៉ុន្តែដើម្បីផ្តល់ប្រឹក្សាយោបល់ក្នុងន័យស្ថាបនាពីមធ្យោបាយដែលប្រទេសនានា អាចធ្វើឲ្យមានវឌ្ឍនភាពកាន់តែប្រសើរឡើង ឆ្ពោះទៅរកការធានាថាមនុស្សគ្រប់រូបអាចប្រើប្រាស់សិទ្ធិទាំងឡាយ ដែលមានចែងក្នុងសន្ធិសញ្ញាទាំងនេះ ។ ស្ថាប័នសន្ធិសញ្ញានេះ មិនពឹងផ្អែកទាំងស្រុងលើព័ត៌មាន ដែលបានផ្តល់នៅក្នុងរបាយការណ៍ទាំងឡាយរបស់រដ្ឋាភិបាលដើម្បីធ្វើការវាយតម្លៃនោះទេ ។ គណៈកម្មាធិការបើកចំហផងដែរ ចំពោះការដាក់ស្នើពីអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ព្រមទាំងទីភ្នាក់ងារអង្គការសហប្រជាជាតិ ដូចជា អង្គការសុខភាពពិភពលោក (WHO) ឬអង្គការពលកម្មអន្តរជាតិ (ILO) ជាដើម ។

សម្រាប់ពលរដ្ឋខ្មែរក្រោមវិញ សហព័ន្ធខ្មែរកម្ពុជាក្រោម (KKF) តែងតែចូលប្រជុំគ្រប់លើកទាំងអស់នៅពេលដែលប្រទេសវៀតណាម ដល់វេនឡើងឆ្លើយបំភ្លឺចំពោះ អ.ស.ប. នៅទីក្រុងហ្សឺណែវ ប្រទេសស្វិស និងទីក្រុង New York សហរដ្ឋអាមេរិក ។ នៅក្នុងកិច្ចប្រជុំ សហព័ន្ធខ្មែរកម្ពុជាក្រោម បានថ្លែងការណ៍ និងដាក់របាយការណ៍អំពីករណីរំលោភសិទ្ធិមនុស្ស និងបញ្ហាប្រឈមផ្សេងៗរបស់ខ្មែរក្រោមទៅ អ.ស.ប. ឲ្យ

សហគមន៍អន្តរជាតិបានជ្រាប និងជំរុញឲ្យរបបយួនកុម្មុយនីស្តគោរពសិទ្ធិជាមូលដ្ឋានរបស់ជនជាតិដើមខ្មែរក្រោម ។

**ជនជាតិដើម ជានរណា?**

«ជនជាតិដើម» ជាក្រុមមនុស្ស ឬជនជាតិមួយដែលបានរស់នៅជាយូរលង់នៅលើទឹកដីមួយ មុនពេលដែលជនជាតិ ឬក្រុមមនុស្សដទៃចូលមករស់នៅ ដោយមានភាសា វប្បធម៌ អក្សរសាស្ត្រ ប្រពៃណី ទំនៀមទម្លាប់ និងសាសនា ដាច់ដោយឡែករបស់ខ្លួន ។ ដូចជា «ខ្មែរក្រោម» ជាជនជាតិដើម នៃទឹកដីកម្ពុជាក្រោម ដោយសារពួកគាត់បានរស់នៅតពូជតពង្សនៅលើទឹកដីនេះតាំងពីដើមដំបូងបង្អស់ មុនពេលដែលជនជាតិយួន និងជនជាតិផ្សេងៗទៀត មកឈ្លានពាន និងធ្វើអាណានិគម ។

ក្នុងភាសាអង់គ្លេស «ជនជាតិដើម» គេហៅថា Indigenous peoples, First peoples, Aboriginal peoples ឬ Native peoples ។ តាម អ.ស.ប. ក្រុមមនុស្សដែលគេចាត់ទុកថាជា «ជនជាតិដើម» នោះ ត្រូវផ្អែកលើមូលដ្ឋានដូចខាងក្រោម៖

- ♦ ទទួលស្គាល់ខ្លួនឯងជាជនជាតិដើម និងមានការទទួលស្គាល់ដោយសហគមន៍របស់ខ្លួនថាជាសមាជិករបស់ពួកគេ ។
- ♦ មានពូជអម្បូរជាអ្នកតាំងលំនៅមុនគេបង្អស់នៅលើទឹកដីមួយ ។
- ♦ ជីវិតផ្សារភ្ជាប់នឹងទឹកដី និងធនធានធម្មជាតិនៅជុំវិញ ។
- ♦ មានប្រព័ន្ធសង្គម សេដ្ឋកិច្ច និងនយោបាយដាច់ដោយឡែក ។
- ♦ មានភាសា វប្បធម៌ និងជំនឿដាច់ដោយឡែក ។
- ♦ ពួកគេបន្តអភិរក្ស និងអភិវឌ្ឍបរិស្ថានកេរដូនតា និងរបៀបរស់នៅខុសពីប្រជាជនដទៃ ។ [35]

បើនិយាយអំពីសិទ្ធិសេរីភាពវិញ ជនជាតិដើមទូទាំងពិភពលោក ត្រូវគេបដិសេធនូវ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ដែលជាគោលការណ៍មួយមានចែងនៅក្នុងច្បាប់អន្តរជាតិថា ប្រជាជនទាំងអស់មានសិទ្ធិក្នុងការកំណត់នូវឋានៈនយោបាយ និងបន្តអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ពួកគេដោយសេរី ។ តែផ្ទុយទៅវិញ

[35] UNPFII, 'Who are indigenous peoples?', un.org, (ស្រង់ប្រភព៖ ២១ ធ្នូ ២០២០), https://is.gd/eclxOo

ជនជាតិដើម តែងតែរងនូវអំពើហិង្សា និងការគាបសង្កត់ពីរបបអាណានិគមជាបន្តបន្ទាប់ ។

ជនជាតិដើម តែងតែត្រូវប្រឈមមុខនឹងបញ្ហាដ៏ជូរចត់ ដោយសារការបណ្តេញចេញពីទឹកដីដូនតារបស់ខ្លួន ត្រូវគេបដិសេធឱកាសដើម្បីបង្ហាញពីវប្បធម៌ ត្រូវវាយប្រហារលើរាងកាយ និងត្រូវគេចាត់ទុកជាពលរដ្ឋវណ្ណៈទីពីរនៅក្នុងសង្គម ។

ជនជាតិដើម ច្រើនតែត្រូវគេមើលងាយ ប្រឈមនឹងការរើសអើងនៅក្នុងប្រព័ន្ធច្បាប់របស់ប្រទេសដែលធ្វើឲ្យពួកគេកាន់តែងាយរងគ្រោះដោយអំពើហិង្សា និងការរំលោភបំពាន ។ អ្នកការពារសិទ្ធិជនជាតិដើមដែលហ៊ានសម្តែងមតិ ត្រូវប្រឈមនឹងការបំភិតបំភ័យ និងត្រូវរងនូវអំពើហិង្សា ។ ក្រៅពីនេះ អ្នកខ្លះអាចត្រូវសម្លាប់ដោយសារតាំងខ្លួនជាជនជាតិដើម ។

កិច្ចខិតខំប្រឹងប្រែងដោយសន្តិភាពរបស់ជនជាតិដើម ក្នុងការរក្សានូវអត្តសញ្ញាណវប្បធម៌ ឬការគ្រប់គ្រងលើទឹកដីប្រពៃណីរបស់ខ្លួន ជាកន្លែងដែលសម្បូរទៅដោយធនធានធម្មជាតិ និងជីវចម្រុះនោះ បែរជាត្រូវគេចោទពីបទក្បត់ជាតិ ឬពីបទភេរវកម្មទៅវិញ ។

ការរើសអើងគឺជាមូលហេតុដែលនាំឲ្យជនជាតិដើមមានចំនួន ១៥% នៃប្រជាជនក្រីក្របំផុតនៅក្នុងពិភពលោក ។ ទូទាំងពិភពលោក ជនជាតិដើមក៏ទទួលរងនូវអត្រាខ្ពស់នៃភាពគ្មានដីធ្លី កង្វះអាហារូបត្ថម្ភ និងការផ្លាស់ទីលំនៅក្នុងតំបន់ ច្រើនជាងក្រុមមនុស្សដទៃទៀត ផងដែរ ។ [36]

សុភាសិតខ្មែរពោលថា «ទីណាមានការគាបសង្កត់ ទីនោះមានការរើបម្រះ» នៅតែមានន័យសម្រាប់ការតស៊ូរបស់ជនជាតិមួយដែលត្រូវគេជិះជាន់ ។ កាលពីសម័យមុន ប្រជាជាតិដែលត្រូវប្រទេសមហាអំណាចធ្វើអាណានិគម និងជិះជាន់នោះ បាននាំគ្នាក្រោកឡើងតស៊ូដើម្បីទាមទារនូវ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» និងបានទទួល «ឯករាជ្យ» រៀងៗខ្លួន ។ យ៉ាងណាមិញ នៅក្នុងសម័យនេះ ជនជាតិដើមនៅក្នុងពិភពលោក ដែលត្រូវប្រទេសផ្សេងៗធ្វើអាណានិគម និងជិះជាន់នោះ ក៏មានសិទ្ធិក្នុង

[36] Amnesty International, ‘Indigenous peoples’, amnesty.org, (ស្រង់ប្រភព៖ ១០ តុលា ២០២០), https://is.gd/JVhbE9

ការអនុវត្តនូវគោលការណ៍ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ដើម្បីកំណត់នូវឋានៈនយោបាយ អភិវឌ្ឍសេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ខ្លួន ឲ្យបានរុងរឿង និងថ្លៃថ្នូរ ដូចជាជាតិសាសន៍នានាដែលមានប្រទេស និងឯករាជ្យ ផងដែរ ។

សព្វថ្ងៃ ប្រជាជាតិដែលតស៊ូដើម្បី «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» នោះមិនមែនមានតែខ្មែរក្រោមម្នាក់ឯងនោះទេ គឺមានប្រជាជាតិក្នុងពិភពលោកជាច្រើនដែលមានវាសនា «នៅក្រោមអាណានិគមបរទេស» ដូចគ្នា កំពុងតែតស៊ូដើម្បីបាននូវ «ឥស្សរភាព» និង «ឯករាជ្យ» នៅលើទឹកដីរបស់ខ្លួនដែរ ។ ជនជាតិទាំងនោះ រួមមានសមាជិកទាំង ៤៥ នៃ UNPO ដូចជា កោះតៃវ៉ាន (Taiwan) ជនជាតិម៉ុង (Hmong) នៅភាគខាងជើងវៀតណាម និងកាតាឡូញ៉ា (Catalonia) នៅក្នុងប្រទេសអេស្ប៉ាញ ជាដើម [37] ទឹកដីមិនគ្រប់គ្រងដោយខ្លួនឯង (Non-Self-Governing Territories) ទាំង ១៧ នៅក្នុងបញ្ជី អ.ស.ប.[38] តំបន់ស្វយ័តដែលឋិតនៅក្រោមចំណុះប្រទេសដទៃ (Dependent Territory) ដូចជា ណីងសៀ (Ningxia), ឥនទើ ម៉ុងហ្គោល (Inner Mongolia), សិនធៀង (Xinjiang) និង ទីបេត៍ (Tibet) នៅក្រោមចំណុះប្រទេសចិន, នូណាវុត (Nunavut) នៅក្រោមចំណុះប្រទេសកាណាដា និងអាចេហ៍ (Aceh) នៅក្នុងប្រទេសឥណ្ឌូណេស៊ី ជាដើម ។

ការលើកឡើងដូច្នេះ ដោយយើងមើលឃើញថា សព្វថ្ងៃ អ.ស.ប. កំពុងតែបន្តអនុវត្តនូវផែនការលុបបំបាត់អាណានិគមនៅឡើយ ។ ផែនការនេះ អ.ស.ប. អនុវត្តតាមរយៈ «គណៈកម្មាធិការពិសេសស្តីពីការលុបបំបាត់អាណានិគម» ជាស្ថាប័នមួយដែលខ្លួនបានបង្កើតឡើងកាលពីឆ្នាំ ១៩៦១ បន្ទាប់ពីមានសេចក្តីសម្រេចលេខ 1514 (XV) ឆ្នាំ ១៩៦០ ក្នុងការផ្តល់ឯករាជ្យដល់ប្រទេស និងប្រជាជនទាំងឡាយដែលនៅក្រោមអាណានិគម ។

ពេលបង្កើត អ.ស.ប. នៅឆ្នាំ ១៩៤៥ មានប្រជាជន ៧៥០ លាននាក់ រស់នៅលើ «ទឹកដីដែលមិនគ្រប់គ្រងដោយខ្លួនឯង» ពឹងផ្អែកលើអំណាចអាណានិគម ។ ចាប់តាំង

[37] UNPO, ‘Members’, unpo.org, (ស្រង់ប្រភព៖ ២០ ធ្នូ ២០២០), https://unpo.org/nations-peoples

[38] UN, ‘United Nations and decolonization’, un.org, (ស្រង់ប្រភព៖ ២១ តុលា ២០២០), https://is.gd/RpdlOw

ពីពេលនោះមក អតីតទឹកដីអាណានិគមចំនួន ៨០ បានទទួលឯករាជ្យ ។ ក្នុងចំណោមប្រទេសទាំងនោះ មាន ១១ ជាទឹកដីឋិតនៅក្នុងភារៈគ្រប់គ្រងដោយ អ.ស.ប. (Trust Territories) ដែលបានទទួលនូវ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ជាលក្ខណៈរដ្ឋឯករាជ្យ ឬចូលរួមដោយសេរីជារដ្ឋសមាគមជាមួយនឹងរដ្ឋឯករាជ្យដទៃ ។ សព្វថ្ងៃមានដែនដីមិនគ្រប់គ្រងដោយខ្លួនឯងនៅសល់ចំនួន ១៧ ហើយមានប្រជាជនមិនដល់ ២ លាននាក់កំពុងតែរស់នៅលើដែនដីទាំងនេះ [39] និងត្រូវបានយកចិត្តទុកដាក់ និងជួយទំនុកបម្រុងដោយ «គណៈកម្មាធិការពិសេសស្តីពីការលុបបំបាត់អាណានិគម» នៃ អ.ស.ប. ដើម្បីឲ្យប្រជាជនទាំងនោះមានលទ្ធភាពបង្កើតជារដ្ឋាភិបាលដោយខ្លួនឯង ។

> *“ថ្ងៃនេះ ទឹកដីមិនគ្រប់គ្រងដោយខ្លួនឯងទាំង ១៧ ទូទាំងពិភពលោក នៅតែស្ថិតនៅក្រោមការឃ្លាំមើលពីគណៈកម្មាធិការនេះ [គណៈកម្មាធិការពិសេសស្តីពីការលុបបំបាត់អាណានិគម] ។ ខ្ញុំសូមអំពាវនាវដល់សហគមន៍អន្តរជាតិ ឲ្យជួយដោះស្រាយនូវបញ្ហាគ្រប់គ្រងដោយខ្លួនឯង និងជួយផ្តល់ជាគំនិត និងវិធីសាស្ត្រជាក់ស្តែងដើម្បីអនុវត្តនូវដំណើរការលុបបំបាត់អាណានិគម”* ។ [40]
>
> —អគ្គលេខាធិការ អ.ស.ប. Ban Ky-Moon - ខែកុម្ភៈ ២០១៥—

ពិភពលោកនឹងមានការផ្លាស់ប្តូរ របបអាណានិគមនឹងត្រូវរលាយ នៅពេលដែលមនុស្សគ្រប់ជាតិសាសន៍មានការយល់ដឹងអំពីសិទ្ធិ និងមានសេចក្តីក្លាហានហ៊ានក្រោកឡើងដើម្បី «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ។ ប្រវត្តិតស៊ូនៃប្រទេសនីមួយៗដែលបានទទួលឯករាជ្យ និងបានចូលជាសមាជិកពេញសិទ្ធិរបស់ អ.ស.ប. នោះ ក៏ល្មមបញ្ជាក់ឲ្យឃើញនូវសច្ចភាពនេះ គឺនៅពេលដែលបង្កើត អ.ស.ប. នៅឆ្នាំ ១៩៤៥ មានប្រទេសចូលជាសមាជិកតែ ៥១ ប៉ុណ្ណោះ តែមកដល់ឆ្នាំ ២០១១ សមាជិកបានកើនឡើងដល់ទៅ ១៩៣ ប្រទេសនៅជុំវិញពិភពលោក ។ ទោះជាយ៉ាងនេះក្តី អ.ស.ប. នៅមិនទាន់បញ្ចប់បេសកកម្មអនុវត្តគោលការណ៍លុបបំបាត់ នូវអាណានិគមនៅឡើយ

[39] UN, ‘United Nations and decolonization’, un.org, (ស្រង់ប្រភព៖ ២១ តុលា ២០២០), https://is.gd/RpdlOw

[40] UN, ‘What the UN Can Do To Assist Non-Self Governing Territories’, un.org, (ស្រង់ប្រភព៖ ២១ តុលា ២០២០), https://is.gd/FVyUwQ

ដោយនៅក្នុងបីទសវត្សរ៍ចុងក្រោយនេះ អ.ស.ប. បានដាក់ចេញនូវផែនការ «ទសវត្សអន្តរជាតិដើម្បីលុបបំបាត់អាណានិគមនិយម» ក្នុងគោលដៅចុងក្រោយ ដើម្បីអនុវត្តឲ្យបានពេញលេញលើ «សេចក្តីប្រកាសស្តីពីការផ្តល់ឯករាជ្យដល់ប្រជាជន និងប្រទេសនៅក្រោមអាណានិគម» ដែលខ្លួនបានអនុម័តកាលពីឆ្នាំ ១៩៦០ និងក្នុងគោលដៅលុបបំបាត់ឲ្យអស់ទាំងស្រុង នូវរបបអាណានិគមក្នុងសតវត្សរ៍ ២១ នេះ ។ តាំងពីឆ្នាំ ១៩៩០ ដល់ឆ្នាំ ២០២០ នេះ អ.ស.ប. បានប្រកាសអនុវត្តនូវផែនការនេះចំនួន ៣ លើករួចមកហើយ គឺក្នុងមួយលើក ១០ ឆ្នាំ ។ លើកទីមួយ ពីឆ្នាំ ១៩៩០ ដល់ ២០០០ តាមសេចក្តីសម្រេចលេខ 43/47 ។[41] លើកទីពីរ ពីឆ្នាំ ២០០០ ដល់ ២០១០ តាមសេចក្តីសម្រេចលេខ 55/146 ។[42] និងលើកទីបី ពីឆ្នាំ ២០១០ ដល់ ២០២០ តាមសេចក្តីលេខ 65/119 ។ នៅក្នុងសេចក្តីសម្រេចនេះ អ.ស.ប. បានអំពាវនាវដល់សមាជិករបស់ខ្លួនឲ្យខិតខំប្រឹងប្រែងទ្វេដង ដើម្បីអនុវត្តនូវផែនការក្នុងទសវត្សរ៍ទីបីរបស់ខ្លួន ។[43] តែមកដល់ពេលនេះ ផែនការលុបបំបាត់អាណានិគមនៅមិនទាន់បានបញ្ចប់ទាំងស្រុងនៅឡើយ ដោយ អ.ស.ប. បានប្រកាសនៅ ថ្ងៃទី ៦ ខែវិច្ឆិកា ឆ្នាំ ២០២០ យោងតាមពង្រាងសេចក្តីសម្រេចលេខ ២០ (ឯកសារA/៧៥/២៣, ជំពូក ៥, ទំព័រ ១០៦) (draft resolution XX (document A/75/23, chapter V, p.106) ថា ផែនការលុបបំបាត់អាណានិគមក្នុងទសវត្សរ៍ទី ៤ នឹងអនុវត្តចាប់ពីឆ្នាំ ២០២១ ដល់ ២០៣០ ។[45]

សរុបសេចក្តីមក នៅក្នុងសតវត្សរ៍ទី ២១ នេះ ជាយុគសម័យមួយសម្រាប់ជនជាតិដើមទាំងអស់នៅក្នុងពិភពលោក មានឱកាសទាញយកផលប្រយោជន៍ពីផែនការរបស់ អ.ស.ប. ដើម្បីបានរើខ្លួនចេញពីនឹមអាណានិគម និងមានឱកាសអនុវត្តនូវគោលការណ៍

[41] United Nations General Assembly Session 46 Report of the Secretary-General 634 Rev. 1. Implementation of the Declaration on the Granting of Independence to Colonial Countries and Peoples A/46/634/Rev.1 13 December 1991, (ស្រង់ប្រភព៖ ១០ កញ្ញា ២០២០), https://is.gd/ExAzM9

[42] United Nations General Assembly Session 55 Resolution 146. Second International Decade for the Eradication of Colonialism A/RES/55/146, (ស្រង់ប្រភព៖ ១០ កញ្ញា ២០២០), https://is.gd/ICiXeW

[43] United Nations General Assembly Session 65 Resolution 119. Third International Decade for the Eradication of Colonialism A/RES/65/119, (ស្រង់ប្រភព៖ ១០ កញ្ញា ២០២០), https://is.gd/8eOWJq

[45] UN, (៦ វិច្ឆិកា ២០២០), ‘Fourth Committee Approves 23 Texts on Decolonization, as It Concludes Main Part of Seventy-Fifth General Assembly Session’, un.org, (ស្រង់ប្រភព៖ ២០ ធ្នូ ២០២០), https://is.gd/dXypas

«សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» នៅលើទឹកដីរបស់ខ្លួន ។

ព័ត៌មានដែលបានរៀបរាប់មកខាងលើ បង្ហាញឲ្យឃើញថា អ.ស.ប. កំពុងតែបន្តអនុវត្តនូវផែនការលុបបំបាត់អាណានិគមទាំងស្រុងនៅក្នុងពិភពលោក និងបញ្ជាក់ឲ្យឃើញថា របបយួនដែលកំពុងតែធ្វើអាណានិគមលើជនជាតិដើមខ្មែរក្រោមនោះ បានចុះសន្ធិសញ្ញាជាច្រើនជាមួយនឹង អ.ស.ប. ដោយបានសន្យាថា នឹងគោរពនូវសិទ្ធិក្នុងការអនុវត្តនូវគោលការណ៍ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» របស់ប្រជាជន និងជនជាតិដើមទាំងអស់នៅក្នុងប្រទេសវៀតណាម ។

យោងតាមសន្ធិសញ្ញាអន្តរជាតិទាំងឡាយ ដែលរបបយួនបានចុះហត្ថលេខាជាមួយ អ.ស.ប. នោះ ប្រជាជនខ្មែរក្រោមមានសិទ្ធិគ្រប់គ្រាន់ក្នុងការអនុវត្តនូវ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» នៅលើទឹកដីកម្ពុជាក្រោម យ៉ាងពិតប្រាកដ ។

នៅក្នុងសតវត្សរ៍ទី ២១ នេះ ជនជាតិដើមខ្មែរក្រោមមាន «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ដែរឬទេ វាអាស្រ័យលើទំហំនៃសមត្ថភាពរបស់ពួកគាត់ម្នាក់ៗក្នុងការអនុវត្តនូវសិទ្ធិដ៏សំខាន់មួយនេះបានត្រឹមប៉ុណ្ណាតែប៉ុណ្ណោះ ។ ប្រធានាធិបតីទី ១៦ របស់សហរដ្ឋអាមេរិក អាប្រាហាម លីនខូន បានថ្លែងថា “***វិធីល្អបំផុតដើម្បីទស្សន៍ទាយនូវអនាគតរបស់អ្នក គឺត្រូវបង្កើតវា***” ។ ដូច្នេះ ប្រសិនបើប្រជាជនខ្មែរក្រោមគ្រប់រូបចង់ដឹងថា នៅពេលអនាគត ពួកគាត់មាន «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ដែរឬទេនោះ គឺត្រូវនាំគ្នាបង្កើតវាដោយខ្លួនឯងចាប់ពីពេលនេះទៅ ដោយកុំសង្ឃឹមថា នឹងមាននរណាម្នាក់យកវាដាក់លើជើងពានមកជូនឲ្យសោះ ព្រោះថា លើលោកនេះគ្មានវត្ថុអ្វីដែលបានមកដោយមិនមានការតស៊ូ និងលះបង់ឡើយ ។ម្យ៉ាងទៀត អ្នកតស៊ូដ៏ល្បីប្រឆាំងនឹងការរើសអើងពូជសាសន៍នៅអាហ្វ្រិកខាងត្បូង គឺ លោក បែនតុ ស្ទីវផែន ប៊ីកូ (Bantu Stephen Biko) (១៩៤៦ - ១៩៧៧) បានថ្លែងថា “***គ្មានសេរីភាពឡើយនៅក្នុងភាពស្ងប់ស្ងៀម***” (*There is no freedom in silence*) ។ សម្ដីនេះមានន័យសម្រាប់ដាស់ស្មារតីថា ប្រសិនបើពលរដ្ឋខ្មែរក្រោមគ្រប់រូបនៅដេកសម្ងំស្ងៀម មិនព្រមនាំគ្នាតវ៉ាទាមទារនោះទេ សិទ្ធិសេរីភាពជាមូលដ្ឋាននឹងមិនអាចកើតឡើងដោយ

ឯកឯងដល់ពួកគាត់ឡើយ ។

**លក្ខណសម្បត្តិជា «ប្រទេស» មួយនៅក្នុងច្បាប់អន្តរជាតិ៖**

«ប្រទេស» គឺជាដែនដី, តំបន់ ឬរដ្ឋ ដែលគ្រប់គ្រងដោយកិច្ចការនយោបាយរបស់រដ្ឋាភិបាលណាមួយនៅក្នុងពិភពលោក ។ «ប្រទេស» ក៏ជាទីកន្លែង ឬជាទឹកដីដែលបានផ្តល់នូវកំណើត, លំនៅអចិន្ត្រៃយ៍ និងសញ្ជាតិដល់បុគ្គលម្នាក់ៗ ផងដែរ ។

ពាក្យ «ប្រទេស» អាចសំដៅទៅលើរដ្ឋ [46] មួយដែលមានឯករាជ្យពេញលេញជាសមាជិក នៃ អ.ស.ប. ឬរដ្ឋដែលមិនមែនជាសមាជិក អ.ស.ប. តែមានរដ្ឋាភិបាលស្វ័យគ្រប់គ្រងរបស់ខ្លួននៅក្នុងតំបន់ ឬដែនដីណាមួយ ។

តើត្រូវប្រកបដោយលក្ខណសម្បត្តិដូចម្តេច ទើបបានក្លាយជាប្រទេសមួយស្របតាមច្បាប់អន្តរជាតិ ។ បើយោងតាមមាត្រា ១ នៃ «អនុសញ្ញាស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់រដ្ឋ [ប្រទេស]» (Montevideo Convention on Rights and Duties of States) ឆ្នាំ ១៩៣៣ បានបញ្ជាក់ថា៖“***ប្រទេសមួយដែលស្របតាមច្បាប់អន្តរជាតិនោះគួរតែប្រកបដោយលក្ខណសម្បត្តិដូចតទៅ៖***

*ក.* ***មានប្រជាជនរស់នៅជាអចិន្ត្រៃយ៍,***

*ខ.* ***មានទឹកដីច្បាស់លាស់,***

*គ.* ***មានរដ្ឋាភិបាលមួយ****, និង*

*ឃ.* ***មានសមត្ថភាពបង្កើតទំនាក់ទំនងជាមួយនឹងប្រទេសដទៃ***”។ [47]

លក្ខណសម្បត្តិទាំងបួន ខាងលើត្រូវបានគេមើលឃើញថា ជាលក្ខណវិនិច្ឆ័យដែលមានការទទួលស្គាល់យ៉ាងទូលំទូលាយ ក្នុងលក្ខណៈជាប្រទេសមួយស្របតាម

---

[46] ពាក្យ «រដ្ឋ» មកពីភាសាអង់គ្លេសថា «State» សំដៅលើ «ប្រទេស» ដូចពាក្យ «Country» ដែរ ។ ប៉ុន្តែពាក្យ «រដ្ឋ» ឬ «State» ត្រូវបានគេប្រើជាផ្លូវការនៅក្នុងឯកសារច្បាប់ផ្សេងៗរបស់ អ.ស.ប. សំដៅលើ «ប្រទេស» ។ ឧទាហរណ៍៖ រដ្ឋសមាជិក, រដ្ឋឯករាជ្យ ឬរដ្ឋស្វយ័ត ជាដើម ។

[47] Charles I. Bevans, (1931-1945), ‘Treaties and Other International Agreements of the United States of America 1776-1949’, ទំព័រ ១៤៥ - ១៥១, www.loc.gov, (Download: ២០ មករា ២០២០), https://is.gd/rwmGw4

សេចក្តីដើមជាភាសាអង់គ្លេស៖ “*Article 1 The state as a person of international law should possess the following qualifications: a ) a permanent population; b ) a defined territory; c ) government; and d) capacity to enter into relations with the other states.*”

ច្បាប់អន្តរជាតិ ។ ប៉ុន្តែបទបញ្ញត្តិប៉ុណ្ណោះនេះ មិនមែនមានន័យថា វាគ្រប់គ្រាន់ និងមិនមានការផ្លាស់ប្តូរនោះឡើយ គឺត្រូវយោងទៅតាមទម្ងន់នៃករណីនីមួយៗ និងត្រូវរាប់បញ្ចូលទាំង **«សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង»** និង **«ការទទួលស្គាល់»** ជាប្រទេសមួយពីសហគមន៍អន្តរជាតិមួយទៀត ។ [48]

ផ្ទុយទៅវិញ នៅក្នុងករណីជាក់ស្តែងខ្លះ វាមិនចាំបាច់តម្រូវឲ្យគ្រប់លក្ខណសម្បត្តិទាំង ៤ ខាងលើនោះទេ ។ ឧទាហរណ៍ដូចជានៅក្នុងមតិផ្តល់ប្រឹក្សាយោបល់របស់ខ្លួននៅក្នុងឆ្នាំ ១៩៩១ ផ្ញើទៅសន្និសីទយូហ្គោស្លាវីនៃសហគមន៍អឺរ៉ុប គណៈកម្មការអាជ្ញាកណ្តាលបានបញ្ជាក់ថា៖

> *"ប្រទេស ជាទូទៅ ត្រូវបានគេកំណត់និយមន័យថា ជាសហគមន៍មួយដែលមានទាំងទឹកដី និងប្រជាជន ព្រមស្ថិតនៅក្រោមអំណាចនយោបាយដែលបានរៀបចំឡើង"* ។ [49]

សម្រាប់ករណីដែនដីកម្ពុជាក្រោមវិញ ប្រសិនបើពលរដ្ឋខ្មែរក្រោមចង់រំដោះខ្លួនចេញពីនឹមអាណានិគមយួន និងបង្កើតជាប្រទេសមួយឲ្យស្របតាមច្បាប់អន្តរជាតិនោះ ពួកគាត់ត្រូវមានលក្ខណសម្បត្តិដូចបានរៀបរាប់មកខាងលើ នោះគឺ ត្រូវមានប្រជាជននៅជាអចិន្ត្រៃយ៍, មានទឹកដីច្បាស់លាស់, មានរដ្ឋាភិបាលមួយសម្រាប់គ្រប់គ្រង, មានសមត្ថភាពខាងវិស័យការទូតដើម្បីពង្រឹងទំនាក់ទំនងកិច្ចការបរទេស, មានសិទ្ធិក្នុងការអនុវត្តនូវ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» នៅលើទឹកដីរបស់ខ្លួន និងធ្វើការតស៊ូមតិនៅលើឆាកអន្តរជាតិ ដើម្បីឲ្យអង្គការសហប្រជាជាតិទទួលស្គាល់នូវឋានៈរបស់ខ្លួន ។

♦ **ប្រជាជនរស់នៅជាអចិន្ត្រៃយ៍៖** សព្វថ្ងៃ ខ្មែរក្រោមជាជនជាតិដើមរស់នៅជាអចិន្ត្រៃយ៍នៅលើទឹកដីកម្ពុជាក្រោមជាយូរមកហើយ ។ យោងតាមច្បាប់អន្តរជាតិ

---

[48] Malcolm N. Shaw, (2008). INTERNATIONAL LAW, (6th ed.), Cambridge University Press, ទំព័រ ១៩៨-១៩៩, (ស្រង់ប្រភព៖ ១០ តុលា ២០២០), https://is.gd/nys068

[49] Alain Pellet, The Opinions of the Badinter Arbitration Committee A Second Breath for the Self-Determination of Peoples, European Journal of International Law, Volume 3, Issue 1, 1992, ទំព័រ ១៨២, (ស្រង់ប្រភព៖ ២០ ធ្នូ ២០២០), http://ejil.org/pdfs/3/1/1175.pdf

គេមិនបានកំណត់ថា ប្រជាជននោះ ត្រូវមានចំនួនតិច ឬច្រើនប៉ុណ្ណាឡើយ ។ [50] ប្រទេសជាសមាជិក នៃ អ.ស.ប. ដែលមានប្រជាជនតិចជាងគេនោះ ដូចជា ទូវ៉ាលូ (Tuvalu) [51], ណាអូរូ (Nauru) [52] មានប្រជាជនប្រមាណជាង ១០.០០០ នាក់ និងបុរីវ៉ាទីកង់ (Vatican City) ជាប្រទេសអ្នកសង្កេតការណ៍នៅក្នុង អ.ស.ប. មានប្រជាជនប្រមាណ ៨២៥ នាក់ប៉ុណ្ណោះ [53] ។ ប៉ុន្តែនៅដែនដីកម្ពុជាក្រោម មានប្រជាជនចម្រុះជាតិសាសន៍ដល់ទៅជាង ៣៥ លាននាក់ ក្នុងនោះ ពលរដ្ឋខ្មែរក្រោមមានប្រមាណ ៧ លាននាក់ ឯណោះ ។[54]

♦ **ទឹកដីច្បាស់លាស់៖** ដែនដីកម្ពុជាក្រោម មានផ្ទៃដីទំហំ ៦៧.៧០០ គីឡូម៉ែត្រក្រឡា ដែលជាទឹកដីរបស់ជនជាតិដើមខ្មែរក្រោម តែត្រូវអាណានិគមបារាំងផ្ទេរឲ្យទៅយួននៅថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ១៩៤៩ បន្តធ្វើអាណានិគមរហូតមកដល់ សព្វថ្ងៃ ។

♦ **រដ្ឋាភិបាល៖** សព្វថ្ងៃ ខ្មែរក្រោមគ្មានរដ្ឋាភិបាលដែលបានបង្កើតឡើងដោយខ្លួនឯងនៅកម្ពុជាក្រោម ដើម្បីគ្រប់គ្រងខ្លួនឯងទេ ដោយពួកគាត់កំពុងតែរស់នៅក្រោមនឹមត្រួតត្រារបស់អាណានិគមយួន ។ មិនត្រឹមតែមិនមានរដ្ឋាភិបាលនោះទេ សូម្បីតែគណបក្សនយោបាយ, សមាគម ឬ អង្គការក្រៅរដ្ឋាភិបាល (NGO) ក៏គ្មានដែរ ព្រោះរបបអាណានិគមយួនជារដ្ឋាភិបាលកុម្មុយនីស្ត មិនអនុញ្ញាតឲ្យប្រជាជនបង្កើតជាគណបក្សនយោបាយ, សមាគម ឬអង្គការក្រៅរដ្ឋាភិបាលនោះទេ ។ ប៉ុន្តែ នេះជាការរំលោភបំពានសិទ្ធិមនុស្សមួយយ៉ាងធ្ងន់មកលើប្រជាជន និងជនជាតិដើម ដោយសាររដ្ឋាភិបាលយួនបានចុះហត្ថលេខាលើសន្ធិសញ្ញាសិទ្ធិមនុស្សជាច្រើនជាមួយ អ.ស.ប. ដោយបានសន្យាថា នឹងគោរពសិទ្ធិមនុស្សជាមូលដ្ឋាន ។

♦ **សមត្ថភាពបង្កើតទំនាក់ទំនងជាមួយនឹងប្រទេសដទៃ៖** របបអាណានិគមយួនបាន

---

[50] ដូចលេខយោង [48], ទំព័រ ១៩៩

[51] 'Tuvalu Population & Housing Mini-Census 2017 Preliminary Report', sdd.spc.int, (ស្រង់ប្រភព៖ ១០ ធ្នូ ២០២០), https://is.gd/f55wha ។ ឆ្នាំ ២០១៧ ប្រជាជនទូវ៉ាលូ មាន ១០.៦៤៥ នាក់ ។

[52] The World Bank, 'Population, total - Nauru', (ស្រង់ប្រភព៖ ១០ ធ្នូ ២០២០), https://is.gd/7ZHNC8 ឆ្នាំ ២០១៩ ប្រជាជនណាអូរូ មាន ១២៥៨១ នាក់ ។

[53] Vatican City State, (១ កុម្ភៈ ២០១៩),'Popolazione', vaticanstate.va, (ស្រង់ប្រភព៖ ២០ ធ្នូ ២០២០), https://is.gd/IVyKtV

[54] សូមមើលចំនួនខ្មែរក្រោមនៅទំព័រ ៥៥ - ៥៧

លាក់បាំងខ្មែរក្រោមឲ្យនៅខាងក្រោយវាំងននៃឆាកនយោបាយរបស់គេ ដោយគេធ្វើអ្វីគ្រប់យ៉ាង ដើម្បីបិទបាំងមិនឲ្យសហគមន៍អន្តរជាតិបានស្គាល់ខ្មែរក្រោមជានរណាឡើយ ។ ដូចជានៅក្នុងពិធីបុណ្យវិសាខបូជា អ.ស.ប. ដែលបានប្រារព្ធជារៀងរាល់ឆ្នាំ សមាគមពុទ្ធសាសនាវៀតណាម ដែលជាស្ថាប័នមួយរបស់រដ្ឋាភិបាលយួន មិនដែលឲ្យតំណាងព្រះសង្ឃខ្មែរក្រោមឡើងថ្លែងការណ៍នៅចំពោះមុខអន្តរជាតិម្តងណាឡើយ ។ ប៉ុន្តែសំណាងល្អ ដោយសារសព្វថ្ងៃមាន សហព័ន្ធខ្មែរកម្ពុជាក្រោម នៅក្រៅប្រទេស តែងតែចូលថ្លែងការណ៍ជាបន្តបន្ទាប់នៅក្នុង អ.ស.ប. អំពីករណីដែលរបបយួនជិះជាន់លើជនជាតិដើមខ្មែរក្រោមឲ្យសហគមន៍អន្តរជាតិបានជ្រាប ។

♦ **សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង៖** របបអាណានិគមយួនបានក្តាប់អំណាចទាំងស្រុងលើពលរដ្ឋខ្មែរក្រោម ។ ទោះបីរបបយួនបានចុះហត្ថលេខាលើអនុសញ្ញា និងកតិកាសញ្ញាអន្តរជាតិជាច្រើន ស្តីពីការគោរពនូវសិទ្ធិនេះយ៉ាងណាក៏ដោយ តែគេមិនបានអនុវត្តតាមកិច្ចព្រមព្រៀងឡើយ ។ ដូច្នេះ សព្វថ្ងៃ ជនជាតិដើមខ្មែរក្រោម គ្មានសិទ្ធិក្នុងការអនុវត្តនូវ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» នៅលើទឹកដីកំណើតរបស់ខ្លួនឡើយ ។ ទង្វើនេះបង្ហាញឲ្យឃើញថា របបអាណានិគមយួនកំពុងតែរំលោភបំពានជាទម្ងន់លើ សេចក្តីសម្រេចលេខ 1514 (XV) ឆ្នាំ ១៩៦៩ របស់ អ.ស.ប., ប្រការ ១ មាត្រា ១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិស៊ីវិល និងនយោបាយ (ICCPR), សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ICESCR) និងសេចក្តីប្រកាសស្តីពីសិទ្ធិជនជាតិដើម (UNDRIP) ឆ្នាំ ២០០៧ របស់ អ.ស.ប. ដែលបានចែងថា ប្រជាជន ឬជនជាតិដើមទាំងអស់មាន «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ។

♦ **ការទទួលស្គាល់៖** ដោយមានការតស៊ូពីជំនាន់មួយទៅជំនាន់មួយក្នុងបុព្វហេតុទប់ទល់នឹងការឈ្លានពានទឹកដីរបស់យួន និងការពារជាតិ និងសាសនាមិនឲ្យរលាយក្រោមមហិច្ឆតារំលាយពូជសាសន៍ពីអាណានិគមយួននោះ នៅដើមសតវត្សរ៍ទី ២១ ខ្មែរក្រោម បានក្លាយជាសមាជិកពេញសិទ្ធិនៃ UNPO នៅឆ្នាំ ២០០១ ហើយអង្គការនេះបានទទួលស្គាល់ថាជាប្រជាជាតិមួយដែលមានពូជអម្បូរ និងទឹកដីរបស់ខ្លួន តែត្រូវ

បរទេសឈ្លានពាន និងធ្វើអាណានិគម ។ តាំងពីពេលនោះមក ទង់ជាតិកម្ពុជាក្រោម ដែលមានបីព័ណ៌ គឺ ខៀវ លឿង និង ក្រហម ត្រូវបានបង្ហូតឡើងនៅក្នុងទីស្នាក់ការនៃអង្គការ UNPO នាទីក្រុងឡាអេ ប្រទេសហុល្លង់ ក្នុងចំណោមទង់ជាតិនៃប្រជាជាតិ និងប្រជាជននានានៅក្នុងពិភពលោក ដែលជាសមាជិករបស់ UNPO ។ បួនឆ្នាំក្រោយមក គឺចាប់តាំងពីឆ្នាំ ២០០៤ សហព័ន្ធខ្មែរកម្ពុជាក្រោម បានចូលថ្លែងការណ៍នៅក្នុង វេទិកាអចិន្ត្រៃយ៍នៃ អ.ស.ប. ស្តីពីបញ្ហាជនជាតិដើម (UNPFII) ជារៀងរាល់ឆ្នាំ ។ នេះគ្រាន់តែជាការតស៊ូរបស់ចលនាខ្មែរក្រោមនៅក្រៅប្រទេស ដើម្បីតំណាងខ្មែរក្រោមនៅក្នុងស្រុកដែលត្រូវយួនបិទសំឡេងតែប៉ុណ្ណោះ ។

ដូច្នេះ មកដល់ពេលនេះ ការតស៊ូរបស់ខ្មែរក្រោម ទើបតែធ្វើដំណើរដល់ដំណាក់កាលមួយបានទទួលឋានៈជា «ជនជាតិដើម» នៅក្នុង អ.ស.ប. តែមានឋានៈជា «ជនជាតិភាគតិច» នៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលអាណានិគមយួន ។ ទោះបីបានបោះឆ្នោតគាំទ្រនូវសេចក្តីប្រកាសរបស់ អ.ស.ប. ស្តីពីសិទ្ធិជនជាតិដើម (UNDRIP) យ៉ាងណាក៏ដោយ តែរដ្ឋាភិបាលវៀតណាមមិនបានទទួលស្គាល់ជនជាតិដែលខ្លួនចាត់ទុកថាជា «ជនជាតិភាគតិច» នោះជា «ជនជាតិដើម» ឡើយ ។ ប្រទេសវៀតណាមមាន ៥៤ ជនជាតិ ក្នុងនោះមាន ៥៣ ជនជាតិ (ក្រៅពីយួន) ត្រូវបានរដ្ឋាភិបាលទទួលស្គាល់ថាជា «ជនជាតិភាគតិច» ដើម្បីឲ្យគេមើលឃើញថាជាប្រទេសមួយដែលមានចម្រុះជនជាតិ ។ រដ្ឋាភិបាលវៀតណាមមិនប្រើពាក្យ «ជនជាតិដើម» សម្រាប់សម្គាល់ជនជាតិដែលគេចាត់ទុកថាជាជនជាតិភាគតិចណាមួយនោះឡើយ ដោយប្រើពាក្យ «ជនជាតិភាគតិច» ជំនួសវិញ ។ [55]

## នីតិវិធីក្នុងការបង្កើតជា «ប្រទេស» មួយៈ

បន្ទាប់ពីប្រទេសកូសូវ៉ូបានប្រកាសឯករាជ្យជាឯកតោភាគី ផ្តាច់ខ្លួនចេញពីប្រទេសស៊ែប៊ៀ (Serbia) កាលពីឆ្នាំ ២០០៨ រួចមក បានធ្វើឲ្យប្រទេសជាច្រើននៅជុំវិញពិភពលោកយកគំរូតាមប្រទេសមួយនេះ ។ ដើម្បីបង្កើតជាប្រទេសមួយស្របតាមច្បាប់អន្តរជាតិ និងមានការទទួលស្គាល់ពី អ.ស.ប. នោះ តើត្រូវចាប់ផ្តើមពីណាទៅ ?

[55] IWGIA , 'Indigenous peoples in Vietnam', (ស្រង់ប្រភព៖ ១៤ ធ្នូ ២០២០), https://www.iwgia.org/en/vietnam

ប្រវត្តិនៃការបង្កើតជាប្រទេសនីមួយៗនៅក្នុងពិភពលោក បានបង្ហាញឲ្យឃើញថា វាមិនមែនជារឿងងាយស្រួលនោះទេ គឺប្រជាជាតិនីមួយៗទម្រាំតែមានប្រទេសនៅក្នុងផែនទីពិភពលោកនោះ ពួកគេត្រូវឆ្លងកាត់នូវការតស៊ូដោយការបង្ហូរឈាមនៅក្នុងភ្នក់ភ្លើងសង្គ្រាមដ៏យូរអង្វែង ។ ទម្រាំបានទទួលឯករាជ្យ និងសន្តិភាពនោះ មនុស្សម្នាត្រូវស្លាប់ គ្រួសារប្តីប្រពន្ធកូនចៅត្រូវព្រាត់ប្រាស ទ្រព្យសម្បត្តិត្រូវវិនាសហិនហោច និងជីវិតរស់នៅក្នុងគ្រោះភ័យគ្រប់ពេលវេលា ។ ទោះបីយ៉ាងនេះក្តី មនុស្សគ្រប់ជាតិសាសន៍បានធ្វើពលិកម្មគ្រប់បែបសព្វយ៉ាង ដើម្បីប្តូរយក «ឯករាជ្យ» និង «សេរីភាព» នៅលើទឹកដីរបស់ខ្លួនដោយសេចក្តីក្លាហាន ព្រោះពួកគេយល់ឃើញថា ផ្លែផ្កាដែលកើតចេញពីការលះបង់នោះ នឹងធ្វើឲ្យជាតិសាសន៍របស់គេមានឥស្សរភាព និងបានរួចផុតនឹមត្រួតត្រារបស់អាណានិគម ។

ដើម្បីបង្កើតជាប្រទេសមួយឲ្យមានការទទួលស្គាល់ជាលក្ខណៈអន្តរជាតិនោះ ត្រូវអនុវត្តតាមនីតិវិធី ៤ ជំហាន ដូចជា ការសិក្សាអំពីលទ្ធភាព, ប្រកាសឯករាជ្យ, មានការទទួលស្គាល់, និងចូលជាសមាជិក នៃ អ.ស.ប. ។

♦ **ជំហានទី ១ សិក្សាអំពីលទ្ធភាព៖** ដើម្បីបង្កើតជាប្រទេសមួយ មុនដំបូង គេត្រូវសិក្សាអំពីលទ្ធភាពនៃប្រទេសនោះសិន ព្រោះច្បាប់អន្តរជាតិមានកំណត់នូវបទដ្ឋានជាអប្បបរមានូវឋានៈភាពជាប្រទេសមួយ ។ ប្រទេសដែលគេនឹងបង្កើតនោះ ត្រូវប្រកបដោយលក្ខណសម្បត្តិ ៤ យ៉ាងគឺ មានប្រជាជនរស់នៅជាអចិន្ត្រៃយ៍, មានទឹកដីច្បាស់លាស់, មានរដ្ឋាភិបាលមួយសម្រាប់គ្រប់គ្រងដោយប្រសិទ្ធភាព និងមានសមត្ថភាពក្នុងការធ្វើទំនាក់ទំនងកិច្ចការបរទេស ដែលមានចែងនៅក្នុងមាត្រា ១ នៃ «អនុសញ្ញាស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ប្រទេស» ។ ត្រង់ចំណុចនេះ បើយើងពិចារណាចំពោះករណីខ្មែរក្រោមវិញ ឃើញថា សព្វថ្ងៃ ពួកគាត់នៅមិនទាន់មានរដ្ឋាភិបាលស្វ័យគ្រប់គ្រងមួយរបស់ខ្លួននៅដែនដីកម្ពុជាក្រោមនៅឡើយ ។

♦ **ជំហានទី ២ ប្រកាសឯករាជ្យ៖** ពេលមានលទ្ធភាពគ្រប់គ្រាន់ហើយ ត្រូវប្រកាសឯករាជ្យ ។ ពេលប្រកាសឯករាជ្យរួចហើយ អ្នកនឹងបានទទួលនូវអត្ថប្រយោជន៍មួយ

ចំនួនយ៉ាងពិតប្រាកដ ទោះបីប្រទេសនោះ នៅមិនទាន់មានអ្នកទទួលស្គាល់យ៉ាងណាក៏ដោយចុះ ។ លោក ស្ទីហ្វែន តាម៉ុន (Stefan Talmon) ជាសាស្ត្រាចារ្យច្បាប់អន្តរជាតិសាធារណៈនៃសាកលវិទ្យាល័យ Oxford និងជាអ្នកនិពន្ធអំពី «ការទទួលស្គាល់នៅក្នុងច្បាប់អន្តរជាតិ» បានថ្លែងថា នៅពេលដែលអង្គភាពមួយបានបង្កើតជាប្រទេសមួយជាក់ស្តែង វានឹងបានទទួលនូវអត្ថប្រយោជន៍ពីបូរណភាពទឹកដី និងមានការធានាជាក់លាក់នៃអធិបតេយ្យភាព ។ ឧទាហរណ៍ ដូចជានៅឆ្នាំ ២០០៨ កូសូវ៉ូបានប្រកាសឯករាជ្យបង្កើតជាប្រទេសមួយ ស៊ែប៊ៀមិនអាចវាយប្រហារដោយសេរីដើម្បីដណ្តើមយកកូសូវ៉ូមកវិញបានទេ ព្រោះវាត្រូវបានទទួលនូវអត្ថប្រយោជន៍ពីការហាមឃាត់ការប្រើកម្លាំងទ័ពយោងតាមធម្មនុញ្ញនៃ អ.ស.ប. ។ ច្បាប់ទាំងនេះត្រូវបានបង្កើតឡើងក្នុងអំឡុងពេលសង្គ្រាមត្រជាក់ ដើម្បីការពារប្រទេសថ្មីដែលមិនទាន់ត្រូវបានទទួលស្គាល់ដោយក្រុមប្រទេសនានា ។[56]

ពេលប្រកាសឯករាជ្យនៅឆ្នាំ ២០០៨ កូសូវ៉ូ មានប្រទេសចំនួន ១១៧ ក្នុងចំណោម ១៩៣ ជាសមាជិកនៃ អ.ស.ប. ទទួលស្គាល់ តែមកដល់ឆ្នាំ ២០២០ នេះ នៅសល់តែ ៩៧ ប្រទេសប៉ុណ្ណោះ ដោយសារប្រទេសខ្លះ បានដកនូវការទទួលស្គាល់របស់ខ្លួនឡើងវិញ ។[57] មុនពេលប្រកាសឯករាជ្យ កូសូវ៉ូធ្លាប់បានធ្វើប្រជាមតិម្តងរួចមកហើយ នៅឆ្នាំ ១៩៩១ ដោយមានអ្នកបោះឆ្នោតចំនួន ៩៩% គាំទ្រឯករាជ្យនៅកូសូវ៉ូ ប៉ុន្តែត្រូវបានធ្វើពហិការដោយក្រុមជនជាតិស៊ែប (Serb) ជាប្រជាជនមួយដែលមានចំនួនប្រមាណ ១០% រស់នៅក្នុងតំបន់នោះ ។ [58] ដោយសារមានសង្គ្រាមបែងចែកពូជសាសន៍រវាងជនជាតិអាលបាណៀ (Albania) និងជនជាតិស៊ែប នៅក្នុងឆ្នាំ ១៩៩៨ និង ឆ្នាំ ១៩៩៩ ក្រុមប្រឹក្សាសន្តិសុខ អ.ស.ប. បានចេញសេចក្តីសម្រេចលេខ ១២៤៤ នៅថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ១៩៩៩ សម្រេចឲ្យកូសូវ៉ូ ឋិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មការ

[56] JOSHUA KEATING, (២៦ កុម្ភៈ ២០០៨), “How to Start Your Own Country in Four Easy Steps”, Foreign Policy, (ស្រង់ប្រភព៖ ១០ កញ្ញា ២០២០), https://is.gd/ZEQbEk

[57] Craig Turp-Balazs, (១៦ មករា ២០២០), “Serbia’s campaign to reduce the number of countries which recognise Kosovo is working’, Emerging Europe, (ស្រង់ប្រភព៖ ១០ វិច្ឆិកា ២០២០), https://is.gd/H4jiaE

[58] Direct Democracy, (៣ តុលា ២០១៧), ‘Kosovo (Jugoslawien), 30. September 1991 : Unabhängigkeit, (ស្រង់ប្រភព៖ ១២ កក្កដា ២០២០), https://is.gd/1pMbQ3

«បេសកម្មរបស់ អ.ស.ប. នៅកូសូវ៉ូ» (United Nations Mission in Kosovo) ។ សេចក្ដីសម្រេចនេះបានអនុម័តថា កូសូវ៉ូនឹងមានរដ្ឋាភិបាលស្វយ័តមួយនៅក្នុងចំណោះប្រទេសសាធារណរដ្ឋសហព័ន្ធយូហ្គូស្លាវី ។ [59] ពេលមានលទ្ធភាពគ្រប់គ្រាន់ហើយ រដ្ឋសភារដ្ឋាភិបាលសាធារណរដ្ឋកូសូវ៉ូ បានយល់ព្រមជាឯកច្ឆន្ទលើការប្រកាសឯករាជ្យផ្ដាច់ខ្លួនចេញពីប្រទេសស៊ែប៊ី នៅថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ២០០៨ នៅក្នុងកិច្ចប្រជុំមួយជាប្រវត្តិសាស្ត្រ ។ ពិធីអបអរសាទរបុណ្យឯករាជ្យជាតិ បានធ្វើឡើងនៅពេលរាត្រី បន្ទាប់ពីនាយករដ្ឋមន្ត្រីកូសូវ៉ូ លោក ហាស៊ិម ថាស៊ី (Hashim Thaci) បានប្រកាសសន្យាថា នឹងគោរពនូវសិទ្ធិរបស់ជនជាតិទាំងអស់ ។ លោក ថាស៊ី បានថ្លែងថា៖

> *“យើងបានរង់ចាំថ្ងៃនេះជាយូរមកហើយ ។ ចាប់ពីថ្ងៃនេះតទៅ យើងមានមោទនភាពចំពោះឯករាជ្យ និងសេរីភាព”* ។[60]

♦ **ជំហានទី ៣ មានការទទួលស្គាល់៖** ស្វែងរកការទទួលស្គាល់ជាលក្ខណៈអន្តរជាតិពីប្រទេសនានាក្នុងពិភពលោក ព្រោះការទទួលស្គាល់បានធ្វើឲ្យប្រទេសមានភាពស្របច្បាប់នៅក្នុងសហគមន៍អន្តរជាតិ ។ លោក ស៊ីហ្វែន តាម៉ុន បានមានប្រសាសន៍ថា ដើម្បីឲ្យប្រទេសមួយមានការទទួលស្គាល់នោះ មានភាពស្មុគស្មាញណាស់ ពីព្រោះវារួមបញ្ចូលទាំងច្បាប់អន្តរជាតិផង និងនយោបាយអន្តរជាតិផង ។ តែអ្នកខ្លះលើកឡើងថា ការទទួលស្គាល់គឺជាទង្វើនយោបាយសុទ្ធសាធ ។ [61]

♦ **ជំហានទី ៤ សុំចូលជាសមាជិកអង្គការសហប្រជាជាតិ (អ.ស.ប.)៖**

ចាប់តាំងពីបានបង្កើតឡើងនៅឆ្នាំ ១៩៤៥ សមាជិកភាពនៅក្នុង អ.ស.ប. បានក្លាយជាស្តង់ដារមាសនៃភាពស្របច្បាប់អន្តរជាតិ ។ លោក ស៊ីហ្វែន តាម៉ុន មានប្រសាសន៍ថា នៅពេលដែលអ្នកត្រូវបានគេអនុញ្ញាតឲ្យចូលជាសមាជិក អ.ស.ប. នោះ គឺជាទម្រង់នៃការយល់ព្រមមួយ ។ វាដូចជាត្រាមួយសម្រាប់បញ្ជាក់ថា ឥឡូវនេះ អ្នកគឺជា

[59] BBC, (១៧ មិថុនា ១៩៩៩), ‘RESOLUTION 1244 (1999)’, (ស្រង់ប្រភព៖ ១១ សីហា ២០២០), https://is.gd/3wXKel

[60] BBC NEWS, (១៧ កក្កដា ២០០៨), ‘Kosovo MPs proclaim independence’, (ស្រង់ប្រភព៖ ២១ ធ្នូ ២០២០), https://is.gd/TWDoM6

[61] ដូចលេខយោង [56]

សមាជិកពេញលេញរបស់សហគមន៍អន្តរជាតិ ។ [62]

លក្ខណវិនិច្ឆ័យសម្រាប់ការទទួលយកនូវសមាជិកថ្មីនៅក្នុង អ.ស.ប. មានចែងក្នុងប្រការ ៤ ជំពូកទី ២ នៃធម្មនុញ្ញរបស់ អ.ស.ប. ថា៖

> *“១. សមាជិកភាពរបស់ អ.ស.ប. គឺបើកចំហចំពោះរដ្ឋទាំងឡាយដែលស្រឡាញ់សន្តិភាព ហើយយល់ព្រមលើកាតព្វកិច្ចដែលមានចែងក្នុងធម្មនុញ្ញ និងនៅក្នុងសេចក្តីសម្រេចរបស់ អ.ស.ប. អាចនឹងមានឆន្ទៈក្នុងការទទួលខុសត្រូវលើភារកិច្ចទាំងអស់នេះ ។*
>
> *២. ការទទួលយករដ្ឋណាមួយចូលទៅជាសមាជិកភាពនៅក្នុង អ.ស.ប. នឹងត្រូវឆ្លងកាត់នូវសេចក្តីសម្រេចរបស់មហាសន្និបាតតាមអនុសាសន៍របស់ក្រុមប្រឹក្សាសន្តិសុខ ”* ។[63]

ការទទួលស្គាល់នូវប្រទេស ឬរដ្ឋាភិបាលថ្មីណាមួយឲ្យចូលជាសមាជិកនៃ អ.ស.ប. នោះ មិនមែនជាការសម្រេចចិត្តរបស់ អ.ស.ប. ទេ ប៉ុន្តែ វាជាការសម្រេចរបស់ប្រទេស និងរដ្ឋាភិបាលឯករាជ្យនៅក្នុង អ.ស.ប. ទៅវិញ ។

> *“ការទទួលស្គាល់នូវប្រទេស ឬរដ្ឋាភិបាលថ្មីណាមួយគឺជាទង្វើមួយដែលមានតែប្រទេស និងរដ្ឋាភិបាលដទៃទេ ដែលអាចផ្តល់ ឬបដិសេធ ។ ជាទូទៅ វាបង្ហាញពីការត្រៀមខ្លួនដើម្បីសន្មតនូវទំនាក់ទំនងការទូត ។ អ.ស.ប. មិនមែនជាប្រទេស និងរដ្ឋាភិបាលទេ ដូច្នេះ មិនមានសិទ្ធិអំណាចណាមួយ ក្នុងការទទួលស្គាល់នូវប្រទេស និងរដ្ឋាភិបាលណាមួយឡើយ ។ ក្នុងនាមអង្គការមួយនៃប្រទេសឯករាជ្យ បានត្រឹមតែទទួលយកនូវប្រទេសថ្មីមួយឲ្យចូលជាសមាជិករបស់ខ្លួន ឬទទួលយកនូវលិខិតតែងតាំងតំណាងនៃរដ្ឋាភិបាលថ្មីណាមួយតែប៉ុណ្ណោះ”* ។ [64]

នីតិវិធីក្នុងការដាក់ពាក្យចូលជាសមាជិកនៃ អ.ស.ប. នោះ មានលក្ខណៈសង្ខេបដូច

[62] ដូចលេខយោង [56], https://is.gd/ZEQbEk

[63] United Nations, ‘Charter of the United Nations, Chapter II: Membership’, un.org, (ស្រង់ប្រភព៖ ១ តុលា ២០២០), https://is.gd/EuTJCq

[64] UN, ‘About UN Membership’, un.org, (ស្រង់ប្រភព៖ ២៣ តុលា ២០២០), https://is.gd/I0PcUO

ខាងក្រោម៖

♦ រដ្ឋ ឬ ប្រទេស ត្រូវដាក់ពាក្យសុំចូលជាសមាជិកមួយច្បាប់ទៅអគ្គលេខាធិការ អ.ស.ប. និងលិខិតមួយបញ្ជាក់ជាផ្លូវការប្រកាសថា ខ្លួនព្រមទទួលយកនូវកាតព្វកិច្ចដែលមានចែងនៅក្នុង ធម្មនុញ្ញ អ.ស.ប. ។

♦ ក្រុមប្រឹក្សាសន្តិសុខ អ.ស.ប. នឹងពិចារណាលើពាក្យសុំនេះ ។ អនុសាសន៍ណាមួយសម្រាប់ការចូលជាសមាជិកនោះ ត្រូវតែទទួលបានសំឡេងគាំទ្រពីសមាជិកទាំង ៩ ក្នុងចំណោមសមាជិកទាំង ១៥ នៃក្រុមប្រឹក្សាសន្តិសុខ (9/15) ក្នុងលក្ខខណ្ឌដោយមិនមានសមាជិកណាមួយក្នុងចំណោមសមាជិកទាំង ៥ នៃសមាជិកអចិន្ត្រៃយ៍ក្រុមប្រឹក្សានេះ រួមមាន ចិន, បារាំង, សហព័ន្ធរុស្ស៊ី, ចក្រភពអង់គ្លេស, អៀរឡង់ខាងជើង និង សហរដ្ឋអាមេរិក បោះឆ្នោតជំទាស់នឹងពាក្យសុំនេះ ។

♦ ប្រសិនបើក្រុមប្រឹក្សាផ្តល់អនុសាសន៍ឲ្យដាក់ពាក្យ អនុសាសន៍នោះនឹងត្រូវបានប្រគល់ជូនទៅមហាសន្និបាតដើម្បីពិចារណា ។ មហាសន្និបាតត្រូវការសំឡេងភាគច្រើនពីរភាគបី (2/3) ដើម្បីទទួលយករដ្ឋ ឬប្រទេសថ្មីចូលជាសមាជិក ។

♦ សមាជិកភាពមានប្រសិទ្ធភាពចាប់ពីថ្ងៃធ្វើសេចក្តីសម្រេចលើការសុំចូលត្រូវបានអនុម័ត ។ [65]

អង្គការសហប្រជាជាតិ ឬ អ.ស.ប. គឺជាអង្គការអន្តររដ្ឋាភិបាលដែលមានភារកិច្ចថែរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ អភិវឌ្ឍទំនាក់ទំនងមិត្តភាព រវាងប្រជាជាតិនានា សម្រេចឲ្យបាននូវកិច្ចសហប្រតិបត្តិការអន្តរជាតិ និងជាមជ្ឈមណ្ឌលសម្រាប់ការធ្វើសមាហរណកម្មសកម្មភាពរបស់ប្រជាជាតិនានា ។ [66] អ.ស.ប. គឺជាអង្គការអន្តររដ្ឋាភិបាលដែលមានប្រជាប្រិយ និងល្បីល្បាញជាងគេបំផុត និងជាអង្គការអន្តររដ្ឋាភិបាលដ៏មានឥទ្ធិពលបំផុតនៅក្នុងពិភពលោក ។ អង្គការនេះ ត្រូវបានបង្កើតឡើង

[65] ដូចលេខយោង [64]

[66] UN, 'Charter of UN Chapter I', un.org, (ស្រង់ប្រភព៖ ២ កញ្ញា ២០២០), https://is.gd/o5diRq

បន្ទាប់ពីសង្គ្រាមលោកលើកទី ២ ក្នុងគោលបំណងទប់ស្កាត់សង្គ្រាមនាពេលអនាគត ហើយទទួលបានជោគជ័យក្នុងការបែងចែកសម្ព័ន្ធប្រជាជាតិ ។ [67] ពេលដែលបង្កើត អ.ស.ប. នៅឆ្នាំ ១៩៤៥ អ.ស.ប. មានសមាជិកត្រឹមតែ ៥១ ប្រទេសតែប៉ុណ្ណោះ តែមកដល់ពេលបច្ចុប្បន្ន អ.ស.ប. មានសមាជិកចំនួន ១៩៣ ប្រទេស ។ [68]

ឧបសគ្គធំបំផុតចំពោះការសុំចូលជាសមាជិកភាពនៅក្នុង អ.ស.ប. នោះគឺ អំណាចនយោបាយ ។ បញ្ហានេះ បានធ្វើឲ្យប្រទេសកូរ៉េខាងជើង និងកូរ៉េខាងត្បូង មិនបានចូលជាសមាជិក អ.ស.ប. រហូតដល់ឆ្នាំ ១៩៩១ ដោយសារតែការបដិសេធនូវសមាជិកភាពពីប្រទេសដែលមាននិន្នាការនយោបាយប្រកាន់តាមប្លុកនេះ ឬប្លុកនោះ នៅក្នុងសម័យសង្គ្រាមត្រជាក់ ។ សូម្បីតែសព្វថ្ងៃនេះ សិទ្ធិជំទាស់ (Veto) របស់រុស្ស៊ី នៅក្នុងក្រុមប្រឹក្សាសន្តិសុខ អ.ស.ប. ប្រហែលជានឹងរារាំងមិនឲ្យប្រទេសកូសូវ៉ូ ឆាប់ទទួលបាននូវអាសនៈមួយនៅ អ.ស.ប. ។ សាធារណរដ្ឋចិន ឬ កោះតៃវ៉ាន់ គឺជាសមាជិកស្ថាបនិកនៃ អ.ស.ប. ហើយធ្លាប់មានអាសនៈអចិន្ត្រៃយ៍នៅក្រុមប្រឹក្សាសន្តិសុខ តំណាងប្រទេសចិននៅក្នុង អ.ស.ប. ទៀតផង តែត្រូវ អ.ស.ប. បដិសេធនូវសមាជិកភាព ដោយបានចេញសេចក្តីសម្រេចលេខ 2758 ក្នុងឆ្នាំ ១៩៧១ ទទួលស្គាល់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន (ចិនកុម្មុយនីស្ត) ជាតំណាងប្រទេសចិនស្របច្បាប់នៅក្នុង អ.ស.ប. ទៅវិញ ។ រដ្ឋាភិបាលតៃវ៉ាន់បានដាក់ពាក្យសុំចូលជាសមាជិករៀងរាល់ឆ្នាំ ចាប់តាំងពីឆ្នាំ ១៩៩៣ មក ប៉ុន្តែគ្មានបានផលអ្វីឡើយ ។ មិនត្រឹមតែប៉ុណ្ណោះ អ.ស.ប. មិនឃ្លានសូម្បីតែបើកមើលលិខិតថ្មីៗបំផុតរបស់តៃវ៉ាន់ ទៀតផង ។

ដូចយើងបានឃើញស្រាប់ហើយ ដែនដីមួយដែលបានក្លាយជារដ្ឋ ឬប្រទេសមួយជាផ្លូវការនោះមានច្រើនណាស់ តែការបានទទួលស្គាល់ពីសហគមន៍អន្តរជាតិ គឺជាពានរង្វាន់មួយទៀតសែនពិបាកក្នុងការទទួលយកវា ។ ផ្ទុយទៅវិញ ការណ៍នេះជាដំណឹងល្អមួយសម្រាប់ជាតិសាសន៍ដែលចេះតស៊ូ អត់ធ្មត់ និងរង់ចាំ ព្រោះថា “*អ្នករង់ចាំកាន់តែ*

[67] National Geographic, (២៣ ធ្នូ ២០១២), ‘International Organization’, www.nationalgeographic.org, (ស្រង់ប្រភព៖ ២ កញ្ញា ២០២០), https://is.gd/cj2bhl

[68] UN, ‘Growth in United Nations membership, 1945-present’, (ស្រង់ប្រភព៖ ២ កញ្ញា ២០២០), https://is.gd/F5A9Mw

*យូរ ឱកាសរបស់អ្នកកាន់តែប្រសើរឡើង ។ នៅក្នុងច្បាប់អន្តរជាតិ ច្រើនតែយោងទៅលើក្រមរដ្ឋប្បវេណីជាមូលដ្ឋាន ពេលដែលអ្នកអាចរក្សាទុនូវអធិបតេយ្យភាពជាក់ស្តែង (de facto sovereignty) កាន់តែយូរ អ្នកកាន់តែមានលទ្ធភាពក្នុងការទទួលស្គាល់" ។*

កម្លាំងនៃការដណ្តើមបានឯករាជ្យរបស់កូសូវ៉ូ ផ្តាច់ខ្លួនចេញពីប្រទេសស៊ែប៊ៀនោះគឺមួយភាគដ៏ធំ គេពឹងលើមូលដ្ឋានជាក់ស្តែងមួយដែលគេមានគំនិត និងគោលបំណងលើឯករាជ្យនេះរាប់ទសវត្សរ៍មកហើយ ។ ម្យ៉ាងទៀត សាធារណរដ្ឋម៉ាល់តា (Malta) ជាប្រទេសកោះមួយនៅភាគខាងត្បូងទ្វីបអឺរ៉ុប មានផ្ទៃដីត្រឹមតែ ៣១៦ គីឡូម៉ែត្រការ៉េ មានប្រជាជនប្រមាណ ៤៥០.០០០ នាក់ប៉ុណ្ណោះ ជាប្រទេសតូចជាងគេនៅក្នុងពិភពលោក មានអធិបតេយ្យភាព ៩០០ ឆ្នាំ មានទំនាក់ទំនងការទូតជាមួយនឹងប្រទេសចំនួន ១០០ នៅក្នុងពិភពលោក និងសព្វថ្ងៃ ជាប្រទេសអ្នកសង្កេតការណ៍នៅក្នុង អ.ស.ប. នៅតែខំប្រឹងបន្តតស៊ូ ដើម្បីបានចូលជាសមាជិកពេញលេញរបស់ អ.ស.ប. រហូតមកដល់សព្វថ្ងៃ ។ ដូច្នេះ សូមកុំបាក់ទឹកចិត្ត ចូរចាប់ផ្តើមបង្កើតប្រទេសរបស់ខ្លួនឯងទៅ មិនមែនថាវាមិនអាចធ្វើទៅបាននោះទេ ។ វានឹងតម្រូវឲ្យមានការអត់ធ្មត់ខ្លាំង និងមានមិត្តភក្តិសមប្រកប ។ [69]

សម្រាប់ខ្មែរក្រោមជាជនជាតិដើមនៃដែនដីកម្ពុជាក្រោមវិញ ជាជាតិសាសន៍មួយដែលគោរពប្រតិបត្តិតាមទ្រឹស្តី **«អត្តាហិ អត្តនោ នាថោ»** ឬ **«ខ្លួនជាទីពឹងរបស់ខ្លួន»** នៅក្នុងពុទ្ធសាសនាជាយូរមកហើយ ។ បច្ចុប្បន្ន ទ្រឹស្តី «ខ្លួនជាទីពឹងរបស់ខ្លួន» ត្រូវនឹងពាក្យ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ដែលមានចែងនៅក្នុងសេចក្តីប្រកាសរបស់ អ.ស.ប. ស្តីពីសិទ្ធិជនជាតិដើម និងនៅក្នុងច្បាប់អន្តរជាតិនានា នឹងក្លាយទៅជាមាគ៌ាតស៊ូមួយដ៏មានប្រសិទ្ធភាពសម្រាប់ខ្មែរក្រោមអនុវត្តនូវសិទ្ធិសេរីភាពជាមូលដ្ឋាននៅលើទឹកដីកម្ពុជាក្រោមរបស់ខ្លួន ។

ដើម្បីឲ្យខ្មែរក្រោមមាន «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» នោះ គេត្រូវធ្វើដំណើរនៅលើផ្លូវតស៊ូដ៏វែងឆ្ងាយមួយ ក្នុងការរំដោះខ្លួនចេញពីនឹមអាណានិគមទាំងពីរនោះគឺ អាណានិគមយួន និងអាណានិគមផ្នត់គំនិត ។ ការរំដោះខ្លួនចេញពីអាណានិគម

[69] ដូចលេខយោង [56], https://is.gd/ZEQbEk

ផ្ទត់គំនិតនោះ គឺត្រូវមានការសិក្សាអប់រំឲ្យបានទូលំទូលាយ ដើម្បីទទួលបានចំណេះដឹងក្នុងការត្រិះរិះពិចារណា ការពង្រឹងអំណាច និងបង្កើតជំនាញដែលពួកគេត្រូវការក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងវប្បធម៌ នៅដែនដីកម្ពុជាក្រោមឲ្យកាន់តែប្រសើរឡើង ។ មេដឹកនាំប្រឆាំងការប្រកាន់ពូជសាសន៍ដ៏ល្បី និងជាប្រធានាធិបតីដំបូងរបស់ អាហ្វ្រិកខាងត្បូង លោក នែលសិន ម៉ាន់ដេឡា (Nelson Mandela) បានថ្លែងថា៖ "***ការអប់រំគឺជាអាវុធដ៏មានឥទ្ធិពលបំផុត ដែលអ្នកអាចប្រើដើម្បីផ្លាស់ប្តូរពិភពលោក*** " ។ កាលណាពលរដ្ឋខ្មែរក្រោមគ្រប់រូបបានទទួលការសិក្សាអប់រំត្រឹមត្រូវហើយ ចំណេះវិជ្ជានឹងធ្វើឲ្យពួកគាត់បានរំដោះខ្លួនចេញពីទីងងឹត ហើយធ្វើដំណើរទៅកាន់ទីដែលមានពន្លឺ ។ ត្រង់ចំណុចនេះ ទស្សនវិទូជនជាតិអាមេរិក លោក អាឡែន ប្លូម (Allan Bloom) បានមានប្រសាសន៍ថា៖ "***ការអប់រំគឺជាចលនាពីទីងងឹតទៅកាន់ទីភ្លឺ***"។ នេះមានន័យថា នៅពេលដែលខ្មែរក្រោមគ្រប់រូបមានការសិក្សាអប់រំហើយ ពួកគាត់នឹងមានការយល់ដឹងថា តើសិទ្ធិរបស់ខ្លួនមានទំហំប៉ុណ្ណា ហើយរដ្ឋាភិបាលអាណានិគមយួនបានរំលោភបំពានលើសិទ្ធិរបស់ខ្លួនត្រង់ចំណុចណាខ្លះ ពួកគាត់នឹងមានសេចក្តីក្លាហានក្នុងការទាមទារ និងអនុវត្តនូវសិទ្ធិទាំងនេះ ដើម្បីបានទទួលនូវសេរីភាពពិតប្រាកដមួយនៅលើទឹកដីរបស់ខ្លួន ។ ម្យ៉ាងទៀត របបអាណានិគមយួននឹងមិនលើកយក «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ដាក់លើជើងពានមកប្រគល់ជូនខ្មែរក្រោមដោយងាយៗនោះទេ គឺខ្មែរក្រោមម្នាក់ៗជាម្ចាស់ស្រុកត្រូវចេះទាមទារ និងអនុវត្តនូវសិទ្ធិនេះដោយខ្លួនឯងទើបបានសម្រេច ។ មេដឹកនាំចលនាទាមទារសិទ្ធិប្រជាពលរដ្ឋប្រឆាំងនឹងការប្រកាន់ពូជសាសន៍នៅសហរដ្ឋអាមេរិក លោក ម៉ាធីន លូធើ ឃីង (Martin Luther King Jr.) បានថ្លែងថា៖ "***សេរីភាពមិនដែលត្រូវបានផ្តល់ដោយអ្នកជិះជាន់ឡើយ ។ វាត្រូវតែទាមទារដោយអ្នកដែលត្រូវគេជិះជាន់***" ។

# វគ្គទី ២

# កាលប្បវត្តិ

# នៃ

# ដែនដីកម្ពុជាក្រោម

# កម្ពុជាក្រោម

កម្ពុជាក្រោម ជាទឹកដីរបស់ជនជាតិដើមខ្មែរក្រោម និងជាទឹកដីរបស់ប្រទេសកម្ពុជាក្នុងសម័យចក្រភពខ្មែរ ត្រូវសន្តតិវង្ស ង្វៀង របស់យួនប្រើពេលអស់ ២០០ ឆ្នាំ ដើម្បីឈ្លានពាន និងដណ្តើមយកទៅកាន់កាប់ ។ បន្ទាប់មក នៅពាក់កណ្តាលសតវត្សរ៍ទី ១៩ បារាំងបានវាយដណ្តើមយកពីយួនមកធ្វើអាណានិគម ជាដែនដីឯនាយសមុទ្ររបស់ខ្លួនអស់រយៈពេល ៩០ ឆ្នាំ ។ ពេលចេញទៅ បារាំងបានផ្ទេរកម្ពុជាក្រោមឲ្យយួនបន្តធ្វើអាណានិគម នៅថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ១៩៤៩ ។ ពេលបារាំងអស់អំណាចកម្ពុជាក្រោម ត្រូវរបបយួនខាងត្បូងបន្តត្រួតត្រាអស់រយៈពេល ២៦ ឆ្នាំ ដែលប្រកបដោយភាពចម្រូងចម្រាសនៃការហែកហួរគ្នា ដោយសង្គ្រាមរវាងយួនខាងត្បូង និងយួនកុម្មុយនីស្តខាងជើង ។ ក្រោយមក ក្រុមយួនកុម្មុយនីស្តខាងជើងបានឈ្នះសង្គ្រាមលើរបបយួនខាងត្បូង នៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៧៥ ហើយដាក់បញ្ចូលទឹកដីកម្ពុជាក្រោមឲ្យចូលទៅក្នុងប្រទេសវៀតណាមតែមួយ ឈ្មោះថា សាធារណរដ្ឋសង្គមនិយមវៀតណាម ។ មកដល់ពេលនេះ គឺចាប់តាំងពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ២០២០ មានរយៈពេល ៤៥ ឆ្នាំហើយ ដែលរបបយួនកុម្មុយនីស្តបានធ្វើអាណានិគមលើទឹកដីកម្ពុជាក្រោម ។ ដូច្នេះ ចាប់តាំងពីដើមសតវត្សរ៍ទី ១៧ មកដល់ពេលនេះ ដែនដីកម្ពុជាក្រោម ត្រូវប្រឈមនឹងការវាតត្បាត វាតទី ឈ្លានពាន ត្រួតត្រា និងធ្វើអាណានិគមដោយជនជាតិយួន និងបារាំងអស់រយៈពេលប្រមាណ ៤០០ ឆ្នាំ ។

# ផែនទី
# ដែនដីកម្ពុជាក្រោម



# កម្ពុជាក្រោម
# នៅក្នុងរបបគ្រប់គ្រងនីមួយៗ

| ឆ្នាំ (គ. ស.) | **កម្ពុជាក្រោម** ជាផ្នែកមួយនៃទឹកដី | ចំនួនឆ្នាំ |
|---|---|---|
| ១ - ៥៥០ | នគរភ្នំ ឬ ភ្នូណាន ឬ ហ្វូណន | ៥៥០ ឆ្នាំ |
| ៥៥០ - ៦៨១ | អាណាចក្រចេនឡា | ១៣១ ឆ្នាំ |
| ៦៨១ - ៨០២ | ចេនឡាទឹក | ១២១ ឆ្នាំ |
| ៨០២ - ១៤៣១ | អាណាចក្រខ្មែរ | ៦២៩ ឆ្នាំ |
| ១៤៣១ - ១៦៩៨ | កម្ពុជា | ៦២៩ ឆ្នាំ |
| ១៦៩៨ - ១៨៣២ | យួនចូលវាតទីអំណាច | ១៣៤ ឆ្នាំ |
| ១៨៣២ - ១៨៥៩ | យួនបង្កើតជារដ្ឋបាល ៦ ខេត្ត | ២៧ ឆ្នាំ |
| ១៨៥៩ - ១៩៤៩ | កូស័ងស៊ីនបារាំងសែស | ៩០ ឆ្នាំ |
| ១៩៤៩ - ១៩៧៥ | សាធារណរដ្ឋវៀតណាម | ២៦ ឆ្នាំ |
| ១៩៧៥ - បច្ចុប្បន្ន | សាធារណរដ្ឋសង្គមនិយមវៀតណាម | ៤៥ ឆ្នាំ |

# អំពី
# កម្ពុជាក្រោម

កម្ពុជាក្រោម ជាទឹកដីរបស់ជនជាតិដើមខ្មែរក្រោម ដែលមានផ្ទៃដីលាតសន្ធឹងទូទាំងដែនដីសណ្តទន្លេមេគង្គ ឬភាគខាងត្បូងនៃប្រទេសវៀតណាម បច្ចុប្បន្ន [1] ។ សព្វថ្ងៃ ទឹកដីកម្ពុជាក្រោម កំពុងតែត្រូវជនជាតិយួនកាន់កាប់ និងធ្វើអាណានិគមដោយរបបកុម្មុយនីស្ត នៃរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម ។ កម្ពុជាក្រោមមានផ្ទៃដីទំហំ ៦៧.៧០០ គីឡូម៉ែត្រការ៉េ [2] ដោយមានព្រំប្រទល់ខាងលិចជាប់ឈូងសមុទ្រសៀម ខាងកើត និងអាគ្នេយ៍ជាប់សមុទ្រចិនខាងត្បូង ខាងជើង និងពាយព្យជាប់ប្រទេសកម្ពុជា និងឦសានជាប់ភាគកណ្តាលនៃប្រទេសវៀតណាម (អតីតនគរចម្ប៉ា) ។ ព្រៃនគរ ជាទីក្រុងរដ្ឋបាល និងសេដ្ឋកិច្ចដ៏សំខាន់នៅដែនដីកម្ពុជាក្រោម ដែលជនជាតិយួនហៅថា ទីក្រុងសាយហ្គន (Sài Gòn) និងក្រោយមក របបកុម្មុយនីស្តយួនសព្វថ្ងៃ បានប្តូរឈ្មោះទៅជាទីក្រុង ហូ ជី មិញ (Hồ Chí Minh) ។ កម្ពុជាក្រោមមាន ២១ ខេត្តក្រុង និងកោះធំៗ ចំនួន ២ គឺ កោះត្រល់ និង កោះត្រឡាច, ឆ្នាំ ២០១៩ មានប្រជាជនចម្រុះជាតិសាសន៍ (ខ្មែរក្រោម, ចិន, យួន និងជនជាតិផ្សេងៗ) ចំនួន ៣៥.១០២.៥៣៧ នាក់ ក្នុងនោះ ខ្មែរក្រោម មានតែ ១.៣១៩.៦៥២ នាក់ប៉ុណ្ណោះ [3]

[1] យោងតាមកំណើត វត្តសម្បួររង្សី (សម្បួរ) ជាវត្តមួយដែលខ្មែរក្រោមបានបង្កើតឡើងនៅ ភូមិតាខៅ ឃុំក្រសាំង ស្រុកកំពង់ស្ពានខេត្តព្រះត្រពាំង ក្នុង គ. ស. ៣៧៣ នៅក្នុងសម័យនគរភ្នំ (ចិនៈ 扶南 ភ្វូណាន ឬ ហ្វូណន, យួនៈ Phù Nam) (គ. ស. ៥២– គ. ស. ៦២៧ ) ។ យោងតាមប្រវត្តិសាស្ត្រយួនបានបញ្ជាក់ថា នៅពេលដែលយួនមានសង្គ្រាមបែងចែកទឹកដីរវាងចៅហ្វាយទាំងពីរក្រុមគឺ ត្រិញ និង ង្វៀង (Trịnh – Nguyễn) ចាប់ពីឆ្នាំ ១៦២៧ ដល់ ១៦៧២ នោះ ជនជាតិយួនជាច្រើនដែលគាំទ្រក្រុម ង្វៀង បានរត់ចោលទឹកដីដ៏ក្រៀមក្រោះភាគខាងជើងរបស់ខ្លួន មករស់នៅធ្វើស្រែចម្ការនៅកម្ពុជាក្រោមជាទឹកដីរបស់ខ្មែរ នៅតំបន់ព្រះសួគ៌ា, ត្រពាំងចង្វា និង ព្រៃនគរ និង នៅឆ្នាំ ១៦២៣ ង្វៀង ផុក ង្វៀង (Nguyễn Phúc Nguyên) ជាស្តេចត្រាញ់ ឬ ចៅហ្វាយរបស់យួន បានបង្កើតចំណងមេត្រីភាពតាមរយៈឪពុកក្មេក និងកូនប្រសារជាមួយ ព្រះបាទ ជ័យជេដ្ឋា ទី ២ ជាស្តេចរបស់ខ្មែរ បានខ្ចីដីព្រៃនគររបស់ខ្មែរ បង្កើតជាទីស្នាក់ការគយ ដើម្បីយកពន្ធពីជនជាតិយួនដែលមករស់នៅតាមតំបន់ព្រៃនគរ, ត្រពាំងចង្វា និង ព្រះសួគ៌ា (Sài Gòn, Đồng Nai, Bà Rịa) ។ ប្រៀបធៀបកាលប្បវត្តិទាំងពីរនេះឃើញថា ជនជាតិយួនបានចូលមកវាតទីទឹកដីកម្ពុជាក្រោម ក្រោយខ្មែរក្រោមកសាង វត្តសម្បួររង្សី ១២៥៤ ឆ្នាំ ។ ដូច្នេះ កម្ពុជាក្រោមជាទឹកដីរបស់ជនជាតិដើមខ្មែរក្រោម ។

[2] Khmers Kampuchea-Krom Federation, The Khmer-Krom Journey to Self-Determination, (USA: 2009), ទំព័រ ៦០

[3] Central Population and Housing Census Steering Committee, (2020), Results of the 2019 Census on Population and Housing in Viet Nam, Hanoi: Statistics Puplishing House, (Download: ២១ តុលា ២០២០), https://bit.ly/2TeWSIY ។ លទ្ធផលជំរឿន ឆ្នាំ ២០១៩ អំពីប្រជាជន និងលំនៅឋាននៅវៀតណាម ចេញផ្សាយឆ្នាំ ២០២០ ដោយ គណៈកម្មការរៀបចំជំរឿននៃរដ្ឋាភិ-បាលវៀតណាម ។ តួលេខ ១.៣១៩.៦៥២ នាក់ បានមកពីណា បើខ្មែរក្រោមមិនដែលបានឆ្លើយនឹងសំណួរនៅលើ “ទម្រង់ធ្វើជំរឿនប្រជាជននិងលំនៅឋាន” (PHIẾU ĐIỀU TRA DÂN SỐ VÀ NHÀ Ở) ដែលរដ្ឋាភិបាលយួនតម្រូវឲ្យប្រជាជនធ្វើនៅពេលធ្វើជំរឿន ផងនោះ? ។




ផែនទីចក្រភពខ្មែរនៅក្នុងឆ្នាំ ៩០០ (គ្រឹស្តសករាជ) ។

ប៉ុន្តែ សហព័ន្ធខ្មែរកម្ពុជាក្រោម (KKF) និង អង្គការប្រជាជាតិ និងប្រជាជនគ្មានតំណាង (UNPO) ថា ពលរដ្ឋខ្មែរក្រោមមានប្រមាណ ៧ លាននាក់ **[4]**, ឆ្នាំ ២០១៤ មានព្រះសង្ឃខ្មែរក្រោមចំនួន ៨.៧៥០ អង្គ **[5]** និង ឆ្នាំ ២០១៨ មានវត្តអារាមខ្មែរចំនួន ៤៦២ វត្ត **[6]** ។

កម្ពុជាក្រោម ជាអតីតទឹកដីមួយភាគរបស់ប្រទេសកម្ពុជាក្នុងសម័យចក្រភពខ្មែរ ដែលនៅក្នុងសម័យនោះ ខ្មែរជាមហានគរ មានផ្ទៃដីធំលាតសន្ធឹងគ្របដណ្តប់លើប្រទេសថៃ លាវ ភាគកណ្តាល និងភាគខាងត្បូង នៃប្រទេសវៀតណាម សព្វថ្ងៃ **[7]** ។ នៅពេលដែលអាណាចក្រខ្មែរបានធ្លាក់ចុះទន់ខ្សោយ នាសតវត្សរ៍ទី ១៧ វត្តមានជនភៀសខ្លួនជនជាតិយួនកាន់តែច្រើន បាននាំគ្នាមករស់នៅលើទឹកដីកម្ពុជាក្រោម ។ ឆ្នាំ ១៦៩៨ ស្តេចត្រាញ់ ឬ ចៅហ្វាយរបស់យួនខាងត្រកូល ង្វៀង (Chúa Nguyễn) បានបញ្ជូនមេទ័ពរបស់ខ្លួនឲ្យចុះមកកម្ពុជាក្រោម បង្កើតជាប្រព័ន្ធរដ្ឋបាលមូលដ្ឋានទៅជាភូមិស្រុករបស់យួននៅតំបន់ត្រពាំងចង្វា (Biên Hòa) ដើម្បីវាតទី និងកាន់កាប់ ។ គ្រានោះ នៅក្នុងឆ្នាំ ១៦៩៩ ព្រះបាទ ជ័យជេដ្ឋា ទី ៤ ឬ ចៅពញាសូរ (ប្រសូតៈ ១៦៥៦-ទិវង្គតៈ ១៧២៥) បានធ្វើការវាយតប ដើម្បីរារាំងនូវមហិច្ឆតាវាតត្បាតទឹកដីខ្មែរពីយួនដែរ តែមិនបានជោគជ័យ **[8]** ។ នៅឆ្នាំ ១៨៣២ ស្តេច មិញ ម៉ាង (Minh Mạng) (រជ្ជកាលៈ ១៨២០ - ១៨៤១) របស់យួន ដែលសោយរាជ្យនៅទីក្រុងហ្វេ (Huế) បានបែងចែកទឹកដីកម្ពុជាក្រោមចេញជា ៦ ខេត្ត ដើម្បីវាតទីកាន់កាប់ដោយបានដាក់ឈ្មោះជាភាសាយួនថា ណាមគីឡុកទិញ (Nam Kỳ Lục Tỉnh, 南圻六省) មានន័យថា

[4] UNPO, Member Profile: Khmer-Krom / Khmers Kampuchea-Krom Federation (KKF), (Begium: 2018), ទំព័រ ១, (Download: ៣ កក្កដា ២០២០), www.unpo.org/downloads/2372.pdf

[5] ព្រះតេជព្រះគុណ ថាច់ សុខ សាន្ត ជាព្រះចៅអធិការវត្តអង្គរាជបុរី (អង្គ) និងជាមន្ត្រីសង្ឃនៅក្នុងសមាគមពុទ្ធសាសនាវៀតណាម ថ្លែងនៅថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០១៤ ហើយបានចុះផ្សាយដោយ កាសែត ព្រៃនគរ លេខ ៤៥ បោះពុម្ព ថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ២០១៤ ។

[6] ភិក្ខុ សឺង យ៉ឹង រតនា (សុវណ្ណបញ្ញោ) និង ភិក្ខុ ថាច់ ប្រីជា គឿន (សុធម្មប្បញ្ញោ), វត្តនៅកម្ពុជាក្រោម ភាគ ១ (នាយកដ្ឋានព័ត៌មាន នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម, ព. ស. ២៥៦២ - គ. ស. ២០១៨), ទំព័រ ១៣៤ ។

[7] Human Rights Wach, On the Margins Rights Abuses of Ethnic Khmer in Vietnam's Mekong Delta (2009), ទំព័រ ១៤

[8] Nam Tiến (ដំណើរចុះមកទិសខាងត្បូងរបស់ជនជាតិយួន), (០៨ ឧសភា ២០២០), Wikipedia, https://bit.ly/39rMI8G




ខេត្តរដ្ឋបាលទាំង ៦ ដែល ស្តេចយួន មិញ ម៉ាង បានបង្កើត
ដើម្បីវាតទី និងកាន់កាប់ទឹកដីកម្ពុជាក្រោម កាលពីឆ្នាំ ១៨៣២ ។

ប្រាំមួយខេត្តភាគខាងត្បូង ឬ ណាមគី (Nam Kỳ) មានន័យថា ភាគខាងត្បូង **[9]** ។

នៅក្នុងឆ្នាំ ១៨៤១ ខ្មែរក្រោមនៅគ្រប់ទិសទីបានក្រោកឡើងតស៊ូដេញយួនឈ្លានពានទឹកដី និងប្រឆាំងនឹងច្បាប់រំលាយពូជសាសន៍ “ញឹកទីដុងញើង” (Nhứt Thị Đồng Nhơn) មានន័យថា “មនុស្សដូចគ្នាត្រូវមានជាតិតែមួយ” ដែលស្ដេចយួន មិញ ម៉ាង និង ទេវ ទ្រី បានចេញបញ្ជាឲ្យរាស្ត្រខ្មែរនៅកម្ពុជាក្រោម ត្រូវតែអនុវត្តតាមប្រពៃណីរបស់យួន ដូចជាបង្ខំឲ្យខ្មែរមានត្រកូលដូចយួន និងព្រះសង្ឃខ្មែរដែលគ្រងស្បង់ចីវរត្រូវតែស្លៀកខោពាក់អាវព៌ណ៌ឈាមជ្រូក សូត្រធម៌គោះត្រដោក ដូចព្រះសង្ឃយួន ជាដើម ។ ក្នុងសម័យនោះ ពលរដ្ឋខ្មែរក្រោមដែលងើបឡើងតស៊ូដេញយួនឈ្លានពានមានដូចជា នៅខេត្តព្រះត្រពាំង ដឹកនាំដោយ ចៅហ្វាយ គុយ និង ទេសា សោម ឬ ឡឹម សោម (Lâm Sâm) ជាដើម **[10][11]** ។ ចំណែក នៅខេត្តឃ្លាំង ដឹកនាំដោយ សេនាទា សេនា មាន់ និង សេនា សួស **[12]** ។ ម្យ៉ាងទៀត តាមឯកសារយួនបានបញ្ជាក់ថាមានចលនាតស៊ូរបស់មន្ត្រីខ្មែរម្ចាស់ស្រុកនៅស្រុកឃ្លាំង (Ba Xuyên) ២ រូប គឺ សឹងតោក (Sơn Tốt) (? - ១៨៤១) និង ត្រឹង ឡឹម (Trần Lâm) (? - ១៨៤២) ក៏បានដឹកនាំខ្មែរក្រោមងើបឡើងដេញយួនឈ្លានពានទឹកដី ផងដែរ **[13]** ។ នៅក្នុងព្រឹត្តិការណ៍នេះ ខ្មែរក្រោមគ្រប់ខេត្តនៅទឹកដីកម្ពុជាក្រោម និងរាស្ត្រខ្មែរនៅក្នុងប្រទេសកម្ពុជា បានស្រុះគ្នាងើបឡើងយ៉ាងអង់អាចដេញយួនឈ្លានពានទឹកដី ។ យោងតាមឯកសារយួនបានបញ្ជាក់ថា ស្ដេចយួនបានបញ្ជាឲ្យទ័ពយួនចុះមកបង្ក្រាបការបះបោររបស់ខ្មែរ តែបង្ក្រាបបានកន្លែងនេះ ងើបនៅកន្លែងនោះ មិនចេះចប់ **[14]** ។ ទ្រៀង មិញ យ៉ាង

[9] អត្ថបទភាសាអង់គ្លេសនិយាយអំពី ស្ដេចយួន មិញ ម៉ាង បែងចែកទឹកដីកម្ពុជាក្រោម ចេញជា ៦ ខេត្ត, Six Provinces of Southern Vietnam, (០៧ ឧសភា ២០២០), Wikipedia, https://bit.ly/3jCZExb

[10] កែវ សុវត្ថិ, ចៅ ហ្វាយ គុយ, (ភ្នំពេញ៖ ១៩៧១)

[11] Cuộc nổi dậy của Lâm Sâm, (ការបះបោររបស់ ឡឹម សោម ឬ ទេសា សោម), (២៤ មីនា ២០២០), Wikipedia, https://bit.ly/2OTKVQD

[12] ទៀ ថេន, រឿងរ៉ាវ នៃ ទឹកដីកម្ពុជាក្រោម, (ភ្នំពេញ៖ ២០០៥ ), ទំព័រ ១៦០ - ១៦៤ ។

[13] Cuộc nổi dậy ở Ba Xuyên, 1841, (ការបះបោររបស់ខ្មែរក្រោមនៅខេត្តឃ្លាំង, ១៨៤១), (១០ សីហា ២០១៦), Wikipedia, https://bit.ly/2WRbhqv

[14] Trần Trọng Kim, Việt Nam Sử Lược (Ha Noi: 1919), ជំពូក ៤ រជ្ជកាល ទេវ ទ្រី (Thieu Tri)

(Trương Minh Giảng) ជាមេទ័ពយួនដែលចូលឈ្លានពានប្រទេសកម្ពុជាពីឆ្នាំ ១៨៣៥ ដល់ ឆ្នាំ ១៨៤១ ហើយលើកបន្តុប ក្សត្រី អង្គម៉ី (រជ្ជកាលៈ ១៨៣៥ - ១៨៤០) ឡើងគ្រងរាជ្យនៅប្រទេសកម្ពុជានោះ បានដកទ័ពថយទៅខេត្តមាត់ជ្រូក ហើយបាននាំទាំងក្សត្រី អង្គមី ព្រះមហាឧបរាជ ព្រះរាជវង្សានុវង្ស និងគ្រួសារទាំងអស់ ទៅប្រថាប់ នៅទីនោះ **[15]** ។ ដោយសារចាញ់សង្គ្រាម ទ្រឿង មិញ យ៉ាង ត្រូវស្តេចយួនចាប់ខ្លួន និងបានធ្វើអត្តឃាតស្លាប់នៅក្នុងគុក នៅឆ្នាំ ១៨៤១ **[16]** ។ ទោះបីយួនបានដកទ័ពថយចេញពីកម្ពុជា តែសង្គ្រាមសៀមយួន ចាប់ពីឆ្នាំ ១៨៤១ ដល់ ១៨៤៥ នៅតែបន្តឆាបឆេះនៅលើទឹកដីកម្ពុជាដដែល ។ បន្ទាប់ពីមានការចរចាសន្ធិសញ្ញាសន្តិភាពរវាងសៀម និងយួន នៅឆ្នាំ ១៨៤៥ ព្រះបាទ អង្គដួង (រជ្ជកាលៈ ១៨៤០-១៨៦០) ដែលបានយាងត្រឡប់មកពីសៀមនោះ បានឯកភាពយល់ព្រមពីរដ្ឋាភិបាលទាំងពីរគឺ សៀម និងយួន ឲ្យទ្រង់ឡើងសោយរាជ្យជាព្រះរាជាខ្មែរ នៅឆ្នាំ ១៨៤៧ ហើយយួនក៏បានដោះលែងព្រះរាជវង្សានុវង្ស និងមន្ត្រីខ្មែរឲ្យវិលត្រឡប់មកព្រះរាជនគរវិញ តាមរយៈកិច្ចព្រមព្រៀងឲ្យដោះលែងឈ្លើយសឹកទាំងសងខាង **[17]** ។ នៅក្នុងពេលជាមួយគ្នានោះដែរ យួនក៏បានដកទ័ពចេញពីប្រទេសកម្ពុជា ។ ទីបំផុត យួនបានបាត់បង់នូវអំណាចត្រួតត្រារបស់ខ្លួនមកលើប្រទេសកម្ពុជា ។ កម្ពុជាបានទទួលឯករាជ្យពីយួន ទោះបីមានទ័ពរបស់សៀមខ្លះកំពុងនៅប្រទេសកម្ពុជា យ៉ាងណាក៏ដោយ ។ ស្តេចខ្មែរមានភាពម្ចាស់ការ

---

[15] អេង សុត, ឯកសារ មហាបុរសខ្មែរ ភាគ ៧, “ផែនដីព្រះអង្គម៉ីក្សត្រី” ។

[16] Cambodian Rebellion, (1840) (ការបះបោររបស់រាស្ត្រខ្មែរ, ១៨៤០), (០៥ ឧសភា ២០២០), Wikipedia, https://bit.ly/39q4IR7 ។ ត្រឹង ទ្រង់ គឹម, ប្រវត្តិសាស្ត្រវៀតណាម (Việt Nam Sử Lược ) បោះពុម្ពឆ្នាំ ១៩២០ បញ្ជាក់ថា ដោយសារអាម៉ាស់ និងឈឺចាប់ខ្លាំងពេកបណ្តាលឲ្យ ទ្រឿង មិញ យ៉ាង ធ្លាក់ខ្លួនឈឺរហូតដល់ស្លាប់ នៅខេត្តមាត់ជ្រូក ។ អាដេម៉ារ ឡឺក្លែរ, ប្រវត្តិសាស្ត្រប្រទេសកម្ពុជា បោះពុម្ពឆ្នាំ ១៩១៤ បកប្រែជាភាសាខ្មែរ ឆ្នាំ ២០០៥ ត្រង់ទំព័រ ៣៧៦ ថា “ទ័ពសៀមវាយរុញច្រានទ័ពអណ្ណាម ដែលដកថយទៅជាក្រុមតូចៗ ដោយដេញតាមរហូតទៅជិតដល់ចូវដុក [មាត់ជ្រូក] ។ នៅទីនោះ មេទ័ពអណ្ណាមជាច្រើន ក្នុងនោះ រួមមានទាំងមេទ័ពប្រចាំខែត្រពោធិ៍សាត់ ទាំង ៣ នាក់ផង បាននាំគ្នាលេបថ្នាំសម្លាប់ខ្លួន ដើម្បីចៀសវាងការទទួលទណ្ឌកម្មពីព្រះចៅអធិរាជ” ។ Wikipedia ជាភាសាអង់គ្លេស (៩ មិថុនា ២០២០) បានបញ្ជាក់ដោយយោងតាម អាដេម៉ារ ឡឺក្លែរ ថា “ទ្រឿង មិញ យ៉ាង បានស្លាប់យ៉ាងទាន់ហន់ នៅតាមផ្លូវត្រឡប់ទៅទីក្រុងហ្វេ (Huế) ដោយគាត់បានលេបថ្នាំពុលជាមួយនឹងមេទ័ពកំពូល ២ រូបផ្សេងទៀត ដើម្បីចៀសវាងការទទួលទណ្ឌកម្មពីព្រះចៅអធិរាជ” ។ https://bit.ly/3g0PqET

[17] ប្រវត្តិសាស្ត្រប្រទេសកម្ពុជា, ទេព ម៉េង ឃាន ប្រែសម្រួល, ឆ្នាំ ២០០៥, ទំព័រ ៣៧៩-៣៨០ ។ ច្បាប់ដើមៈ (អាដេម៉ារ ឡឺក្លែរ), Adhémard Leclère, Histoire Du Cambodge, Paris: 1914 ។

ជាងមុន [18] ។ ចំណែក ទឹកដីកម្ពុជាក្រោម វិញ នៅតែបន្តឋិតនៅក្រោមអំណាចត្រួតត្រា និងឈ្លានពានរបស់យួនដដែល រហូតដល់សម័យដែលបារាំងបានចូលមកធ្វើសង្គ្រាមដណ្តើមអំណាចពីយួន ។

**សម័យអាណានិគមបារាំង ឬ កូស័ងស៊ីនបារាំងសែស (១៨៥៩ - ១៩៤៩)៖**

បន្ទាប់ពីរងការវាតត្បាត ឈ្លានពាន វាតទី និងពង្រីកអំណាចត្រួតត្រាពីសំណាក់ជនជាតិយួន អស់រយៈពេលជាង ២០០ ឆ្នាំ មក [19] នៅពាក់កណ្តាលសតវត្សរ៍ទី ១៩ កម្ពុជាក្រោម បានស្គាល់រសជាតិរបបត្រួតត្រាថ្មីមួយទៀត នោះគឺរបបអាណានិគមបារាំង ។ បារាំងបានធ្វើអាណានិគមលើទឹកដីកម្ពុជាក្រោមជិតមួយសតវត្សរ៍ គឺចាប់ពីឆ្នាំ ១៨៥៩ ដល់ឆ្នាំ ១៩៤៩ (រយៈពេល ៩០ ឆ្នាំ) ដោយបានហៅឈ្មោះជាភាសាបារាំងថា "កូស័ងស៊ីនបារាំងសែស" (Cochinchine Française ឬ French Cochin China) ដែលគេនិយមហៅថា កូស័ងស៊ីន (Cochinchine) ។ ពេលបញ្ចប់អាណានិគមកិច្ចរបស់ខ្លួន បារាំងបានផ្ទេរទឹកដីកម្ពុជាក្រោមទៅឲ្យយួនគ្រប់គ្រងបន្ត ដោយគ្មានការដឹងឮពីខ្មែរក្រោមជាម្ចាស់ទឹកម្ចាស់ដីឡើយ ។

បារាំងបានចូលមកវាយដណ្តើមយកទឹកដីកម្ពុជាក្រោមពីយួន នៅពេលដែលទឹកដីនេះ កំពុងតែឋិតនៅក្រោមការគ្រប់គ្រងរបស់ស្តេចយួន ទឺ ឌឹក (Tự Đức) (រជ្ជកាល៖ ១៨៤៧ - ១៨៨៣) សោយរាជ្យនៅរាជធានីហ្វេ (Huế) ភាគកណ្តាលនៃប្រទេសវៀតណាម បច្ចុប្បន្ន ។

[18] Cambodian Rebellion, 1840 (ការបះបោររបស់ប្រជារាស្ត្រខ្មែរ, ១៨៤០), (០៥ ឧសភា ២០២០), Wikipedia, https://bit.ly/39u4wA0

[19] គិតចាប់តាំងឆ្នាំ ១៦២៣ ពេលដែល ស្តេចត្រាញ់យួន ខាងត្រកូល ង្វៀង (Chúa Nguyễn) បានមកខ្ចីដីខ្មែរនៅតំបន់ព្រៃនគរ បង្កើតជាទីស្នាក់ការគយ ដើម្បីយកពន្ធពីជនជាតិយួន ដែលទើបតែមករស់នៅថ្មីៗនៅលើទឹកដីកម្ពុជាក្រោម ដល់ឆ្នាំ ១៨៦២ ពេលដែលបារាំងចូលមកដណ្តើមអំណាចពីយួន ត្រូវជា ២៣៩ ឆ្នាំ ។ ឯកសារយួនថា នៅក្នុងសម័យនោះ ជនជាតិយួនជាច្រើនដែលនៅក្រោមការគ្រប់គ្រងដោយក្រុមសន្តតិវង្ស ង្វៀង បានបោះបង់ទឹកដីភាគកណ្តាលដ៏ក្រៀមក្រោះ ហើយភៀសខ្លួនមកកម្ពុជាក្រោម ទន្ទ្រានដីធ្វើស្រែនៅតំបន់ ព្រះសួគ៌ា (Bà Rịa) ត្រពាំងចង្វា (Đồng Nai) និង ព្រៃនគរ (Sài Gòn) ។ តាម អាដេម៉ារ ឡឺក្លែរ ថា ជនជាតិយួនបានទន្ទ្រានដីស្រែរបស់ខ្មែរក្រោមដោយរបៀប "ដើរចាក់រុករករឿងឈ្លោះ យប់ឡើងចេញដើរលួចឆក់ បង្កការលំបាកមិនឲ្យខ្មែររស់នៅបានសុខស្រួលឡើយ ។ គ្មានយុត្តិធម៌ចំពោះម្ចាស់ដីទេ..." គឺ បើយួនណាម្នាក់មកសាបព្រោះចុងក្រោយលើដីរបស់ខ្មែរ ចៅក្រមយួនសម្រេចថាជាដីរបស់យួន ឬដីដែលខ្មែរទុកទំនេរ បើមានយួនម្នាក់មកកាន់កាប់ ចៅក្រមយួនសម្រេចថា ម្ចាស់ដីបានបោះបង់ចោល ។

ដោយលើកហេតុផលដែលរាជការយួនដាយណាម (Đại Nam) **[20]** បានសម្លាប់ពួកសាសនទូតកាតូលិក ស្ដេច ណាប៉ូឡេអុង ទី ៣ (Napoleon III) របស់បារាំង បានចេញបញ្ជាឲ្យ ឧត្ដមនាវី Charles Rigault de Genouilly ដឹកនាំបេសកកម្មដាក់ទណ្ឌកម្មប្រឆាំងនឹងដាយណាម ។ នៅខែកញ្ញា ឆ្នាំ ១៨៥៨ កងទ័ពជើងទឹករបស់បារាំង និងអេស្ប៉ាញបានចុះមកចតនៅកំពង់ផែទួរ៉ាន (Tourane ឬ Đà Nẵng) ហើយបានវាយដណ្ដើមយកទីក្រុងនេះ **[21]** ។ ក្រោយមក លោកឧត្ដមនាវីបារាំងបានដឹកនាំកងទ័ពជើងទឹករបស់ខ្លួនចុះមកកម្ពុជាក្រោម ហើយវាយដណ្ដើមយកទីក្រុងព្រៃនគរ (Sai Gon) ពីរាជការយួនដាយណាម នៅថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ១៨៥៩ ។ ដោយមានបំណងចង់ប្រមូលផ្ដុំកម្លាំងដណ្ដើមយកទឹកដីកម្ពុជាក្រោមជាង លោកឧត្ដមនាវីបារាំងបានសម្រេចចិត្តបោះបង់ទួរ៉ាន (Đà Nẵng) ចោលវិញ នៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ ១៨៥៩ **[22]** ។

មូលហេតុដែលនាំឲ្យឧត្ដមនាវីបារាំងបោះបង់ចោលទីក្រុងដាណាំង ហើយសម្រេចចិត្តវាយដណ្ដើមយកទីក្រុងព្រៃនគរវិញនោះ ដោយសារព្រៃនគរ ជាទីតាំងយុទ្ធសាស្ត្រល្អសម្រាប់ធ្វើសង្គ្រាម ។ យោងតាមលិខិតចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ ១៨៥៩ របស់ឧត្ដមនាវីបារាំង Charles Rigault de Genouilly ផ្ញើទៅរដ្ឋមន្ត្រីកងទ័ពជើងទឹកបារាំងនៅទីក្រុងប៉ារីស បានបញ្ជាក់ថា៖ *"ព្រៃនគរ ឋិតនៅចំទន្លេមួយដែលនាវាចម្បាំងរបស់យើងងាយចូលចត និងពេលណាទ័ពយើងឡើងលើគោកនឹងវាយចូលទីក្រុងតែម្ដង...។ ព្រៃនគរ ក៏ជាជង្រុកស្រូវដ៏ធំមួយ ដែលប្រជាជន និងទាហាន [យួន] នៅរាជធានីហ្វេ (Huế) រស់បានក៏អាស្រ័យលើអង្ករនៅព្រៃនគរនេះដែរ ។ មកដល់ខែមីនា សំពៅដឹកជញ្ជូនស្រូវអង្ករ នឹងចេញដំណើរពីព្រៃនគរទៅហ្វេ ។ យើងសម្រេចថានឹងស្កាត់ស្រូវអង្ករនោះមក"*[23] ។

ពេលដណ្ដើមបានទីក្រុងព្រៃនគរ ឧត្ដមនាវីបារាំងបានប្រគល់បញ្ជាការទៅឲ្យនាយ

[20] ដាយណាម (Đại Nam) ជាឈ្មោះប្រទេសវៀតណាមដែលក្រុមរាជវង្ស ង្វៀង ប្រើចាប់ពីឆ្នាំ ១៨៣៩ ដល់ ១៩៤៥ ។

[21] Cochinchina Campaign (ការប្រយុទ្ធនៅដែនដីកម្ពុជាក្រោម), (១៣ កក្កដា ២០២០), Wikipedia, https://bit.ly/2CK7qoo

[22] អាដេម៉ារ ឡឺក្លែរ, ប្រវត្តិសាស្ត្រប្រទេសកម្ពុជា, ទេព ម៉េង ឃាន ប្រែសម្រួល (២០០៥), ទំព័រ ៤២៦

[23] Trận thành Gia Định, 1859 (ឆាកប្រយុទ្ធនៅព្រៃនគរ, ១៨៥៩), (១៩ កក្កដា ២០២០), Wikipedia, https://bit.ly/3jGLBXq

កប៉ាល់ម្នាក់នៅប្រចាំការ ឯខ្លួនគាត់ បានដឹកនាំកម្លាំងមួយផ្នែកធំត្រឡប់ទៅបង្ក្រាបនៅស្រុកចិនវិញ ដោយសារចិនមិនបានគោរពតាមសន្ធិសញ្ញាដែលបានចុះជាមួយគ្នាកាលពីឆ្នាំ ១៨៥៨ ។ ឆ្លៀតឱកាសដែលទ័ពបារាំងនៅសល់តិចនោះ ពួកយួនក៏បានសាកល្បងវាយដណ្តើមយកទីក្រុងព្រៃនគរមកវិញដែរ តែមិនបានជោគជ័យ ។

ក្រោយពីបង្ក្រាបពួកចិនរួចហើយ នៅថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ១៨៦១ ទ័ពបារាំងបានត្រឡប់មកទីក្រុងព្រៃនគរជាថ្មី ហើយក៏ចាប់ផ្តើមវាយដណ្តើមយកទឹកដីកម្ពុជាក្រោមពីយួន ដែលបានផ្អាកអស់មួយរយៈជាបន្តឡើងវិញទៀត ។

នៅថ្ងៃទី ១២ ខែមេសា ឆ្នាំ ១៨៦១ លោកឧត្តមនាវីត្រី ប៉ាឆ៍ បានដណ្តើមយកខេត្តមេស (Định Tường ឬ Mỹ Tho) ។ នៅថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ១៨៦១ លោកឧត្តមនាវីត្រី បូណា បានដណ្តើមយកខេត្តត្រពាំងចង្វា (Biên Hòa) និងបន្ទាប់មក នៅថ្ងៃទី ២៨ ខែមីនា ឆ្នាំ ១៨៦២ បានដណ្តើមយកខេត្តលង់ហោរ (Vĩnh Long) ។ នៅថ្ងៃទី ៥ ខែមិថុនា ឆ្នាំ ១៨៦២ ស្តេច ទី ឌឹក របស់យួនដាយណាមបានយល់ព្រមចុះសន្ធិសញ្ញាជាមួយបារាំង ហើយបានប្រគល់ខេត្ត ៣ គឺ ព្រៃនគរ មេស និង ត្រពាំងចង្វា នៃទឹកដីកម្ពុជាក្រោម ទៅឲ្យបារាំងជារៀងរហូត ។

ខេត្តទាំង ៣ ដែលបារាំងទើបតែដណ្តើមបានពីយួននោះ មិនបានសុខទេ គឺយួនបានបង្កឲ្យមានការលុកលុយធ្វើបាបទៅលើអ្នក ដែលស្ថិតនៅក្រោមកិច្ចការពាររបស់បារាំង និងបានធ្វើឲ្យមានការរំជើបរំជួលប្រកបទៅដោយគ្រោះថ្នាក់ឥតដាច់ ។ នៅពេលដែលបារាំងរិះរកវិធីសម្របសម្រួលអស់ចិត្តហើយ ហើយពិនិត្យឃើញថា ពួកមន្ត្រីយួននៅតែសន្សំចិត្តស្នេហាជាតិចង់បានខេត្តដែលស្តេចយួនដាយណាម បានចុះសន្ធិសញ្ញា ឆ្នាំ ១៨៦២ ប្រគល់ឲ្យបារាំងយកមកវិញនោះ បារាំងលែងទុកចិត្តលើសម្តីរបស់យួនតទៅទៀត ក៏បានរៀបចំទ័ពមួយកងធំវាយដណ្តើមយកខេត្តចំនួន ៣ ព្រមទាំងទីក្រុងផង ដែលយួនកំពុងតែកាន់កាប់លើទឹកដីកម្ពុជាក្រោម ក្នុងពេលតែ ៥ ថ្ងៃប៉ុណ្ណោះ គឺ ដណ្តើមបានខេត្តលង់ហោរ (Vĩnh Long) នៅថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ១៨៦៧, ខេត្តមាត់ជ្រូក (An Giang ឬ Châu Đốc) នៅថ្ងៃទី ២២ និងខេត្តពាម (Hà

Tiên) នៅថ្ងៃទី ២៤ ។ ទីក្រុងទាំង ៣ នេះហើយ និងក្រុងមួយចំនួនទៀត ដែលបារាំងដណ្ដើមបាននាពេលនោះ សុទ្ធតែបានត្រូវគេសង់ឡើងវិញតាមប្លង់ដែលនាយទាហានបារាំងបានរៀបចំ ជាពិសេស គឺលោក វិកទ័រអូលីវីយេដឺពុយម៉ាណែល ដែលបម្រើស្ដេច យ៉ាឡុង (Gia Long) ពីឆ្នាំ ១៧៨៩ រហូតដល់ឆ្នាំ ១៨២០ ។

មកដល់សម័យនេះឃើញថា ទឹកដីកម្ពុជាក្រោម ដែលពួកសន្តតិវង្ស ង្វៀង (Nhà Nguyễn) របស់យួនបានប្រើពេលអស់ ២ សតវត្សរ៍ ដើម្បីដណ្ដើមយកពីប្រទេសកម្ពុជា មិនមែនដណ្ដើមបានត្រឹមតែប្រើកម្លាំងទ័ពវាយនោះទេ តែជាពិសេសគឺដោយបញ្ជូនប្រជាជនទាំងគ្រួសារៗឱ្យចូលនៅតែម្ដង ឥឡូវនេះបានធ្លាក់ទៅជារបស់បារាំងអស់ហើយ ។

នៅថ្ងៃទី ១៥ ខែមីនា ឆ្នាំ ១៨៧៤ ស្ដេច ទឺ ឌឹក របស់យួនបានយល់ព្រមចុះសន្ធិសញ្ញាសន្តិភាពមួយទៀត ទទួលស្គាល់អធិបតេយ្យភាពពេញលេញរបស់បារាំងមកលើកម្ពុជាក្រោម ដែលបារាំងហៅថា កូស័ងស៊ីន ជាទឹកដីមួយកន្លែងដែលមានកម្ពុជានៅពីខាងលិច ឈូងសមុទ្រសៀមនៅពីខាងត្បូង សមុទ្រចិននៅពីខាងកើត និងខេត្តបិនទ្វឹង (Bình Thuận) នៅពីខាងជើង [24] ។

បន្ទាប់ពីដណ្ដើមបានទឹកដីកម្ពុជាក្រោមពីយួនទាំងស្រុងហើយ បារាំងបានលុបនូវប្រព័ន្ធរដ្ឋបាលដែលរាជវង្ស ង្វៀង របស់យួនបានបង្កើតជា ៦ ខេត្ត កាលពីឆ្នាំ ១៨៣២ ចោល ហើយបង្កើតជាប្រព័ន្ធរដ្ឋបាលដឹកនាំតាមរបៀបបារាំងវិញ [25] ។

### ការសាងសង់វិមាននរោត្តមៈ

ម្យ៉ាងទៀត ដើម្បីពង្រឹងអំណាចអាណានិគមរបស់ខ្លួនឱ្យបានរឹងមាំ និងយូរអង្វែងនៅកម្ពុជាក្រោម និងនៅឥណ្ឌូចិន បារាំងបានកសាងនូវវិមានរដ្ឋបាលដ៏ធំមួយនៅទីក្រុងព្រៃនគរ ហើយបានដាក់ឈ្មោះថា វិមាននរោត្តម ។ នៅថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ១៨៦៩ លោក Pierre-Paul de La Grandière ជាទេសាភិបាលដែនកូស័ងស៊ីន បានប្រារព្ធពិធី

[24] អាដេម៉ារ ឡឺក្លែរ, ប្រវត្តិសាស្ត្រប្រទេសកម្ពុជា, ទេព ម៉េង ឃាន ប្រែសម្រួល (២០០៥), ទំព័រ ៤២៦ - ៤២៧

[25] Six Provinces of Southern Vietnam (ខេត្តទាំង ៦ នៅភាគខាងត្បូងវៀតណាម), (៧ ឧសភា ២០២០), Wikipedia, https://bit.ly/30PeNTy

សម្ពោធបញ្ចុះបឋមសិលាជាលើកដំបូង ដើម្បីចាប់ផ្តើមដំណើរការកសាងវិមានថ្មីនេះ នៅទីក្រុងព្រៃនគរ សម្រាប់ទេសាភិបាលដែនកូស័ងស៊ីនស្នាក់នៅ និងធ្វើការជំនួសឲ្យអគារចាស់ធ្វើពីឈើដែលបានសាងកាលពីឆ្នាំ ១៨៦៣ ។ វិមានថ្មីនេះ បានរចនាប្លង់ដោយវិស្វករបារាំង Achille-Antoine Hermitte ។ ផ្ទាំងបឋមសិលាជាប្រវត្តិសាស្ត្រនេះ គេបានយកមកពីខេត្តត្រពាំងចង្វា (Biên Hoà) មានទំហំ ៥0 Cm បួនជ្រុងស្មើ និងមានប្រហោងពីខាងក្នុងសម្រាប់ដាក់ប្រាក់កាសនាសម័យនោះ ដែលបានផលិតពីមាសប្រាក់ និងស្ពាន់ និងមានឆ្លាក់រូបស្តេចបារាំង ណាប៉ូឡេអុង ទី ៣ ។

ពេលបានកសាងសម្រេចជាស្ថាពរ បារាំងដាក់ឈ្មោះអគារនេះថា "វិមាននរោត្តម" និងផ្លូវនៅពីមុខវិមាននេះ ក៏បានដាក់ឈ្មោះថា "រុក្ខវិថីនរោត្តម" ផងដែរ ដើម្បីឧទ្ទិសដល់ ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម (រជ្ជកាលៈ ១៨៦០ - ១៩០៤) ជាព្រះចៅក្រុងកម្ពុជាធិបតី នាពេលនោះ [26] ។

### ចូលជាសហភាពឥណ្ឌូចិនៈ

ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង បារាំងបានបង្កើតជាសហភាពឥណ្ឌូចិន ហើយបានដាក់ទឹកដីកម្ពុជាក្រោម ឲ្យចូលទៅក្នុងសហភាពនេះនៅឆ្នាំ ១៨៨៧ ។

សហភាពឥណ្ឌូចិន ដែលបារាំងបានបង្កើតនោះ មាន ៥ រដ្ឋផ្សេងគ្នា គឺ កម្ពុជា លាវ តុងកឹង (វៀតណាមខាងជើង) អណ្ណាម (វៀតណាមកណ្តាល) និងដែនដីកូស័ងស៊ីន ឬកម្ពុជាក្រោម ដែលស្ថិតនៅភាគខាងត្បូងវៀតណាមបច្ចុប្បន្ន ។ កម្ពុជា លាវ តុងកឹង និង អណ្ណាម ថ្វីដ្បិតតែត្រូវស្ថិតក្រោមអំណាចអាណានិគមបារាំង ក៏ប៉ុន្តែ នៅមានទម្រង់ជាប្រទេស និងមានអំណាចនយោបាយដាច់ពីបារាំង ។ ចំណែក កម្ពុជាក្រោម ត្រូវបារាំងកាត់យកធ្វើជាអាណាខេត្តរបស់ខ្លួនទាំងស្រុង ដោយមានលក្ខន្តិកៈជាដែនដីបារាំងនៅនាយសមុទ្រ (Territoire d'Outre-mer) [27] ។

ទាក់ទងនឹងការបង្កើតសហភាពឥណ្ឌូចិននេះដែរ បារាំងបានចេញក្រឹត្យមួយចុះថ្ងៃ

[26] វិមានឯករាជ្យ, Dinh Độc Lập, (១៦ សីហា ២០២០), Wikipedia, https://bit.ly/2D8z12l

[27] សេង ឌីណា, (២៥ មករា ២០១៥), 'ការភ្ជាប់ទឹកដីកម្ពុជាក្រោម (កូស័ងស៊ីន) ទៅក្នុងប្រទេសវៀតណាមឆ្នាំ ១៩៤៩', វិទ្យុបារាំងអន្តរជាតិ (RFI), (ស្រង់ប្រភពៈ ២០ មីនា ២០២០), https://bit.ly/3jSoARo




ផែនទីឥណ្ឌូចិន ដែលមានរដ្ឋចំនួន ៥ គឺ កូស័ងស៊ីន ឬ កម្ពុជាក្រោម, កម្ពុជា, ឡាវ, អណ្ណាម និងតុងកឹង ដែលនៅក្រោមអាណានិគមបារាំង ។

ទី ១៧ ខែតុលា ឆ្នាំ ១៨៨៧ ឲ្យបង្កើត "អគ្គទេសាភិបាលឥណ្ឌូចិន" ដែលមានទីស្នាក់ការនៅតុងកឹង (Tonkin) ហើយលោកអគ្គទេសាភិបាលមានមុខនាទីមើលត្រួតត្រាលើរដ្ឋទាំង ៥ នៅឥណ្ឌូចិន ដែលពីមុនមុខងារនេះត្រូវបានបំពេញដោយលោកទេសាភិបាលកូស័ងស៊ីន [28] ។

## ការបែងចែកខេត្តខណ្ឌនៅកម្ពុជាក្រោមក្នុងសម័យបារាំង៖ [29]

នៅក្នុងសម័យអាណានិគមបារាំង ទឹកដីកម្ពុជាក្រោម ត្រូវបានបារាំងបែងចែកទៅជាខេត្តខណ្ឌជាច្រើនលើកដើម្បីបង្កើតជាប្រព័ន្ធរដ្ឋបាលគ្រប់គ្រង ។ ការបង្កើតរដ្ឋបាលដែលមានលក្ខណៈទ្រង់ទ្រាយធំនោះ យ៉ាងហោចចំនួន ៧ លើក ។

## លើកទី ១ ឆ្នាំ ១៨៦៤ បែងចែកខេត្ត ៣ ទៅជា ៧ មណ្ឌល៖ [30]

ដើម្បី "ពង្រឹងរដ្ឋបាល" ឬបើនិយាយឲ្យចំ "ពង្រឹងអំណាច" របស់បារាំងឲ្យកាន់តែខ្លាំងឡើងៗ លោកឧត្តមនាវីទោ ទេសាភិបាល ដឺ ឡាហ្គ្រង់ដៀរ (Pierre-Paul de La Grandière) (១៨៦៣ - ១៨៦៨) បានបង្កើតជា "នាយកដ្ឋានមហាផ្ទៃ" នៅឆ្នាំ ១៨៦៤ ។ ពង្រឹងអំណាចបារាំង ក៏ដូចជាបារាំងពង្រឹងកងកម្លាំងយួនឲ្យសង្កត់ខ្មែរក្រោមនោះដែរ ។ ក្រៅពីមន្ត្រីរាជការបារាំងបន្តិចបន្តួច មន្ត្រីរាជការស៊ីវិលជាយួន ទាហានបារាំងភាគច្រើនជាយួន ប៉ូលិសការពារសន្តិសុខក៏ជាយួន ខ្មែរក្រោមត្រូវបង្ខំចិត្តរស់នៅក្រោមអាជ្ញាធរយួនតំណាងបារាំង ដែលបារាំងបានតែងតាំងឡើងកាន់តែច្រើនៗ ។

លោកឧត្តមនាវីទោ ទេសាភិបាលបានរៀបចំឡើងវិញនូវខេត្តទាំង ៣ គឺ ត្រពាំងចង្វា (Biên Hòa) ព្រៃនគរ (Gia Định) និង មេស (Định Tường) ដែលស្តេចយួន ទឺ ឌឹក បានចុះសន្ធិសញ្ញាប្រគល់ឲ្យបារាំង នៅថ្ងៃទី ៥ ខែមិថុនា ឆ្នាំ ១៨៦២ ដោយបែងចែកចេញជា ៧ មណ្ឌល (Cercles) ។ មណ្ឌលទាំង ៧ នោះ រួមមាន ព្រះសួគ៌ា (Bà Rịa) កន្ទួត? (Cần Giuộc) មេស (Mỹ Tho) ត្រពាំងចង្វា (Biên Hoà) ព្រៃនគរ (Sài Gòn/

[28] ត្រាំងឆាត ប៊ុត, (ភ្នំពេញ ២០០៥), កម្ពុជាក្រោម អំណាចគ្មានខ្មែរក្រោម, (ការផ្សាយរបស់ ឥន្ទ្រទេវី), ទំព័រ ១៨៧ ។

[29] ចំណុចនេះ យោងតាម "កម្ពុជាក្រោម អំណាចគ្មានខ្មែរក្រោម" ទំព័រ ១៨៤ - ១៩១ និងអត្ថបទពាក់ព័ន្ធនៅលើ Wikipedia ។

[30] ឈ្មោះ មណ្ឌល ឬ ខេត្ត ដែលបារាំងបានបង្កើតជាផ្លូវការ នាពេលនោះ សុទ្ធតែជាភាសាយួនសរសេរជាអក្សរបារាំង ។ ចំណែកឈ្មោះដើមជាភាសាខ្មែរ ដូចជា ព្រៃនគរ ព្រះត្រពាំង មាត់ជ្រូក មេស និង ឃ្លាំង ជាដើម ជាឈ្មោះដែលខ្មែរនិយមហៅក្រៅផ្លូវការតែប៉ុណ្ណោះ ។ សូម្បីតែឈ្មោះ "កម្ពុជាក្រោម" ក៏បារាំងប្រើជាផ្លូវការថា "កូស័ងស៊ីនបារាំងសែស" (Cochinchine Française) ដែរ ។

Chợ Lớn) កំពង់គោ (Tân An), កោះគង (Gò Công) និង រោងដំរី (Tây Ninh) ។

មណ្ឌលទាំង ៧ នេះ ត្រូវឋិតនៅក្រោមការទទួលខុសត្រូវរបស់ «នាយកដ្ឋានមហាផ្ទៃ» តាមសេចក្ដីសម្រេចចុះថ្ងៃទី ៩ ខែវិច្ឆិកា ឆ្នាំ ១៨៦៤ ។

**លើកទី ២ ឆ្នាំ ១៨៦៧ បែងចែកខេត្ត ៣ នៅខាងលិចទន្លេមេគង្គទៅជា ៧ មណ្ឌល៖**

បន្ទាប់ពីបារាំងបានវាយដណ្ដើមយកខេត្តទាំង ៣ គឺ លង់ហោរ ពាម និងមាត់ជ្រូក ដែលនៅខាងលិចទន្លេមេគង្គ នៅឆ្នាំ ១៨៦៧ លោកឧត្តមនាវីទោ ទេសាភិបាល ដឺ ឡាហ្គ្រង់ដ្យេរ បានបែងចែកខេត្តមាត់ជ្រូក (An Giang) ចេញជា ៥ មណ្ឌល ក្នុងនោះមាន មណ្ឌល មាត់ជ្រូក (Châu Đốc) បារាជ (Long Xuyên) ផ្សារដែក (Sa Đéc) ឃ្លាំង (Sóc Trăng) និង ព្រែកឫស្សី (Cần Thơ) ។ រាប់បញ្ចូលមណ្ឌល លង់ហោរ (Vĩnh Long) និង ពាម (Hà Tiên) ២ ទៀត ត្រូវជា ៧ មណ្ឌល ។

**លើកទី ៣ ឆ្នាំ ១៨៧៦ បែងចែកជា ៤ មណ្ឌលរដ្ឋបាល មាន ១៩ ខណ្ឌ និង ២៣៥០ ឃុំ/សង្កាត់៖**

យោងតាមសេចក្ដីសម្រេចចុះថ្ងៃទី ៥ ខែមករា ឆ្នាំ ១៨៧៦ លោកឧត្តមនាវីទោ ទេសាភិបាលកូស័ងស៊ីន ឃុំពែររេ (Victor Auguste Duperré) បានបែងចែក ទឹកដីកម្ពុជាក្រោម ចេញជា ៤ មណ្ឌលរដ្ឋបាល (Circonscription Administrative) ក្នុងនោះ មាន ១៩ ខណ្ឌ **[31]** (Arrondissement) និង ២៣៥០ ឃុំ (Villages) **[32]** ។

មណ្ឌលទាំង ៤ នោះ ចែកចេញ៖

| | | |
|---|---|---|
| មណ្ឌល ព្រៃនគរ | (Sài Gòn) | មាន ៥ ខណ្ឌ |
| មណ្ឌល មេស | (Mỹ Tho) | មាន ៤ ខណ្ឌ |
| មណ្ឌល លង់ហោរ | (Vĩnh Long) | មាន ៤ ខណ្ឌ |
| មណ្ឌល បាសាក់ | (Bassac) | មាន ៦ ខណ្ឌ ។ |

[31] ខណ្ឌ ជាពាក្យ 'ប្រើតែក្នុងសម័យជាន់ដើម, សព្វថ្ងៃគេប្រើពាក្យ ស្រុក ជំនួស ខណ្ឌ វិញ' ឧទាហរណ៍ ខណ្ឌភ្នំពេញ ។ សម្ដេចព្រះសង្ឃរាជ ជួន ណាត, (១៩៦៧), វចនានុក្រមខ្មែរ, ពុទ្ធសាសនបណ្ឌិត្យ, ទំព័រ ៩៥ ។

[32] មុនឆ្នាំ ១៨៦២ គឺមុនពេលដែលបារាំងចូលធ្វើអាណានិគម យួនបានបែងចែកទឹកដីកម្ពុជាក្រោមចេញជា ៦ ខេត្ត ក្នុងនោះមាន ១០ ទីរួមស្រុក (Phủ) ២៥ ស្រុក (Huyện) ១៣៥ ឃុំ (Tổng) និង ១.៦៣៧ ភូមិ (Xã Thôn Phường) ។ https://bit.ly/39EbfHT

| ខណ្ឌទាំង ១៩ នៅកម្ពុជាក្រោម ឆ្នាំ ១៨៧៦ | | |
|---|---|---|
| ល.រ. | ឈ្មោះជាភាសាខ្មែរ | ឈ្មោះជាភាសាយួន |
| មណ្ឌល **ព្រៃនគរ** (Sài Gòn) ចែកចេញជា ៥ ខណ្ឌ | | |
| ១ | ខណ្ឌ រោងដំរី | Tây Ninh |
| ២ | ខណ្ឌ ទួលតាមោក | Thủ Dầu Một |
| ៣ | ខណ្ឌ ចង្វាត្រពាំង | Biên Hòa |
| ៤ | ខណ្ឌ បារា / ព្រះសួគ៌ា | Bà Rịa |
| ៥ | ខណ្ឌ ព្រៃនគរ | Sài Gòn |
| មណ្ឌល **មេស** (Mỹ Tho) ចែកចេញជា ៤ ខណ្ឌ | | |
| ១ | ខណ្ឌ មេស | Mỹ Tho |
| ២ | ខណ្ឌ កោះគង | Gò Công |
| ៣ | ខណ្ឌ កំពង់គោ | Tân An |
| ៤ | ខណ្ឌ ផ្សារធំ | Chợ Lớn |
| មណ្ឌល **លង់ហោរ** (Vĩnh Long) ចែកចេញជា ៤ ខណ្ឌ | | |
| ១ | ខណ្ឌ លង់ហោរ | Vĩnh Long |
| ២ | ខណ្ឌ កំពង់ឫស្សី | Bến Tre |
| ៣ | ខណ្ឌ ព្រះត្រពាំង | Trà Vinh |
| ៤ | ខណ្ឌ ផ្សារដែក | Sa Đéc |
| មណ្ឌល **បាសាក់** (Bát Xắc, Bassac) ចែកចេញជា ៦ ខណ្ឌ | | |
| ១ | ខណ្ឌ មាត់ជ្រូក | Châu Đốc |
| ២ | ខណ្ឌ ពាម | Hà Tiên |
| ៣ | ខណ្ឌ បារាជ | Long Xuyên |
| ៤ | ខណ្ឌ ក្រមួនស | Rạch Giá |
| ៥ | ខណ្ឌ ព្រែកឫស្សី | Cần Thơ |
| ៦ | ខណ្ឌ ឃ្លាំង | Sóc Trăng |

មកដល់ ឆ្នាំ ១៨៨២ បារាំងបានបង្កើតខណ្ឌថ្មីមួយទៀតឈ្មោះថា បាកលីវ (Bạc Liêu) ខ្មែរហៅថា ពលលាវ ។ ដូច្នេះ មកដល់ពេលនេះឃើញថានៅកម្ពុជាក្រោម មាន ២០ ខណ្ឌ ។

បារាំងចៀសវាងប្រើឈ្មោះ «ខេត្ត» ដោយគេបានចាត់ទុកទឹកដីកម្ពុជាក្រោមទាំងមូលដូចជា «ខេត្ត» របស់គេមួយ (Department) ។

**លើកទី ៤ ឆ្នាំ ១៨៩២ បែងចែកជា ២០ ខណ្ឌ និង ទីក្រុង ១៖**

តាមសេចក្តីសម្រេចមួយចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ ១៨៩២ លោកអគ្គទេសាភិបាល ដឺ ឡាណែសាន (De Lanessane) បានរៀបចំរដ្ឋបាលនៅកម្ពុជាក្រោមឡើងវិញ ដោយមានទីក្រុងព្រៃនគរ (Sài Gòn) និង ខណ្ឌ ចំនួន ២០ គឺ៖

| | | | |
|---|---|---|---|
| ពលលាវ | (Bạc Liêu) | បាសាក់ | (Long Xuyên) |
| ព្រះសួគ៌ា | (Bà Rịa) | មេស | (Mỹ Tho) |
| កំពង់ឫស្សី | (Bến Tre) | ក្រមួនស | (Rạch Giá) |
| ត្រពាំងចង្វា | (Biên Hòa ) | ផ្សារដែក | (Sa Đéc) |
| ព្រែកឫស្សី | (Cần Thơ) | ឃ្លាំង | (Sóc Trăng) |
| មាត់ជ្រូក | (Châu Đốc) | កំពង់គោ | (Tân An) |
| ផ្សារធំ | (Chợ Lớn) | រោងដំរី | (Tây Ninh) |
| ឧកញ៉ា អ៊ិន | (Gia Định) | ទួលតាមោក | (Thủ Dầu Một) |
| កោះគង | (Gò Công) | ព្រះត្រពាំង | (Trà Vinh) |
| ពាម | (Hà Tiên) | លង់ហោរ | (Vĩnh Long) |

**លើកទី ៥ ឆ្នាំ ១៨៩៥ បង្កើតទីក្រុងអូរកាប់៖**

នៅខែឧសភា ឆ្នាំ ១៨៩៥ លោកអគ្គទេសាភិបាល រូស្សូ (Rousseau) បានបង្កើតទីក្រុងថ្មីមួយទៀត គឺ Cap Saint Jacques ខ្មែរហៅ អូរកាប់ យួនហៅ Vũng Tàu ។

**លើកទី ៦ ឆ្នាំ ១៩០០ ប្តូរពី ខណ្ឌ ទៅជា ខេត្ត៖**

ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ ១៩០០ តទៅ ដោយយោងតាមសេចក្តីសម្រេចរបស់

លោកអគ្គទេសាភិបាល ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ១៨៩៩ ខណ្ឌទាំងអស់នៅកម្ពុជាក្រោម ត្រូវប្ដូរទៅជាខេត្តវិញ ហើយខេត្តនីមួយៗត្រូវនៅក្រោមការត្រួតត្រារបស់អភិបាលខេត្តម្នាក់ ។ ដូច្នេះ មកដល់ពេលនេះ ឃើញថា កម្ពុជាក្រោម មានខេត្តចំនួន ២០ និង ទីក្រុង ១ គឺ ព្រៃនគរ ។

**លើកទី ៧ ឆ្នាំ ១៩១១ យកខេត្ត ២០ ដាក់បញ្ចូលទៅជា ៣ មណ្ឌលៈ**

ក្រោយមកទៀត យោងតាមសេចក្ដីសម្រេចចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ១៩១១ លោកអគ្គទេសាភិបាលឥណ្ឌូចិន ប. លុស្ស (P. Luce) បានដាក់បញ្ចូលខេត្តនីមួយៗ នៅកម្ពុជាក្រោមឲ្យចូលទៅក្នុងមណ្ឌលទាំង ៣ គឺៈ

**មណ្ឌលទី ១ មាន ៦ ខេត្តៈ** បារា (Bà Rịa) ត្រពាំងចង្វា (Biên Hòa) ទួលតាមោក (Thủ Dầu Một) ផ្សារធំ (Chợ Lớn) រោងដំរី (Tây Ninh) ឧកញ៉ា អ៊ិន / ពញ៉ា ឌិន / តា ឌិន (Gia Định) ។

**មណ្ឌលទី ២ មាន ៧ ខេត្តៈ** កំពង់គោ (Tân An) កោះគង (Gò Công) មេស (Mỹ Tho) កំពង់ឫស្សី (Bến Tre) ព្រះត្រពាំង (Trà Vinh) លង់ហោរ (Vĩnh Long) ផ្សារដែក (Sa Đéc) ។

**មណ្ឌលទី ៣ មាន ៧ ខេត្តៈ** ពលលាវ (Bạc Liêu) បារាជ (Long Xuyên) ក្រមួនស (Rạch Giá) ព្រែកឫស្សី (Cần Thơ) ឃ្លាំង (Sóc Trăng) មាត់ជ្រូក (Châu Đốc) ពាម (Hà Tiên) ។

| ខេត្ត / ក្រុងនានា ២១ នៅកម្ពុជាក្រោម ឆ្នាំ ១៩០០ | | |
|---|---|---|
| ល.រ. | ឈ្មោះភាសាខ្មែរ | ឈ្មោះភាសាយួន |
| ១ | ទីក្រុង ព្រៃនគរ | Sài Gòn |
| ២ | ខេត្ត រោងដំរី | Tây Ninh |
| ៣ | ខេត្ត ទួលតាមោក | Thủ Dầu Một |
| ៤ | ខេត្ត ត្រពាំងចង្វា | Biên Hòa |
| ៥ | ខេត្ត ព្រះសួគ៌ា | Bà Rịa |
| ៦ | ខេត្ត ឧកញ៉ា អ៊ុម / ពញា ឱន / តា ឱន | Gia Định |
| ៧ | ខេត្ត មេស | Mỹ Tho |
| ៨ | ខេត្ត កោះគង | Gò Công |
| ៩ | ខេត្ត កំពង់គោ | Tân An |
| ១០ | ខេត្ត ផ្សារធំ | Chợ Lớn |
| ១១ | ខេត្ត លង់ហោរ | Vĩnh Long |
| ១២ | ខេត្ត កំពង់ឫស្សី | Bến Tre |
| ១៣ | ខេត្ត ព្រះត្រពាំង | Trà Vinh |
| ១៤ | ខេត្ត ផ្សារដែក | Sa Đéc |
| ១៥ | ខេត្ត មាត់ជ្រូក | Châu Đốc |
| ១៦ | ខេត្ត ពាម | Hà Tiên |
| ១៧ | ខេត្ត បារាជ | Long Xuyên |
| ១៨ | ខេត្ត ក្រមួនស | Rạch Giá |
| ១៩ | ខេត្ត ព្រែកឫស្សី | Cần Thơ |
| ២០ | ខេត្ត ឃ្លាំង | Sóc Trăng |
| ២១ | ខេត្ត ពលលាវ | Bạc Liêu |

## កម្ពុជាក្រោម ពីឆ្នាំ ១៩៤១ ដល់ ១៩៧៥៖

កម្ពុជាក្រោម ត្រូវជប៉ុនដណ្តើមអំណាចពីបារាំងមកកាន់កាប់នៅក្នុងអំឡុងសង្គ្រាមលោកលើកទី ២ (១៩៤១ - ១៩៤៥) ក៏ប៉ុន្តែបានប្រគល់ឲ្យបារាំងវិញនៅពេលដែលជប៉ុនចាញ់សង្គ្រាម ។ ក្រោយឆ្នាំ ១៩៤៥ ស្ថានភាពនៅកម្ពុជាក្រោម គឺជាប្រធានបទនៃការខ្វែងគំនិតគ្នារវាងបារាំង និងក្រុមកុម្មុយនីស្តយួនយៀកមិញដែលមាន ហូ ជី មិញ ជាមេដឹកនាំ ។ នៅឆ្នាំ ១៩៤៦ កម្ពុជាក្រោម ត្រូវបានបារាំងប្រកាសបង្កើតជារដ្ឋាភិបាលមួយឈ្មោះថា «សាធារណរដ្ឋស្វយ័តកូស័ងស៊ីន» (République autonome de Cochin chine) ដែលជាបុព្វហេតុមួយនាំឲ្យមានសង្គ្រាមរវាងបារាំង និងក្រុមកុម្មុយនីស្តយួនយៀកមិញ (សង្គ្រាមឥណ្ឌូចិនលើកទី ១) ។ នៅឆ្នាំ ១៩៤៩ បារាំងបានចេញសេចក្តីប្រកាសមួយ ចុះថ្ងៃទី ៤ ខែមិថុនា ផ្ទេរ កម្ពុជាក្រោម ឲ្យទៅជារដ្ឋចំណុះនៃរដ្ឋាភិបាល «រដ្ឋវៀតណាម» (Quốc gia Việt Nam) (១៩៤៩ - ១៩៥៥) ជារដ្ឋាភិបាលមួយដែលបាវ ដាយ ទើបតែបានបង្កើតថ្មី និងក្រោយមក នៅឆ្នាំ ១៩៥៥ រដ្ឋាភិបាលនេះបានប្តូរទៅជា «សាធារណរដ្ឋវៀតណាម» (Việt Nam Cộng hòa) (១៩៥៥ - ១៩៧៥) បន្ទាប់ពីមានសន្និសីទអន្តរជាតិ នៅទីក្រុងហ្សឺណែវ បានតម្រូវឲ្យយួនចែកប្រទេសចេញជាពីរ គឺ ចាប់ពីខ្សែស្របទី ១៧ ចុះមកខាងត្បូងគ្របដណ្តប់លើដែនដីកម្ពុជាក្រោម ដឹកនាំដោយក្រុមយួនសេរីដែលមានអាមេរិកគាំទ្រ និងចាប់ពីខ្សែស្របទី ១៧ ឡើងទៅខាងជើង ដឹកនាំដោយក្រុមកុម្មុយនីស្តយួនយៀកមិញ ។ ទីបំផុត រដ្ឋាភិបាល «សាធារណរដ្ឋវៀតណាម» ខាងត្បូង ត្រូវរដ្ឋាភិបាល “សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម» ខាងជើង ផ្តួលរំលំនៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៧៥ ហើយរបបយួនកុម្មុយនីស្តបានដាក់បញ្ចូល «ទឹកដីកម្ពុជាក្រោម» ឲ្យចូលទៅក្នុងប្រទេសវៀតណាមតែមួយ ឈ្មោះថា «សាធារណរដ្ឋសង្គមនិយមវៀតណាម» រហូតមកដល់សព្វថ្ងៃ ។

## ជប៉ុនដណ្តើមអំណាចពីបារាំង ជំរុញឲ្យ បាវ ដាយ ប្រកាសឯករាជ្យ ឆ្នាំ ១៩៤៥៖

នៅក្នុងអំឡុងសង្គ្រាមលោកលើកទីពីរ (១៩៣៩ - ១៩៤៥) ទាហានបារាំងបានបាត់អំណាចកាន់កាប់នៅក្នុងសហភាពឥណ្ឌូចិន ហើយអំណាចបានធ្លាក់ទៅក្នុងកណ្តាប់ដៃជប៉ុននៅឆ្នាំ ១៩៤១ ។ ទោះបីយ៉ាងនេះក្តី មន្ត្រីបារាំងក៏ត្រូវបានជប៉ុនរក្សាទុកមកផងដែរ និងមានសិទ្ធិបញ្ជាការនៅពីក្រោយ តែប៉ុណ្ណោះ ។ នៅក្នុងព្រឹត្តិការណ៍នេះ ជប៉ុនបានជំរុញឲ្យ ស្តេច បាវ ដាយ ប្រកាសឯករាជ្យបង្កើតរដ្ឋាភិបាលនៅតុងកឹង និងអណ្ណាម ហើយឲ្យទទួលស្គាល់នូវសិទ្ធិអំណាចរបស់ជប៉ុនមកលើប្រទេសយួន និងនៅក្នុងតំបន់អាស៊ីខាងកើត ។

ថ្ងៃទី ៩ ខែមីនា ឆ្នាំ ១៩៤៥ ពេលដែលស្ថានភាពសង្គ្រាមអាស៊ីប៉ាស៊ីហ្វិក (Asia-Pacific War) មានការប្រែប្រួលមិនអំណោយផល ជប៉ុនបានផ្លាស់ប្តូរយុទ្ធសាស្ត្រ និងបានធ្វើពលប្រហារដណ្តើមអំណាចពីបារាំង ដោយបានចាប់ខ្លួនមេទ័ពបារាំង និងដកសិទ្ធិអំណាចកងទ័ពបារាំងនៅឥណ្ឌូនចិន ។ នៅទីក្រុងហ្វេ (Hue) ឯណោះវិញ ជប៉ុនបានចូលទៅផ្តល់ដំណឹងដល់ ស្តេច បាវ ដាយ អំពីការអស់អំណាចរបស់បារាំង ។ នៅថ្ងៃបន្ទាប់គឺនៅថ្ងៃទី ១០ ខែមីនា ជប៉ុនបានចាប់បង្ខំឲ្យ ស្តេច បាវ ដាយ ចុះហត្ថលេខាលើ «សេចក្តីប្រកាសឯករាជ្យ» និងការបង្កើតរដ្ឋាភិបាលដែលគេបានសរសេរជាស្រេច ។

នៅថ្ងៃទី ១១ ខែមីនា ឆ្នាំ ១៩៤៥ ស្តេច បាវ ដាយ បានជួបទីប្រឹក្សាជាន់ខ្ពស់របស់ជប៉ុន គឺ លោកអគ្គរាជទូត Yokoyama Masayuki នៅវិមានកៀងត្រុង (Kiến Trung) ក្នុងព្រះបរមរាជវាំងយួន នារាជធានីហ្វេ ដើម្បីចុះហត្ថលេខាលើ «សេចក្តីប្រកាសឯករាជ្យ» (Tuyên cáo Việt Nam độc lập) បង្កើតជាប្រទេសយួនមួយមានឈ្មោះថា «ដេក្វឹកវៀតណាម» (Đế quốc Việt Nam / Empire of Vietnam) មានន័យថា «អាណាចក្រវៀតណាម» ដោយមានផ្ទៃដីគ្របដណ្តប់លើរដ្ឋអណ្ណាម (ភាគកណ្តាល) និងតុងកឹង (ភាគខាងជើង) វៀតណាម ។ ចំណែកទឹកដីកម្ពុជាក្រោម ត្រូវឋិតនៅក្រោមការគ្រប់គ្រងរបស់ជប៉ុន ។ «សេចក្តីប្រកាសឯករាជ្យ» នេះ ស្តេច បាវ ដាយ បានលុបចោលនូវសន្ធិសញ្ញានយោបាយផ្សេងៗរវាងយួន និងបារាំង ក្នុងនោះ មានសន្ធិសញ្ញា

ទីក្រុងហ្វេ ឆ្នាំ ១៨៨៤ (Treaty of Huế, 1884) ដែលយួនបានយល់ព្រមដាក់ដែនដីអណ្ណាម និងតុងកឹង ឲ្យនៅក្រោមអាណាព្យាបាលបារាំង ។

*“ យោងតាមស្ថានការណ៍របស់ពិភពលោកទាំងមូល និងស្ថានការណ៍នៅទ្វីបអាស៊ី រដ្ឋាភិបាលវៀតណាម សូមប្រកាសជាឱឡារិកថា ចាប់ពីថ្ងៃនេះតទៅ សន្ធិសញ្ញាអាណាព្យាបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយនឹងប្រទេសបារាំង នឹងត្រូវលុបចោល និងចាត់ទុកជាមោឃៈ ។ វៀតណាមនឹងយកមកទាំងស្រុងនូវអធិបតេយ្យរបស់ខ្លួនជាប្រទេសមួយដែលមានឯករាជ្យ ”* ។ –សម្រង់សេចក្ដីប្រកាសឯករាជ្យ របស់ បាវ ដាយ–

គ្រាន់តែបង្កើតបានរដ្ឋាភិបាលភ្លាម នាយករដ្ឋមន្ត្រីយួន ត្រឹង ទ្រង់ គឹម បានបញ្ជូនមន្ត្រីរបស់ខ្លួនចុះមកកម្ពុជាក្រោម ដើម្បីបញ្ចុះបញ្ចូលជប៉ុនឲ្យប្រគល់ទឹកដីកូស័ងស៊ីនដែលយួនហៅថា ណាមគី នោះ ឲ្យយួនវិញ តែជប៉ុនមានការអល់អែក ដោយសារព្រះរាជាខ្មែរក៏បានទាមទារយកទឹកដីកម្ពុជាក្រោម មកវិញដែរ [33] ។

ដោយបានដំណឹងថា ជប៉ុនមានបំណងប្រគល់ តុងកឹង អណ្ណាម និងកូស័ងស៊ីន ឬកម្ពុជាក្រោម ឲ្យទៅស្ដេច បាវ ដាយ កាន់កាប់ នៅថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ១៩៤៥ ព្រះមហាក្សត្រខ្មែរ ព្រះបាទសម្ដេច ព្រះនរោត្តម សីហនុ បានចេញរាជប្រកាសមួយបញ្ជាក់អំពីកម្ពុជាក្រោមជាកម្មសិទ្ធិរបស់កម្ពុជា ដោយស្នើឲ្យមានគណៈកម្មការមួយចរចាគ្នាអំពីបញ្ហាព្រំដែន ។ ផ្ទុយទៅវិញ នៅថ្ងៃទី ៨ ខែសីហា ឆ្នាំ ១៩៤៥ ជប៉ុន បានប្រគល់ តុងកឹង អណ្ណាម និង កម្ពុជាក្រោម ឲ្យទៅ បាវ ដាយ ដដែល ។ ជប៉ុនខិតខំជំរុញឲ្យមានឯកភាពនៅវៀតណាម ដោយបានបញ្ចូលទាំងកម្ពុជាក្រោម ទៅជាមួយផង ទោះបីជប៉ុនខ្លួនឯងមិនបានកាន់កាប់គ្រប់តំបន់នៅឥណ្ឌូចិននេះក៏ដោយ [34] ។

រដ្ឋាភិបាល របស់ បាវ ដាយ ដែលមានជប៉ុនគាំទ្រនោះ មានអាយុកាលដ៏ខ្លីត្រឹមតែ ៦ ខែ ១១ ថ្ងៃ ប៉ុណ្ណោះ ក៏ត្រូវរំសាយនៅថ្ងៃទី ២៣ ខែសីហា ឆ្នាំ ១៩៤៥ ។ ការរំសាយនេះ ដោយសារអាមេរិកបានទម្លាក់គ្រាប់បែកបរមាណូលើប្រទេសជប៉ុន នៅទីក្រុង

[33] Đế quốc Việt Nam (អាណាចក្រវៀតណាម), (១៩ កក្កដា ២០២០), Wikipedia, https://bit.ly/3ieFp7P

[34] ត្រាំងឆាត ប៊ុត, កម្ពុជាក្រោម អំណាចគ្មានខ្មែរក្រោម, ទំព័រ ២៤៧

ហ៊ីរ៉ូស៊ីម៉ា (Hiroshima) និង ណាហ្គាសាគី (Nagasaki) នៅថ្ងៃទី ៦ និងទី ៩ ខែសីហា ឆ្នាំ ១៩៤៥ បានធ្វើឲ្យជប៉ុនចុះចាញ់ក្រុមសម្ព័ន្ធមិត្ត ហើយរដ្ឋាភិបាលរបស់ បាវ ដាយ ដែលពឹងលើកម្លាំងយោធារបស់ជប៉ុននោះ គ្មានកម្លាំងតតាំង ក៏ត្រូវក្រុមយៀកមិញ (Việt Minh) ដែលមាននិន្នាការប្រឆាំងបារាំង និងជប៉ុន ដណ្តើមយកអំណាច និងបានបង្ខំឲ្យ ស្តេច បាវ ដាយ ដាក់រាជ្យ ។ ហូ ជី មិញ បានប្រកាសឯករាជ្យ និងបង្កើតជារដ្ឋាភិបាលថ្មីមួយទៀតឈ្មោះថា សាធារណរដ្ឋប្រជាធិតេយ្យវៀតណាម ។

**យៀកមិញ ដណ្តើមអំណាច បង្ខំឲ្យ ស្តេច បាវ ដាយ ដាក់រាជ្យ ឆ្នាំ ១៩៤៥៖**

ពេលដែលក្រុមយៀកមិញដណ្តើមបានអំណាចពីរដ្ឋាភិបាលរបស់ ស្តេច បាវ ដាយ នៅហាណូយ (Hà Nội) និងនៅទីតាំងជាច្រើនទៀត នាយករដ្ឋមន្ត្រី ត្រឹង ទ្រង់ គីម (Trần Trọng Kim) នៅរាជធានីហ្វេ បានសរសេរលិខិតសុំលាលែងពីតំណែង ។

នៅថ្ងៃទី ២២ ខែសីហា ឆ្នាំ ១៩៤៥ យៀកមិញបានផ្ញើលិខិតបង្ខំឲ្យស្តេច បាវ ដាយ ដាក់រាជ្យ ដោយបានអះអាងថា គេដណ្តើមបានអំណាចទូទាំងប្រទេសអស់ហើយ ។

ស្តេច បាវ ដាយ បានប្រកាសយល់ព្រមដាក់រាជ្យ និងបោះបង់ចោលនូវរាជបល្ល័ង្ក ហើយធ្វើជារាស្ត្រធម្មតាវិញ ដែលមានឈ្មោះដើមថា ង្វៀង ផុក វិញ ទៃ (Nguyễn Phúc Vĩnh Thụy) បន្ទាប់ពីបានសោយរាជ្យអស់រយៈពេល ២០ ឆ្នាំ ។

ថ្ងៃទី ៣០ ខែសីហា ឆ្នាំ ១៩៤៥ ជនជាតិយួនរាប់ពាន់នាក់ បានមកជួបជុំគ្នានៅមុខព្រះបរមរាជវាំង នៅរាជធានីហ្វេ ដើម្បីមើលស្តេចអាននូវ «រាជប្រកាសដាក់រាជ្យ» ។ ស្តេច បាវ ដាយ បានថ្លែងនៅក្នុងពិធីដាក់រាជ្យថា៖“ ***យើងចង់ធ្វើជារាស្ត្ររបស់ប្រទេសមួយដែលមានសេរីភាព ជាជាងធ្វើជាស្តេចនៃប្រទេសមួយដែលនៅក្រោមរណបគេ*** [35] ។ បន្ទាប់ពីបានក្លាយជារាស្ត្រធម្មតាភ្លាម បាវ ដាយ បានប្រគល់ត្រា និងព្រះខាន់រាជ្យជូនទៅតំណាងយៀកមិញ គឺ លោក ត្រឹង វី លៀវ (Trần Huy Liệu) ដែលមានងារជារដ្ឋមន្ត្រីក្រសួងព័ត៌មាន និងឃោសនាការ **[36][37]** ។

[35] សម្តីដើមជាភាសាយួនថា “Trẫm muốn được làm dân một nước tự do, hơn làm Vua một nước nô lệ”

[36] Bảo Đại (ស្តេច បាវ ដាយ), (៥ សីហា ២០២០), Wikipedia, https://bit.ly/33sjBkX

[37] Cách mạng Tháng Tám (បដិវត្តខែសីហា ឆ្នាំ ១៩៤៥), (២៧ សីហា ២០២០), Wikipedia, https://bit.ly/2XqekpV

មកដល់ពេលនេះឃើញថា ប្រទេសយួនមានការប្រែប្រួលមួយយ៉ាងធំនៅក្នុងប្រវត្តិសាស្ត្រនោះគឺ របបរាជានិយមបានត្រូវដួលរលំ និងជនជាតិយួនលែងមានស្តេចចាប់តាំងពីពេលនោះ រហូតមកដល់សព្វថ្ងៃ ។

## ហូ ជី មិញ ប្រកាសឯករាជ្យ បាវ ដាយ ចុះចូលជាមួយយៀកមិញ

បន្ទាប់ពីស្តេច បាវ ដាយ បានដាក់រាជ្យជាផ្លូវការរួច នៅទីលានបាឌិញ (Ba Đình) នាទីក្រុងហាណូយ ហូ ជី មិញ បានប្រកាស "សេចក្តីប្រកាសឯករាជ្យ" និងបង្កើតជារដ្ឋាភិបាលថ្មីមួយទៀតឈ្មោះថា "សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម" (Việt Nam Dân chủ Cộng hòa) នៅថ្ងៃទី ២ ខែកញ្ញា ឆ្នាំ ១៩៤៥ ។ សេចក្តីប្រកាសឯករាជ្យនេះ បានចម្លងតាមសេចក្តីប្រកាសឯករាជ្យរបស់សហរដ្ឋអាមេរិក ដោយមានសេចក្តីផ្តើមថា៖ "*មនុស្សគ្រប់រូបកើតមកមានសិទ្ធិស្មើគ្នា ។ ធម្មជាតិបានបង្កើតឲ្យពួកគេមានសិទ្ធិ ដោយគ្មាននរណាម្នាក់អាចបំពានបានឡើយ ។ សិទ្ធិទាំងនោះមានដូចជាសិទ្ធិរស់រានមានជីវិត សិទ្ធិសេរីភាព និងសិទ្ធិក្នុងការទទួលបាននូវសេចក្តីសុខ* "។ ម្យ៉ាងទៀត ហូ ជី មិញ ក៏បានស្រង់នូវសេចក្តីប្រកាសឯករាជ្យរបស់ប្រទេសបារាំងដែលបានប្រកាសនៅក្នុងឆ្នាំ ១៧៩១ មកធ្វើជាសេចក្តីប្រកាសឯករាជ្យរបស់ខ្លួន ផងដែរ ។

នៅក្នុងសេចក្តីប្រកាសឯករាជ្យនេះដែរ ហូ ជី មិញ បានប្រកាសថា រដ្ឋាភិបាលរបស់ខ្លួនបានលុបចោលរាល់កិច្ចព្រមព្រៀងទាំងឡាយ ដែលបារាំងបានចុះហត្ថលេខាជាមួយនឹងវៀតណាម និងបានលុបចោលទាំងស្រុងនូវអំណាចរបស់បារាំងមកលើប្រទេសវៀតណាម ។

សូមបញ្ជាក់ថា មុនពេលប្រកាសឯករាជ្យ ហូ ជី មិញ ក៏បានអញ្ជើញ បាវ ដាយ ឲ្យទៅហាណូយ ដើម្បីផ្តល់ជាតំណែងនៅក្នុងរដ្ឋាភិបាលដែលទើបតែបង្កើតថ្មី ផងដែរ ។ នៅថ្ងៃទី ៣១ ខែសីហា ឆ្នាំ ១៩៤៥ ក្រោយថ្ងៃ បាវ ដាយ ប្រកាសដាក់រាជ្យមួយថ្ងៃ និងមុនថ្ងៃ ហូ ជី មិញ ប្រកាសឯករាជ្យ ២ ថ្ងៃ បាវ ដាយ បានទទួលលិខិតអញ្ជើញមួយច្បាប់ពី ហូ ជី មិញ ក្នុងនាមរដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ឲ្យទៅហាណូយ ដើម្បីទទួលតំណែងជាទីប្រឹក្សាជាន់ខ្ពស់របស់រដ្ឋាភិបាល ។

*"រដ្ឋាភិបាលបណ្តោះអាសន្ន សូមអញ្ជើញ លោក វិញ ថៃ [បាវ ដាយ] ទៅហាណូយ ដើម្បីធ្វើជាទីប្រឹក្សាជាន់ខ្ពស់ឲ្យរដ្ឋាភិបាល ។ ប្រសិនបើយល់ព្រម យើងនឹងមានសេចក្តីណែនាំជាចាំបាច់មួយ ដើម្បីសម្រួលឲ្យលោកទីប្រឹក្សាអាចចេញដំណើរទៅហាណូយបានឆាប់បំផុត ។*

*ហត្ថលេខា ហូ ជី មិញ"* ។

បន្ទាប់ពីបានពិចារណាច្បាស់លាស់ហើយ បាវ ដាយ បានយល់ព្រមចូលធ្វើការជាមួយនឹងរដ្ឋាភិបាលថ្មីមួយនេះ និងបានចេញដំណើរពីទីក្រុងហ្វេទៅហាណូយចំថ្ងៃដែល ហូ ជី មិញ ប្រកាសឯករាជ្យតែម្តង ។ ហូ ជី មិញ បានផ្តល់តំណែង ដល់ បាវ ដាយ ជាទីប្រឹក្សាជាន់ខ្ពស់ ដូចអ្វីដែលខ្លួនបានសន្យាមែន និងនៅថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ១៩៤៥ បានតែងតាំង បាវ ដាយ ជាសមាជិកម្នាក់ ក្នុងចំណោមសមាជិកទាំង ៧ នាក់ នៃគណៈកម្មការព្រាងច្បាប់រដ្ឋធម្មនុញ្ញសម្រាប់រដ្ឋាភិបាលបណ្តោះអាសន្ន "សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម" ។ ក្រោយពីប្រកាសឯករាជ្យបានបីខែ រដ្ឋាភិបាលនេះបានរៀបចំការបោះឆ្នោតជាតិអាណត្តិទីមួយនៅថ្ងៃទី ៦ ខែមករា ឆ្នាំ ១៩៤៦ ហើយ ហូ ជី មិញ បានជាប់ឆ្នោតជានាយករដ្ឋមន្ត្រី និងជាប្រមុខរដ្ឋ ។

**បាវ ដាយ ផ្តាច់ខ្លួនចេញពី ហូ ជី មិញ ហើយនិរទេសខ្លួនទៅនៅហុងកុងៈ**

បន្ទាប់ពីបានដាក់ខ្លួនចុះចូលជាមួយនឹងក្រុមយៀកមិញបានប៉ុន្មាន ៦ ខែ ក្នុងឱកាសដែលគាត់បានទៅបំពេញទស្សនកិច្ចនៅចិន បាវ ដាយ ក៏បានផ្តាច់ខ្លួនចេញពីរដ្ឋាភិបាល ហើយបាននិរទេសខ្លួនទៅនៅហុងកុង ដើម្បីស្វែងរកការគាំទ្រពីបរទេសក្នុងការបង្កើតជារដ្ឋាភិបាលថ្មីមួយទៀត ។

នៅថ្ងៃទី ១៦ ខែមីនា ឆ្នាំ ១៩៤៦ បាវ ដាយ បានរដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ចាត់ឲ្យដឹកនាំប្រតិភូមួយក្រុមទៅបំពេញទស្សនកិច្ចនៅចិន ។ មានឱកាសបានចេញទៅប្រទេសក្រៅ បាវ ដាយ ក៏សម្រេចចិត្តលែងវិលត្រឡប់ចូលស្រុកវិញ ដោយបានផ្តាច់ខ្លួនចេញពីប្រតិភូ ហើយនិរទេសខ្លួនទៅនៅហុងកុង ។

នៅហុងកុង បាវ ដាយ បានទាក់ទងអ្នកនយោបាយបរទេសជាច្រើន ក្នុងនោះ មាន

អគ្គមេបញ្ជាការកងទ័ព ចច ម៉ារសល្ល (George Marshall) ជាប្រេសិតពិសេសរបស់សហរដ្ឋអាមេរិកប្រចាំប្រទេសចិន (១៩៤៥ - ១៩៤៧) អ្នកដែលបានយកនូវកិច្ចចរចាជាមួយ បាវ ដាយ ទៅជូនប្រធានាធិបតីសហរដ្ឋអាមេរិក ហែររី អេស ទ្រូមែន (Harry S. Truman) (១៩៤៥ - ១៩៥៣) ។

បានដឹងការណ៍នេះ ហូ ជី មិញ បានបញ្ជូនមន្ត្រីរបស់ខ្លួនទៅហុងកុងជាច្រើនលើកដើម្បីបញ្ចុះបញ្ចូលឲ្យ បាវ ដាយ ត្រឡប់មកប្រទេសវិញ តែគ្មានលទ្ធផល ។

ឆ្នាំ ១៩៤៧ ហូ ជី មិញ បានឆ្លើយតបនឹងសារព័ត៌មានអំពីរឿង បាវ ដាយ និរទេសខ្លួននៅបរទេសថា៖ “*យើងខ្ញុំឃ្លាតគ្នាតែកាយទេ តែចិត្តមិនបែកពីគ្នាឡើយ ។ រដ្ឋាភិបាល និងប្រជាជនវៀតណាមមានទំនុកចិត្តយ៉ាងមុតមាំចំពោះភក្ដីភាពរបស់ លោកទីប្រឹក្សាវិញ ទៃ [បាវ ដាយ] ទោះបីសព្វថ្ងៃកំពុងនៅបរទេសក៏ដោយ ក៏គាត់នៅតែបន្តធ្វើការឲ្យរដ្ឋាភិបាលជាតិ និងគាត់នៅជាសមាជិករបស់យើងដដែល*” ។

ផ្ទុយពីអ្វីដែល ហូ ជី មិញ បាននិយាយ មិនយូរប៉ុន្មាន បាវ ដាយ ក៏បានផ្ញើលិខិតពីក្រៅប្រទេសមកសុំលាលែងតំណែង «ទីប្រឹក្សាជាន់ខ្ពស់» នៃរដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ។

ចាប់តាំងពីពេលនោះមក បាវ ដាយ និង ហូ ជី មិញ បានក្លាយជាសត្រូវនឹងគ្នាគ្មានទីបញ្ចប់ ។ សត្រូវនោះ ដោយសារ បាវ ដាយ បានត្រឡប់ចូលស្រុកវិញ ហើយរួមដៃជាមួយបារាំងបង្កើតជារដ្ឋាភិបាលថ្មីមួយទៀតឈ្មោះថា “រដ្ឋវៀតណាម” (Quốc gia Việt Nam) ជារដ្ឋាភិបាលមួយឋិតនៅក្នុងលក្ខន្តិកៈនៃសហភាពបារាំងសែស (Union Française) ។ មកដល់ពេលនេះ សង្គ្រាមហែកហួរគ្នារវាងយួនកុម្មុយនីស្តយៀកមិញខាងជើង និងយួនខាងត្បូងដែលមានបារាំង និងសហរដ្ឋអាមេរិកគាំទ្រ បានបន្តឆាបឆេះកាន់តែខ្លាំងឡើងៗ នៅលើទឹកដីកម្ពុជាក្រោម តុងកឹង និងអណ្ណាម អូសបន្លាយថែម ៣០ ឆ្នាំទៀត (១៩៤៥ - ១៩៧៥) ។

**កម្ពុជាក្រោម ក្នុងសម័យ «សាធារណរដ្ឋស្វយ័តកូស័ងស៊ីន» ពីឆ្នាំ ១៩៤៦ - ១៩៤៨៖**

ចាប់ពីឆ្នាំ ១៩៤៦ ដល់ ១៩៤៩ កម្ពុជាក្រោម ត្រូវបានបារាំងបង្កើតជារដ្ឋាភិបាលមួយ

ឈ្មោះថា «សាធារណរដ្ឋស្វយ័តកូស័ងស៊ីន» (République autonome de Cochin chine) នៅក្នុងលក្ខន្តិកៈនៃសហភាពបារាំង ដោយមានជនជាតិយួនដែលស្និទ្ធនឹងបារាំងជាអ្នកកាន់កាប់ផ្ទាល់លើកិច្ចការផ្សេងៗ តែមន្ត្រីបារាំងជាអ្នកត្រួតត្រានៅពីលើ ។ ការបង្កើតរដ្ឋាភិបាលថ្មីនេះ បន្ទាប់ពីបារាំងបានដណ្តើមអំណាចពីជប៉ុនមកកាន់កាប់ឡើងវិញ នៅក្នុងឆ្នាំ ១៩៤៥ ។

បន្ទាប់ពីបានរំដោះប្រទេសបារាំងចេញពីពួកអាល្លឺម៉ង់ណាស៊ី លោកឧត្តមសេនីយ៍ ឆារល៍ ឌឺ ហ្គោល្លិ៍ (Charles de Gaulle) ក្នុងឋានៈជាប្រធានរដ្ឋាភិបាលសាធារណរដ្ឋបារាំងបណ្តោះអាសន្ន បានប្រកាសគោលនយោបាយរបស់បារាំងសម្រាប់ឥណ្ឌូចិន នៅថ្ងៃទី ២៤ ខែមីនា ឆ្នាំ ១៩៤៥ ថា៖

*"ប្រទេសទាំង ៥ ដែលបង្កើតជាសហព័ន្ធឥណ្ឌូចិន ដែលត្រូវបានសម្គាល់ដោយអារ្យធម៌ ពូជសាសន៍ និងប្រពៃណី នោះ នៅតែបន្តរក្សានូវសញ្ញលក្ខណ៍ផ្ទាល់ខ្លួនរបស់ពួកគេនៅក្នុងសហព័ន្ធដដែល"* ។[38]

តាមរយៈសេចក្តីថ្លែងការណ៍នេះ ឃើញថា នៅពេលសង្គ្រាមលោកលើកទី ២ បានបញ្ចប់ បារាំងនៅតែចាត់ទុក កម្ពុជាក្រោម ដែលបារាំងហៅថា កូស័ងស៊ីន អណ្ណាម តុងកឹង លាវ និងកម្ពុជា ជាប្រទេស ៥ ដាច់ដោយឡែកពីគ្នានៅក្នុងសហព័ន្ធឥណ្ឌូចិន ។ នេះមានន័យថា បារាំងនៅតែចាត់ទុក កម្ពុជាក្រោម ថាជាទឹកដីឯនាយសមុទ្ររបស់ខ្លួនដដែល វាផ្ទុយនឹងគំនិតរបស់ ហូ ជី មិញ ដែលតែងតែចង់ឲ្យប្រទេសវៀតណាមបានទទួលឯករាជ្យដោយឯកភាពទឹកដីនៅលើតំបន់ទាំង ៣ គឺ តុងកឹង (ភាគខាងជើង) អណ្ណាម (ភាគកណ្តាល) និង កម្ពុជាក្រោម ដែលយួនហៅថា ណាមគី (Nam Kỳ) (ភាគខាងត្បូង) ។

ពេលសង្គ្រាមលោកលើកទី ២ បានបញ្ចប់ ជប៉ុនបានចាញ់សង្គ្រាមក្រុមសម្ព័ន្ធមិត្ត នៅថ្ងៃទី ១៥ ខែសីហា ឆ្នាំ ១៩៤៥ ទឹកដីកម្ពុជាក្រោម ត្រូវកងទ័ពអង់គ្លេសកាន់កាប់

[38] Martin Shipway, (2003), The Road to War: France and Vietnam 1944 - 1947, Berghahn Books, ទំព័រ ១២៩, សេចក្តីថ្លែងជាភាសាអង់គ្លេស "The five lands which comprise the Indochinese Federation, and which are distinguished by civilization, race and traditions, will maintain their characters within the Federation."

ដោយឧត្តមសេនីយ៍ ដាកគ្លើស គ្រេស៊ី (Douglas Gracey) ក្នុងឋានៈជាអ្នកតំណាងរបស់ក្រុមសម្ព័ន្ធមិត្ត (Allies) [39] ។ នៅក្នុងខែតុលា បន្ទាប់ពីទ័ពរបស់អង់គ្លេសបានប្រគល់សិទ្ធិអំណាចមកឲ្យទ័ពបារាំង ទើបបារាំងបានចាប់ផ្ដើមបញ្ជាទ័ពរបស់ខ្លួនមកដណ្ដើមកាន់កាប់ទូទាំងដែនដីកម្ពុជាក្រោម ឡើងវិញ ។ សង្គ្រាមរវាងបារាំង និងទ័ពព្រៃយៀកមិញ [40] ក៏បានចាប់ផ្ដើមផ្ទុះឡើង ។

នៅពាក់កណ្ដាលឆ្នាំ ១៩៤៦ បារាំងបានកាន់កាប់ទឹកដីកម្ពុជាក្រោម និងអណ្ណាមឡើងវិញ តែតាមការពិត ការកាន់កាប់នេះ មិនបាននៅគ្រប់ច្រកល្ហកទេ គឺមានតែនៅក្នុងទីប្រជុំជន ។ ចំណែកនៅតាមស្រុកស្រែចម្ការ តំបន់ដាច់ស្រយាល និងនៅតាមព្រៃភក់ល្បាប់ កាន់កាប់ដោយទាហានយៀកមិញ ក្រោមការទទួលខុសត្រូវរបស់ ត្រឹងវ៉ាំង យ៉ាវ (Trần Văn Giàu) បានបន្តការរៀបចំរចនាសម្ព័ន្ធ និងវាយឆ្មក់តាមរបៀបទ័ពព្រៃ ។ [41]

នៅថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ ១៩៤៦ លោកឧត្តមនាវីស្នងការជាន់ខ្ពស់ប្រចាំឥណ្ឌូចិន ដាកហ្សង់ឡឺយើ (D'Argenlieu) បានចេញញត្តិមួយឲ្យបង្កើត «ក្រុមប្រឹក្សាពិគ្រោះកូស័ងស៊ីន» (Conseil consultatif de Cochinchine) ដោយមានសមាជិក ១២ នាក់ ក្នុងនោះ មានយួនដែលមានសញ្ជាតិបារាំង ៨ នាក់ [42] និងបារាំង ៤ នាក់ ។ [43]

នៅថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ១៩៤៦«ក្រុមប្រឹក្សាពិគ្រោះកូស័ងស៊ីន» បានប្ដូរឈ្មោះថ្មីទៅជា «ក្រុមប្រឹក្សាកូស័ងស៊ីន» (Conseil de Cochinchine) ដោយមានសមាជិក

---

[39]“ក្រុមសម្ព័ន្ធមិត្តនៃសង្គ្រាមលោកលើកទី ២” (Allies of World War II) ត្រូវបានហៅថា “សហប្រជាជាតិ” ចាប់តាំងពីមានសេចក្ដីប្រកាសថ្ងៃទី ១ ខែមករា ឆ្នាំ ១៩៤២ ។ នេះជាឈ្មោះហៅសំដៅលើក្រុមប្រទេសដែលបានចងសម្ព័ន្ធភាពយោធាជាមួយគ្នា ដើម្បីប្រឆាំងនឹងមហាអំណាចអ័ក្ស (Axis) នៅក្នុងសង្គ្រាមលោកលើកទី ២ (១៩៣៩ – ១៩៤៥) ។ ក្រុមសម្ព័ន្ធមិត្តបានពង្រឹងសម្ព័ន្ធភាពជាមួយគ្នា ដើម្បីគ្រប់គ្រងការឈ្លានពានរបស់មហាអំណាចអ័ក្ស (Axis) មាន អល្លឺម៉ង់ ជប៉ុន និង អ៊ីតាលី ។ ខាង “ក្រុមសម្ព័ន្ធមិត្ត” មានប្រទេស អង់គ្លេស បារាំង ប៉ូឡូញ ឥណ្ឌា អូស្ត្រាលី កាណាដា នូវែលសេឡង់ អាហ្វ្រិកខាងត្បូង សហរដ្ឋអាមេរិក សូវៀត ចិន និងប្រទេសមួយចំនួនទៀត ។

(40] “យៀកមិញ” មកពីភាសាយួនថា “Việt Nam Độc lập Đồng minh Hội” ហៅកាត់ថា “Việt Minh” ជាចលនានយោបាយមួយដែលបានបង្កើតឡើងដោយ បក្សកុម្មុយនីស្តឥណ្ឌូចិន នៅថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ១៩៤១ ដើម្បីទាមទារឯករាជ្យនៅវៀតណាមពីជប៉ុន និងបារាំង ដែលមាន ហូ ជី មិញ ជាមេដឹកនាំ ។

[41][43] ត្រាំងឆាត ប៊ុត, កម្ពុជាក្រោម អំណាចគ្មានខ្មែរក្រោម, ទំព័រ ២៥២ ។

[42] Allan E, (1973), Politics in War: The Bases of Political Community in South Vietnam, Harvard University Press, ទំព័រ ២០ ។

កើនឡើងដល់ទៅចំនួន ៤២ នាក់ ។

ថ្ងៃទី ១ ខែមិថុនា ឆ្នាំ ១៩៤៦ ស្នងការជាន់ខ្ពស់ប្រចាំឥណ្ឌូចិន ដាកហ្សង់ឌីយើ បានប្រកាសបង្កើតរដ្ឋាភិបាលមួយឈ្មោះថា «សាធារណរដ្ឋស្វយ័តកូស័ងស៊ីន» ដោយមានលោក ង្វៀង វ៉ាំង ធិន (Nguyễn Văn Thinh) ធ្វើជាប្រធាន និង លោក ង្វៀង វ៉ាំង ស៊្វឹង (Nguyễn Văn Xuân) ជាអនុប្រធាន [44] ។ អ្នកទាំងពីរនេះ ជាជនជាតិយួនដែលមានសញ្ជាតិបារាំង និងធ្លាប់បានសិក្សានៅប្រទេសបារាំង ដូចគ្នា ។

លោក ធិន ឡើងដឹកនាំមិនបានមួយឆ្នាំផង ក៏បានធ្វើអត្តឃាតដោយចងកសម្លាប់ខ្លួនឯង នៅថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ១៩៤៦ ហើយ លោក ឡេ វ៉ាំង វ៉ាច់ (Lê Văn Hoạch) បានឡើងដឹកនាំបន្តរហូតដល់ឆ្នាំ ១៩៤៧ និងចុងក្រោយបង្អស់ លោក ង្វៀង វ៉ាំង ស៊្វឹង បានឡើងដឹកនាំបន្តរហូតដល់ថ្ងៃគាត់សុំលាលែងពីតំណែងនៅថ្ងៃទី ២៧ ខែឧសភា ឆ្នាំ ១៩៤៨ ដើម្បីទៅដឹកនាំរដ្ឋាភិបាលថ្មីមួយទៀតឈ្មោះថា "រដ្ឋាភិបាលកណ្ដាលបណ្ដោះអាសន្នវៀតណាម" ដែលបានបង្កើតដោយ បាវ ដាយ ជាអតីតស្ដេចអណ្ណាមដែលត្រូវហូ ជី មិញ បង្ខំឱ្យដាក់រាជ្យ និងកំពុងតែនិរទេសខ្លួននៅហុងកុង ។

មេដឹកនាំជនជាតិយួនដែលដឹកនាំរដ្ឋាភិបាល "សាធារណរដ្ឋស្វយ័តកូស័ងស៊ីន" ចាប់ពីឆ្នាំ ១៩៤៦ ដល់ ១៩៤៨ រួមមាន ៣ រូប គឺ៖

| **ល.រ.** | **ឈ្មោះពេញ** | **កាលបរិច្ឆេទចូលកាន់តំណែង** |
|---|---|---|
| ១ | ង្វៀង វ៉ាំង ធិន | ២៦ មីនា - ៣១ ឧសភា ១៩៤៦ (លើកទី ១ បណ្ដោះអាសន្ន) |
| | | ០១ មិថុនា - ១០ វិច្ឆិកា ១៩៤៦ (លើកទី ២) |
| ២ | ឡេ វ៉ាំង វ៉ាច់ | ២៩ វិច្ឆិកា ១៩៤៦ - ២៩ កញ្ញា ១៩៤៧ |
| ៣ | ង្វៀង វ៉ាំង ស៊្វឹង | ០៨ តុលា ១៩៤៧ - ២៧ ឧសភា ១៩៤៨ (លាលែងពីតំណែង) |

[44] អត្ថបទក្នុងភាសាបារាំង និងអង់គ្លេស ប្រើពាក្យ "President" មានន័យថា "ប្រធាន" សម្រាប់សម្គាល់តំណែងនៅក្នុងរដ្ឋាភិបាលនេះ តែជនជាតិយួនបានប្រើពាក្យ "Thủ tướng" ដែលមានន័យថា "នាយករដ្ឋមន្ត្រី" ឬ "Prime Minister" ជំនួសវិញ ។

## កម្ពុជាក្រោម ក្នុងសម័យ «រដ្ឋាភិបាលកណ្ដាលបណ្ដោះអាសន្នវៀតណាម»៖

នៅក្នុងឆ្នាំ ១៩៤៨ និង ១៩៤៩ ទឹកដីកម្ពុជាក្រោម ត្រូវក្រុមមេដឹកនាំយួនដែលមាននិន្នាការប្រឆាំងនឹងយៀកមិញ និងស្និទ្ធជាមួយនឹងបារាំង បានបង្កើតជារដ្ឋាភិបាលថ្មីមួយទៀតឈ្មោះថា "រដ្ឋាភិបាលកណ្ដាលបណ្ដោះអាសន្នវៀតណាម" (Chính phủ Trung ương lâm thời Việt Nam / Gouvernement central provisoire du Viêt Nam) ក្នុងគោលបំណងរារាំងនូវមហិច្ឆតាដណ្ដើមអំណាច និងឯកភាពជាតិវៀតណាម ដោយ ហូ ជី មិញ នៃរដ្ឋាភិបាល សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ខាងជើង ។ ម្យ៉ាងទៀត រដ្ឋាភិបាលបណ្ដោះអាសន្ននេះ មានតួនាទីចរចាជាមួយបារាំងអំពី«ឯករាជ្យ» និងអំពីអ្វីមួយដែលយួនហៅថា «ឯកភាពទឹកដី» នៅលើភូមិភាគ ឬតំបន់ទាំង ៣ គឺ ភាគខាងជើង ភាគកណ្ដាល និងភាគខាងត្បូង ឬ ដែនដីកម្ពុជាក្រោម ដែលយួនហៅថា ណាមគី ។ ក្រោយមក ក្រុមមេដឹកនាំនៃរដ្ឋាភិបាលនេះ បានរួបរួមគ្នាជាមួយ បាវ ដាយ បង្កើតជារដ្ឋាភិបាលថ្មីមួយទៀតឈ្មោះថា « រដ្ឋវៀតណាម» (Quốc gia Việt Nam / État du Viêt Nam) បន្ទាប់ពីបារាំងបានយល់ព្រមភ្ជាប់ «ទឹកដីកម្ពុជាក្រោម» ឲ្យចូលជាមួយនឹងទឹកដីវៀតណាម នៅឆ្នាំ ១៩៤៩ ។

នៅថ្ងៃទី ២២ ខែមករា ឆ្នាំ ១៩៤៧ លោក ប៉ុល រ៉ាម៉ាឌីយេ (Paul Ramadier) បានឡើងកាន់តំណែងជានាយករដ្ឋមន្ត្រីនៃប្រទេសបារាំងភ្លាម បានធ្វើសេចក្ដីថ្លែងការណ៍មួយថា រដ្ឋាភិបាលរបស់លោក គ្មានជំទាស់អ្វីនឹងឯករាជ្យ និងឯកភាពជាតិរបស់វៀតណាមទេ ឲ្យតែវៀតណាមនោះ ឋិតនៅក្នុងសហព័ន្ធឥណ្ឌូចិន (Fédération indochinoise) និងសហភាពបារាំង (Union française) [45] និងបារាំងនឹងស្វាគមន៍ជានិច្ចចំពោះការចរចាជាមួយនឹងតំណាងពិតប្រាដកមួយរបស់វៀតណាម ។ បីខែក្រោយមក នៅថ្ងៃទី ១៣ ខែមីនា លោក អ៊ីមីល បូលឡាអែរត៍ (Émile Bollaert) បានទទួលតំណែងជាស្នងការជាន់ខ្ពស់នៅឥណ្ឌូចិនជំនួស ឧត្តមនាវី ដាកហ្សង់ឌីយេ ។ បន្ទាប់ពីខិតខំមិនបានជោគជ័យក្នុងការទប់ស្កាត់ការបាញ់ និងវាយប្រហារដោយទ័ពព្រៃយៀក

[45] ត្រាំងឆាត ប៊ុត, កម្ពុជាក្រោម អំណាចគ្មានខ្មែរក្រោម, ទំព័រ ២៦៣ ។

មិញមក លោក បូលឡាអែរត៍ បានងាកមករកធ្វើការចរចាជាមួយ បាវ ដាយ ក្នុងគោលបំណងបញ្ចុះបញ្ចូលឲ្យអតីតស្តេចដាក់រាជ្យរូបនេះ វិលត្រឡប់ចូលស្រុកធ្វើជាមេដឹកនាំ និងកាន់អំណាចឡើងវិញ ដើម្បីឯកភាពទឹកដីវៀតណាម ប៉ុន្តែការចរចានេះត្រូវអូសបន្លាយពេលជាច្រើនខែ ព្រោះ បាវ ដាយ ងឿកគេចចេញទៅកម្សាន្តនៅអឺរ៉ុបជាច្រើនសា ដោយសារ បារាំងមិនព្រមដាក់ភ្ជាប់ ទឹកដីកម្ពុជាក្រោម ឲ្យចូលជាមួយនឹងទឹកដីវៀតណាម ។ [46]

បានជ្រាបការណ៍នេះ សម្ព័ន្ធគណបក្សនយោបាយជាតិនិយមយួនមួយក្រុម ដែលប្រឆាំងនឹងយៀកមិញ គឺ «សម្ព័ន្ធរណសិរ្សឯកភាពជាតិ» (Mặt trận Thống nhất Quốc gia Liên hiệp / Front d'Union Nationale) បានចេញសេចក្តីសម្រេចមួយគាំទ្រគោលនយោបាយឲ្យ បាវ ដាយ ចរចាជាមួយនឹងបារាំងស្តីអំពី «ឯករាជ្យ» របស់វៀតណាម ។ នៅខែឧសភា ឆ្នាំ ១៩៤៧ រណសិរ្សនេះ បានបញ្ជូនប្រតិភូរបស់ខ្លួនទៅហុងកុង ដើម្បីបញ្ចុះបញ្ចូលឲ្យ បាវ ដាយ បង្កើតជារដ្ឋាភិបាលកណ្តាលមួយ ហើយធ្វើការចរចាជាមួយបារាំងអំពី «ឯករាជ្យ» នៅវៀតណាម ។ ក្រុមចលនានយោបាយជាសមាជិកនៃសម្ព័ន្ធរណសិរ្ស ដែលគាំទ្រ បាវ ដាយ នោះ រួមមាន កាវដាយ (Cao Đài), ហ្វាហាវ (Hòa Hảo), សម្ព័ន្ធបដិវត្តន៍វៀតណាម (Việt Nam Cách mệnh Đồng minh Hội), គណបក្សប្រជាជាតិដាយវៀត (Đại Việt Quốc dân đảng) និងគណបក្សប្រជាជាតិវៀតណាម (Việt Nam Quốc dân Đảng) ។[47]

នៅខែវិច្ឆិកា ឆ្នាំ ១៩៤៧ លោក បូឡាអែរត៍ បានស្នើសុំជួប បាវ ដាយ ។ ប្រហែលមួយខែក្រោយមក អ្នកទាំងពីរបានជួបគ្នា ២ ថ្ងៃ គឺនៅថ្ងៃទី ៦ និង ៧ ខែធ្នូ នៅលើនាវាចម្បាំងរបស់បារាំង នាឆកសមុទ្រហាឡុង (Vịnh Hạ Long) ។ នៅក្នុងកិច្ចប្រជុំលើកទីមួយនេះ បាវ ដាយ បានចុះសន្និសញ្ញាមួយជាមួយនឹងបារាំង ដោយបារាំងបានសន្យាថានឹងផ្តល់ឯករាជ្យខាងនយោបាយដល់វៀតណាម ។ ពាក្យ «ឯករាជ្យ» ដែលបារាំងបាន

[46] Émile Bollaert, (១០ សីហា ២០២០), Wikipedia, https://bit.ly/31SXxgC

[47] The Pentagon Papers, Chapter 2, 'U.S. Involvement in the Franco-Viet Minh War, 1950-1954', U.S. POLICY AND THE BAO DAI REGIME (ស្រង់ប្រភព៖ ១៤ សីហា ២០២០), https://bit.ly/33WXKCb

ផ្តល់ឲ្យ បាវ ដាយ នាពេលនោះ មានលក្ខណៈចង្អៀតចង្អល់ បានធ្វើឲ្យក្រុមសម្ព័ន្ធគណបក្សនយោបាយជាតិនិយមយួនដែលធ្លាប់គាំទ្រ បាវ ដាយ ឲ្យមានកិច្ចចរចានោះបានថ្កោលទោសភ្លាមៗថា សន្ធិសញ្ញានេះ វៀតណាមមិនបានទទួលឯករាជ្យពិតប្រាកដនោះទេ ។ បាវ ដាយ ខកចិត្ត ក៏បានដកខ្លួនចេញពីឆាកនយោបាយម្តងទៀត ហើយបានទៅលាក់ខ្លួនលេងសប្បាយភ្លើតភ្លើននៅមជ្ឈមណ្ឌលកម្សាន្តនៅអឺរ៉ុបអស់ ៤ ខែ បានធ្វើឲ្យលោកក្លាយទៅជា «អធិរាជក្លឹបរាត្រី» (night club emperor) ។ [48]

ខែមករា ឆ្នាំ ១៩៤៨ ស្នងការជាន់ខ្ពស់ឥណ្ឌូចិន លោក បូលឡាអែរត៍ បានទៅជួប បាវ ដាយ នៅទីក្រុងហ្សឺណែវ ប្រទេសស្វិស ដើម្បីបញ្ចុះបញ្ចូលគាត់ឲ្យវិលចូលស្រុកបន្តពិភាក្សាគ្នា និងបង្កើតជារដ្ឋាភិបាល ។ បាវ ដាយ បានបញ្ជាក់ថា ប្រសិនបើ «សន្ធិសញ្ញាឆកសមុទ្រហាឡុង» (Hiệp ước Vịnh Hạ Long) មិនបានបំពេញបន្ថែមទេ គាត់នឹងមិនវិលត្រឡប់ចូលស្រុកឡើយ ។ បន្ទាប់មក បាវ ដាយ បានធ្វើដំណើរទៅបារាំងដើម្បីស្ទាបស្ទង់ស្ថានការណ៍ និងបានវិលត្រឡប់ទៅហុងកុង វិញ ។ [49]

ខែមីនា ឆ្នាំ ១៩៤៨ បាវ ដាយ និង ក្រុមមេដឹកនាំយួននៃ “សម្ព័ន្ធរណសិរ្សឯកភាពជាតិ” បានជួបជុំគ្នានៅហុងកុង ហើយឯកភាពបង្កើតជារដ្ឋាភិបាលមួយឈ្មោះថា “រដ្ឋាភិបាលកណ្តាលបណ្តោះអាសន្នវៀតណាម” ។ [50] នៅថ្ងៃទី ២៧ ខែឧសភា បារាំងបានទទួលយល់ព្រមតាមការស្នើរបស់ បាវ ដាយ ឲ្យបង្កើតរដ្ឋាភិបាលបណ្តោះអាសន្នមួយនេះ ក្រោមការដឹកនាំរបស់ ឧត្តមសេនីយ៍ ង្វៀង វ៉ាំង ស្វឹង ដែលក្នុងនោះមានរដ្ឋមន្ត្រីតំណាងមកពីហាណូយ (ភាគខាងជើង) ហ្វេ (ភាគកណ្តាល) និងព្រៃនគរ (ភាគខាងត្បូង ឬ កម្ពុជាក្រោម) ។ [51]

(48] ឯកសារមន្ទីរបញ្ចកោណ, ‘ទំនាក់ទំនងសហរដ្ឋអាមេរិក - វៀតណាម, ១៩៤៥ - ១៩៦៧៖ ការសិក្សាត្រៀម ដោយក្រសួងការពារជាតិសហរដ្ឋអាមេរិក’ (ឯកសារសម្ងាត់ និងរសើប ត្រូវបានទម្លាយសម្ងាត់ ក្នុងខែមិថុនា ឆ្នាំ ២០១១) ។ Pentagon Papers, ‘United States – Vietnam Relations, 1945–1967: A Study Prepared by the Department of Defense’, (Top Secret - Sensitive, declassified, June 2011), (Download: ១៥ សីហា ២០២០), https://bit.ly/3gXJooN

[49] Archimedes L.A Patti, Why Vietnam, Nhà xuất bản Đà Nẵng, 2008, ទំព័រ ៦៤៨ - ៦៤៩ ។

[50] Quốc gia Việt Nam, (១៣ សីហា ២០២០), Wikipedia, https://bit.ly/3kO0rMt

[51] ត្រាំងឆាត ប៊ុត, កម្ពុជាក្រោម អំណាចគ្មានខ្មែរក្រោម, ទំព័រ ២៦៤

## បារាំងបង្កើតផែនការ «ដំណោះស្រាយ បាវ ដាយ» ដើម្បីប្រឆាំងនឹងយៀកមិញ

នៅពេលនោះ យួនមានរដ្ឋាភិបាលពីរគឺ "រដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម" បានបង្កើតឡើងដោយក្រុមយៀកមិញ ដែលមាន ហូ ជី មិញ ជាប្រធាន និង «រដ្ឋាភិបាលកណ្ដាលបណ្ដោះអាសន្នវៀតណាម» ហើយក្រោយមកក្លាយទៅជារដ្ឋាភិបាល "រដ្ឋវៀតណាម" ដែលដឹកនាំ ដោយ បាវ ដាយ ។ ហូ ជី មិញ ជាសត្រូវរបស់បារាំង និងជាអ្នកកុម្មុយនីស្ដនិយម បានប្រកាសឯករាជ្យជាឯកតោភាគី នៅថ្ងៃទី ២ ខែកញ្ញា ឆ្នាំ ១៩៤៥ ហើយបានប្រកាសធ្វើសង្គ្រាមប្រឆាំងនឹងបារាំងតាមរយៈទ័ពព្រៃ ដើម្បីឲ្យបារាំងដកអាណានិគមចេញពីវៀតណាម ។ បាវ ដាយ ជាអតីតស្ដេចរបស់យួន ដែលត្រូវយៀកមិញបង្ខំឲ្យដាក់រាជ្យ ស្និទ្ធនឹងបារាំង និងជាអ្នកសេរីនិយម បានបង្កើតជារដ្ឋាភិបាលផ្ដាច់ខ្លួនចេញពី ហូ ជី មិញ ហើយបានបារាំងទទួលស្គាល់ជារដ្ឋាភិបាលនៅក្នុងក្របខ័ណ្ឌនៃសហភាពបារាំង ។ ហូ ជី មិញ និង បាវ ដាយ ប្រកាន់យកគោលជំហរចង់បាន "ឯករាជ្យ" និង "ឯកភាពទឹកដី" ឬ ចង់លេបយក "ទឹកដីកម្ពុជាក្រោម" ដូចគ្នា តែខុសគ្នាត្រង់ថា ហូ ជី មិញ ជាមនុស្សកុម្មុយនីស្ដ ប្រឆាំងបារាំង ចំណែក បាវ ដាយ ជាមនុស្សសេរី ស្និទ្ធនឹងបារាំង ។

ក្រោយសង្គ្រាមលោកលើកទី ២ បារាំងនៅតែបន្តពង្រីកអំណាចដើម្បីធ្វើអាណានិគមនៅឥណ្ឌូចិន តែត្រូវប្រឈមនឹងការក្រោកឡើងប្រឆាំងយ៉ាងខ្លាំងពីកងទ័ពយៀកមិញដែលដឹកនាំដោយ ហូ ជី មិញ ។ ក្នុងស្ថានភាពដ៏លំបាកនេះ បារាំងក៏បាននឹកឃើញនូវល្បិចកល «បន្លាមុតយកបន្លាដោះ»ដោយបានបង្កើតឲ្យមាននយោបាយ «ដំណោះស្រាយ បាវ ដាយ» (Giải pháp Bảo Đại/The Bao Dai Solution) ដើម្បីបង្វែរពីសង្គ្រាមរវាងបារាំងជាមួយនឹងយៀកមិញ ទៅជាសង្គ្រាមរវាងយួនយៀកមិញជាមួយនឹងយួន បាវ ដាយ ម្ដងវិញ ។

«ដំណោះស្រាយ បាវ ដាយ»ជាផែនការមួយដែលបារាំងបានព្យាយាមបញ្ចុះបញ្ចូលឲ្យអតីតស្ដេច បាវ ដាយ វិលចូលស្រុកវិញ ហើយបង្កើតជារដ្ឋាភិបាលយួនមួយ ដើម្បីប្រឆាំងនឹងកងទ័ពឧទ្ទាមកុម្មុយនីស្ដយៀកមិញ ។

ថ្ងៃទី ២ ខែមករា ឆ្នាំ ១៩៤៧ ឆ្លើយនឹងទីភ្នាក់ងារព័ត៌មាន France-Sor ឧត្តមសេនីយ៍ ដាកហ្សង់ឌីយើ ជាស្នងការជាន់ខ្ពស់ឥណ្ឌូចិន បានថ្លែងថា៖ “*ចាប់តាំងពីថ្ងៃនេះតទៅមុខ យើងគ្មានអ្វីត្រូវចរចាជាមួយនឹង ហូ ជី មិញ ទៀតទេ*” ។ ម្យ៉ាងទៀត “*យើងនឹងស្វែងរកឲ្យឃើញនូវមនុស្សផ្សេងទៀតនៅក្នុងស្រុកនេះសម្រាប់ចរចា*” ។ [52]

បារាំងគិតថា ចាប់តាំងពី បាវ ដាយ បានដាក់រាជ្យមក យួនដែលគាំទ្រ បាវ ដាយ ជាច្រើន បានចុះចូលជាមួយនឹងយៀកមិញ ។ ដូច្នេះ ប្រសិនបើអាចធ្វើឲ្យ បាវ ដាយ វិលចូលស្រុកបង្កើតជារដ្ឋាភិបាលបាន អ្នកទាំងនោះ នឹងរត់ចេញពីជំរំតស៊ូរបស់យៀកមិញ ហើយមកចុះចូលជាមួយនឹងបារាំង ប្រឆាំងត្រឡប់ទៅយៀកមិញ ដែលដឹកនាំដោយ ហូ ជី មិញ ជាមិនខាន ។ នៅក្នុងលិខិតចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ១៩៤៧ ឧត្តមសេនីយ៍ ដាកហ្សង់ឌីយើ បានសរសេរថា៖ “ *ដំណើរវិលត្រឡប់របស់ស្តេច [បាវ ដាយ] ប្រហែលជាមានប្រសិទ្ធភាពធ្វើឲ្យស្ងប់ចិត្តអ្នកដែលបារម្ភអំពីការថ្កោលទោសថាជាជនក្បត់ជាតិ ដោយសារតែចុះចូលជាមួយនឹងយៀកមិញ*” ។ [53]

ដើម្បីអនុវត្តនូវផែនការនេះ ស្នងការនយោបាយសហព័ន្ធឥណ្ឌូចិន ឡេអុង ពីញ៉ុង (Léon Pignon) និងក្រោយមក គាត់បានក្លាយជាស្នងការជាន់ខ្ពស់ឥណ្ឌូនចិន ជំនួសលោក បូលឡាអែរត៍ បានសរសេរនៅក្នុងខែមករា ឆ្នាំ ១៩៤៧ ថា៖ “*ទិសដៅរបស់យើងច្បាស់លាស់ណាស់ គឺបង្វែរបញ្ហាប្រឈមរបស់យើង [បារាំង] ជាមួយនឹងយៀកមិញ ទៅជាការប្រឈមមុខដាក់គ្នានៅក្នុងចំណោមជនជាតិយួនគ្នាឯង និងយើងគ្រាន់តែចូលរួមតិចតួចបំផុតដែលអាចធ្វើទៅបាន នៅក្នុងយុទ្ធនាការប្រតិបត្តិការសឹក និងការសងសឹក ដែលការណ៍នេះ គួរតែជាកិច្ចការរបស់ម្ចាស់ស្រុកដែលជាគូសត្រូវរបស់យៀកមិញ*” ។ [54]

បញ្ជាក់កាន់តែច្បាស់ផែនការនេះ អគ្គមេបញ្ជាការជាន់ខ្ពស់នៃកងទ័ពបារាំងប្រចាំឥណ្ឌូចិន ហ្សង់ ជៀន វ៉ាលុយ (Jean Étienne Valluy) បានថ្លែងថា៖ “*ត្រូវបង្កើតឲ្យ*

[52] Devillers, Philippe (1988), Paris - Saigon - Hanoi, Paris: Gallimard-Julliard, ទំព័រ ៣២០

[53] Devillers, Philippe, ទំព័រ ៣២៤

[54] The Pentagon Papers, Chapter 2, "U.S. Involvement in the Franco-Viet Minh War, 1950-1954", U.S. POLICY AND THE BAO DAI REGIME (ស្រង់ប្រភពថ្ងៃទី ១៤ សីហា ២០២០), https://bit.ly/33WXKCb

*មានសង្គ្រាមផ្ទៃក្នុងបន្តិចបន្តួចរវាងជនជាតិយួនគ្នាឯង"* ។ [55]

នៅឆ្នាំ ១៩៤៧ អតីតមេយកការណ៍សម្ងាត់របស់បារាំងម្នាក់ប្រចាំឥណ្ឌូចិនឈ្មោះ កុស សូ (Cousseau) បានជួប បាវ ដាយ នៅហុងកុង ដើម្បីអញ្ជើញគាត់ឱ្យវិលចូលស្រុកកាន់អំណាចឡើងវិញតាមផែនការ «ដំណោះស្រាយ បាវ ដាយ» ។ មានមតិលើកឡើងថា ការណ៍នេះធ្វើឡើងក្នុងគោលបំណងប្រឆាំងនឹងយុទ្ធនាការទាមទារឯករាជ្យរបស់ចលនាយៀកមិញ។[56] មតិមួយចំនួនទៀតបានលើកឡើងថា "ដំណោះស្រាយ បាវ ដាយ" ធ្វើឡើង ក្នុងគោលបំណងឆ្លើយតបនឹងទំនោរអន្តរជាតិក្នុងការផ្តល់ឯករាជ្យដល់ប្រទេសដែលនៅក្រោមអាណានិគម និងដើម្បីទប់ទល់នឹងការពង្រឹងឥទ្ធិពលនៃលទ្ធិកុម្មុយនីស្តនៅឥណ្ឌូចិន ។ [57] តែសម្រាប់ បាវ ដាយ ខ្លួនឯងផ្ទាល់វិញបានបញ្ជាក់ថា៖ *"អ្វីដែលគេហៅថា ដំណោះស្រាយ បាវ ដាយ នោះ តាមពិត គ្រាន់តែជាដំណោះស្រាយរបស់បារាំងតែប៉ុណ្ណោះ"* ។ [58]

ដោយសារ បាវ ដាយ បានដឹងអំពីគំនិត "បារាំងត្រូវការ បាវ ដាយ" ទើប បាវ ដាយ ចេះតែងឿក [59] ជាច្រើនលើកច្រើនសា ដោយវិធីយកលេសដកខ្លួនចេញពីឆាកនយោបាយ ហើយគេចទៅលាក់ខ្លួននៅបរទេសដើម្បីឱ្យបារាំងអង្វរ ។ នៅពេលបានឃើញបារាំងកាន់តែទោរទន់ទៅរកខ្លួននោះ បាវ ដាយ ក៏បានតថ្លៃថា ប្រសិនបើបារាំងមិនព្រមលុបចោលនូវរបបអាណានិគមនៅលើទឹកដីកម្ពុជាក្រោម ដែលយួនហៅថា ណាមគី និងមិនព្រមប្រគល់ទឹកដីកម្ពុជាក្រោមឱ្យទៅយួននោះទេ គាត់នឹងមិនវិលត្រឡប់ចូលស្រុកឡើយ ។

**សន្ធិសញ្ញាឆកសមុទ្រហាឡុង ឆ្នាំ ១៩៤៨៖**

នៅថ្ងៃទី ៥ ខែមិថុនា ឆ្នាំ ១៩៤៨ បាវ ដាយ បានធ្វើជាសាក្សីនៅក្នុងកិច្ចប្រជុំ ជា

[55] Devillers, Philippe (1988), Paris - Saigon - Hanoi, ទំព័រ ៣៣៥

[56] Quỳnh Cư, Đỗ Đức Hùng, Các triều đại Việt Nam (ព្រះរាជាវៀតណាម), Nhà Xuất bản Thanh niên, 1999, ទំព័រ ៣៨៤

[57] The first Indochina war: French and American policy 1945-54 - Ronald E Irving - London: Croom Helm, 1986

[58] Tucker, Spencer, (2011), The Encyclopedia of the Vietnam War: A Political, Social, and Military History (2nd ed.), California, ABC-CLIO, LLC, ទំព័រ ៣៤៣ "What they call Bao Dai solution turns out to be just a French solution"

[59] ងឿក យ. ( កិ. ) ក្លែងក្និចគេចមិនព្រម : ក្មេងនេះងឿកអីម៉្លេះ ? ងឿកង៉ែ ងឿកយំង៉ែៗ; ងឿកក្និចក្នក់ ។ សម្ដេចព្រះសង្ឃរាជ ជួន ណាត ជោតញ្ញាណោ, វចនានុក្រមខ្មែរ, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត, (ភ្នំពេញ៖ ព. ស. ២៥១១ គ. ស. ១៩៦៧), ទំព័រ ១៧០

លើកទីពីរ នៅលើនាវាចម្បាំង ឌូហ្គេ ទ្រូវើន (Duguay Trouin) របស់បារាំង នាឆកសមុទ្រហាឡុង ដើម្បីចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍រួមមួយដែលហៅថា «សន្ធិសញ្ញាឆកសមុទ្រហាឡុង» (The Ha Long Bay Agreement, 1948) ។ សន្ធិសញ្ញានេះ បានចុះហត្ថលេខាដោយ ឧត្តមសេនីយ៍ ង្វៀង វ៉ាំង ស៊ឹង ជាតំណាងរដ្ឋាភិបាលកណ្តាលបណ្តោះអាសន្នវៀតណាម និងស្នងការជាន់ខ្ពស់ឥណ្ឌូចិន បូលឡាអែរត៍ ជាតំណាងរដ្ឋាភិបាលសាធារណរដ្ឋបារាំង ។ សន្ធិសញ្ញានេះ បារាំងបានទទួលស្គាល់ជាឱឡារិកនូវការផ្តល់ឯករាជ្យដល់វៀតណាម ប៉ុន្តែ បារាំងនៅតែកាន់កាប់ផ្នែកទំនាក់ទំនងការបរទេស និងយោធា ដដែល ។ ក្រៅពីនេះ បារាំងបានពន្យាការផ្ទេរសិទ្ធិអំណាចលើមុខងារផ្សេងៗរបស់រដ្ឋាភិបាលនៅក្នុងកិច្ចពិភាក្សានាពេលអនាគត ។ តាមការណ៍ពិតគ្មានសិទ្ធិអ្វីមួយដែលបារាំងបានផ្ទេរឲ្យជនជាតិយួននោះទេ ។ បាវ ដាយ ងើកម្តងទៀតក៏បានគេចចេញទៅអឺរ៉ុប ។ [60] សេចក្តីថ្លែងការណ៍នោះ មាន ៣ ចំណុចៈ

> *១. បារាំងទទួលស្គាល់ជាឱឡារិកនូវឯករាជ្យរបស់វៀតណាម ដោយមានសេរីភាពក្នុងការអនុវត្តនូវការឯកភាពទឹកដីរបស់ខ្លួន ។ ចំណែកខាងវៀតណាម បានប្រកាសចូលជាសមាជិកនៃសហភាពបារាំង ក្នុងឋានៈជាប្រទេសសមាគមនឹងបារាំង ។ ឯករាជ្យរបស់វៀតណាម គ្មានអ្វីក្រៅពីឋិតក្នុងក្របខ័ណ្ឌនៃសហភាពបារាំងឡើយ ។*
>
> *២. វៀតណាមសន្យាថា នឹងគោរពនូវសិទ្ធិ និងផលប្រយោជន៍របស់ប្រជាជនបារាំង ធានាឲ្យមានការគោរពនូវគោលការណ៍ប្រជាធិបតេយ្យ និងស្នើឲ្យមានទីប្រឹក្សា និង អ្នកបច្ចេកទេសបារាំងជាអាទិភាព តាមតម្រូវការក្នុងការរៀបចំអង្គការផ្ទៃក្នុង និងសេដ្ឋកិច្ចរបស់ខ្លួន ។*
>
> *៣. ចាប់តាំងពីបង្កើតរដ្ឋាភិបាលបណ្តោះអាសន្ននេះតទៅ តំណាងរបស់វៀតណាមនឹងដោះស្រាយយ៉ាងសមរម្យជាមួយនឹង*

[60] The Pentagon Papers, Chapter 2, 'U.S. Involvement in the Franco-Viet Minh War, 1950-1954', U.S. POLICY AND THE BAO DAI REGIME (ស្រង់ប្រភពៈ ១៤ សីហា ២០២០), https://bit.ly/33WXKCb

*តំណាងរបស់សាធារណរដ្ឋបារាំង លើផ្នែកវប្បធម៌ ការទូត យោធា សេដ្ឋកិច្ច ហិរញ្ញវត្ថុ និងបច្ចេកទេស ។*[61]

**ហូ ជី មិញ ថ្កោលទោស បាវ ដាយ និង បារាំង៖**

បន្ទាប់ពី«សន្ធិសញ្ញាឆកសមុទ្រហាឡុង» បានចេញជាផ្លូវការ រដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ដែលដឹកនាំដោយ ហូ ជី មិញ បានប្រកាសថ្កោលទោសរដ្ឋាភិបាលកណ្ដាលបណ្ដោះអាសន្នវៀតណាម ដែលបានបង្កើតដោយ បាវ ដាយ ថា នោះគ្រាន់តែជារដ្ឋាភិបាលអាយ៉ងដែលបានបង្កើតឡើងដោយបារាំងតែប៉ុណ្ណោះ ។

នៅថ្ងៃទី ៧ ខែមិថុនា ឆ្នាំ ១៩៤៨ ហូ ជី មិញ បានថ្លែងថ្កោលទោស បាវ ដាយ និង បារាំងអំពីសន្ធិសញ្ញានេះ ហើយត្រូវបាន «កាសែតការពិត» (Báo Sự Thật) របស់យៀកមិញ យកទៅចុះផ្សាយនៅថ្ងៃទី ១៩ មិថុនា ១៩៤៨ មានសេចក្ដីថា៖

*“ថ្ងៃនេះ អាណានិគមបារាំងបានបង្កើតរដ្ឋាភិបាលអាយ៉ងមួយសម្រាប់គ្រប់គ្រងទូទាំងប្រទេសក្នុងមហិច្ឆតាជួញដូរនូវមាតុភូមិវៀតណាមរបស់យើង ។ រដ្ឋាភិបាល និងប្រជាជនវៀតណាម នឹងយកច្បាប់របស់រដ្ឋមកពិន័យជនក្បត់ជាតិទាំងនោះ ។ សម្រាប់ប្រទេសទាំងឡាយនៅក្នុងពិភពលោក ខ្ញុំតំណាងរដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម សូមប្រកាសជាឱឡារិកថា នឹងមិនទទួលស្គាល់នូវលិខិតអ្វីមួយ ដែលក្រុមអាយ៉ងនោះ បានចុះកិច្ចព្រមព្រៀងជាមួយនឹងប្រទេសណាមួយជាដាច់ខាត” ។*[62]

**ព្រះរាជាខ្មែរតវ៉ា៖**

បន្ទាប់ពីសេចក្ដីថ្លែងការណ៍រួមនេះបានចេញផ្សាយជាផ្លូវការ ព្រះរាជាខ្មែរ ព្រះបាទនរោត្តម សីហនុ បានធ្វើសេចក្ដីតវ៉ាមួយតាមព្រះរាជសារ ចុះថ្ងៃទី ១៨ ខែមិថុនា ឆ្នាំ ១៩៤៨ អំពីការដែលបារាំងមានបំណងភ្ជាប់ទឹកដីកម្ពុជាក្រោម ជាមួយនឹងវៀតណាម

[61] Le Texte Officiel De L'accord De La Baie D'along (ឯកសារជាផ្លូវការនៃសន្ធិសញ្ញាឆកសមុទ្រហាឡុង), (០៩ មិថុនា ១៩៤៨), Le Monde, (ស្រង់ប្រភព៖ ១៦ មិថុនា ២០២០), https://bit.ly/3iMkglp

[62] Báo Sự thật, (ការពិត), កាសែតរបស់យៀកមិញជាភាសាយួន, លេខ ៩៥, ចេញផ្សាយថ្ងៃទី ១៩ មិថុនា ១៩៤៨

នេះ (*ឯកសារកម្ពុជានៅក្នុងអង្គការសហប្រជាជាតិ*) ។ [63]

ក្រោយមក បាវ ដាយ បានដកខ្លួនចេញពីនយោបាយ និងបានគេចទៅអឺរ៉ុបម្តងទៀត ។ នៅថ្ងៃទី ២៥ ខែសីហា ឆ្នាំ ១៩៤៨ បាវ ដាយ បានផ្តល់ដំណឹងដល់ស្នងការជាន់ខ្ពស់ឥណ្ឌូចិន បូលឡាអែរត៍ ថា លោកនឹងមិនវិលត្រឡប់ចូលវៀតណាមទៀតឡើយ ប្រសិនបើបារាំង មិនព្រមលុបចេញនូវរបបអាណានិគមនៅណាមគី (Nam Kỳ) និងមិនព្រមប្រគល់ទឹកដីណាមគី គឺ ទឹកដីកម្ពុជាក្រោម ឲ្យទៅវៀតណាម ទេនោះ ។ម្យ៉ាងទៀត បាវ ដាយ បានអះអាងថា ប្រសិនបើលោកមិនទទួលបាននូវការធានាណាមួយពីបារាំងថានឹងប្រគល់ "ឯករាជ្យ" ឲ្យវៀតណាម នោះទេ លោកនឹងមិនវិលចូលស្រុកឡើយ ។ [64]

**កិច្ចព្រមព្រៀងរវាង វ៉ាំងសង់ អូរីយ៉ូល និង បាវ ដាយ មុនពេលរដ្ឋសភាបារាំងអនុម័តផ្ទេរទឹកដីកម្ពុជាក្រោមឲ្យទៅយួនៈ**

ដើម្បីអនុវត្តនូវផែនការ«ដំណោះស្រាយ បាវ ដាយ» ប្រធានាធិបតីបារាំង វ៉ាំងសង់ អូរីយ៉ូល (Vincent Auriol) និង បាវ ដាយ បានចុះកិច្ចព្រមព្រៀងមួយហៅថា «កិច្ចព្រមព្រៀងអេលីសេ» (Accords de l'Elysée) នៅថ្ងៃទី ៨ ខែមីនា ឆ្នាំ ១៩៤៩ នាវិមានប្រធានាធិបតីអេលីសេ (Palais de l'Élysée) ដែលមានទីតាំងនៅទីក្រុងប៉ារីស ។ តាមរយៈកិច្ចព្រមព្រៀងនេះ បារាំងបានយល់ព្រមផ្ទេរអំណាចរដ្ឋបាល និងទទួលស្គាល់នូវ "រដ្ឋវៀតណាម" ថាជាប្រទេសមួយដែលមានឯករាជ្យនៅក្នុងសហភាពបារាំង ដោយមាន បាវ ដាយ ជាប្រមុខរដ្ឋ ។ នៅក្នុងកិច្ចព្រមព្រៀងនេះដែរ បារាំងមិនជំទាស់នូវការភ្ជាប់ទឹកដីកម្ពុជាក្រោមដែលយួនហៅថាណាមគី ជាមួយនឹងទឹកដីវៀតណាមឡើយ តែការភ្ជាប់នោះ ត្រូវតែស្របតាមរដ្ឋធម្មនុញ្ញនៃប្រទេសបារាំង ដោយតម្រូវឲ្យមានការធ្វើប្រជាមតិមួយទៅលើប្រជាជនដែលពាក់ព័ន្ធ ឬ អ្នកតំណាងរបស់ពួកគេ ។

កិច្ចព្រមព្រៀងអេលីសេ (Elysée Agreement) មាន ៣ ចំណុចធំៗ គឺៈ

**ទីមួយៈ** សារលិខិតរបស់ប្រធានាធិបតីបារាំង និងប្រធានសហភាពបារាំង ផ្ញើជូន

[63] ត្រាំងនាត ប៊ុត, កម្ពុជាក្រោម អំណាចគ្មានខ្មែរក្រោម, ទំព័រ ២៦៥

[64] Why Vietnam, Archimedes L.A Patti, Nhà Xuất bản Đà Nẵng, 2008, ទំព័រ ៦៥០

ចំពោះ បាវ ដាយ និយាយអំពីនីតិវិធីក្នុងការភ្ជាប់ទឹកដីកម្ពុជាក្រោម ជាមួយនឹងរដ្ឋពីរផ្សេងទៀតនៃប្រទេសវៀតណាមគឺ តុងកឹង និងអណ្ណាម ដូចអ្វីមួយដែលយួនហៅថា "ឯកភាពទឹកដី" ។ សារលិខិតនេះ ក៏និយាយអំពី ការទូត តុលាការ អំណាចអធិបតេយ្យផ្ទៃក្នុង វប្បធម៌ យោធា សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃប្រទេសវៀតណាមនៅក្នុងក្របខណ្ឌនៃសហភាពបារាំង ផងដែរ ។

**ទីពីរ៖** សារលិខិតរបស់ បាវ ដាយ ផ្ញើជូនចំពោះប្រធានាធិបតីបារាំង និងប្រធានសហភាពបារាំងថា ខ្លួនបានទទួលស្គាល់ និងបានទទួលយក ព្រមទាំងបានយល់ព្រមចំពោះលក្ខខណ្ឌរបស់សារលិខិតខាងលើ ។

**ទីបី៖** សារលិខិតរបស់ប្រធានាធិបតីបារាំង ផ្ញើជូនចំពោះ បាវ ដាយ ដោយបានបំពេញបន្ថែមតាមសំណើរបស់ បាវ ដាយ ទាក់ទងនឹងបញ្ហាភ្ជាប់ទឹកដីកម្ពុជាក្រោម ជាមួយនឹងប្រទេសវៀតណាមដែលយួនហៅថា «ឯកភាពទឹកដី» និងបញ្ហាទំនាក់ទំនងការបរទេស ជាពិសេស ការផ្លាស់ប្តូរមន្ត្រីការទូត ។ [65]

យោងតាមសារលិខិតរបស់ប្រធានាធិបតីបារាំង វ៉ាំងសង់ អារីយ៉ូល ដែលបានចុះហត្ថលេខាជាមួយនឹង បាវ ដាយ នៅក្នុងកិច្ចព្រមព្រៀងអេលីសេនេះ ត្រង់ចំណុចទីមួយស្តីពី «ឯកភាពទឹកដី» បានបញ្ជាក់អំពីការភ្ជាប់ទឹកដីកម្ពុជាក្រោម ជាមួយនឹងរដ្ឋពីរផ្សេងទៀត នៃប្រទេសវៀតណាមថា៖

> *" ទោះបីសន្ធិសញ្ញាពីមុននៅតែមានសុពលភាពក្តី ប្រទេសបារាំងសូមបញ្ជាក់ឡើងវិញនូវសេចក្តីសម្រេចរបស់ខ្លួនជាឱឡារិកថា មិនថាតាមរយៈច្បាប់ ឬតាមភាពជាក់ស្តែងទេ [បារាំង] នឹងមិនរារាំងដោយប្រការណាមួយចំពោះការដែលទឹកដីកូសាំងស៊ីន [កម្ពុជាក្រោម] ត្រូវភ្ជាប់ជាមួយនឹងប្រទេសវៀតណាមឡើយ ។ វាត្រូវបានកំណត់ដោយ ការរួបរួមនូវទឹកដីទាំងបីតំបន់គឺ តុងកឹង (ភាគខាងជើង) អណ្ណាម (ភាគកណ្តាល) និង កូសាំងស៊ីន (ភាគខាងត្បូង) [កម្ពុជាក្រោម] ។*

[65] Bảo Đại, Con Rồng Việt Nam (កូនទាគវៀតណាម), Hồi Ky Chánh Trị 1913 –1987 (កំណត់ហេតុនយោបាយ ១៩១៣ - ១៩៨៧), Nguyễn Phước Tộc Xuất Bản, 1990, ទំព័រ ៣៤២

*ប៉ុន្តែការភ្ជាប់នូវទឹកដីកូសាំងស៊ីនជាមួយនឹងទឹកដីឯទៀតរបស់វៀតណាមនោះ អាចប្រព្រឹត្តទៅបានទាល់តែធ្វើឡើងនៅក្នុងក្របខណ្ឌច្បាប់ ដោយឆ្លងកាត់ការធ្វើប្រជាមតិមួយចំពោះប្រជាជនដែលពាក់ព័ន្ធ ឬដោយតំណាងរបស់ពួកគេ”។*[66]

នៅថ្ងៃទី ២៥ ខែមេសា ឆ្នាំ ១៩៤៩ សម្តេច **នរោត្តម សីហនុ** នៃប្រទេសកម្ពុជា បានបញ្ជូនប្រតិភូមួយក្រុម ដឹកនាំដោយ លោក **សឺន សាន** ទៅទីក្រុងប៉ារីស ដើម្បីជំទាស់នឹងសហភាពបារាំងឲ្យផ្អាកការសម្រេចចិត្តរបស់រដ្ឋសភាបារាំង ដែលបានយល់ព្រមប្រគល់ទឹកដីកម្ពុជាក្រោមឲ្យទៅវៀតណាមនោះ ។ តែការតវ៉ានោះ មិនត្រូវបានរដ្ឋាភិបាលបារាំងធ្វើតាមឡើយ ។ [67]

## ហូ ជី មិញ ចោទ បាវ ដាយ ថា ជាជនក្បត់ជាតិ៖

ពេលបានទទួលដំណឹងថា បារាំងបានប្រគល់ «ឯករាជ្យ» និង «ឯកភាពទឹកដី» ឲ្យទៅបាវ ដាយ នោះ ហូ ជី មិញ បានថ្កោលទោស បាវ ដាយ ថាជាជនក្បត់ជាតិ ព្រោះថា ហូ ជី មិញ ខ្លួនគាត់ផ្ទាល់ ខំប្រឹងតស៊ូយ៉ាងស្វិតស្វាញនៅក្នុងព្រៃច្បាំងជាមួយនឹងបារាំង ដើម្បីបានទទួលនូវ «ឯករាជ្យ» និង «ឯកភាពទឹកដី» នេះ តែបារាំងមិនព្រមផ្តល់ឲ្យគាត់ បែរជាផ្តល់ឲ្យ បាវ ដាយ ទៅវិញ ។ ឆ្លើយតបនឹងសំណួររបស់អ្នកកាសែតជប៉ុន នៅថ្ងៃទី ៣ ខែមេសា ឆ្នាំ ១៩៤៩ ហូ ជី មិញ បានបញ្ជាក់អំពីកិច្ចព្រមព្រៀងរវាងវ៉ាំងសង់ អារីយ៉ូល និង បាវ ដាយ យ៉ាងនេះថា៖

*“សម្រាប់ប្រជាជនវៀតណាម នោះគ្រាន់តែជាក្រដាសមួយសន្លឹកដែលច្រឡំ ។ អ្វីដែលគេហៅថា ឯកភាពទឹកដី និងឯករាជ្យក្លែងក្លាយនោះ វាមិនអាចបោកប្រាស់ គេបានទៀតទេ ។ សូម្បីតែប្រជាជន*

---

[66] Nguyễn Quốc Vĩ, (១៦ មិថុនា ២០១៤), Hiệp định Pháp-Việt ngày 8 tháng 3 năm 1949 (កិច្ចព្រមព្រៀង បារាំង - យួន ថ្ងៃទី ៨ ខែមីនា ឆ្នាំ ១៩៤៩), Nghiên Cứu Lịch Sử, (ស្រង់ប្រភព៖ ២១ សីហា ២០២០), https://bit.ly/3aIN7ED ។ ស្រង់ចេញពីសារលិខិត (អត្ថបទប្រែសម្រួលជាភាសាយួន) ដែលប្រធានាធិបតីបារាំង វ៉ាំងសង់ អារីយ៉ូល ចុះហត្ថលេខាជាមួយនឹង បាវ ដាយ នៅក្នុង “កិច្ចព្រមព្រៀង Elysée ” ។ សារលិខិតជាភាសាអង់គ្លេស ដែលមានចំណងជើងថា “Franco-Vietnamese Agreement on March 8, 1949” មានរក្សាទុកនៅក្នុងបណ្ណាល័យ នៃ សកលវិទ្យាល័យជាតិ សាន ឌីអេហ្គោ (San Diego State University) រដ្ឋ California សហរដ្ឋអាមេរិក ដោយមានលេខកូដ CU17881072 ។

[67] សហព័ន្ធខ្មែរកម្ពុជាក្រោម, សៀវភៅមគ្គុទ្ទេសក៏ ផ្លូវទៅយកសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង, បោះពុម្ពឆ្នាំ ២០០៩

*បារាំង និងមជ្ឈដ្ឋានពិភពលោក ក៏បានយល់ និងបានថ្កោលទោសចំពោះទង្វើនេះដែរ ។ ពេលណាអាណានិគមបារាំងបានដកទាហានចេញអស់ពីទឹកដីវៀតណាម ពេលនោះ ទើបបានឯកភាពទឹកដី និង ឯករាជ្យ ។*

*វិញ ទៃ [បាវ ដាយ] ធ្វើជាអាយ៉ងរបស់អាណានិគម គឺជាជនក្បត់ជាតិ ។ ច្បាប់របស់វៀតណាម ទោះបីលើកលែងទោសដល់មនុស្សដែលចេះកែកំហុស តែនឹងពិន័យទោសយ៉ាងម៉ឺងម៉ាត់ចំពោះបុគ្គលទាំងឡាយណា មានឈ្មោះជាឃួនទុច្ចរិត ដែលបានលក់ជាតិ និងធ្វើស្រែលើខ្នងរាស្ត្រ"* ។ [68]

សម្រាប់ បាវ ដាយ វិញ បានចាត់ទុក «កិច្ចព្រមព្រៀងអេលីសេ» ថាជាជោគជ័យមួយដ៏ធំធេងដែលខ្លួនបាននាំមកនូវ «ឯករាជ្យ» និង «ឯកភាពទឹកដី» តាមរយៈការចរចា និងទាមទារឲ្យបារាំងកាត់ទឹកដី កម្ពុជាក្រោម ភ្ជាប់ជាមួយនឹងទឹកដីនៃប្រទេសវៀតណាមឡើងវិញ ។

*"ចាប់ពីពេលនេះទៅ សន្ធិសញ្ញានេះនឹងជំនួសឲ្យសន្ធិសញ្ញាទាំងឡាយដែលដូនតារបស់ខ្ញុំ បានចុះហត្ថលេខា [ជាមួយនឹងបារាំង] និងខ្ញុំសូមបញ្ជាក់ថា ខ្ញុំនឹងឈានជើងមកជាន់លើទឹកដីរបស់ខ្ញុំ ។ រួមរស់ជាមួយនឹងប្រជាជនរបស់ខ្ញុំ ដែលមានទឹកដី និងព្រំដែនជាប្រវត្តិសាស្ត្រ ។ ខ្ញុំសន្យាធានាថា នឹងនាំមកនូវផលប្រយោជន៍សម្ភារៈ និងវប្បធម៌បារាំង...។*

*...ចាប់ពីថ្ងៃនេះតទៅ ខ្ញុំបានដណ្ដើមយកមកវិញ (Thu hồi) នូវទឹកដីណាមគី [កម្ពុជាក្រោម] ។ ខ្ញុំមើលឃើញថា ភារកិច្ចរបស់ខ្ញុំអំពីការចរចាបានចប់ហើយ ។ នៅក្នុងដំណាក់កាលថ្មីនេះ ជាភារកិច្ចរបស់ខ្ញុំក្នុងការកសាងប្រទេសវៀតណាមឡើងវិញ ។ កិច្ចព្រមព្រៀង ថ្ងៃទី ៨ មីនា បានទទួលផលចំណេញមួយយ៉ាងធំធេង គឺ [យើង] នៅតែរក្សា*

[68] គេហទំព័រ គណៈកម្មការគ្រប់គ្រងផ្ទះ ហូ ជី មិញ, បទសម្ភាសន៍ដែល ហូ ជី មិញ ឆ្លើយតបនឹងសារព័ត៌មាន (ភាគ ៤), (ស្រង់ប្រភព៖ ១៩ សីហា ២០២០), https://bit.ly/3l0gpTU

*បាននូវទំនាក់ទំនងជាមួយនឹង ប្រទេសបារាំង” តែបញ្ហាលម្អិតទាំងឡាយ សម្រាប់ខ្ញុំ មិនចាំបាច់ដឹងឮឡើយ ។ ប្រសិនបើខ្ញុំយល់ព្រមចូលជាសហភាពបារាំង វាគ្មានអ្វីទាក់ទងនឹងការណ៍នេះច្រើននោះទេ ។ វាគ្រាន់តែជាហេតុផលមួយសម្រាប់ផ្លូវវែងឆ្ងាយតែប៉ុណ្ណោះ ។...ម្យ៉ាងទៀត សន្ធិសញ្ញានេះ នៅចំពោះមុខខ្ញុំ គ្រាន់តែជាដំណាក់កាលមួយដើម្បីឆ្ពោះទៅយកឯករាជ្យទាំងស្រុង ។ គំរូជោគជ័យ នៃការបានទទួលឯករាជ្យបែបនេះ ធ្លាប់បានកើតឡើងសម្រាប់ប្រទេសជិតខាងនៅតំបន់អាស៊ីអាគ្នេយ៍រួចមកហើយ ដូចជា ហ្វីលីពីន ភូមា និង ឥណ្ឌា... បានធ្វើឲ្យខ្ញុំកាន់តែមានជំនឿ នៅក្នុងក្តីសង្ឃឹម ។ ខ្ញុំជឿជាក់ថា សន្ធិសញ្ញាថ្ងៃទី ៨ មីនា គឺជាមូលហេតុដ៏សំខាន់មួយក្នុងការនាំមកនូវសន្តិភាពជានិរន្តរ៍ ។ សូមសួរទៅយៀកមិញថា នៅចង់បានអ្វីទៀត ពេលដែលខ្ញុំបានទទួលជោគជ័យ ខណៈដែលពួកគេត្រូវបរាជ័យយ៉ាងអាម៉ាស់នៅក្នុងសន្និសីទ Fontainebleau និងដាឡាក ក្នុងឆ្នាំ ១៩៤៦” ។* [69]

កិច្ចព្រមព្រៀង Élysée ឆ្នាំ ១៩៤៩ នេះ ហាក់ដូចជាសន្ធិសញ្ញាមួយ ដើម្បីស្រាយនូវចំណង “សន្ធិសញ្ញាទីក្រុងហ្វេ” (Treaty of Huế) ឆ្នាំ ១៨៨៤ ដែលបារាំងបានចងយួនឲ្យយល់ព្រមដាក់ប្រទេសអណ្ណាមនៅក្រោមអាណាព្យាបាលរបស់បារាំង នៅក្នុងសម័យស្តេចយួន កៀង ផុក (Kiến Phúc) (រជ្ជកាលៈ ១៨៨៣ - ១៨៨៤) ។ “សន្ធិសញ្ញាទីក្រុងហ្វេ” ជាកិច្ចព្រមព្រៀងដែលបារាំងបានបង្ខំឲ្យមន្ត្រីយួនចុះហត្ថលេខា នៅទីក្រុងហ្វេ ថ្ងៃទី ៦ ខែមិថុនា ឆ្នាំ ១៨៨៤ ដើម្បីធ្វើអាណាព្យាបាលទាំងស្រុងលើទឹកដីភាគកណ្តាល និងភាគខាងជើង នៃប្រទេសអណ្ណាម (An Nam) (70) ។ [71]

យោងតាម សន្ធិសញ្ញា ឆ្នាំ ១៨៨៤ ឃើញថា នៅក្នុងសម័យនោះ យួនបានយល់ព្រមនៅក្រោមអាណាព្យាបាលបារាំងនៅក្នុងប្រទេសមួយដែលមានផ្ទៃដីគ្របដណ្តប់ពី

[69] Bảo Đại, Con Rồng Việt Nam: ទំព័រ ៣៤២-៣៤៤

[70] អណ្ណាម (An Nam, 安南 ) ជាឈ្មោះនិយមប្រើសម្រាប់ហៅប្រទេសវៀតណាម ចាប់ពីឆ្នាំ ៦៧៩ ដល់ ១៩៤៥ ។

[71] French Extend Influence in Indochina. (២១ កក្កដា ២០១១). Internet Archive. (ស្រង់ប្រភពៈ ២១ សីហា ២០២០), https://bit.ly/3gdi8la

ខេត្តបិនទ្វឹង (Bình Thuận) ឡើងទៅភាគខាងជើងតែប៉ុណ្ណោះ មានន័យថា យួនបាន ទទួលស្គាល់ទឹកដីរបស់ខ្លួនមានតែពីរតំបន់ទេ គឺ តុងកឹង (ភាគខាងជើង) និងអណ្ណាម (ភាគកណ្តាល) ជាទឹកដីដែលយួនបានដណ្តើមយកពីជនជាតិចាម្ប៉ ។ រីឯ កូស័ងស៊ីន ឬ កម្ពុជាក្រោម ជាទឹកដីរបស់ខ្មែរដែលត្រូវយួនចូលវាតទីកាន់កាប់អស់មួយរយៈ ទើប ក្រោយមក បារាំងបានចូលមកវាយដណ្តើមយកពីយួនកាន់កាប់បន្តនៅឆ្នាំ ១៨៥៩ ។ បារាំងចាត់ទុកកម្ពុជាក្រោម ជាដែនដីឯនាយសមុទ្ររបស់ខ្លួន បន្ទាប់ពី ស្តេចយួន ទី ឌឹក បានចុះសន្ធិសញ្ញាប្រគល់ឲ្យបារាំងទាំងស្រុងនៅឆ្នាំ ១៨៧៤ ។

**បារាំងប្រគល់ ដែនដីកម្ពុជាក្រោម ឲ្យទៅ បាវ ដាយ ឆ្នាំ ១៩៤៩៖**

នៅថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ១៩៤៩ បារាំងបានប្រកាសច្បាប់មួយ ភ្ជាប់កម្ពុជាក្រោម ឲ្យជាប់ជាមួយនឹងទឹកដីរបស់យួនទាំងពីរតំបន់ឯទៀត រួមមាន តុងកឹង (ខាងជើង) និង អណ្ណាម(កណ្តាល) ឲ្យរួបរួមបញ្ចូលគ្នាជាទឹកដីរបស់យួនតែមួយ ឬបើនិយាយឲ្យចំទៅ “បារាំងបានកាត់ទឹកដីកម្ពុជាក្រោមប្រគល់យួន” ដោយគ្មានការដឹងឮពីខ្មែរក្រោម ដែល ជាម្ចាស់ស្រុកឡើយ ។ ច្បាប់នេះបានចូលជាធរមាននៅថ្ងៃ ទី ១៤ ខែមិថុនា ហើយ រដ្ឋាភិបាល “រដ្ឋវៀតណាម” ដែល បាវ ដាយ បានបង្កើតជាបណ្តោះអាសន្នពីមុននោះ ត្រូវបានប្រកាសជាផ្លូវការនៅថ្ងៃទី ២ ខែកក្កដា ដោយមាន បាវ ដាយ ធ្វើជាប្រមុខរដ្ឋ ។ បន្ទាប់ពីបារាំងបានប្រគល់ទឹកដីកម្ពុជាក្រោមឲ្យទៅ បាវ ដាយ ហើយ បារាំងមិនបាន ប្រគល់ឯករាជ្យពេញលេញទាំងស្រុងដល់ បាវ ដាយ ទេ គ្រាន់តែប្រគល់ស្វ័យភាពខ្លះ តែប៉ុណ្ណោះ ។ រដ្ឋាភិបាល “រដ្ឋវៀតណាម” របស់ បាវ ដាយ នៅតែជាប្រទេសមួយ ដែលនៅក្រោមអាណាព្យាបាលបារាំង (Associated State) ឋិតនៅក្នុងក្របខ័ណ្ឌ សហភាពបារាំងដដែល ។ ក្នុងឋានៈជាប្រមុខរដ្ឋនៃរដ្ឋាភិបាលថ្មីមួយនេះ បាវ ដាយ បាន ខិតខំតស៊ូធ្វើសង្គ្រាមប្រឆាំងនឹងមេកុម្មុយនីស្ត ហូ ជី មិញ ដល់ទីបញ្ចប់ ដើម្បីដណ្តើម យកនូវភាពស្របច្បាប់របស់រដ្ឋាភិបាលវៀតណាម នៅក្នុងសង្គ្រាមឥណ្ឌូចិនលើកទី ១ ឬ សង្គ្រាមរវាងបារាំង និងយៀកមិញ ។ “រដ្ឋវៀតណាម” របស់ បាវ ដាយ បានការគាំទ្រ ដោយរដ្ឋាភិបាលបារាំង និងសហរដ្ឋអាមេរិក (១៩៥០-១៩៥៤) ខណៈដែល “រដ្ឋាភិបាល

សាធារណរដ្ឋប្រជាធិបតេយ្យ” របស់ ហូ ជី មិញ បានការគាំទ្រ និងផ្តល់ជំនួយដោយរដ្ឋាភិបាលចិនកុម្មុយនីស្ត (ចាប់ពីឆ្នាំ ១៩៥០) និងដោយសហភាពសូវៀត ។ ទោះបី បាវ ដាយ មានការគាំទ្រដោយបារាំងយ៉ាងណាក៏ដោយ តែ ៦០% នៃរដ្ឋបាលទូទាំងប្រទេសវៀតណាម ត្រូវឋិតនៅក្រោមការកាន់កាប់ដោយទ័ពព្រៃយៀកមិញ នៅក្នុងឆ្នាំ ១៩៥២ ។ បន្ទាប់ពីសន្និសីទអន្តរជាតិនៅទីក្រុងហ្សឺណែវ ឆ្នាំ ១៩៥៤ វៀតណាមបានទទួលឯករាជ្យពេញលេញ តែត្រូវពុះប្រទេសចេញជាពីរគឺ ចាប់ពីខ្សែស្របទី ១៧ ចុះមកភាគត្បូងគ្របដណ្តប់លើទឹកដីកម្ពុជាក្រោម គ្រប់គ្រងដោយ រដ្ឋវៀតណាម ដឹកនាំដោយ បាវ ដាយ និងចាប់ពីខ្សែស្របទី ១៧ ឡើងទៅភាគខាងជើង កាន់កាប់ដោយរដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ដឹកនាំដោយ ហូ ជី មិញ ។ នៅឆ្នាំ ១៩៥៥ ង៉ោ ឌិញ យេម (Ngô Đình Diệm) ជានាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាល “រដ្ឋវៀតណាម” បានធ្វើប្រជាមតិមួយដក បាវ ដាយ ចេញពីប្រមុខរដ្ឋ ហើយបានបង្កើតជារដ្ឋាភិបាលថ្មីមួយទៀតឈ្មោះថា “សាធារណរដ្ឋវៀតណាម” (Việt Nam Cộng hòa) ។ [72] បាវ ដាយ បានបញ្ចប់ជីវិតនយោបាយ ត្រឹមនេះ ហើយបាននិរទេសខ្លួនទៅនៅបារាំងរហូតដល់ថ្ងៃស្លាប់នៅក្នុងឆ្នាំ ១៩៩៧ ក្នុងជន្មាយុ ៨៣ ឆ្នាំ ។ [73]

**នីតិវិធីនៃការប្រគល់ ទឹកដីកម្ពុជាក្រោម ឲ្យ បាវ ដាយ៖**

ដើម្បីធ្វើឲ្យស្របច្បាប់ក្នុងការប្រគល់ទឹកដីកូស័ងស៊ីន ឬ កម្ពុជាក្រោម ឲ្យទៅរដ្ឋាភិបាលរបស់ បាវ ដាយ នោះ សភាបារាំងត្រូវអនុវត្តទៅតាមនីតិវិធី ដូចខាងក្រោម៖

**ទីមួយ** សភាបារាំងត្រូវអនុម័តច្បាប់មួយ ដើម្បីបង្កើតជា “សភាដែនដីកូស័ងស៊ីន” ឲ្យស្របទៅតាមមាត្រាទី ៧៧ នៃរដ្ឋធម្មនុញ្ញរបស់បារាំង ។ សភាដែនដីកូស័ងស៊ីន (Assemblée Territoriale de la Cochinchine) មានករណីយកិច្ចផ្តល់ ឬបញ្ចេញយោបល់អំពីការផ្លាស់ប្តូរលក្ខន្តិកៈនៅដែនដីកូស័ងស៊ីន គឺ ការភ្ជាប់ដែនដីកូស័ងស៊ីន ឲ្យជាប់ជាមួយនឹងទឹកដីរបស់វៀតណាម ។

**ទីពីរ** សភាបារាំង ដែលក្នុងនោះរួមមាន សភាសហភាពបារាំង (Assemblée de

[72] State of Vietnam (រដ្ឋវៀតណាម), (១៦ សីហា ២០២០), Wikipedia ។ www.en.wikipedia.org/wiki/State_of_Vietnam

[73] Bảo Đại, (១៣ សីហា ២០២០), Wikipedia ។ https://bit.ly/2YAl3yq

l'Union Française) រដ្ឋសភា (Assemblée Nationale) និងក្រុមប្រឹក្សាសាធារណរដ្ឋ (Conseil de le République) ត្រូវអនុម័តច្បាប់មួយដោយយោងតាមយោបល់របស់សភាដែនដីកូស័ងស៊ីន ដើម្បីឲ្យស្របទៅតាមមាត្រាទី ៧៥ នៃរដ្ឋធម្មនុញ្ញបារាំង ។[74]

**ការបង្កើត សភាដែនដីកូស័ងស៊ីនៈ**

នៅថ្ងៃទី ១២ ខែមីនា ឆ្នាំ ១៩៤៩ រដ្ឋសភាបារាំង បានបោះឆ្នោតដោយមាន ៣៣៩ សំឡេងគាំទ្រ និង ២០១ សំឡេងប្រឆាំង សម្រេចអនុម័តច្បាប់មួយស្តីពីការបង្កើតសភាដែនដីកូស័ងស៊ីន ដែលសភានេះមានតួនាទីក្នុងការបោះឆ្នោត ដើម្បីផ្លាស់ប្តូរនូវលក្ខន្តិកៈ ឬស្ថានភាពនៃដែនដីកូស័ងស៊ីនក្នុងការភ្ជាប់ទឹកដីកម្ពុជាក្រោមទៅជារដ្ឋចំណុះវៀតណាម ឬដោយការជ្រើសរើសនូវលក្ខន្តិកៈដទៃទៀតឋិតនៅក្នុងក្របខ័ណ្ឌសហភាពបារាំង ។[75]

បន្ទាប់ពីបានអនុម័តបានពីរថ្ងៃរួច នៅថ្ងៃទី ១៤ ខែមីនា ប្រធានាធិបតីបារាំង វ៉ាំងសង់ អារីយ៉ូល (Vincent Auriol) នាយករដ្ឋមន្ត្រីបារាំង អង់រីកើយ (Henri Queuille) និងរដ្ឋមន្ត្រីទឹកដីបារាំងឯនាយសមុទ្រ ប៉ូល កូស្ត ផ្លរេត៍ (Paul Coste-Floret) បានរួមគ្នាចុះហត្ថលេខា និងប្រកាសឲ្យប្រើច្បាប់នេះជាផ្លូវការ ។ នេះជាច្បាប់លេខ ៤៩-៣៣៩ ដែលមាន ៥ មាត្រា ស្តីពីការបង្កើតសភាតំណាងរាស្ត្រសម្រាប់ការបោះឆ្នោតនៅដែនដីកូស័ងស៊ីន ។ មាត្រា ១ នៃច្បាប់នេះ បានតម្រូវឲ្យ សភាដែនដីកូស័ងស៊ីន ត្រូវមានសមាជិកទាំងអស់ចំនួន ៦៤ នាក់ ក្នុងនោះ មានបារាំង ១៦ នាក់ និងយួន ៤៨ នាក់ ។ នៅក្នុងមាត្រា ៤ បានចែងថាៈ“*សភានេះមានករណីយកិច្ចផ្តាច់មុខក្នុងការផ្តល់យោបល់របស់ខ្លួនឲ្យស្របតាមមាត្រា ៧៥ នៃរដ្ឋធម្មនុញ្ញ [បារាំង] ស្តីពីការផ្លាស់ប្តូរលក្ខន្តិកៈ នៃទឹកដីកូស័ងស៊ីន [កម្ពុជាក្រោម] នៅក្នុងក្របខ័ណ្ឌរបស់សហភាពបារាំង ឬភ្ជាប់ជាមួយនឹងរដ្ឋចំណុះនៃប្រទេសវៀតណាម ឬក៏តាមរយៈការជ្រើសរើសលក្ខន្តិកៈដទៃទៀតដែលមានចែងក្នុងមាត្រា ៦០ នៃរដ្ឋធម្មនុញ្ញ* ។[76]

[74] ត្រាំងឆាត ប៊ុត, កម្ពុជាក្រោម អំណាចគ្មានខ្មែរក្រោម, ទំព័រ ២៦៧

[75] Ellen J. Hammer, (1967) The Struggle for Indochina, 1940-1955, California: Stanford University Press, ទំព័រ ២៤០

[76] រដ្ឋាភិបាលសាធារណរដ្ឋបារាំង, (១៥ មីនា ១៩៤៩), Journal Officiel de la République Française, ទំព័រ ២៦៤៤, (Download: ២៨ សីហា ២០២០), https://bit.ly/2G6qmiD

នៅថ្ងៃទី ១០ ខែមេសា ឆ្នាំ ១៩៤៩ សភារបស់ដែនដីកូស័ងស៊ីន បានកើតឡើងជាផ្លូវការតាមរយៈការបោះឆ្នោតមួយ នៅតាមខេត្តខណ្ឌទូទាំងដែនដីកម្ពុជាក្រោម ដើម្បីជ្រើសរើសតំណាងរាស្ត្រសម្រាប់ធ្វើការនៅក្នុងសភានេះ ។ តំណាងរាស្ត្រជាជនជាតិយួនបានក្លាយជាសមាជិកដ៏ច្រើនលើសលុបនៅក្នុងសភាថ្មីមួយនេះ ។ លទ្ធផលនៃការបោះឆ្នោត សភាដែនដីកូស័ងស៊ីន មានតំណាងរាស្ត្រជនជាតិយួនចំនួន ៥០ នាក់ និងជនជាតិបារាំងចំនួន ១៦ នាក់ ។ [77]

នៅថ្ងៃទី ២៣ ខែមេសា ដប់បីថ្ងៃបន្ទាប់ពីការបោះឆ្នោត សមាជិកសភាចំនួន ៦៣ រូប ដែលមានវត្តមាននៅក្នុងសភាដែនដីកូស័ងស៊ីន ក្នុងនោះ ៥៥ នាក់ បានបោះឆ្នោតគាំទ្រ ៦ នាក់ ជំទាស់ និង ២ នាក់ អនុប្បវាទ អនុម័តលើសេចក្ដីសម្រេចក្នុងការភ្ជាប់ទឹកដីកម្ពុជាក្រោម ឲ្យចូលជាមួយនឹងទឹកដីរបស់យួនទាំងពីរគី (Kỳ) ផ្សេងទៀត តាមអ្វីមួយដែលយួនហៅថា "ឯកភាពទឹកដីទាំងបីគី" ឲ្យរួមចូលគ្នាជាប្រទេសវៀតណាមតែមួយ ។ បន្ទាប់ពី សភាដែនដីកូស័ងស៊ីន ប្រកាសសេចក្ដីអនុម័តខាងលើ បាវ ដាយ មិនបានរង់ចាំរដ្ឋសភាបារាំងអនុវត្តតាមអនុសាសន៍របស់ខ្លួនឡើយ គាត់បានប្រញាប់ប្រញាល់ធ្វើមាតុភូមិនិវត្តន៍ នៅថ្ងៃទី ២៥ ខែមេសា ដោយស្ងាត់ៗ និងគ្មានរៀបចំពិធីស្វាគមន៍ធំដុំអ្វីនោះទេ ។ អស់រយៈពេល ៣ ឆ្នាំ និរទេសខ្លួននៅបរទេស ទីបំផុត បាវ ដាយ បានត្រឡប់ចូលស្រុកវិញ ហើយទៅស្នាក់នៅទីក្រុងដាឡាត (Đà Lạt) ជាកន្លែងកម្សាន្តមួយបិតនៅភាគកណ្ដាលនៃប្រទេសវៀតណាម ដើម្បីរង់ចាំសេចក្ដីសម្រេចចុងក្រោយរបស់សភាបារាំងក្នុងការកាត់ទឹកដីកម្ពុជាក្រោមឲ្យទៅយួន ។ [78]

រដ្ឋធម្មនុញ្ញរបស់ប្រទេសបារាំង ដែលជាប់ទាក់ទងនឹងការកាត់ទឹកដីកម្ពុជាក្រោមឲ្យទៅយួននោះ មាន ៣ មាត្រា គឺ មាត្រា ៦០, ៧៥ និង ៧៧ ។ រដ្ឋធម្មនុញ្ញនេះ ត្រូវបានអនុម័តដោយសភាធម្មនុញ្ញ មានការយល់ព្រមពីប្រជាជន និងប្រធានាធិបតីនៃរដ្ឋាភិបាលបណ្ដោះអាសន្នសាធារណរដ្ឋបារាំង ប្រកាសឲ្យប្រើជាផ្លូវការ នៅឆ្នាំ ១៩៤៦ ។ មាត្រាទាំងបីនេះ មានសេចក្ដីដូចតទៅះ

[77] Philippe Franchini, Les Guerres d'Indochine, vol. I, Pygmalion - Gérard Watelet, Paris, 1988, ទំព័រ ៣៩៥-៤០៨

[78] Ellen J. Hammer, (1967) The Struggle for Indochina, 1940-1955, California: Stanford University Press, ទំព័រ ២៤២

## TITRE VIII
De l'Union française.

## SECTION I
Principes.

### Article 60.
L'Union française est formée, d'une part, de la République française qui comprend la France métropolitaine, les départements et Territoires d'outre-mer, d'autre part des territoires et Etats associés.

## SECTION III
Des départements et Territoires d' outre-mer

### Article 75.
Les statuts respectifs des membres de la République et de l'Union française sont susceptibles d'évolution.
Les modifications de statut et les passages d'une catégorie à l'autre, dans le cadre fixé par l'article 60, nepeuvent résulter que d'une loi votée par le Parlement,
après consultation des Assemblées territoriales et de l'Assemblée de l'Union.

### Article 77.
Dans chaque territoire est instituée une Assemblée élue.
Le régime électoral, la composition et la compétence de.
cette Assemblée sont déterminés par la loi. [78]

[78] រដ្ឋាភិបាលសាធារណរដ្ឋបារាំង, (២៨ តុលា ១៩៤៦), Journal Officiel de la République Française, ទំព័រ ៩១៦៧ - ៩១៧៥, (Download: ២៨ សីហា ២០២០), https://bit.ly/32twKYA

# ជំពូក ទី ៨

## សហភាពបារាំង

ផ្នែកទី ១

គោលការណ៍

### មាត្រា ៦០

សហភាពបារាំង ត្រូវបានបង្កើតឡើងជាចំណែកមួយនៃសាធារណរដ្ឋបារាំង ដែលរួបរួមដោយប្រទេសបារាំង និងនាយកដ្ឋាននៅឯនាយសមុទ្រ និងដែនដីនៅក្រៅប្រទេស ព្រមទាំងទឹកដី និងរដ្ឋដែលជាប់ពាក់ព័ន្ធ ។

### ផ្នែកទី ៣

នាយកដ្ឋាន និង ដែនដីនៅបរទេស

### មាត្រា ៧៥

លក្ខន្តិកៈនីមួយៗរបស់សមាជិកនៃសាធារណរដ្ឋ និងសហភាពបារាំង អាចនឹងមានការផ្លាស់ប្តូរ ។

ការផ្លាស់ប្តូរលក្ខន្តិកៈ [ស្ថានភាព] និងការអនុម័តពីប្រភេទមួយទៅប្រភេទមួយទៀតនោះ ត្រូវឋិតនៅក្នុងក្របខ័ណ្ឌដែលបានកំណត់ដោយមាត្រា ៦០ ។ [ការផ្លាស់ប្តូរនេះ] អាចកើតឡើងបានទាល់តែមានច្បាប់មួយដែលបានអនុម័តដោយរដ្ឋសភា បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសភាដែនដី និងសភាសហភាព ។

### មាត្រា ៧៧

នៅក្នុងដែនដីនីមួយៗ ត្រូវបង្កើតឲ្យមានសភាបោះឆ្នោតមួយ ។

ប្រព័ន្ធបោះឆ្នោត សមសភាព និងអំណាចនៃរដ្ឋសភានេះ ត្រូវតែកំណត់ដោយច្បាប់ ។ [79]

[79] សេចក្តីប្រែសម្រួលក្រៅផ្លូវការ មាត្រា ៦០, ៧៥ និង ៧៧ នៃ រដ្ឋធម្មនុញ្ញប្រទេសបារាំង ឆ្នាំ ១៩៤៦

## គម្រោងច្បាប់ភ្ជាប់ទឹកដីកម្ពុជាក្រោមទៅវៀតណាមៈ

មុនពេលបារាំងអនុម័ត និងប្រកាសជាផ្លូវការនូវច្បាប់លេខ ៤៩-៧៣៣ ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ១៩៤៩ ក្នុងការប្រគល់ទឹកដីកម្ពុជាក្រោមឲ្យទៅយួននោះ សភាបារាំងទាំងបី រួមមាន សភាសហភាព រដ្ឋសភានៃក្រុមប្រឹក្សាសាធារណរដ្ឋ និងរដ្ឋសភា ព្រមទាំង គណៈកម្មការដែនដីបារាំងឯនាយសមុទ្រ បានជជែកដេញដោលគ្នាលើគម្រោងច្បាប់នេះតែប៉ុន្មានលើកប៉ុណ្ណោះ ។ គម្រោងច្បាប់នេះ មានការកែប្រែបន្តិចបន្តួចដោយសារមានការតវ៉ាពីប្រតិភូនៃប្រទេសកម្ពុជា និងតំណាងរាស្ត្របារាំងខ្លះដែលពួកគេជួយការពារផលប្រយោជន៍របស់កម្ពុជា និងផលប្រយោជន៍ខ្មែរនៅកម្ពុជាក្រោម ។

នៅថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ១៩៤៩ លោក អង់រីកឹយ ជានាយកដ្ឋមន្ត្រីបារាំង និងលោក ប៉ូល កូស្ត ផ្លរេត៍ ជារដ្ឋមន្ត្រីទឹកដីបារាំងឯនាយសមុទ្រ បានដាក់ជូនរដ្ឋសភាបារាំងដើម្បីពិនិត្យនូវគម្រោងច្បាប់ “ភ្ជាប់ទឹកដីកូស័ងស៊ីនទៅវៀតណាម” ។ ច្បាប់ព្រាងនេះមាន ៣ មាត្រាៈ

**មាត្រា ១.** – ក្នុងក្របខណ្ឌមាត្រា ៦០ នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋបារាំង និងតាមមតិរបស់ សភាដែនដីកូស័ងស៊ីន នាសម័យប្រជុំកាលពីថ្ងៃទី ២៣ ខែមេសា ឆ្នាំ ១៩៤៩ លក្ខន្តិកៈទឹកដីកូស័ងស៊ីន បានត្រូវកែប្រែតាមមាត្រា ដូចមានចែងខាងក្រោម ។

**មាត្រា ២.** – ទឹកដីកូស័ងស៊ីនត្រូវបានភ្ជាប់ទៅជារដ្ឋចំណុះវៀតណាម យោងតាមសេចក្តីប្រកាសរួមកាលពីថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ ១៩៤៨ និងសេចក្តីប្រកាសរបស់រដ្ឋាភិបាលបារាំងកាលពីថ្ងៃទី ១៩ ខែសីហា ឆ្នាំ ១៩៤៨ ។ ទឹកដីកូស័ងស៊ីនឈប់ស្ថិតនៅក្នុងលក្ខន្តិកៈជាទឹកដីឯនាយសមុទ្ររបស់បារាំងទៀតហើយ ។

**មាត្រា ៣.** – បទបញ្ញត្តិនៃច្បាប់នេះ នឹងត្រូវទទួលមោឃភាព ក្នុងករណីដែលមានការផ្លាស់ប្តូរលក្ខន្តិកៈប្រទេសវៀតណាមនៅក្នុងសហភាពបារាំង ។

## ការតវ៉ារបស់ប្រទេសកម្ពុជាៈ

នៅថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ១៩៤៩ សភាសហភាពបារាំង បានបើកកិច្ចពិភាក្សាលើគម្រោងច្បាប់នេះ ។ បន្ទាប់ពីបានជជែកគ្នាអស់មួយថ្ងៃមួយយប់ សភាបានអនុម័តលើ

មាត្រា ១ និង មាត្រា ២ ។ ប៉ុន្តែ មាត្រា ៣ ត្រូវកែប្រែទាំងស្រុង ដោយសារមានការតវ៉ា ពី គណៈប្រតិភូខ្មែរទាំង ៤ រូប គឺ លោក សុខ ឆុង, សុិម វ៉ា, ថុន អ៊ុក និង ព្រះអង្គម្ចាស់ ក្សត្រីយ៍ ពីងពាង យុគន្ធរ ។

**មាត្រា ៣** ដែលបានកែប្រែឡើងវិញនោះ មានសេចក្តីថា៖ *"ក្នុងករណីដែលលក្ខន្តិកៈប្រទេសវៀតណាមត្រូវកែប្រែ លក្ខន្តិកៈដែនដីកូសាំងសុីននឹងត្រូវបានទុកជាកម្មវត្ថុនៃការសម្រេចរបស់សភាខាងលើ ដូចមានចែងក្នុង **មាត្រា ៧៥** នៃរដ្ឋធម្មនុញ្ញ (ជំពូក VIII: សហភាពបារាំង)"* ។

ទាក់ទងនឹងផលប្រយោជន៍របស់ប្រទេសកម្ពុជា មាត្រា ៣ ដដែល បានបន្ថែមថា៖ *"ដោយការអនុវត្តនៃច្បាប់នេះ គ្មានផលប្រយោជន៍ណាមួយរបស់កម្ពុជា ត្រូវមានការប៉ះពាល់នោះទេ ។ ផលប្រយោជន៍ទាំងនេះ នឹងត្រូវដោះស្រាយតាមកិច្ចព្រមព្រៀងរវាងវៀតណាម និងកម្ពុជា ដែលមានបារាំងជាអាជ្ញាកណ្តាល ។ ឯចំណែកជនជាតិភាគតិចទាំងអស់ដែលនៅកូសាំងសុីន ក៏ដូចគ្នាដែរ"* ។ [80]

រដ្ឋាភិបាលខ្មែរបានប្រឆាំងជាប្រចាំចំពោះគម្រោងច្បាប់ណាមួយក្នុងការប្រគល់ទឹកដីកម្ពុជាក្រោមឲ្យទៅយួន ។ ការតវ៉ាបានធ្វើឡើងជាបន្តបន្ទាប់តាំងពីមុនពេលដែលបារាំង និង បាវ ដាយ បានចុះ "សន្ធិសញ្ញាឆកសមុទ្រហាឡុង" មក ។ រដ្ឋាភិបាលខ្មែរមានការព្រួយបារម្ភចំពោះការធានា នូវសិទ្ធិរបស់ខ្មែរក្រោមជាង ៤៥០.០០០ នាក់ [81] ដែលកំពុងតែរស់នៅលើទឹកដីកម្ពុជាក្រោម សិទ្ធិរបស់ប្រទេសកម្ពុជាក្នុងការធ្វើនាវាចរណ៍ដោយសេរីនៅតាមដងទន្លេមេគង្គ ការប្រើប្រាស់កំពង់ផែព្រៃនគរដែលជាច្រកចេញទៅសមុទ្រដោយមិនអាចខ្វះបាន និងបញ្ហាព្រំដែនដែលមានវិវាទ ។ ព្រះអង្គម្ចាស់ក្សត្រីយ៍ ពីងពាង យុគន្ធរ បានមានព្រះបន្ទូលនៅក្នុងសភាសហភាពបារាំងថា៖

*"យើងសូមស្នើជាសាមញ្ញថា ផលប្រយោជន៍របស់យើងនៅកូសាំងសុីន នឹងត្រូវបានពិចារណា មុននឹងភ្ជាប់ទឹកដីកូសាំងសុីន [ទៅវៀតណាម] ពីព្រោះ*

[80] ត្រាំងឆាត ប៊ុត, កម្ពុជាក្រោម អំណាចគ្មានខ្មែរក្រោម, ទំព័រ ២៦៩

[81] យោងតាមកិច្ចប្រជុំ ថ្ងៃទី ១២ ខែមីនា ឆ្នាំ ១៩៤៩ នៃ រដ្ឋសភាបារាំង កម្ពុជាក្រោម ឬ កូស័ងសុីន មានប្រជាជនចម្រុះជាតិសាសន៍ ប្រមាណ ៤.៥០០.០០០ នាក់ ក្នុងនោះ ពលរដ្ឋខ្មែរក្រោម មាន ៤៥០.០០០ នាក់ ។ រដ្ឋាភិបាលសាធារណរដ្ឋបារាំង, (១៣ មីនា ១៩៤៩), Journal Officiel de la République Française, ទំព័រ ១៦១១, (Download: ០១ កញ្ញា ២០២០), https://bit.ly/2QM83S2

*យើងខ្លាចនូវផែនការដែលមានចរិតជាចក្រពត្តិនិយមរបស់វៀតណាម និងខ្លាចថា ប្រសិនបើការភ្ជាប់ទឹកដីកូស័ងស៊ីន បានធ្វើឡើងដោយមិនបានការពារនូវផលប្រយោជន៍អ្វីមួយរបស់កម្ពុជានោះទេ យើងនឹងមិនអាចទទួលបាននូវសម្បទានទាំងនេះ ពីប្រទេសវៀតណាមឡើយ "* ។ [82]

បន្ទាប់ពីមានការតវ៉ាយ៉ាងច្រើនពីតំណាងរាស្ត្របារាំង និងប្រតិភូខ្មែររួចមក រដ្ឋសភាបារាំងបានអនុម័តលើ "ញត្តិដឺហ្វែរ" (Motion Defferre) ដើម្បីការពារផលប្រយោជន៍ជូនប្រទេសកម្ពុជា ដោយមាន ៣៨៣ សំឡេងគាំទ្រ និង ១២៨ សំឡេងប្រឆាំង ។ ផលប្រយោជន៍ដែលបានមកប្រទេសកម្ពុជា និងពលរដ្ឋខ្មែរក្រោមជាម្ចាស់ស្រុកនៃដែនដីកម្ពុជាក្រោម នោះ មានតែ ៤ ចំណុចតែប៉ុណ្ណោះ ។

**ទី ១ - ជនជាតិខ្មែរភាគតិចនៅកូស័ងស៊ីន៖**

ខ្មែរក្រោមចំនួន ៤៥០.០០០ នាក់ នៅកូស័ងស៊ីន បានរស់នៅទីនេះតាំងពីមុនយួនអណ្ណាមបានមកដល់ម្ល៉េះ ។ សិទ្ធិជនជាតិខ្មែរភាគតិចនេះត្រូវការពារជាដាច់ខាត ។

**ទី ២ - ផ្លូវទៅដល់សមុទ្រ៖**

ផ្លូវទៅដល់សមុទ្ររបស់កម្ពុជាគឺតាមទន្លេមេគង្គ ។ វាជាការចាំបាច់ពីផ្លូវទៅដល់សមុទ្រនេះ កម្ពុជានៅតែប្រើប្រាស់បានដដែលដូចកាលពីមុន ។

**ទី ៣ - ការប្រើប្រាស់កំពង់ផែព្រៃនគរ៖**

បន្ទាប់ពីទន្លេមេគង្គ កំពង់ផែគឺជាទូចំហទៅរកមហាសមុទ្រ ទៅតាមទន្លេមេគង្គកម្ពុជាអាចទាក់ទងបានងាយស្រួលនឹងបរទេស ។ ការប្រើប្រាស់កំពង់ផែនេះ ជាការចាំបាច់ចំពោះកម្ពុជា ។

**ទី ៤ - ការកែតម្រូវព្រំដែន៖**

កម្ពុជាមានបំណងចង់ឲ្យបារាំងដោះស្រាយបញ្ហានេះឲ្យហើយ មុននឹងប្រគល់ទឹកដីកូស័ងស៊ីនឲ្យទៅវៀតណាម យើងក៏ចង់បានដូចគ្នាដែរ....។

រដ្ឋសភាសុំឲ្យរដ្ឋាភិបាលធ្វើយ៉ាងណា ដើម្បីឲ្យការសម្រុះសម្រួលគ្នា រវាងផល

[82] Ellen J. Hammer, (1967) The Struggle for Indochina, 1940-1955, California: Stanford University Press, ទំព័រ ២៤៣

ប្រយោជន៍របស់ប្រទេសកម្ពុជា និងប្រទេសវៀតណាម ត្រូវបានធានាយ៉ាងឆាប់បំផុត ទៅតាមនីតិវិធីយោគយល់គ្នាទៅវិញទៅមក ឬតាមស្ថាប័នផ្សេងៗដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។ [83]

**បារាំងប្រកាសច្បាប់ភ្ជាប់ទឹកដីកម្ពុជាក្រោមទៅជាមួយនឹងវៀតណាមៈ**

នៅថ្ងៃទី ៣ ខែមិថុនា ឆ្នាំ ១៩៤៩ សមាជិកសភាចំនួន ៥៨៨ រូប នៅក្នុងរដ្ឋសភាបារាំង បានបោះឆ្នោត ៣៦៧ សំឡេងស្រប និង ២២១ សំឡេងប្រឆាំងលើ "គម្រោងច្បាប់កែប្រែនូវលក្ខន្តិកៈទឹកដីកូស័ងស៊ីននៅក្នុងសហភាពបារាំង" (du projet de loi modifiant le statut de la Cochinchine dans l'Union française) ដើម្បីភ្ជាប់ទឹកដីកម្ពុជាក្រោមទៅជាមួយនឹងវៀតណាម ។ ការបោះឆ្នោតនេះធ្វើឡើង បន្ទាប់ពី គណៈកម្មការទឹកដីបារាំងឯនាយសមុទ្រ សភាសហភាព រដ្ឋសភា និងរដ្ឋសភានៃក្រុមប្រឹក្សាសាធារណរដ្ឋបារាំង បានធ្វើវិសោធនកម្មពិនិត្យជជែកដេញដោលគ្នាតាំងពីពាក់កណ្ដាលខែឧសភាមក ។ ដើម្បីច្បាប់នេះបានចេញជាធរមាន តាមលក្ខខណ្ឌត្រូវមាន ៣១១ សំឡេងស្របពីសមាជិកសភា តែការបោះឆ្នោតកែប្រែច្បាប់នេះ មានសំឡេងស្របឡើងទៅដល់ ៣៦៧ ឯណោះ ដែលអាចធ្វើឲ្យរដ្ឋសភាមានលទ្ធភាពពេញលេញក្នុងការអនុម័តបញ្ចប់នូវ "លក្ខន្តិកៈកូស័ងស៊ីនជាទឹកដីឯនាយសមុទ្ររបស់បារាំង" ដោយបានភ្ជាប់ដែនដីកម្ពុជាក្រោមដែលជាទឹកដីរបស់ប្រទេសកម្ពុជា ទៅជាមួយនឹងទឹកដីរបស់ប្រទេសវៀតណាម ។ [84]

ក្រោយរដ្ឋសភាអនុម័តបានមួយថ្ងៃ មេដឹកនាំកំពូលរបស់បារាំងទាំងបីរូប គឺ លោក វ៉ាំងសង់ អូរីយ៉ូល ជាប្រធានាធិបតី លោក អង់រី កឺយ ជានាយករដ្ឋមន្ត្រី និង លោក ប៉ូល កូស្ត ផ្លរេត៍ ជារដ្ឋមន្ត្រីទឹកដីបារាំងនៅឯនាយសមុទ្រ បានចុះហត្ថលេខារួមគ្នាលើច្បាប់លេខ ៤៩-៧៣៣ ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ១៩៤៩ មាន ៣ មាត្រា និងបានប្រកាសឲ្យប្រើជាផ្លូវការ ដែលមានខ្លឹមសារដូចតទៅៈ

[83] ត្រាំងឆាត ប៊ុត, កម្ពុជាក្រោម អំណាចគ្មានខ្មែរក្រោម, ទំព័រ ២៧៤

[84] រដ្ឋាភិបាលសាធារណរដ្ឋបារាំង, (០៤ មិថុនា ១៩៤៩), Journal Officiel de la République Française, ទំព័រ ៣១៥០, (Download: ០១ កញ្ញា ២០២០), https://bit.ly/3bhi6rw

## LOI N°49-733 du 4 juin 1949 modifiant le statut de la Cochinchine dans l'Union française

Après avis de l'Assemblée de l'Union française,

L'Assemblée nationale et le Conseil de la République ont délibéré,

L'Assemblée nationale a adopté,

Le Président de la République promulgue la loi dont la teneur suit:

Art. 1er. – Dans le cadre fixé à l'article 60 de la Constitution de la République française et après l'avis émis, dans sa séance du 23 avril 1949, par l'Assemblée territoriale de Cochinchine, le statut de Cochinchine est modifié dans les conditions prévues à l'article ci-après.

Art. 2. – Le territoire de la Cochinchine est rattaché à l'Etat associé du Viet-Nam suivant les termes de la déclaration commune du 5 juin 1948 et de la déclaration du Gouvernement français du 19 août 1948.

La Cochinchine cesse en conséquence d'avoir le statut de territoire d'outre-mer.

Art. 3. – En cas de changement de statut du Viet-Nam, le statut de la Cochinchine fera l'objet d'une nouvelle délibération des assemblées prévues à l'article 75 de la Constitution (Titre VII : De l'union française).

La présente loi sera exécutée comme loi de l'Etat.

Fait à Toulon, le 4 juin 1949.

VINCENT AURIOL.

Par le Président de la République:

*Le président du conseil des ministres,*

HENRI QUEUILLE.

*Le ministre de la France d'outre-mer,*

PAUL COSTE-FLORET. [85]

---

[85] រដ្ឋាភិបាលសាធារណរដ្ឋបារាំង, (០៥ មិថុនា ១៩៤៩), Journal Officiel de la République Française, ទំព័រ ៥៥០២, (Download: ០១ កញ្ញា ២០២០), https://bit.ly/34VsZ1a

## ច្បាប់លេខ ៤៩-៧៣៣ ចុះថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ១៩៤៩ កែប្រែលក្ខន្តិកៈកូស័ងស៊ីននៅក្នុងសហភាពបារាំង

យោងតាមមតិពីសភានៃសហភាពបារាំង

រដ្ឋសភា និងក្រុមប្រឹក្សានៃសាធារណរដ្ឋបារាំង បានសម្រេច

រដ្ឋសភានៃសាធារណរដ្ឋបារាំងបានអនុម័ត

ប្រធានាធិបតី នៃសាធារណរដ្ឋបារាំង ប្រកាសច្បាប់ដូចតទៅនេះ៖

**មាត្រា ១.** –ក្នុងក្របខណ្ឌមាត្រា ៦០ នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋបារាំង និងតាមមតិរបស់ សភាកូស័ងស៊ីន នាសម័យប្រជុំកាលពីថ្ងៃទី ២៣ ខែមេសា ឆ្នាំ ១៩៤៩ លក្ខន្តិកៈទឹកដីកូស័ងស៊ីន បានត្រូវកែប្រែតាមមាត្រា ដូចមានចែងខាងក្រោម ។

**មាត្រា ២.** –ទឹកដីកូស័ងស៊ីនត្រូវបានភ្ជាប់ទៅជារដ្ឋចំណុះវៀតណាម យោងតាមសេចក្ដីប្រកាសរួមកាលពីថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ ១៩៤៨ និងសេចក្ដីប្រកាសរបស់រដ្ឋាភិបាលបារាំងកាលពីថ្ងៃទី ១៩ ខែសីហា ឆ្នាំ ១៩៤៨ ។ ទឹកដីកូស័ងស៊ីនឈប់ស្ថិតនៅក្នុងលក្ខន្តិកៈជាទឹកដីឯនាយសមុទ្ររបស់បារាំងទៀតហើយ ។

**មាត្រា ៣.**–ក្នុងករណីមានការផ្លាស់ប្ដូរលក្ខន្តិកៈនៅវៀតណាម លក្ខន្តិកៈកូស័ងស៊ីននឹងក្លាយជាប្រធានបទនៃការពិភាក្សាឡើងវិញដោយសភាខាងលើ ដូចមានចែងនៅក្នុងមាត្រា ៧៥ នៃរដ្ឋធម្មនុញ្ញ (ជំពូក ទី ៨: ស្ដីពីសហភាពបារាំង) ។

ច្បាប់នេះនឹងត្រូវបានអនុវត្តដូចជាច្បាប់រដ្ឋ ។

ធ្វើនៅទូឡុង ថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ១៩៤៩

វ៉ាំងសង់ អូរីយ៉ូល (Vincent Auriol)
ប្រធានាធិបតី

អង់រី កឺយ (Henri Queuille)
នាយករដ្ឋមន្ត្រី

ប៉ូល កូស្ត ផ្លរេត៍ (Paul Coste-Floret)
រដ្ឋមន្ត្រីទឹកដីបារាំងឯនាយសមុទ្រ

# ៧០ ឆ្នាំ កម្ពុជាក្រោម បន្តនៅក្រោមអាណានិគមយួន ១៩៤៩-២០១៩

បន្ទាប់ពីបានប្រកាសច្បាប់កាត់ទឹកដីកម្ពុជាក្រោមឲ្យទៅយួនរួចហើយ បារាំងនៅតែបន្តរក្សាឥទ្ធិពលអាណានិគមរបស់ខ្លួននៅឥណ្ឌូចិនដដែល រហូតដល់មានកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ ឆ្នាំ ១៩៥៤ តម្រូវឲ្យបារាំងត្រូវបញ្ចប់អាណានិគមកិច្ចរបស់ខ្លួននៅឥណ្ឌូចិន និងវៀតណាមត្រូវពុះប្រទេសចេញជាពីរដែលមានព្រំដែនត្រង់ចំណុចខ្សែស្របទី ១៧ ។ ពេលបារាំងចេញផុតទៅ អាមេរិកបានចូលមកជំនួសវិញ ។ សង្គ្រាមហែកហួរដណ្ដើមអំណាចគ្នារវាងយួនសេរីខាងត្បូង និងយួនកុម្មុយនីស្តខាងជើង បានផ្ទុះឡើងទូទាំងដែនដីកម្ពុជាក្រោម ដែលគេហៅថា "សង្គ្រាមវៀតណាម" ឬ "សង្គ្រាមឥណ្ឌូចិនលើកទី ២" ដោយបានអូសបន្លាយអស់រយៈពេល ២០ ឆ្នាំ ។ នៅឆ្នាំ ១៩៧៥ ពេលយួនកុម្មុយនីស្តខាងជើងបានឈ្នះសង្គ្រាម ទឹកដីកម្ពុជាក្រោម ត្រូវគេដាក់បញ្ចូលទៅក្នុងប្រទេស "សាធារណរដ្ឋសង្គមនិយមវៀតណាម" តែមួយ ហើយបានបន្តធ្វើអាណានិគមរហូតមកដល់សព្វថ្ងៃ ។

## កម្ពុជាក្រោម ក្នុងសម័យ "រដ្ឋវៀតណាម" ១៩៤៩ - ១៩៥៥៖

នៅថ្ងៃដែលច្បាប់ លេខ ៤៩-៧៣៣ ស្ដីពី "ការកែប្រែលក្ខន្តិកៈកូស័ងស៊ីននៅក្នុងសហភាពបារាំង" ចូលជាធរមាន នៅថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ១៩៤៩ នោះ បាវ ដាយ និង លោក ឡេអុង ពីញ៉ុង (Léon Pignon) ជាស្នងការជាន់ខ្ពស់នៃសហព័ន្ធឥណ្ឌូចិន បានជួបគ្នានៅក្នុងពិធីផ្លូវការមួយនៅទីក្រុងព្រៃនគរ ដើម្បីផ្ទេរនូវសារលិខិតក្នុងការផ្ដល់ឯករាជ្យដល់វៀតណាម ដូចអ្វីដែលប្រធានាធិបតីបារាំង បានចុះកិច្ចព្រមព្រៀងជាមួយនឹង បាវ ដាយ នៅវិមានអេលីសេ (Elysée Palace) កាលពីថ្ងៃទី ៨ ខែមីនា ។ [86] នៅក្នុងពិធីនេះ កម្ពុជាក្រោម ត្រូវគេដាក់បញ្ចូលជាផ្លូវការទៅក្នុងរដ្ឋវៀតណាម (Quốc Gia Việt Nam) ជារដ្ឋាភិបាលមួយដែល បាវ ដាយ បានប្រកាសបង្កើតជាផ្លូវការនៅថ្ងៃទី ២ ខែកក្កដា ដោយមានរដ្ឋធានីនៅទីក្រុងព្រៃនគរ ។

សូមបញ្ជាក់ថា ពេលបារាំងបានប្រគល់ទឹកដីកម្ពុជាក្រោមឲ្យទៅ បាវ ដាយ ហើយនោះ រដ្ឋាភិបាលរដ្ឋវៀតណាម របស់ បាវ ដាយ មិនទាន់បានទទួលឯករាជ្យពេញលេញ

[86] Ellen J. Hammer, (1967) The Struggle for Indochina, 1940-1955, California: Stanford University Press, ទំព័រ ២៤៣

ពីបារាំងនៅឡើយ ។ "ឯករាជ្យ" ដែលបារាំងបានប្រគល់ឲ្យ បាវ ដាយ នោះ គ្រាន់តែជាប្រភេទឯករាជ្យមួយដែលឋិតនៅក្នុងក្របខ័ណ្ឌនៃសហភាពបារាំងតែប៉ុណ្ណោះ ។ ម្យ៉ាងទៀត នៅវៀតណាមពេលនោះ មានរដ្ឋាភិបាលដល់ទៅពីរឯណោះគឺ ទីមួយ "រដ្ឋវៀតណាម" ដឹកនាំដោយ បាវ ដាយ និងទីពីរ "សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម" ដឹកនាំដោយ ហូ ជី មិញ ។ ហូ ជី មិញ មិនបានទទួលស្គាល់រដ្ឋាភិបាល និងឯករាជ្យរបស់ បាវ ដាយ ឡើយ ដោយបានចោទ បាវ ដាយ និង "រដ្ឋវៀតណាម" ថា ជាអាយ៉ងរបស់បារាំង ។ សរុបមក ចាប់ពីឆ្នាំ ១៩៤៩ ដល់ ១៩៥៤ រដ្ឋាភិបាលរបស់ បាវ ដាយ គ្រាន់តែទទួលបាននូវស្វ័យភាពខ្លះពីបារាំងក្នុងឋានៈជារដ្ឋចំណុះ (Associated State) មួយនៅក្នុងក្របខ័ណ្ឌនៃសហភាពបារាំង តែប៉ុណ្ណោះ ។

ការណ៍ដែលបារាំងមិនព្រមប្រគល់ឯករាជ្យទាំងស្រុងឲ្យ បាវ ដាយ នោះ ត្រូវបានលោក Archimedes L.A Patti អ្នកនិពន្ធសៀវភៅ "Why Vietnam?" បានកត់សម្គាល់នៅក្នុងសៀវភៅរបស់គាត់ថា៖

> *"ប្រាកដណាស់ ពួកគេ [រដ្ឋវៀតណាម] បានយល់ច្រឡំ ។ បារាំងមិនដែលប្រគល់ឯករាជ្យពិតប្រាដកឲ្យវៀតណាម ដើម្បីធ្វើឲ្យបាត់បង់អំណាចនៅឥណ្ឌូចិនឡើយ ។ បាវ ដាយ បានត្រឡប់មកវៀតណាម និងគិតថា គាត់បានប្រឹងប្រែងឲ្យអស់ពីសមត្ថភាព ដើម្បីបារាំងរក្សានូវពាក្យសន្យារបស់គេ ។ គាត់បានរង់ចាំ និងសង្កេតមើលដោយរំពឹងថា សហរដ្ឋអាមេរិកនឹងជួយគាត់ ។ ប៉ុន្តែ បន្ទាប់ពីគាត់បានស្នាក់នៅទីក្រុងព្រៃនគរ អស់មួយថ្ងៃ ឃើញថា បារាំងបានបដិសេធមិនឲ្យគាត់ចូលធ្វើការនៅក្នុង វិមាននរោត្តម ជាការិយាល័យកណ្តាលរបស់អាណានិគមបារាំងនោះ ទើប បាវ ដាយ បានដកខ្លួនទៅស្នាក់នៅផ្ទះរបស់គាត់នៅដាឡាត (Da Lat) ។ ការណ៍នេះ បង្ហាញឲ្យឃើញកាន់តែច្បាស់ថា ស្ថានភាព [ឯករាជ្យ] គ្មានអ្វីប្រែប្រួលឡើយ"* ។ [**87**]

រដ្ឋាភិបាល "រដ្ឋវៀតណាម" របស់ បាវ ដាយ បានការគាំទ្រ និងជំនួយពីរដ្ឋាភិបាល

[87] Why Vietnam, Archimedes L.A Patti, Nhà xuất bản Đà Nẵng, 2008, ទំព័រ ៦៥៥

សាធារណរដ្ឋបារាំង និងសហរដ្ឋអាមេរិក ចាប់ពីឆ្នាំ ១៩៥០ ដល់ ១៩៥៤ ខណៈដែល ហូ ជី មិញ បានការគាំទ្រ និងជំនួយពីរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន ចាប់ពីឆ្នាំ ១៩៥០ និងពីសហភាពសូវៀតដែលមានកម្រិតតិចជាង ។ ទោះបីមិនទទួលបានការគាំទ្រពីបារាំងក៏ដោយ តែ ៦០% នៃអំណាចគ្រប់គ្រងទូទាំងប្រទេសវៀតណាម ត្រូវធ្លាក់ចូលទៅក្នុងការកាន់កាប់របស់ពួកយៀកមិញនៅក្នុងឆ្នាំ ១៩៥២ ។ [88]

**សន្និសីទទីក្រុងហ្សឺណែវ ឆ្នាំ ១៩៥៤ ពុះប្រទេសវៀតណាមចេញជាពីរៈ**

ក្រោយ "កិច្ចព្រមព្រៀងក្រុងហ្សឺណែវ" នៅឆ្នាំ ១៩៥៤ រដ្ឋាភិបាល "រដ្ឋវៀតណាម" ដែលបានបង្កើតឡើងដោយ បាវ ដាយ បានទទួលឯករាជ្យទាំងស្រុងដោយបានផ្តាច់ខ្លួនចេញពីក្របខ័ណ្ឌសហភាពបារាំង តែវៀតណាមត្រូវពុះប្រទេសចេញជាពីរជាបណ្តោះអាសន្នដោយមានព្រំដែនត្រង់ខ្សែស្របទី ១៧ ។

សន្និសីទក្រុងហ្សឺណែវ ធ្វើឡើងនៅទីក្រុងហ្សឺណែវ នៃប្រទេសស្វិស ចាប់ពីថ្ងៃទី ២៦ ខែមេសា ដល់ថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ១៩៥៤ [89] ដោយផ្អែកលើកម្មវត្ថុ ២ យ៉ាង គឺ ស្វែងរកវិធីបង្រួបបង្រួមប្រទេសកូរ៉េ និងដោះស្រាយបញ្ហាសង្គ្រាមរវាងបារាំង និងយៀកមិញ ឬបញ្ឈប់នូវអរិភាពនៅឥណ្ឌូចិន [90] ។ ហេតុនាំឲ្យមានកិច្ចពិភាក្សាស្តីពីបញ្ហាវៀតណាមនៅក្នុងសន្និសីទនេះ ដោយសារកងទ័ពបារាំងបានចាញ់សង្គ្រាម និងមូលដ្ឋានយោធារបស់បារាំងនៅឌៀងបៀងភូ (Điện Biên Phủ) ត្រូវវាយប្រហារ និងកាន់កាប់ដោយកងទ័ពយៀកមិញ ។ [91] សន្និសីទបានបញ្ចប់ទៅ ដោយបារាំងបានសន្យាថា នឹងដកកងទ័ពចេញពីប្រទេសកម្ពុជា លាវ និង វៀតណាម [92] ។ សហរដ្ឋអាមេរិកបានចាប់ផ្តើមលូកដៃចូលពាក់ព័ន្ធនឹងសង្គ្រាមនៅវៀតណាម ។ [93]

---

[88] Pierre Montagnon, L'Indochine française, Tallandier, 2016, ទំព័រ ៣២៥

[89] Young, Marilyn (1991), The Vietnam Wars: 1945–1990. New York: HarperPerennial, ទំព័រ ៤១

[90] The Avalon Project, 'Indochina - Midway in the Geneva Conference: Address by the Secretary of State, May 7, 1954', Yale Law School - Lillian Goldman Law Library, (ស្រង់ប្រភពៈ ៤ កញ្ញា ២០២០), https://bit.ly/3jP57k0

[91] [93] History.com Editors, (១៣ វិច្ឆិកា ២០០៩), 'Geneva Conference to resolve problems in Asia begins', HISTORY, A&E Television Networks, (ស្រង់ប្រភពៈ ៤ កញ្ញា ២០២០), https://bit.ly/2GxiyXr

[92] United States Department of State, 'Declaration by the Government of the French Republic' (សេចក្តីប្រកាសដោយរដ្ឋាភិបាលសាធារណរដ្ឋបារាំង ថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ១៩៥៤, (ស្រង់ប្រភពៈ ៦ កញ្ញា ២០២០), https://bit.ly/3bFwMkA




ផែនទីដែនដីកម្ពុជាក្រោមនៅក្នុងរបបសាធារណរដ្ឋវៀតណាម
ចាប់ពីឆ្នាំ ១៩៥៤ ដល់ ១៩៧៥ ពេលដែលយួនត្រូវបែកបាក់ជាតិចេញជាពីរ ។

តំណាងប្រទេសដែលបានចូលរួមប្រជុំនៅក្នុងសន្និសីទនេះ រួមមាន៖

១. ចក្រភពអង់គ្លេស តំណាងដោយ លោក Anthony Eden ។

២. សហរដ្ឋអាមេរិក តំណាងដោយ លោក Bedell Smith ។

៣. សហភាពសូវៀត តំណាងដោយ លោក Viacheslav Molotov ។

៤. សាធារណរដ្ឋប្រជាមានិតចិន តំណាងដោយ លោក ជូ អេន ឡាយ ។

៥. សាធារណរដ្ឋបារាំង តំណាងដោយ លោក Georges Bidault ។

៦. យួនយៀកមិញ តំណាងដោយ លោក ផាម វ៉ាំង ដុង (Phạm Văn Đồng) ។

៧. យួន បាវ ដាយ តំណាងដោយ លោក ង្វៀង ក្វឹក ឌិញ (Nguyễn Quốc Định)

៨. ព្រះរាជាណាចក្រលាវ តំណាងដោយ លោក Phumi Sananikone ។

៩. ព្រះរាជាណាចក្រកម្ពុជា តំណាងដោយ លោក សម សារី និង ទេព ផន ។ [94]

**កិច្ចព្រមព្រៀងស្តីពីបទឈប់បាញ់គ្នានៅវៀតណាម៖**

នៅថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៥៤ តំណាងអគ្គមេបញ្ជាការនៃកងកម្លាំងសហភាពបារាំងប្រចាំឥណ្ឌូចិន ឧត្តមសេនីយ៍ Henri Delteil និងតំណាងអគ្គមេបញ្ជាការ នៃកងទ័ពប្រជាជនវៀតណាម លោក តា ក្វាង បូវ (Tạ Quang Bửu) ជាអនុរដ្ឋមន្ត្រីនៃក្រសួងការពារជាតិនៃរដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម បានចុះហត្ថលេខារួមគ្នាលើ “កិច្ចព្រមព្រៀងស្តីពីបទឈប់បាញ់” នៅវៀតណាម ដែលមាន ៦ ជំពូក ៤៧ មាត្រា និងចំណុច ។ សហរដ្ឋអាមេរិកមិនបានចុះហត្ថលេខា លើកិច្ចព្រមព្រៀងនេះទេ [95] តែបានប្រកាសថាខ្លួន “នឹងតាមដានរាល់ការកើតឡើងជាថ្មី នៃការឈ្លានពានដោយរំលោភលើកិច្ចព្រមព្រៀង ជាមួយការព្រួយបារម្ភយ៉ាងខ្លាំង និងជាការគំរាមកំហែងជាទម្ងន់ដល់សន្តិភាព និងសន្តិសុខអន្តរជាតិ”។ [96] រដ្ឋាភិបាល “រដ្ឋវៀតណាម” របស់ បាវ ដាយ ក៏មិនបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះដែរ ព្រោះប្រតិភូរបស់

[94] United States Department of State, ‘Schedule of Plenary and Restricted Sessions on Indochina’, (ស្រង់ប្រភព៖ ៦ កញ្ញា ២០២០), https://bit.ly/3jZ0q7I

[95] Vincent Ferraro, (១ កុម្ភៈ ២០២០) ‘AGREEMENT ON THE CESSATION OF HOSTILITIES IN VIETNAM, JULY 20, 1954’ (ស្រង់ប្រភព៖ ៩ កញ្ញា ២០២០), https://bit.ly/2RaSOCf

[96] Fox Butterfield, (១៩៧១),‘The American Statement’, The Pentagon Papers, New York City: The New York Times, ទំព័រ ៥២-៥៣

ខ្លួនគ្មានសិទ្ធិអំណាចគ្រប់គ្រាន់ ដើម្បីចូលរួមចុះហត្ថលេខានៅលើកិច្ចព្រមព្រៀងនេះ ដោយសារកម្លាំងយោធាតិចពេក និងកំពុងតែឋិតនៅក្នុងក្របខ័ណ្ឌនៃសហភាពបារាំងនៅឡើយ ។ [97]

## សេចក្ដីប្រកាសចុងក្រោយ នៃសន្និសីទទីក្រុងហ្សឺណែវស្ដីពីឥណ្ឌូចិន៖

នៅថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៥៤ តំណាងនៃប្រទេសពាក់ព័ន្ធ ដែលបានចូលរួមប្រជុំនៅក្នុងសន្និសីទនេះ បានចាប់ផ្ដើមចុះហត្ថលេខាលើបទបញ្ញត្តិ និងកិច្ចព្រមព្រៀងជាច្រើន ក្នុងនោះមាន សន្ធិសញ្ញាស្ដីពី "បទឈប់បាញ់" (Armistice Agreement) នៅប្រទេសកម្ពុជា វៀតណាម និងលាវ, សេចក្ដីប្រកាសដោយរដ្ឋាភិបាលបារាំង, កម្ពុជា, លាវ, វៀតណាម, សហរដ្ឋអាមេរិក និង សេចក្ដីប្រកាសចុងក្រោយស្ដីពីឥណ្ឌូចិន ចុះ ថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ១៩៥៤ មាន ១៣ ចំណុច ។ [98]

១. អង្គសន្និសីទកត់សម្គាល់នូវកិច្ចព្រមព្រៀងបញ្ឈប់នូវអរិភាព នៃសង្គ្រាមនៅក្នុងប្រទេសកម្ពុជា លាវ និងវៀតណាម និងចាត់តាំងនូវការត្រួតពិនិត្យ និងតាមដានជាលក្ខណៈអន្តរជាតិនូវការអនុវត្តលើបទបញ្ញត្តិនៅក្នុងកិច្ចព្រមព្រៀងនេះ ។

២. អង្គសន្និសីទសម្ដែងការពេញចិត្តចំពោះការបញ្ឈប់អរិភាព នៅប្រទេសកម្ពុជា លាវ និងវៀតណាម ។ អង្គសន្និសីទមានជំនឿថា ការអនុវត្តនូវបទបញ្ញត្តិដែលមានចែងនៅក្នុងសេចក្ដីប្រកាស និងកិច្ចព្រមព្រៀងស្ដីពីការបញ្ឈប់នូវអរិភាពនេះ នឹងធ្វើឱ្យប្រទេសកម្ពុជា លាវ និងវៀតណាម ចាប់ពីថ្ងៃនេះតទៅ អាចទទួលបាននូវឯករាជ្យ និងអធិបតេយ្យទាំងស្រុងចំពោះតួនាទីរបស់ខ្លួននៅក្នុងសហគមន៍សន្តិភាពមួយ នៃប្រជាជាតិនីមួយៗ ។

៣. អង្គសន្និសីទកត់សម្គាល់នូវសេចក្ដីប្រកាសរបស់រដ្ឋាភិបាលកម្ពុជា និងលាវ អំពីគោលបំណងរបស់ពួកគេ ក្នុងការអនុម័តនូវវិធានការនានា ដែលអនុញ្ញាតឱ្យពលរដ្ឋគ្រប់រូបចូលរួមនៅក្នុងសង្គមជាតិ ជាពិសេស អាចចូលរួមបោះឆ្នោតទូទៅនាពេល

---

[97] Bernard B. Fall, (1964), The Two Vietnams: A Political and Military Analysis, New York: Praeger

[98] U. S. Department of State, 'The Final Declaration on Indochina, July 21, 1954', (ស្រង់ប្រភព៖ ១១ កញ្ញា ២០២០), https://bit.ly/35szoRN

ខាងមុខ ដែលនឹងចាប់ផ្តើមរៀបចំនៅក្នុងឆ្នាំ ១៩៥៥ ដោយយោងទៅតាមរដ្ឋធម្មនុញ្ញនៃប្រទេសនីមួយៗ តាមរយៈការបោះនូវសន្លឹកឆ្នោតសម្ងាត់ និងក្នុងលក្ខខណ្ឌនៃការគោរពសេរីភាពជាមូលដ្ឋាន ។

៤. អង្គសន្និសីទកត់សម្គាល់នូវបទបញ្ញត្តិដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង ស្តីពីការបញ្ឈប់នូវអរិភាពនៅក្នុងប្រទេសវៀតណាម អំពីការហាមឃាត់នាំកងទ័ព អ្នកជំនាញការយោធា អាវុធគ្រប់ប្រភេទ និងគ្រាប់បែកចូលទៅវៀតណាម ។ អង្គសន្និសីទក៏កត់សម្គាល់ផងដែរ នូវសេចក្តីប្រកាសដែលបានធ្វើឡើងដោយរដ្ឋាភិបាលនៃប្រទេសកម្ពុជា និងលាវ អំពីដំណោះស្រាយរបស់ពួកគេ ដោយមិនបានស្នើសុំជំនួយបរទេសនូវសម្ភារះយោធា បុគ្គលិក ឬអ្នកណែនាំ លើកលែងតែក្នុងគោលបំណងដើម្បីការពារទឹកដីរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពតែប៉ុណ្ណោះ និងក្នុងករណីនៃប្រទេសលាវវិញ វិសាលភាពនៃការកម្រិតត្រូវបានកំណត់នៅក្នុងកិច្ចព្រមព្រៀងស្តីពីការបញ្ឈប់អរិភាព នៅក្នុងប្រទេសលាវ ។

៥. អង្គសន្និសីទកត់សម្គាល់នូវបទបញ្ញត្តិនៅក្នុងកិច្ចព្រមព្រៀង ស្តីពីបញ្ឈប់នូវអរិភាពនៅវៀតណាមបញ្ជាក់ថា មិនត្រូវបង្កើតជាមូលដ្ឋានយោធាបរទេសណាមួយនៅក្នុងតំបន់បោះទីតាំងនៃភាគីទាំងសងខាង ។ ភាគីទាំងសងខាងមានកាតព្វកិច្ចក្នុងការមើលនូវតំបន់ដែលបានបែងចែកដល់ពួកគេ ដោយមិនត្រូវបង្កើតឲ្យក្លាយជាចំណែកមួយនៃសម្ព័ន្ធភាពយោធាណាមួយឡើយ និងមិនត្រូវបានប្រើសម្រាប់ការបន្តអរិភាព ឬនៅក្នុងសេវាកម្មនៃគោលនយោបាយឈ្លានពានឡើយ ។ អង្គសន្និសីទកត់សម្គាល់នូវសេចក្តីប្រកាសរបស់រដ្ឋាភិបាលទាំងពីរគឺ កម្ពុជា និងលាវ ដែលបានថ្លែងថា រដ្ឋាភិបាលទាំងពីរនេះ នឹងមិនចុះហត្ថលេខាលើកិច្ចព្រមព្រៀងណាមួយជាមួយនឹងប្រទេសផ្សេងទៀតឡើយ ប្រសិនបើកិច្ចព្រមព្រៀងនោះ តម្រូវឲ្យពួកគេចូលរួមនៅក្នុងសម្ព័ន្ធភាពយោធា មិនស្របនឹងគោលការណ៍របស់ធម្មនុញ្ញ នៃអង្គការសហប្រជាជាតិ ឬដោយឡែកចំពោះប្រទេសលាវ មិនស្របនឹងគោលការណ៍នៃកិច្ចព្រមព្រៀងបញ្ឈប់នូវអរិភាពនៅលាវ ឬកិច្ចព្រមព្រៀងនោះ តម្រូវឲ្យគេបង្កើតជាមូលដ្ឋានយោធា

បរទេសនៅលើទឹកដីកម្ពុជា ឬលាវ នៅពេលដែលសន្តិសុខរបស់ប្រទេសទាំងពីរនេះ មិនមានការគំរាមកំហែងនោះទេ ។

៦. អង្គសន្និសីទកត់សម្គាល់ថា គោលបំណងសំខាន់នៅក្នុងកិច្ចព្រមព្រៀងទាក់ទងនឹងវៀតណាម គឺដោះស្រាយនូវបញ្ហាយោធា ដើម្បីបញ្ឈប់នូវអរិភាព និងខ្សែបន្ទាត់ព្រំដែនគ្រាន់តែកំណត់ជាបណ្តោះអាសន្ន និងវាមិនគួរត្រូវបានបកស្រាយថា ជាការបង្កើតព្រំដែននយោបាយ ឬទឹកដីនោះទេ ។ អង្គសន្និសីទមានជំនឿថា ការអនុវត្តនូវបទបញ្ញត្តិដែលបានកំណត់នៅក្នុងសេចក្តីប្រកាសនេះ និងនៅក្នុងកិច្ចព្រមព្រៀងស្តីពីការបញ្ឈប់នូវអរិភាពបង្កើតមូលដ្ឋានចាំបាច់សម្រាប់សមិទ្ធផល ក្នុងពេលអនាគតដ៏ខ្លីនៃដំណោះស្រាយនយោបាយនៅវៀតណាម ។

៧. អង្គសន្និសីទប្រកាសថា ចំពោះប្រទេសវៀតណាម ត្រូវតែអនុវត្តផ្អែកលើមូលដ្ឋានគោរពនូវគោលការណ៍ឯករាជ្យ ឯកភាព និងបូរណភាពដែនដី ត្រូវធានាឲ្យពលរដ្ឋវៀតណាមបានទទួលនូវសេរីភាពជាមូលដ្ឋាន ត្រូវធានានូវស្ថាប័នប្រជាធិបតេយ្យដែលបង្កើតឡើងពីលទ្ធផល នៃការបោះឆ្នោតសេរីដោយសន្លឹកឆ្នោតសម្ងាត់ ។ ដើម្បីធានាឲ្យបាននូវវឌ្ឍនភាពគ្រប់គ្រាន់ក្នុងការស្តារសន្តិភាពឡើងវិញ និងអនុវត្តនូវលក្ខខណ្ឌជាចាំបាច់សម្រាប់ពលរដ្ឋវៀតណាមអាចមានសេរីភាព ក្នុងការបញ្ចេញមតិទៅលើឆន្ទះរបស់ជាតិ នៅក្នុងការបោះឆ្នោតទូទៅដែលនឹងរៀបចំនៅក្នុងខែកក្កដា ឆ្នាំ ១៩៥៦ ក្រោមការត្រួតពិនិត្យរបស់ គណៈកម្មការអន្តរជាតិមួយ ដែលមានអ្នកតំណាងរបស់រដ្ឋសមាជិក នៃគណៈកម្មការត្រួតពិនិត្យអន្តរជាតិស្តីពីកិច្ចព្រមព្រៀងស្តីពីការបញ្ឈប់អរិភាព ។ ការពិគ្រោះយោបល់នឹងត្រូវធ្វើឡើងលើប្រធានបទនេះ រវាងអាជ្ញាធរតំណាងមានសមត្ថកិច្ចនៃតំបន់ទាំងពីរ ចាប់ពីថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៥៥ តទៅ ។

៨. បទបញ្ញត្តិនៃកិច្ចព្រមព្រៀងស្តីពីការបញ្ឈប់នូវអរិភាពមានគោលបំណង ដើម្បីធានាការពារបុគ្គល និងទ្រព្យសម្បត្តិ ។ ត្រូវតែអនុវត្តយ៉ាងតឹងរ៉ឹងបំផុតនិងជាពិសេសអនុញ្ញាតឲ្យមនុស្សគ្រប់រូបនៅវៀតណាម សម្រេចចិត្តដោយសេរីនៅក្នុងតំបន់ដែលគាត់ចង់រស់នៅ ។

៩. អាជ្ញាធរតំណាងដែលមានសមត្ថភាពនៃតំបន់ភាគខាងជើង និងខាងត្បូងនៃប្រទេសវៀតណាម និងអាជ្ញាធរនៃប្រទេសលាវ និងកម្ពុជា មិនត្រូវអនុញ្ញាតឲ្យមានការសងសឹកជាបុគ្គល ឬជាសមូហភាព ប្រឆាំងនឹងមនុស្សដែលបានសហការតាមមធ្យោបាយណាមួយ ជាមួយភាគីណាមួយក្នុងពេលសង្គ្រាមឡើយ ។ ឬប្រឆាំងនឹងសមាជិកនៃគ្រួសាររបស់មនុស្សនោះ ។

១០.អង្គសន្និសីទកត់សម្គាល់នូវសេចក្តីប្រកាសរបស់រដ្ឋាភិបាលសាធារណរដ្ឋបារាំងបានថ្លែងថា បារាំងបានត្រៀមខ្លួនរួចជាស្រេច ក្នុងការដកកងទ័ពរបស់ខ្លួនចេញពីទឹកដីនៃប្រទេសកម្ពុជា លាវ និងវៀតណាម តាមសំណើរបស់រដ្ឋាភិបាលដែលពាក់ព័ន្ធ ក្នុងរយៈពេលមួយដែលបានកំណត់ ដោយកិច្ចព្រមព្រៀងរវាងភាគីនីមួយៗ លើកលែងតែក្នុងករណីដែលមានកិច្ចព្រមព្រៀងរវាងភាគីទាំងពីរស្តីពី ចំនួនជាក់លាក់មួយនៃកងទ័ពបារាំង នឹងត្រូវបោះទីតាំងត្រង់ចំណុចដែលបានកំណត់រយៈពេលជាក់លាក់មួយ ។

១១. អង្គសន្និសីទកត់សម្គាល់នូវសេចក្តីប្រកាសរបស់រដ្ឋាភិបាលបារាំង ដែលបានថ្លែងថា ដើម្បីដោះស្រាយរាល់បញ្ហាដែលជាប់ទាក់ទងនឹងការបង្កើតឡើងវិញ និងការពង្រឹងនូវសន្តិភាពនៅកម្ពុជា លាវ និងវៀតណាម រដ្ឋាភិបាលបារាំងនឹងបន្តអនុវត្តតាមគោលការណ៍នៃការគោរពឯករាជ្យ អធិបតេយ្យ ឯកភាព និងបូរណភាពទឹកដីនៃប្រទេសកម្ពុជា លាវ និងវៀតណាម ។

១២. នៅក្នុងទំនាក់ទំនងរបស់ពួកគេជាមួយនឹងប្រទេសកម្ពុជា លាវ និងវៀតណាម សមាជិកនីមួយៗនៃសន្និសីទក្រុងហ្សឺណែវ ត្រូវប្តេជ្ញាចិត្តក្នុងការគោរពអធិបតេយ្យ ឯករាជ្យ ឯកភាព និងបូរណភាពទឹកដីរបស់រដ្ឋដែលបានរៀបរាប់ខាងលើ និងដើម្បីចៀសវាងការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់ពួកគេ ។

១៣. ប្រទេសដែលចូលរួមនៅក្នុងអង្គសន្និសីទ យល់ព្រមពិគ្រោះយោបល់គ្នាលើសំណួរណាមួយ ដែលអាចត្រូវបានបញ្ជូនមកដោយ គណៈកម្មការត្រួតពិនិត្យអន្តរជាតិ ដើម្បីសិក្សាពីវិធានការដែលអាចចាំបាច់ ដើម្បីធានាថា កិច្ចព្រមព្រៀងស្តីពីការបញ្ឈប់នូវអរិភាពនៅក្នុងប្រទេសកម្ពុជា លាវ និងវៀតណាម ត្រូវបានគេគោរព ។

យោងតាមកិច្ចព្រមព្រៀងស្តីពីបទឈប់បាញ់នៅឥណ្ឌូចិន ដែលមាន ៤៧ មាត្រា និងចំណុច និងសេចក្តីប្រកាសចុងក្រោយដែលមាន ១៣ ចំណុច របស់សន្និសីទនេះ ប្រទេសវៀតណាម និង ដែនដីកម្ពុជាក្រោម ត្រូវប្រឈមនឹងការផ្លាស់ប្តូរ និងបានចាប់ផ្តើមឈានចូលនូវរបត់នយោបាយថ្មីមួយទៀត នោះគឺ ៖

- ប្រទេសវៀតណាម ត្រូវបែងចែក ឬពុះចេញជាពីរជាបណ្តោះអាសន្ន ត្រង់ខ្សែស្របទី ១៧ (17th parallel/vĩ tuyến 17) ។ ចាប់ពីខ្សែស្របទី ១៧ គ្របដណ្តប់មកខាងត្បូងលើទឹកដីកម្ពុជាក្រោមទាំងមូល កាន់កាប់ដោយ "រដ្ឋវៀតណាម" (បាវ ដាយ) និងពីខ្សែស្របទី ១៧ ទៅខាងជើងកាន់កាប់ដោយ "សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម" (ហូ ជី មិញ) ។
- កងទ័ពរបស់សហភាពបារាំង និងកងទ័ពរបស់ បាវ ដាយ ត្រូវដកចេញឲ្យអស់ពីខាងជើង មកបោះទីតាំងនៅភាគខាងត្បូង និងកងទ័ពរបស់ ហូ ជី មិញ ត្រូវដកចេញឲ្យអស់ពីខាងត្បូង ទៅបោះទីតាំងនៅខាងជើង ។
- ប្រជាជនយួនមានសិទ្ធិសេរីភាពឆ្លងដែនក្នុងរយៈពេល ៣០០ ថ្ងៃ ក្នុងការជម្លៀសខ្លួនឯងទៅនៅខាងជើង ឬខាងត្បូង ។ នេះក៏ដោយសារតែ មាត្រាទី ៨ នៃសេចក្តីប្រកាសចុងក្រោយរបស់សន្និសីទ និងមាត្រាទី ១៤ និង ១៥ នៃកិច្ចព្រមព្រៀងស្តីពីបទឈប់បាញ់ បានធ្វើឲ្យពលរដ្ឋយួនខាងជើងជិត ១ លាននាក់ (៨១០.០០០ នាក់) បានភៀសខ្លួនភ្លូកទឹកភ្លូកដីមករស់នៅលើទឹកដីកម្ពុជាក្រោម ក្នុងគោលបំណងអ្វីមួយដែលគេហៅថា "យុទ្ធនាការដំណើរឆ្ពោះទៅរកសេរីភាព" (Operation Passage to Freedom/Chiến dịch Con đường đến Tự do) ។ [99] នេះជាដំណើរឆ្ពោះទៅទិសខាងត្បូងជាលើកទីពីររបស់ជនជាតិយួន ចុះមករស់នៅលើទឹកដីកម្ពុជាក្រោម ដែលមានទ្រង់ទ្រាយធំនៅក្នុងសម័យសង្គ្រាមរវាងយួនកុម្មុយនីស្តខាងជើង និងយួនសេរីខាងត្បូង ដូចគ្នានឹងដំណើរឆ្ពោះទៅទិសខាងត្បូងលើកទីមួយរបស់យួន ក្នុងសម័យសង្គ្រាមហែកហួរគ្នាអស់រយៈពេល ១៥០ ឆ្នាំ (១៦២៧ - ១៧៧៥) រវាង សន្តតិវង្ស ទ្រិញ

[99] Frankum, Ronald (2007), Operation Passage to Freedom: The United States Navy in Vietnam, 1954–1955, Lubbock, Texas: Texas Tech University Press, ទំព័រ ១២ - ១៤

ខាងជើង និងសន្តតិវង្ស ង្វៀង ខាងត្បូង (Trịnh–Nguyễn War) ដែរ ។

● កំណត់ឲ្យមានការបោះឆ្នោតទូទៅទូទាំងប្រទេសវៀតណាមនៅឆ្នាំ ១៩៥៦ ដើម្បីប្រជាជនយួនមានសិទ្ធិសម្រេចជោគវាសនាដោយខ្លួនឯងដើម្បី “ឯកភាពទឹកដី” តែការបោះឆ្នោតនេះមិនបានកើតឡើងទេ ។ “ឯកភាពទឹកដី” ក្នុងទីនេះ ស្មើនឹងការយកទឹកដីកម្ពុជាក្រោម ទៅច្របាច់បញ្ចូលគ្នានឹងទឹកដីរបស់យួនខាងជើង ។

●បង្កើតជាគណៈកម្មការអន្តរជាតិមួយសម្រាប់ត្រួតពិនិត្យនូវបទឈប់បាញ់គ្នា នៅឥណ្ឌូចិន ដែលមាន ប៉ូឡូញ និងកាណាដា ជាសមាជិក និងឥណ្ឌា ជាប្រធាន ។

**បារាំងដកអាណានិគមទាំងស្រុងចេញពីកម្ពុជាក្រោម ឆ្នាំ ១៩៥៦៖**

ទោះបីបារាំងបានប្រគល់ទឹកដីកម្ពុជាក្រោម ឲ្យទៅរដ្ឋាភិបាលរបស់ បាវ ដាយ នៅក្នុងឆ្នាំ ១៩៤៩ ក្ដី តែរហូតមកដល់ឆ្នាំ ១៩៥៦ ទើបបារាំងបានដកអាណានិគមទាំងស្រុងចេញពីដែនដីកម្ពុជាក្រោម ។ ការដកអាណានិគមនេះ ដោយសារ ទីមួយ បារាំងបានចុះកិច្ចព្រមព្រៀងនៅទីក្រុងហ្សឺណែវស្ដីពីការបញ្ចប់អាណានិគមនៅឥណ្ឌូចិន ទីពីរ បញ្ហាអស្ថិរភាពនយោបាយ និងបញ្ហាខ្វះខាតហិរញ្ញវត្ថុរបស់បារាំង [100] ទីបី បារាំងត្រូវការបញ្ជូនកងទ័ពទៅទប់ទល់នូវការបះបោរទាមទារឯករាជ្យនៅអាល់ហ្សេរី (Algérie) ជាប្រទេសមួយស្ថិតនៅក្នុងទ្វីបអាហ្វ្រិកខាងជើង ដែលត្រូវឋិតនៅក្រោមអាណានិគមបារាំងចាប់តាំងពីឆ្នាំ ១៨៣០ ដល់ ១៩៦២ [101] និងទីបួន សហរដ្ឋអាមេរិក បានចេញមុខជំនួយសេដ្ឋកិច្ច និងយោធាដល់រដ្ឋាភិបាលយួនខាងត្បូងដែលមានទីតាំងនៅលើទឹកដីកម្ពុជាក្រោម ដើម្បីប្រឆាំងនឹងរបបយួនកុម្មុយនីស្តខាងជើង ។

នៅថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៥៤ ប្រធានាធិបតីសហរដ្ឋអាមេរិក Dwight D. Eisenhower (១៩៥៣ - ១៩៦១) បានប្រកាសផ្ដល់ជំនួយយោធា និងសេដ្ឋកិច្ចដោយផ្ទាល់ដល់រដ្ឋាភិបាលសាធារណរដ្ឋវៀតណាម របស់ ង៉ោ ឌិញ យេម ។ នៅខែកុម្ភៈ ឆ្នាំ ១៩៥៥ សហរដ្ឋអាមេរិកបានកាត់មុខបារាំងទទួលខុសត្រូវក្នុងការបណ្ដុះបណ្ដាលកង

[100] The Central Intelligence Agency (CIA), (1971, 27 July) ‘The Historical Setting and Evolution of The Indochina Struggle’, (ឯកសារសម្ងាត់ ចេញផ្សាយថ្ងៃ ២៥ កញ្ញា ២០០៦), ទំព័រ ៧, (Download៖ ១៦ កញ្ញា ២០២០), https://bit.ly/3iEOMOF

[101] State of Vietnam (រដ្ឋវៀតណាម), (១៦ កញ្ញា ២០២០), Wikipedia, https://bit.ly/3iDSCrh

ទ័ពយួននៅលើទឹកដីកម្ពុជាក្រោម ។ ព្រឹត្តិការណ៍នេះ ជាការកត់សម្គាល់នូវការចាប់ផ្ដើមផ្លាស់ប្ដូរនូវរបត់នយោបាយថ្មីមួយ ដោយបារាំងនឹងត្រូវដកខ្លួនចេញពីវៀតណាម ហើយជំនួសមកវិញដោយសហរដ្ឋអាមេរិក ។

នៅខែធ្នូ ឆ្នាំ ១៩៥៥ ងោ ឌិញ យេម (Ngô Đình Diệm) ជាប្រធានាធិបតីដំបូងនៃរដ្ឋាភិបាល សាធារណរដ្ឋវៀតណាម បានបញ្ចប់កិច្ចព្រមព្រៀងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទាំងអស់ជាមួយបារាំង និងបានដកតំណាងវៀតណាមខាងត្បូងចេញពីសភាសហភាពបារាំង ។ នៅថ្ងៃទី ២៦ ខែមេសា ឆ្នាំ ១៩៥៦ អគ្គបញ្ជាការជាន់ខ្ពស់របស់បារាំង ដែលមានទីតាំងនៅដែនដីកម្ពុជាក្រោមត្រូវបានរំសាយ ហើយបារាំងបានដកកងទ័ពរបស់ខ្លួនទាំងអស់ចេញពីកម្ពុជាក្រោមនៅក្នុងខែកក្កដា ។ ដូច្នេះ សហរដ្ឋអាមេរិកបានក្លាយជាអ្នកធានាចម្បងសម្រាប់អនាគតរបស់រដ្ឋាភិបាលវៀតណាមខាងត្បូង ។ [102]

ទីបំផុត បារាំងបានអស់អំណាចទាំងស្រុងនៅលើទឹកដីកម្ពុជាក្រោម បន្ទាប់ពីបានធ្វើអាណានិគមជាដែនដីឯនាយសមុទ្ររបស់ខ្លួន អស់រយៈពេលជិតមួយសតវត្សរ៍ ។

**កម្ពុជាក្រោម ក្នុងសម័យ សាធារណរដ្ឋវៀតណាម ១៩៥៥ - ១៩៧៥៖**

ពេលបារាំងបានដកអាណានិគមចេញពីទឹកដីកម្ពុជាក្រោម អាមេរិកបានចាប់ផ្ដើមចូលមកជំនួសវិញ ។ ងោ ឌិញ យេម ដែលជាមនុស្សស្និទ្ធជាមួយនឹងសហរដ្ឋអាមេរិក បានប្រកាសបង្កើតរដ្ឋាភិបាលយួនខាងត្បូងមួយឈ្មោះថា “សាធារណរដ្ឋវៀតណាម” បន្ទាប់ពីគាត់បានធ្វើប្រជាមតិមួយដេញ បាវ ដាយ ជាមនុស្សស្និទ្ធនឹងបារាំងឲ្យចេញពីអំណាចនៅក្នុងឆ្នាំ ១៩៥៥ ។ ពេលនោះ ទឹកដីកម្ពុជាក្រោម ត្រូវកាន់កាប់ដោយរបបយួនថ្មីមួយទៀត ដែលពោរពេញទៅដោយភ្លើងសង្គ្រាមរ៉ាំរ៉ៃរវាងយួនសេរីខាងត្បូង ដែលមានអាមេរិកគាំទ្រ និងយួនកុម្មុយនីស្តខាងជើង ត្រូវអូសបន្លាយអស់រយៈពេល ២០ ឆ្នាំ ។

ដោយសារមានទំនាស់ផ្ទៃក្នុងរវាង បាវ ដាយ ជាប្រមុខរដ្ឋ និង ងោ ឌិញ យេម ជាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលរដ្ឋវៀតណាម [103] ទើប ងោ ឌិញ យេម ដែលមាន

[102] [103] ដូចលេខយោង [100], https://bit.ly/3iEOMOF

សហរដ្ឋអាមេរិកគាំទ្រ បានរៀបចំបោះឆ្នោតប្រជាមតិមួយទូទាំងដែនដីកម្ពុជាក្រោម ឬវៀតណាមខាងត្បូង ដើម្បីសម្រេចជោគវាសនាអនាគតនៃ «រដ្ឋវៀតណាម» ដែលជារដ្ឋាភិបាលរបស់យួនមួយ ឋិតនៅក្នុងក្របខ័ណ្ឌសហភាពបារាំង ត្រូវបានបង្កើតឡើងដោយ បាវ ដាយ នៅក្នុងឆ្នាំ ១៩៤៨ ។ យោងតាមសេចក្តីប្រកាសរបស់ក្រុមយួនដែលគាំទ្រចំពោះការធ្វើប្រជាមតិនេះបានថ្លែងថា ប្រជាមតិនេះធ្វើឡើងក្នុងគោលបំណង៖

- បណ្តេញ បាវ ដាយ ចេញពីប្រមុខរដ្ឋ
- បង្កើតរដ្ឋាភិបាលថ្មី ដើម្បីកម្ចាត់ការបះបោរ (សំដៅលើយួនកុម្មុយនីស្ត)
- បង្ខំឲ្យបារាំងដកកងទ័ពចេញពីវៀតណាម
- រៀបចំការបោះឆ្នោតរដ្ឋសភា

លទ្ធផលនៃប្រជាមតិ ង៉ោ ឌិញ យេម បានឈ្នះជាង ៩៨,២ % នៃសន្លឹកឆ្នោត ដែលមតិទូទៅចាត់ទុកថាជាការឈ្នះដោយកេងបន្លំ [104] ក្នុងការដក ឬបណ្តេញ បាវ ដាយ ចេញពីប្រមុខរដ្ឋនៃរដ្ឋាភិបាល «រដ្ឋវៀតណាម» ហើយបង្កើតជារដ្ឋាភិបាលថ្មីមួយទៀតសម្រាប់យួនខាងត្បូងឈ្មោះថា «សាធារណរដ្ឋវៀតណាម» (Việt Nam Cộng Hòa)។

| **លទ្ធផលនៃការបោះឆ្នោតប្រជាមតិ ថ្ងៃទី ២៣ ខែតុលា ឆ្នាំ ១៩៥៥** [105] | | |
|---|---|---|
| **ជ្រើសរើស** | **សន្លឹកឆ្នោត** | **%** |
| របបរាជាធិបតេយ្យអាស្រ័យធម្មនុញ្ញ (បាវ ដាយ) | ៦៣.០១៧ | ១.០៩ |
| របបសាធារណរដ្ឋ (ង៉ោ ឌិញ យេម) | ៥.៧២១.៧៣៥ | ៩៨.៩១ |
| សន្លឹកឆ្នោតមិនបានការ ឬ សន្លឹកឆ្នោតស | 0 | – |
| សរុប | ៥.៧៨៤.៧៥២ | ១០៨.៤២ |
| សរុបចំនួនប្រជាជនចុះឈ្មោះ | ៥.៣៣៥.៦៦៨ | |

[104] Fall, Bernard B. (1963). The Two Viet-Nams. Praeger Publishers, ទំព័រ ២៥៧

[105] Direct Democracy, (២៨ ឧសភា ២០២០) 'Staat Vietnam (Südvietnam), 23. Oktober 1955 : Staatsform und Staatsoberhaupt', (ស្រង់ប្រភព៖ ១៨ កញ្ញា ២០២០), https://bit.ly/3c9dB2M

របបរបស់ ងោ ឌិញ យេម បានប្រកាសថា ប្រជាជនចំនួន **៥.៣៣៥.៦៦៨** នាក់មានសិទ្ធិបោះឆ្នោត ប៉ុន្តែសន្លឹកឆ្នោតសរុបនៅពេលប្រកាសលទ្ធផលមាន **៥.៧៨៤.៧៥២** ឯណោះ គឺឆ្នោតត្រូវលើសដល់ទៅ **៤៤៩.០៨៤** សន្លឹក ។ រដ្ឋាភិបាលរបស់ យេម បានអះអាងថា បេក្ខភាពរបស់គាត់ត្រូវបានទទួលស្គាល់ដោយម្ដាយរបស់ បាវ ដាយ ផងដែរ ទោះបីជា យេម បានបញ្ជាឲ្យទាហានទៅរឹបអូសទ្រព្យសម្បត្តិគ្រួសារ និងបណ្ដេញចេញពីដីរបស់លោកស្រីយ៉ាងណាក៏ដោយ ។ [106]

តាមកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ កងទ័ពរបស់បារាំងនឹងត្រូវដកចេញឲ្យអស់ពីវៀតណាមក្នុងរយៈពេល ២ ឆ្នាំ ហើយតម្រូវឲ្យប្រជាជនយួនខាងត្បូង និងខាងជើងបោះឆ្នោតទូទៅ ដើម្បីអ្វីមួយដែលយួនហៅថា "ឯកភាពទឹកដី" តែតាមសេចក្ដីរាយការណ៍របស់ CIA ជូនប្រធានាធិបតីសហរដ្ឋអាមេរិក Dwight D. Eisenhower បានបញ្ជាក់ថា ចំនួន ៨០% នៃប្រជាជនយួននឹងបោះឆ្នោតឲ្យ ហូ ជី មិញ ប្រសិនបើមានការបោះឆ្នោតនេះ ។ [107] ដោយមិនអាចបណ្ដោយទុកឲ្យ ហូ ជី មិញ ឈ្នះឆ្នោត ហើយបង្កើតជារដ្ឋាភិបាលកុម្មុយនីស្តមួយទូទាំងប្រទេសវៀតណាមនោះ សហរដ្ឋអាមេរិកបានចេញមុខគាំទ្ររដ្ឋាភិបាលយួនខាងត្បូង ក្នុងគោលបំណងរារាំងមិនឲ្យការបោះឆ្នោតប្រព្រឹត្តទៅបាន ដើម្បីបែងចែកវៀតណាមចេញជាពីរប្រទេសជារៀងរហូត ។ សហរដ្ឋអាមេរិកចង់បានរដ្ឋាភិបាលនិរន្តរភាពមួយ ដែលមានទីតាំងនៅទីក្រុងព្រៃនគរ ប្រឆាំងនឹងរបបកុម្មុយនីស្ត ទោះបីជារដ្ឋាភិបាលនោះមិនគោរពលទ្ធិប្រជាធិបតេយ្យ យ៉ាងណាក៏ដោយ ។ [108]

## កម្ពុជាក្រោម ក្នុងរបបផ្ដាច់ការ ងោ ឌិញ យេម ពីឆ្នាំ ១៩៥៥ ដល់ ១៩៦៣៖

នៅក្នុងសម័យសាធារណរដ្ឋវៀតណាម ពលរដ្ឋខ្មែរក្រោមជាមុខសញ្ញានៃការវាយប្រហារទាំងរដ្ឋាភិបាលយួនកុម្មុយនីស្តខាងជើង និងទាំងយួនសេរីខាងត្បូង ដោយសារ

[106] Brownell, William (1963). The American Mandarin: a study of the life of Diem and of the origins of the American involvements. Ithaca, New York: Cornell University, ទំព័រ ១៥៤-១៥៧

[107] Dwight D. Eisenhower, Mandate for Change, 1953-56 (Garden City, NY: Doubleday & Compnay, Inc., 1963), ទំព័រ ៣៧២

[108] Cecil B. Currey, Chiến thắng bằng mọi giá, Nhà xuất bản Thế giới, ទំព័រ ៣៣៣

និន្នាការនយោបាយ ។ ខ្មែរក្រោមខ្លះបានចូលរួមតស៊ូជាមួយនឹងចលនាយួនកុម្មុយនីស្ត ខាងជើង ក៏ក្លាយជាសត្រូវនឹងយួនខាងត្បូង ចំណែកខ្មែរក្រោមខ្លះទៀតគាំទ្រ និងចូល រួមតស៊ូជាមួយនឹងរដ្ឋាភិបាលយួនខាងត្បូង ក៏ក្លាយជាសត្រូវរបស់យួនកុម្មុយនីស្តខាង ជើងទៅវិញ ។ ទីបំផុត ពលរដ្ឋខ្មែរក្រោមបានក្លាយជាជនរងគ្រោះនៅលើទឹកដីរបស់ ខ្លួន ដោយសារតែនយោបាយដណ្តើមអំណាចគ្នានៃរបបយួនទាំងពីរនេះ ។

គោលនយោបាយធំជាងគេរបស់រដ្ឋាភិបាលសាធារណរដ្ឋវៀតណាម ដែលដឹកនាំ ដោយ ងោ ឌិញ យេម គឺកម្ចាត់ ឬកម្ទេចនូវពួកយៀកកុង ឬយៀកមិញ ដែលចាត់តាំង ចលនាសម្ងាត់ឃោសនាប្រឆាំងរដ្ឋាភិបាលយួនខាងត្បូង នៅតាមភូមិស្រុកនៅដែនដី កម្ពុជាក្រោម ។ មាត្រាទី ៧ នៃ រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៥៦ របស់ រដ្ឋាភិបាល សាធារណរដ្ឋ វៀតណាម បានកំណត់ថា៖ “*សកម្មភាពទាំងឡាយណា ដែលមានគោលបំណងផ្សព្វ ផ្សាយ ឬអនុវត្តដោយផ្ទាល់ ឬប្រយោលនូវលទ្ធិកុម្មុយនីស្តតាមគ្រប់រូបភាព សុទ្ធតែ បំពានលើគោលការណ៍នៃរដ្ឋធម្មនុញ្ញ* ” ។ [109] ដើម្បីបង្ហាញពីគោលជំហររបស់ខ្លួន ក្នុងការកម្ចាត់នូវចលនាកុម្មុយនីស្តយួននៅកម្ពុជាក្រោម ងោ ឌិញ យេម បានថ្លែងជា សាធារណៈថា៖ “*ឃើញកុម្មុយនីស្តនៅកន្លែងណា ត្រូវតែបាញ់ចោលភ្លាម ឃើញអ្នក ណាឃោសនាឲ្យកុម្មុយនីស្ត ក៏ត្រូវតែបាញ់ចោលភ្លាមដែរ* ” ។ [110]

នៅក្នុងទសវត្សរ៍ឆ្នាំ ៦០ ព្រះសង្ឃខ្មែរក្រោមជាច្រើន ត្រូវរបប ងោ ឌិញ យេម ធ្វើ ឃាត ក្នុងនោះមាន ព្រះចៅអធិការវត្តឃ្លាំង នៃខេត្តឃ្លាំង នៅក្នុងឆ្នាំ ១៩៦០ និងព្រះ ចៅអធិការវត្តចេកជ្រុំ នៃខេត្តព្រះត្រពាំង នៅក្នុងឆ្នាំ ១៩៦៣ ។ [111]

នៅទសវត្សឆ្នាំ ១៩៥០ និង ១៩៦០ របបយួន ងោ ឌិញ យេម បានបើកយុទ្ធនាការ គាបសង្កត់ខ្មែរក្រោមតាមរយៈក្រឹត្យ “ជាតូបនីយកម្ម” [112] ដែលបានចេងនៅក្នុងឆ្នាំ

---

[109] Hiến pháp Việt Nam Cộng hòa 1956, (២៦ សីហា ២០២០), Wikisource, https://bit.ly/3mLlore

[110] Marilyn B. Young, The Vietnam Wars: 1945-1990, ទំព័រ ២៧៩

[111] អង្គការឃ្លាំមើលសិទ្ធិមនុស្ស (HRW), On the Margins: Rights and Abuses of Ethnic Khmer in Vietnam's Mekong Delta (2009), ទំព័រ ១៧

[112] “ជាតូបនេយ្យកម្ម” មកពីពាក្យ “ជាតិ” + “ឧបនីយកម្ម” ភាសាយួនហៅថា “Quốc Hữu Hóa” មានន័យថា ការធ្វើ ឬការផ្ទេរ របស់អ្វីមួយដែលជារបស់ឯកជន ឬរបស់ជាតិដទៃឲ្យទៅជារបស់ជាតិ ឬរបស់រដ្ឋវិញ ។ តាមរយៈក្រឹត្យនេះ របបយួន ងោ ឌិញ យេម បានលុបបំបាត់ជាតិសាសន៍ខ្មែរនៅកម្ពុជាក្រោមឲ្យក្លាយទៅជាជាតិយួន ហៅថា “យួនឧបនីយកម្ម” ។

១៩៥៦ ។ រដ្ឋាភិបាលបានបញ្ជាឲ្យបិទសាលារៀនអក្សរខ្មែរនៅតាមវត្តអារាម មិនលើកទឹកចិត្តក្នុងការប្រើប្រាស់ភាសាខ្មែរ និងតម្រូវឲ្យខ្មែរក្រោមប្រើត្រកូលជាភាសាយួន ដែលជាគោលនយោបាយមួយបានអនុវត្តតាំងពីសតវត្សរ៍ទី ១៩ នៅក្នុងរជ្ជកាល ស្ដេច មិញ ម៉ាង មកម្ល៉េះ ។ សាលាបារាំង - ខ្មែរ (The Franco-Khmer School) នៅក្នុងខេត្តឃ្លាំង ដែលបន្សល់មកពីសម័យអាណានិគមបារាំង ត្រូវយកទៅធ្វើជាស្ថាប័នរបស់យួនវិញ ។ ង៉ោ ឌិញ យេម ជាអ្នកកាន់សាសនារ៉ូម៉ាំងកាតូលិក បានអនុវត្តច្បាប់ប្រឆាំងនឹងព្រះពុទ្ធសាសនា ដើម្បីរឹតត្បិតដល់ការរីកចម្រើននៃពុទ្ធសាសនាទូទាំងប្រទេសវៀតណាម ក្នុងនោះ មានពុទ្ធសាសនាថេរវាទនៅដែនដីកម្ពុជាក្រោម ផងដែរ ។ របប ង៉ោ ឌិញ យេម បានរឹបយកទឹកដីកេរដូនតារបស់ខ្មែរក្រោមទៅចែកឲ្យជនជាតិយួន នៅក្នុងគោលនយោបាយកែទម្រង់ដីធ្លី និងបញ្ហាចំណាកស្រុករបស់ជនជាតិយួនពីខាងជើងចុះមកខាងត្បូង ដែលបានឧបត្ថម្ភដោយរដ្ឋាភិបាល ។

ដោយសារតែ "គោលនយោបាយយួនឧបនីយកម្ម" ទាំងនេះហើយ បានធ្វើឲ្យមានចលនាជាតិនិយមខ្មែរក្រោម ដើម្បីរំដោះទឹកដីកម្ពុជាក្រោម នៅក្នុងទសវត្សទី ៦០ ។ ចលនាទាំងនោះ រួមមាន ចលនាតស៊ូខ្មែរកម្ពុជាក្រោម ដឹកនាំដោយ លោក ចៅ ដារ៉ា ដែលគេស្គាល់ជាទូទៅថាចលនាតស៊ូ "បក្សកន្សែងស" ជាដើម ។ មូលហេតុនាំឲ្យគេហៅថា "បក្សកន្សែងស" នោះ ដោយសារក្រុមតស៊ូនៃចលនានេះ ពេលចេញធ្វើសង្គ្រាមម្ដងៗ តែងតែយកកន្សែងយន្តព៌ណ៌សដែលបានសូត្រប្រសិទ្ធី ដោយព្រះសង្ឃមកចងនៅលើក្បាល ។[113]

## ការតស៊ូរបស់ព្រះសង្ឃខ្មែរក្រោមឲ្យគោរពសិទ្ធិពុទ្ធសាសនា ឆ្នាំ ១៩៦៣៖

នៅឆ្នាំ ១៩៦៣ ព្រះសង្ឃពុទ្ធសាសនាថេរវាទខ្មែរនៅកម្ពុជាក្រោម និងព្រះសង្ឃពុទ្ធសាសនាមហាយានរបស់ជនជាតិយួនជាច្រើនអង្គ បានដឹកនាំពុទ្ធបរិស័ទធ្វើកូដកម្មបង្អត់អាហារ និងធ្វើអត្តឃាតដោយដុតខ្លួនឯង ដើម្បីទាមទារឲ្យរបប ង៉ោ ឌិញ យេម គោរពសិទ្ធិសេរីភាពក្នុងការប្រតិបត្តិនូវពុទ្ធសាសនា ។ ហេតុការណ៍នេះ បានចាប់ផ្ដើម

[113] តាមប្រសាសន៍ របស់ លោក ចៅ រៀប ជាប្រធានសភាព្រឹទ្ធាចារ្យ នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម ។ លោក ចៅ រៀប មានស្រុកកំណើតនៅខេត្តមាត់ជ្រូក និងធ្លាប់ចូលរួមនៅក្នុងចលនាតស៊ូនេះ ។

ផ្ទុះឡើង ដោយសាររដ្ឋការ ង៉ោ ឌិញ យេម បានបាញ់សម្លាប់ប្រជាជនយួនអ្នកកាន់ពុទ្ធសាសនាចំនួន ៩ នាក់ឲ្យស្លាប់ នៅថ្ងៃទី ៨ ខែឧសភា នៅទីក្រុងហ្វេ (Hue) ទីដែលពួកគេបានធ្វើការតវ៉ាចំពោះអាជ្ញាធរដែលបានហាមមិនឲ្យលើកទង់ព្រះពុទ្ធសាសនា ។ ការតវ៉ានេះធ្វើឡើងនៅពេលដែលរដ្ឋការ ង៉ោ ឌិញ យេម បានចេញសារាចរណែនាំលេខ ៥១៥៩ (Công điện) ហាមលើកទង់សាសនាទាំងអស់នៅទីសាធារណៈ ឬ នៅក្រៅបរិវេណវត្តអារាម និងវិហារកាតូលិក ជាដើម ។

តំណាងពលរដ្ឋ និងព្រះសង្ឃខ្មែរក្រោមដែលបានដឹកនាំតវ៉ាដ៏ខ្លាំងក្លានាពេលនោះមានដូចជា ព្រះតេជព្រះគុណ ឡឹម ឯម (១៨៩៨ - ១៩៧៩) ជាចៅអធិការវត្តចន្ទរង្សីនៅទីក្រុងព្រៃនគរ និងជាសមាជិកនៃសម្ព័ន្ធព្រះពុទ្ធសាសនាវៀតណាម (Tổng Hội Phật Giáo Việt Nam) និង លោក សឺង ថាយ ង្វៀង (Sơn Thái Nguyên) (១៩១០-១៩៧៧) ត្រូវជាប្អូនបង្កើតរបស់ សឺង ង៉ុក ថាញ់ ។

នៅថ្ងៃទី ១០ ខែឧសភា ព្រះតេជព្រះគុណ ឡឹម ឯម បានចូលរួមគាំទ្រញត្តិរួមរបស់សម្ព័ន្ធព្រះពុទ្ធសាសនាវៀតណាម ដើម្បីទាមទារឲ្យរដ្ឋាភិបាលសាធារណរដ្ឋវៀណាមអនុវត្តតាមគោលបំណងទាំង ៥ ចំណុច របស់ពុទ្ធសាសនិក ។

គោលបំណងទាំង ៥ ចំណុចនោះ រួមមានៈ

១. ស្នើឲ្យរដ្ឋាភិបាលសាធារណរដ្ឋវៀតណាមលុបចោលជាស្ថាពរ នូវសារាចរហាមលើកទង់សាសនានៅទីសាធារណៈ ។

២. ស្នើឲ្យពុទ្ធសាសនាត្រូវបានទទួលនូវសិទ្ធិពិសេសមួយ ដូចជាសមាគមផ្សាយសាសនាកាតូលិក ដែលមានចែងនៅក្នុងបទបញ្ញាលេខ ១០ ។ [114]

៣. ស្នើឲ្យរដ្ឋាភិបាលបញ្ឈប់ការចាប់ខ្លួន និងវាយប្រហារលើពុទ្ធសាសនិក ។

៤. ស្នើឲ្យព្រះសង្ឃ និងពុទ្ធបរិស័ទមានសិទ្ធិសេរីភាពក្នុងការផ្សព្វផ្សាយសាសនា ។

៥. ស្នើឲ្យរដ្ឋាភិបាលផ្តល់សំណងឲ្យបានសមរម្យដល់អ្នកស្លាប់យ៉ាងអយុត្តិធម៌ និង

[114] "បទបញ្ញាលេខ ១០" (Đạo Dụ số 10) ត្រូវបានអនុម័តនៅថ្ងៃទី ៦ ខែសីហា ឆ្នាំ ១៩៥០ នៅក្នុងរបប បាវ ដាយ មាន ៦ ជំពូក និង ៤៥ មាត្រា ស្តីពីការបង្កើតសមាគម និងអង្គការក្រៅរដ្ឋាភិបាល ។ នៅក្នុងមាត្រា ៤៤ បានចែងអំពីសិទ្ធិពិសេសសម្រាប់សមាគមអ្នកផ្សាយសាសនាកាតូឡិក ឲ្យនៅក្រៅដែនកំណត់ នៃលក្ខន្តិកៈនេះ ។

ត្រូវចាប់អ្នកនៅពីក្រោយខ្នងនៃអំពើឃាតកម្មមកផ្ដន្ទាទោសតាមច្បាប់ ។

ថ្ងៃទី ១៥ ខែឧសភា ព្រះតេជព្រះគុណ ឡឹម ឯម និងប្រតិភូសង្ឃយួន នៃ សម្ព័ន្ធព្រះពុទ្ធសាសនាវៀតណាម បានចូលទៅ វិមានយ៉ាឡុង (Dinh Gia Long) ដើម្បីជូនញត្តិរួមខាងលើ ដល់ប្រធានាធិបតី ង៉ោ ឌិញ យេម ដោយផ្ទាល់ ។

ថ្ងៃទី ២១ ខែឧសភា ព្រះតេជព្រះគុណ ឡឹម ឯម និងព្រះសង្ឃមហាយានយួន ៤ អង្គទៀតគឺ ព្រះតេជព្រះគុណ មិន ទ្រឹក (Minh Trực), ព្រះតេជព្រះគុណ ទ្រី វ៉ាង (Trí Quang), ព្រះតេជព្រះគុណ ផាប ទ្រី (Pháp Tri), ព្រះតេជព្រះគុណ ទៀង មិុន (Thien Minh) និង ព្រះតេជព្រះគុណ ថាន់ ថាយ (Thanh Thái) ត្រូវបានជ្រើសតាំងឲ្យធ្វើជាទីប្រឹក្សានៃគណៈកម្មការសម្ព័ន្ធការពារព្រះពុទ្ធសាសនា ។ នេះជាគណៈកម្មការមួយត្រូវបានបង្កើតឡើងជាចាំបាច់ នៅពេលដែលព្រះពុទ្ធសាសនាខ្មែរខាងនិកាយថេរវាទ នៅកម្ពុជាក្រោម និងព្រះពុទ្ធសាសនាយួនខាងនិកាយមហាយានមានគ្រោះអាសន្ន ។

នៅថ្ងៃទី ២២ ខែឧសភា ព្រះបាទសម្ដេច ព្រះនរោត្ដម សីហនុ ជាប្រមុខរដ្ឋនៃប្រទេសកម្ពុជា បានមានព្រះបន្ទូលថ្កោលទោសរបប ង៉ោ ឌិញ យេម ថា បានរំលោភបំពាន និងជិះជាន់លើពុទ្ធសាសនិកយួន និងខ្មែរក្រោមនៅកម្ពុជាក្រោម ។ ក្រោយមកកាសែតដែលគាំទ្ររបប ង៉ោ ឌិញ យេម បានចេញផ្សាយនៅថ្ងៃទី ៩ ខែមិថុនា ថា ព្រះសង្ឃខ្មែរក្រោមជាអ្នកនាំអាទិ៍ឲ្យមានវិបត្តិនៅក្នុងពុទ្ធសាសនា និងបានចោទថា វាជាចំណែកមួយនៃគម្រោងរបស់កម្ពុជា ក្នុងការពង្រីកគោលនយោបាយអព្យាក្រឹតរបស់ខ្លួនចូលទៅក្នុងរដ្ឋាភិបាលសាធារណរដ្ឋវៀតណាមខាងត្បូង ។ [115]

នៅថ្ងៃទី ២៥ ខែឧសភា ព្រះតេជព្រះគុណ ឡឹម ឯម និង លោក សឺង ថាយ ង្វៀង ជាតំណាងពលរដ្ឋខ្មែរក្រោម បានចូលរួមប្រជុំនៅក្នុងកិច្ចប្រជុំមួយជាមួយនឹងតំណាងសមាគមព្រះពុទ្ធសាសនាចំនួន ១០ នៅក្នុងវត្តសាឡើយ (Xá Lợi) នាទីក្រុងព្រៃនគរ ដើម្បីពិភាក្សាអំពីយុទ្ធសាស្ត្រតស៊ូដោយអហិង្សា និងបានចុះហត្ថលេខាលើញត្តិរួមគាំទ្រនូវ "គោលបំណងទាំង ៥ ចំណុច" របស់ពុទ្ធសាសនិក ដែលបានប្រកាសកាលពីថ្ងៃទី

[115] Jones, Howard (2003), Death of a Generation: how the assassinations of Diem and JFK prolonged the Vietnam War, New York: Oxford University Press, ទំព័រ ២៧១

១០ ខែឧសភា ។ [116]

ថ្ងៃទី ៣០ ខែឧសភា ព្រះតេជព្រះគុណ ឡឹម ឯម បានធ្វើកូដកម្មបង្អត់អាហារក្នុងអំឡុង ៤៨ ម៉ោង ដែលនេះជាលើកដំបូង នៃការធ្វើកូដកម្មដោយសន្តិវិធី ហើយក៏ជាការចាប់ផ្ដើមធ្វើជាបន្តបន្ទាប់របស់ព្រះសង្ឃមហាយានយួន និងព្រះសង្ឃខ្មែរក្រោម នៅទីក្រុងព្រៃនគរ ដើម្បីទាមទារឲ្យរដ្ឋាភិបាលសាធារណរដ្ឋវៀតណាម គោរពសិទ្ធិព្រះពុទ្ធសាសនា ។

ថ្ងៃទី ៣ ខែមិថុនា វត្តចន្ទរង្សី នៅទីក្រុងព្រៃនគរ ត្រូវអាជ្ញាធររដ្ឋការ ង៉ោ ឌិញ យេម ចេញបទបញ្ជាឲ្យបិទទ្វារ និងឡោមព័ទ្ធយ៉ាងតឹងរ៉ឹង ។ រហូតមកដល់ថ្ងៃទី ១៥ ខែកក្កដា ព្រះសង្ឃដែលមកជួបជុំគ្នានៅក្នុងវត្តនេះ ត្រូវកម្លាំងនគរបាលយួនវាយដំ និងចាប់ទៅសួរចម្លើយយ៉ាងព្រៃផ្សៃ ហើយ ព្រះតេជព្រះគុណ ឡឹម ឯម និងព្រះសង្ឃទាំងអស់ត្រូវចាប់ទៅឃុំឃាំងអស់ ៤ ថ្ងៃ ។

នៅថ្ងៃទី ១១ ខែមិថុនា ព្រះតេជព្រះគុណ ថិត ក្វាង ឌឹក (Thích Quảng Đức) (១៨៩៧ - ១៩៦៣) ជាព្រះសង្ឃយួននិកាយមហាយាន បានធ្វើអត្តឃាតបូជាព្រះកាយខ្លួនឯង នៅខាងមុខស្ថានទូតខ្មែរ នាទីក្រុងព្រៃនគរ ដើម្បីជំទាស់នឹងអ្វីមួយដែលក្រុមបាតុករចាត់ទុកថា របប ង៉ោ ឌិញ យេម បានគាបសង្កត់និងជិះជាន់លើពុទ្ធសាសនា ។ អណ្ដាតភ្លើងឆេះសន្ធោសន្ធៅចេញពីព្រះកាយព្រះសង្ឃពុទ្ធសាសនាអង្គនេះ តាមរយៈរូបថត ដែលបានថតដោយអ្នកកាសែតជនជាតិអាមេរិក មែលខម ប្រោន (Malcolm Browne) ធ្វើឲ្យមានការចាប់អារម្មណ៍យ៉ាងខ្លាំងពីមជ្ឈដ្ឋានអន្តរជាតិ និងនាំឲ្យមានការផ្លាស់ប្ដូរនូវរបត់នយោបាយថ្មីមួយនៅក្នុងរដ្ឋាភិបាលសាធារណរដ្ឋវៀតណាម ។

នៅថ្ងៃទី ០៩ ខែកក្កដា ព្រះតេជព្រះគុណ ឡឹម ឯម បានថ្លែងជំទាស់ចំពោះក្រសួងមហាផ្ទៃនៃរដ្ឋការ ង៉ោ ឌិញ យេម ដែលបានចុះហត្ថលេខាលើអនុក្រឹត្យមួយស្ដីអំពីការអនុញ្ញាតឲ្យពុទ្ធសាសនិកលើកទង់ព្រះពុទ្ធសាសនា ចំពោះតែក្រុមព្រះពុទ្ធសាសនាណាដែលជាសមាជិក នៃ សម្ព័ន្ធព្រះពុទ្ធសាសនាវៀតណាម ។ ព្រះអង្គចាត់ទុកថា នេះជា

[116] Nguyễn Lang (2000), Việt Nam Phật giáo sử luận, Nhà xuất bản Văn học, Hà Nội, ទំព័រ ១០៥១ - ១០៥២

ទង្វើបំបែកបំបាក់ពុទ្ធសាសនា ។ [117]

ការណ៍ដែល ង៉ោ ឌិញ យេម ដាក់ពន្ធនាគារ និងសម្លាប់អ្នកដែលសម្តែងមតិជំទាស់នូវរបបរបស់គាត់ ក្នុងនោះមានព្រះសង្ឃខ្មែរក្រោមជាដើម អ្នកដែលគាត់ចាត់ទុកថាជាក្រុមដែលបានចូលដៃចូលជើងជាមួយនឹងកងទ័ពឧទ្ទាមយួនកុម្មុយនីស្តនោះ បានធ្វើឲ្យប្រជាជនទូទៅទូទាំងដែនដីកម្ពុជាក្រោម ឬវៀតណាមខាងត្បូង ជាពិសេស អ្នកកាន់ពុទ្ធសាសនាបានងើបឡើងប្រឆាំងចំពោះទង្វើរើសអើងរបស់គាត់កាន់តែខ្លាំង ។ បន្ទាប់ពីរបប របស់ យេម បានបាញ់សម្លាប់ជនជាតិយួន អ្នកដែលចេញធ្វើបាតុកម្មតវ៉ាចំពោះបទបញ្ញាហាមលើកទង់ពុទ្ធសាសនានៅក្នុងខែឧសភារួចមក អ្នកកាន់ពុទ្ធសាសនាជាច្រើននៅដែនដីកម្ពុជាក្រោម បានចាប់ផ្តើមធ្វើកូដកម្មជាបន្តបន្ទាប់ ក្នុងនោះ មានព្រះសង្ឃយួន ៣ អង្គ និងដូនជីយួនម្នាក់បានធ្វើអត្តឃាតដោយការដុតខ្លួនឯង ។ ការតស៊ូទាំងនោះហើយ បានធ្វើឲ្យសហរដ្ឋអាមេរិកដកការទុកចិត្ត និងលែងគាំទ្រនូវរបបរបស់ យេម ។ ទីបំផុត ង៉ោ ឌិញ យេម និងប្អូនប្រុសរបស់គាត់ ង៉ោ ឌិញ ញូ (Ngô Đình Nhu) ត្រូវឧត្តមសេនីយ៍នៅក្នុងរបបរបស់ខ្លួន ធ្វើរដ្ឋប្រហារយោធាដោយការបាញ់ប្រហារឲ្យស្លាប់នៅថ្ងៃទី ២ ខែវិច្ឆិកា ឆ្នាំ ១៩៦៣ ។ [118]

**កម្ពុជាក្រោម ក្នុងរបប ង្វៀង វ៉ាំង ទេវ ពីឆ្នាំ ១៩៦៧ ដល់ ១៩៧៥៖**

បន្ទាប់ពី ង៉ោ ឌិញ យេម ត្រូវធ្វើរដ្ឋប្រហារ ង្វៀង វ៉ាំង ទេវ (Nguyễn Văn Thiệu) ដែលមានការគាំទ្រពីសហរដ្ឋអាមេរិក បានជាប់ឆ្នោតជាប្រធានាធិបតី នៃរដ្ឋាភិបាលសាធារណរដ្ឋវៀតណាមនៅឆ្នាំ ១៩៦៧ និងបន្តដឹកនាំរហូតដល់ពេលដែលរដ្ឋាភិបាលនេះត្រូវដួលរលំ ដោយកងទ័ពឧទ្ទាមយួនកុម្មុយនីស្តវាយចូលដណ្តើមអំណាច នៅក្នុងឆ្នាំ ១៩៧៥ ។ ទេវ បានចូលកាន់តំណែង ស្របពេលនៃការចាប់ផ្តើមធ្វើអន្តរាគមន៍របស់សហរដ្ឋអាមេរិក នៅក្នុងសង្គ្រាមវៀតណាមប្រឆាំងនឹងពួកកងទ័ពឧទ្ទាមយៀកកុងខាងជើង និងខាងត្បូង ។ ទោះបីជាមានការរិះគន់អំពីលក្ខណៈផ្តាច់ការនៃរបបរបស់

[117] Thích Đồng Bổn, “HÒA THƯỢNG LÂM  EM (1898 - 1979)”, TIỂU SỬ DANH TĂNG VIỆT NAM THẾ KỶ XX . TẬP I, Thành Hội Phật Giáo TP. Hồ Chí Minh, 1995, (ស្រង់ប្រភព៖ ៣ វិច្ឆិកា ២០២០), https://bit.ly/3mQ1Qm0

[118] Ngo Dinh Diem, 29 Oct. 2020, Encyclopedia Britannica, (ស្រង់ប្រភព៖ ៣ វិច្ឆិកា ២០២០), www.britannica.com/biography/Ngo-Dinh-Diem

គាត់យ៉ាងណាក៏ដោយ ក៏គាត់នៅតែទទួលបានការគាំទ្រពីសហរដ្ឋអាមេរិក នៅក្នុងអំឡុងអាណត្តិរដ្ឋបាលរបស់ប្រធានាធិបតី លីនដុន ប៊ី ចនស្សិន (Lyndon B. Johnson) និង រីឆើតដ៍ អឹម និកហ្សិន (Richard M. Nixon) ។ [119]

ក្នុងរបប ង្វៀង វ៉ាំង ទេវ គេសង្កេតឃើញសង្គមខ្មែរក្រោមបានត្រូវបែងចែកចេញជាច្រើនក្រុមទៅតាមនិន្នាការនយោបាយ ។ អ្នកខ្លះនៅអព្យាក្រឹតធ្វើជារាស្ត្រសាមញ្ញ អ្នកខ្លះចូលបម្រើយួននៅក្នុងរដ្ឋាភិបាលសាធារណរដ្ឋវៀតណាម អ្នកខ្លះចូលបម្រើយួនយៀកកុងដែលបង្កប់ខ្លួននៅកម្ពុជាក្រោម ដើម្បីប្រឆាំងរដ្ឋការសាធារណរដ្ឋវៀតណាម អ្នកខ្លះចូលបម្រើនៅក្នុងកងទ័ពពិសេសរបស់សហរដ្ឋអាមេរិក និងអ្នកខ្លះទៀតបង្កើតជាចលនាតស៊ូដោយកម្លាំងប្រដាប់អាវុធ ដើម្បីរំដោះទឹកដីកម្ពុជាក្រោមពីអាណានិគមយួន ជាដើម ។

ភ្លើងសង្គ្រាមរវាងកងទ័ពយៀកកុង និងទាហាន ទីវ គី បានធ្វើឲ្យសង្គមជាតិខ្មែរនៅកម្ពុជាក្រោម ត្រូវរងគ្រោះជាដំណំ ដូចជា មនុស្សជាច្រើនត្រូវស្លាប់នៅក្នុងសមរភូមិ អ្នកខ្លះត្រូវពិការដោយសារដើរជាន់លើមីន វត្តអារាមជាច្រើន ដូចជា វត្តបឹងខ្សុង នៅខេត្តឃ្លាំង និងវត្តកំពង់ជ្រៃ នៅខេត្តព្រះត្រពាំង ជាដើម ត្រូវរបប ទេវ គី [120] បំផ្លិចបំផ្លាញដោយទម្លាក់គ្រាប់បែកក្នុងហេតុផល ដើម្បីកម្ទេចយៀកកុងដែលបង្កប់ខ្លួននៅតាមវត្ត វត្តទ្រៀក នៅខេត្តមាត់ជ្រូក ត្រូវយៀកកុងដាក់គ្រាប់បែកបំផ្ទុះដើម្បីសម្លាប់ទាហាន ទេវ គី ដែលចូលមកវត្ត និងព្រះសង្ឃត្រូវទាហាន ទេវ គី បាញ់ប្រហារ នៅពេលដែលលោកចេញធ្វើបាតុកម្មទាមទារមិនឲ្យរបបនេះចាប់ផ្សឹកទៅធ្វើទាហាន និងឲ្យទទួលស្គាល់ខ្មែរក្រោមជាជនជាតិដើមភាគតិចនៅកម្ពុជាក្រោម ជាដើម ។

**ការតស៊ូដើម្បីរក្សានូវនាទីជាជនជាតិភាគតិច ឆ្នាំ ១៩៦៩៖**

នៅក្នុងខែវិច្ឆិកា ឆ្នាំ ១៩៦៩ ព្រះសង្ឃ និងពលរដ្ឋខ្មែរក្រោម ចំនួន ១៣ ខេត្ត នៅដែនដីកម្ពុជាក្រោម បានធ្វើបាតុកម្មនៅទីក្រុងព្រៃនគរ និងនៅតាមខេត្ត ដើម្បីទាមទារ

[119] Nguyen Van Thieu, 25 Sep. 2020, Encyclopedia Britannica, (ស្រង់ប្រភព៖ ៤ វិច្ឆិកា ២០២០), www.britan nica.com/biography/Nguyen-Van-Thieu

[120] “ទេវ គី” មកពីពាក្យ “ទេវ” គឺ ង្វៀង វ៉ាំង ទេវ, “គី” គឺ ង្វៀង កាវ គី (Nguyễn Cao Kỳ) ជាអគ្គមេបញ្ជាការកងទ័ពជើងអាកាស និងជាអនុប្រធានាធិបតី នៃរដ្ឋាភិបាលសាធារណរដ្ឋវៀតណាម ។

ឲ្យរដ្ឋការ ង្វៀង វ៉ាំង ទេវ ទទួលស្គាល់ខ្មែរក្រោមជា "ជនជាតិភាគតិច" ឬ "ជនជាតិខ្មែរដើមកំណើតនៅកម្ពុជាក្រោម" ។ ការតវ៉ានេះ ធ្វើឡើងបន្ទាប់ពីប្រធានាធិបតី ង្វៀង វ៉ាំង ទេវ បានចេញក្រឹត្យលេខ ១៤ ចុះថ្ងៃទី ១៤ ខែតុលា ឆ្នាំ ១៩៦៩ ដែលមាន ៥ មាត្រា តម្រូវឲ្យលុបជាតិសាសន៍ខ្មែរចេញពីរដ្ឋធម្មនុញ្ញវៀតណាម គឺរំលាយខ្មែរឲ្យទៅជាយួនសុទ្ធសាធតែម្តង ។ [121] យោងតាម "គណៈកម្មាធិការកណ្តាលដឹកនាំព្រះសង្ឃខ្មែរកំណើតនៅវៀតណាមខាងត្បូងតស៊ូទាមទារដើម្បីរក្សានូវនាទីជាជនជាតិភាគតិច" ជាក្រុមតស៊ូរបស់ខ្មែរក្រោមមួយ ដែលបានបង្កើតឡើងនាពេលនោះ បានបញ្ជាក់អំពីអ្វីដែលខ្លួនហៅថា "ការរំលាយខ្មែរឲ្យទៅជាយួន" នោះ មានន័យថា រដ្ឋការយួន "បានលុបតំណាងខ្មែរចេញពីក្រុមប្រឹក្សាជនជាតិភាគតិច" នៅក្នុងរដ្ឋាភិបាលសាធារណរដ្ឋវៀតណាម ។ ក្រុមតស៊ូរបស់ខ្មែរក្រោមមួយនេះ បានចោទរដ្ឋការ ង្វៀង វ៉ាំង ទេវ ថាបានរំលោភលើរដ្ឋធម្មនុញ្ញ នៃរបបសាធារណរដ្ឋវៀតណាម ដែលបានអនុម័តនៅថ្ងៃទី ១ ខែមេសា ឆ្នាំ ១៩៦៧ ។ ហេតុដែលនាំឲ្យគណៈកម្មការតស៊ូមួយនេះ ទាមទារនូវនាទីជាជនជាតិភាគតិចនោះ ដោយសារពួកគាត់យល់ឃើញថា សង្គមខ្មែរក្រោមនៅដែនដីកម្ពុជាក្រោម នាពេលនោះ នៅមានភាពអន់ថយជាងជនជាតិយួនគ្រប់វិស័យ ។

> *" ខាងវិស័យយោធានៃសាធារណរដ្ឋវៀតណាម ពុំទាន់មានខ្មែរណាម្នាក់បានពាក់សក្តិថ្នាក់វរសេនីយឯកនៅឡើយ ។ ពុំទាន់មានខ្មែរណាម្នាក់បានធ្វើជាវេជ្ជបណ្ឌិតនៅឡើយ ក្នុងវិស័យសុខាភិបាល ។ ពុំទាន់មានខ្មែរណាម្នាក់បានធ្វើជាមេធាវី ក្នុងវិស័យច្បាប់ ។ ពុំទាន់មានខ្មែរណាម្នាក់បានធ្វើជាវិស្វករ ក្នុងវិស័យឧស្សាហកម្ម និងពាណិជ្ជកម្ម ។ ពុំទាន់មានខ្មែរណាម្នាក់បានធ្វើជាសាស្ត្រាចារ្យ នៅក្នុងវិស័យសិក្សាធិការ និងអប់រំ ។ សូម្បីតែនិស្សិតក្នុងមហាវិទ្យាល័យ និងសកលវិទ្យាល័យ ក៏ពុំសូវមានដែរ ។ សរុបមកខ្មែរនៅអន់ខ្សោយគ្រប់វិស័យ "* ។ [122]

[121] ថាច់ ខេមរិន្ទ, (១៩៧១), វត្តមាននៃកងកម្លាំងពិសេសខ្មែរ - សកម្មភាព លោក សឺង ង៉ុក ថាន់ ពីឆ្នាំ ១៩៣០ ដល់ឆ្នាំ ១៩៧០, ភ្នំពេញ, រោងពុម្ព នគរធំ, ទំព័រ ៨៩

[122] ថាច់ សិរ, (១៩៩៧), ទុក្ខខ្មែរក្រោម, សហរដ្ឋអាមេរិក, មជ្ឈមណ្ឌលស្រាវជ្រាវ សឺង ង៉ុក ថាញ់, ទំព័រ ២៤៩

ហេតុនេះ ទើបគណៈកម្មការតស៊ូបានទាមទារឲ្យរដ្ឋការ ង្វៀង វ៉ាំង ទេវ ទទួលស្គាល់ខ្មែរក្រោមជាជនជាតិភាគតិច ដើម្បីមានតំណាងរាស្ត្រខ្មែរនៅក្នុងក្រុមប្រឹក្សាជនជាតិភាគតិចរបស់រដ្ឋាភិបាល ដែលពួកគាត់អាចបញ្ចេញសំឡេងការពារនូវផលប្រយោជន៍ជូនពលរដ្ឋខ្មែរនៅដែនដីកម្ពុជាក្រោម ។

យោងតាមរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៦៧ នៃរបបសាធារណរដ្ឋវៀតណាម បានចែងថា ជនជាតិភាគតិចទាំងអស់ ត្រូវមានតំណាងរបស់ខ្លួននៅក្នុងរដ្ឋសភា ។ ដូច្នេះទើបនៅក្នុងសម័យនោះ គេសង្កេតឃើញខ្មែរក្រោមមួយចំនួនបានធ្វើជាតំណាងរាស្ត្រនៅក្នុងសភាធម្មនុញ្ញ និងសាមញ្ញសភានៃរដ្ឋាភិបាលមួយនេះផងដែរ ។ អ្នកទាំងនោះរួមមានៈ

១. លោក ទីវ ហ៊ី សាង (Tieu Hy Sang) ខេត្តព្រះត្រពាំង

២. លោក សឺង ធី (Son Thi) ខេត្តឃ្លាំង

៣. លោក ថាច់ ស៊ុង (Thach Sung) ខេត្តមាត់ជ្រូក

៤. លោក យ៉ាញ ធូ (Danh Thu) ខេត្តក្រមួនស ។

៥. លោក កៀង សូក (Kien Sot) ខេត្តព្រះត្រពាំង

៦. លោក តាំង បា ស្វឹង (Tang Ba Xuan) ខេត្តឃ្លាំង

៧. លោក ថាច់ ផែន (Thach Phene) ខេត្តពលលាវ

៨. លោក សឺន សឺ (Son Su) ខេត្តពលលាវ

៩. លោក យ៉ាញ កឿង (Danh Cuong) ខេត្តក្រមួនស

១០. លោក ចៅ សូកាន (Chau Sokane) ខេត្តមាត់ជ្រូក

១១. លោក ចៅ ង៉ែត (Chau Nghet) ខេត្តមាត់ជ្រូក

១២. លោក យ៉ាញ ណើ (Danh No) ខេត្តចឿងទៀង [123] ។

នៅថ្ងៃទី ២៥ ខែតុលា ឆ្នាំ ១៩៦៩ តំណាងព្រះសង្ឃ និងពលរដ្ឋខ្មែរក្រោមទាំង ១៣ ខេត្ត/ក្រុង បានមកជួបជុំគ្នានៅវត្តចន្ទរង្សី នាទីក្រុងព្រៃនគរ ដើម្បីបង្កើតជាគណៈកម្មការតស៊ូមួយឈ្មោះ "គណៈកម្មាធិការកណ្តាលដឹកនាំព្រះសង្ឃខ្មែរកំណើតនៅវៀត

[123] ខេត្តចឿងទៀង (Chương Thiện) ជាខេត្តមួយនៅដែនដីកម្ពុជាក្រោម ដែលរដ្ឋការសាធារណរដ្ឋវៀតណាម បានបង្កើត និងប្រើជាផ្លូវការ ចាប់ពីឆ្នាំ ១៩៦១ ដល់ ១៩៧៥ ។ ខេត្តនេះកើតឡើង ដោយការបំបែកផ្ទៃដីចេញខេត្តព្រែកឫស្សី, ខេត្តក្រមួនស និងខេត្តឃ្លាំង ។

ណាមខាងត្បូងតស៊ូទាមទារដើម្បីរក្សានូវនាទីជាជនជាតិភាគតិច” ដែលមាន ព្រះតេជព្រះគុណ ធម្មវីរិយោ គឹម សាង ជាប្រធាន ។ គណៈកម្មការនេះ បានដឹកនាំពលរដ្ឋ និងសង្ឃធ្វើបាតុកម្មនៅទីក្រុងព្រៃនគរ និងនៅតាមខេត្តនានា ចាប់ពីថ្ងៃទី ១៣ ខែវិច្ឆិការហូតដល់ខែធ្នូ ដើម្បីទាមទារឲ្យរដ្ឋការ ទេវ គឺ សងនូវនាទីជាជនជាតិភាគតិចមកឲ្យខ្មែរក្រោមវិញ ។ [124]

កាលសម័យនោះ យួនបានហៅខ្មែរក្រោមជាភាសាយួនថា ងើយវៀតហ្គុកមៀង (Người Việt Gốc Miên) ប្រែថា “ពលរដ្ឋយួនកំណើតខ្មែរ” ។ ពាក្យនេះ យួនចង់សំដៅថា ខ្មែរក្រោមជាមនុស្សដែលបានភៀសខ្លួនចេញពីប្រទេសកម្ពុជា មករស់នៅអាស្រ័យក្នុងប្រទេសវៀតណាម មិនមែនជាម្ចាស់ស្រុកនៃដែនដីកម្ពុជាក្រោម នោះទេ ។ ក្រោយឆ្នាំ ១៩៧៥ របបកុម្មុយនីស្តយួន សព្វថ្ងៃ បានចាត់ទុកខ្មែរក្រោមជាជនជាតិភាគតិចមួយក្នុងចំណោមជនជាតិភាគតិចទាំង ៥៣ នៅក្នុងប្រទេសវៀតណាម តែយួនបានហៅខ្មែរក្រោមជាភាសាយួនថា “ខ្មែរណាមបូ” (Khmer Nam Bộ ) ដែលមានន័យថា “ខ្មែរភាគខាងត្បូង” ទៅវិញ ។ សព្វថ្ងៃ សហព័ន្ធខ្មែរកម្ពុជាក្រោម នៅក្រៅប្រទេស បានទាមទារនៅក្នុងអង្គការសហប្រជាជាតិ (UN) ឲ្យរដ្ឋាភិបាលបក្សកុម្មុយនីស្តយួន ត្រូវទទួលស្គាល់ខ្មែរក្រោមជាជនជាតិដើម (Indigenous peoples) ឬជាម្ចាស់ស្រុកនៃដែនដីកម្ពុជាក្រោម ។

ឆ្លើយនឹងសំណួរថា ហេតុអ្វីខ្មែរក្រោមកាលសម័យនោះ មិនទាមទារឲ្យរដ្ឋការយួនទទួលស្គាល់ខ្មែរក្រោមជាជនជាតិដើម បែរជាឲ្យទទួលស្គាល់ជាជនជាតិភាគតិចទៅវិញ? លោក តាំង សារៈ ជាប្រធានសាខាសហព័ន្ធខ្មែរកម្ពុជាក្រោម ប្រចាំប្រទេសកម្ពុជា និងជាសាក្សីរស់នៃព្រឹត្តិការណ៍នេះ បានបញ្ជាក់ថា ហេតុដែលនាំឲ្យខ្មែរក្រោមក្នុងសម័យនោះតស៊ូទាមទារនូវនាទីជាជនជាតិភាគតិចនោះ ដោយសារនៅក្នុងសម័យនោះ ពាក្យ “ជនជាតិដើម” គេមិនបានយកប្រើប្រាស់ជាផ្លូវការនៅឡើយ ។ [125]

[124] ព្រឹត្តិការណ៍នេះ មាននិយាយពិស្តារនៅក្នុងសៀវភៅ “ទុក្ខខ្មែរក្រោម” ដែលបានរៀបរៀងដោយ លោក ថាច់ សិរ ។

[125] “បទសម្ភាសន៍ លោក តាំង សារៈ អំពីព្រឹត្តិការណ៍ ១៣ វិច្ឆិកា ១៩៦៩”, Youtube, ផ្សាយដោយ ទូរទស្សន៍ ព្រៃនគរ (Prey Nokor News), ថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០២០, https://bit.ly/3fZSOk3

## បាតុកម្មប្រឆាំងការចាប់ព្រះសង្ឃផ្សឹកឲ្យទៅធ្វើជាទាហាន៖

ចាប់ពីឆ្នាំ ១៩៧០ ដល់ ១៩៧៥ ពេលដែលរបបសាធារណរដ្ឋវៀតណាម ជិតដួលរលំ ព្រះសង្ឃនៅដែនដីកម្ពុជាក្រោមបានធ្វើបាតុកម្មជាបន្តបន្ទាប់ ដើម្បីប្រឆាំងនឹងអ្វីមួយដែលពលរដ្ឋខ្មែរក្រោមលើកឡើងថា “រដ្ឋការយួនចាប់ព្រះសង្ឃផ្សឹកឲ្យទៅធ្វើជាទាហាន” នៃរបបសាធារណរដ្ឋវៀតណាម ។ ការធ្វើបាតុកម្មនេះ បានធ្វើឲ្យរដ្ឋាភិបាលសាធារណប្រជាធិបតេយ្យវៀតណាមខាងជើង និងក្រុមកងទ័ពឧទ្ទាមយៀកកុង ដែលបង្កប់ខ្លួននៅកម្ពុជាក្រោមសប្បាយចិត្តយ៉ាងខ្លាំង ព្រោះពួកគេបានចំណេញនយោបាយលើការតស៊ូរបស់ព្រះសង្ឃខ្មែរក្រោម ។ ក្រុមយួនយៀកកុងបានឃោសនាថា របបយួន ទីវ គី បានធ្វើទុក្ខបុកម្នេញលើព្រះសង្ឃខ្មែរក្រោម ដើម្បីឲ្យខ្មែរក្រោមដែលជាអ្នកគោរពព្រះសង្ឃ និងពុទ្ធសាសនានោះ ស្អប់របប ទីវ គី និងសហរដ្ឋអាមេរិក ហើយចូលរួមតស៊ូជាមួយនឹងចលនាយួនយៀកកុង ។ ព្រះសង្ឃអង្គណាដែលសកម្មខ្លាំងក្នុងការដឹកនាំធ្វើបាតុកម្ម ឬឃោសនាឲ្យខ្មែរក្រោមចេះងើបឡើងតស៊ូនោះ តែងតែត្រូវរបប ទីវ គី បាញ់ប្រហារសម្លាប់ជាបន្តបន្ទាប់ ។

ដោយអាស្រ័យមានវីរភាពក្នុងការដឹកនាំពលរដ្ឋខ្មែរក្រោមចេញធ្វើបាតុកម្ម ការពារផលប្រយោជន៍ជូនខ្មែរក្រោមនោះ ព្រះតេជព្រះគុណ មហា សឺន ថាន ជាប្រធានគណៈអាចារ្យ និងជាប្រធានសមណប្បាតុករខេត្តពលលាវ និង លោក លី ឧត្តម ជាអ្នកបើកម៉ូតូជូនព្រះអង្គ ត្រូវរបបសាធារណរដ្ឋវៀតណាមស្កាត់បាញ់សម្លាប់ឲ្យសុគត និងស្លាប់នៅតាមផ្លូវ ។ ករណីធ្វើឃាតកម្មនេះ បានរៀបចំដោយរដ្ឋការ ង្វៀង វ៉ាំង ទេវសហការជាមួយនឹងអាជ្ញាធរយួនខេត្តពលលាវ ដែលមានលោកវរសេនីយ៍ឯក ហ៊ុញង៉ុក ឌីប (Huynh Ngoc Diep) ជាមេខ្លោង បានចេញបញ្ជាឲ្យលោកអនុសេនីយ៍ឯក ត្រឹង យុី ជឿង (Tran Duy Chuong) ជាប្រធានមន្ទីរនគរបាលខេត្តពលលាវធ្វើឃាតព្រះតេជព្រះគុណ មហា សឺន ថាន និង លោក លី ឧត្តម នៅថ្ងៃទី ៣ ខែមេសា ឆ្នាំ ១៩៧៣ ត្រូវនឹងខែចេត្រ ឆ្នាំឆ្លូត ចត្វាស័ក ព. ស. ២៥១៧ វេលាម៉ោង ៥ រសៀល នៅភូមិទឹកចែក ឃុំស្នែត ស្រុកពលលាវ ខេត្តពលលាវ ដោយចោទព្រះអង្គពីបទ តែងតែ

បំផុសឲ្យព្រះសង្ឃធ្វើបាតុកម្ម ។ ព្រះតេជព្រះគុណ មហា សឺន ថាន ប្រសូតនៅ ឆ្នាំ ច ព. ស. ១៤៧៧ គ. ស. ១៩៣៣ នៅតំបន់ឈើចុះ ឃុំទឹកសាប ស្រុកជ្រោយញ ខេត្តពលលាវ ។ ព្រះអង្គបានសាងផ្នួសនៅវត្តទេពារាមព្រៃជាប់ ជាវត្តមួយនៅក្នុងភូមិកំណើតរបស់ព្រះអង្គ ។ [126]

នៅថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ១៩៧៤ ព្រះសង្ឃចំនួន ៤ អង្គ នៅក្នុងខេត្តក្រមួនស ត្រូវរបបយួន ទេវ គី បាញ់ប្រហារឲ្យសុគត នៅក្នុងព្រឹត្តិការណ៍បាតុកម្មមួយ ដើម្បីទាមទារឲ្យដោះលែងព្រះសង្ឃ ដែលត្រូវរបបសាធារណរដ្ឋវៀតណាម ចាប់ផ្សឹកទៅធ្វើជាទាហាន ។

ព្រះសង្ឃទាំង ៤ អង្គដែលត្រូវសុគតនោះ រួមមាន៖

១. ភិក្ខុ យ៉ាញ តឹប (Danh Tâp) ប្រសូតឆ្នាំ ១៩៤១

២. ភិក្ខុ យ៉ាញ ហម (Danh Hòm) ប្រសូតឆ្នាំ ១៩៥០

៣. ភិក្ខុ យ៉ាញ ហយ (Danh Hỏi) ប្រសូតឆ្នាំ ១៩៥១

៤. ភិក្ខុ ឡឹម ហ៊ុង (Lâm Hùng) ប្រសូតឆ្នាំ ១៩៤៧ [127]

នៅថ្ងៃទី ២១ និង ២២ ខែកុម្ភៈ ឆ្នាំ ១៩៧៥ ទាហានរបប ទីវ គី បានឡោមព័ទ្ធវត្តក្រពុំឈូកប្រាលចារ៉ុ បិតនៅក្នុងស្រុកថ្កូវ នៃខេត្តព្រះត្រពាំង ដើម្បីចាប់ព្រះសង្ឃផ្សឹកទៅធ្វើជាទាហាន ។ ព្រះសង្ឃប្រមាណ ១.២០០ អង្គ បាននិមន្តមកពីវត្តនានានៅក្នុងខេត្តរួមគ្នាតតាំងប្រយុទ្ធជាមួយនឹងទាហាន ទេវ គី នៅក្នុងវត្តក្រពុំឈូកប្រាលចារ៉ុ ។ នៅក្នុងឆាកប្រយុទ្ធនេះ ព្រះសង្ឃ ២ អង្គ គឺ ភិក្ខុ យឿង សុខ និង គឹម សុមន៍ ត្រូវទាហាន ទេវ គី បាញ់ប្រហារឲ្យសុគតនៅក្នុងបរិវេណវត្ត ។

១. ភិក្ខុ យឿង សុខ បួសរៀននៅវត្តចារ៉ុ ប្រសូត ឆ្នាំ ១៩៥០ ព្រះជន្ម ២៥ ។

២. ភិក្ខុ គឹម សុមន៍ បួសរៀននៅវត្តកោះស្លា ប្រសូត ឆ្នាំ ១៩៥៣ ព្រះជន្ម ២២ ។

---

[126] តាំង សារៈ, (ខែមករា ព. ស. ២៥៤៧ គ. ស. ២០០៤), ព្រះវីរៈធម្មាចារ្យ មហា សឺន ថាន, ព្រឹត្តិបត្រ កម្ពុជាក្រោម, សហរដ្ឋអាមេរិក, សហព័ន្ធខ្មែរកម្ពុជាក្រោម (KKF), ទំព័រ ១៤, https://is.gd/VVP8J0

[127] Lê Hải, (៧ តុលា ២០១៦), Tưởng niệm các vị hòa thượng liệt sĩ và các anh hùng liệt sĩ, Dân tộc và Miền núi, (ស្រង់ប្រភព៖ ០១ ធ្នូ ២០២០), https://bit.ly/3qj8sf5

នៅក្នុងឆាកប្រយុទ្ធនេះ ក្រៅពីព្រះសង្ឃទាំងពីរអង្គខាងលើត្រូវសុគត មានព្រះសង្ឃចំនួន ១១ អង្គផ្សេងទៀត ត្រូវរបួស គឺធ្ងន់ ៣ ស្រាល ៨ ។ ចំណែកខាងភាគីទាហាន ទេវ គី ត្រូវស្លាប់សក្តិពីរកន្លះម្នាក់ និងរបួស ២ នាក់ ។ [128]

នៅក្នុងព្រឹត្តិការណ៍ដូចគ្នានេះដដែល សាមណេរ គឹម សំណាង អាយុ ១៥ ឆ្នាំ ដែលបានចូលរួមធ្វើបាតុកម្មដោយអហិង្សា ជាមួយនឹងព្រះសង្ឃប្រមាណ ១០០ អង្គ នៅស្រុកកំពង់ធំ (Chau Thanh) នាខេត្តព្រះត្រពាំង (Vinh Binh) ត្រូវមេទាហានយួនម្នាក់ឈ្មោះ ង្វៀង វ៉ាំង សយ (Nguyen Van Soi) បាញ់ប្រហារឲ្យសុគត នៅថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ ១៩៧៥ ។ [129]

នៅក្នុងសង្គ្រាមវៀតណាម គេសង្កេតឃើញពលរដ្ឋខ្មែរក្រោមជាច្រើន ដែលមាននិន្នាការបម្រើយួនកុម្មុយនីស្ត បានស្លាប់ក្នុងបុព្វហេតុប្រឆាំងនឹងរបបយួនសេរី ទេវ គី ផងដែរ ។ យោងតាមអត្ថបទសិក្សាស្រាវជ្រាវជាភាសាយួនមួយ មានចំណងជើងថា "តួនាទីរបស់វត្តអារាមនៅក្នុងជីវភាព និងវប្បធម៌នៃពលរដ្ឋខ្មែរណាមបូ" [130] ដែលបានរៀបរៀងនៅឆ្នាំ ១៩៩៩ និង ២០០០ ដោយក្រុមមន្ត្រីរដ្ឋាភិបាលយួនកំណើតជាខ្មែរក្រោម បានរាយការណ៍ថា នៅក្នុងសម័យអ្វីមួយដែលរដ្ឋាភិបាលកុម្មុយនីស្តយួនសព្វថ្ងៃ ហៅថា "សង្គ្រាមប្រឆាំងនឹងអាណានិគមនិយមបារាំង និងចក្រពត្តិអាមេរិក" នោះ មានពលរដ្ឋខ្មែរក្រោមជាច្រើនជាសមាជិកបក្សកុម្មុយនីស្តយួនត្រូវស្លាប់នៅក្នុងសមរភូមិ និងត្រូវជាប់ពន្ធនាគារ ។ អ្នកដែលបានស្លាប់នោះ ដូចជា ព្រះតេជព្រះគុណ ហ៊ូវ ញ៉ែម (Hữu Nhem), អ្នកស្រី ថាច់ ធី ថាញ់ (Thach Thị Thanh), នាង ង៉ែត (Neang Nghet), ថាច់ ធី ទើយ (Thạch Thị Tươi) និង ថាច់ ង៉ុក បៀង (Thạch Ngọc Biên) ជាដើម ។ អ្នកដែលរបបកុម្មុយនីស្តយួនចាត់ទុកជាវីរជននោះ មានដូចជា អ្នកស្រី កៀង ធី ញ៉ឹង (Kiên Thị Nhẫn), ឡាំ សាក់ (Lâm Sắc), សឺង តង (Sơn Ton),

[128] ព្រះកេសរវិនយោ មហា ត្រឹង យន្ត, (ព. ស. ២៥៥៥ - គ. ស. ២០១១), កម្រងអត្ថបទ សរសេរតាមអានខ្មែរ, ភ្នំពេញ, ក្រុមសិស្សានុសិស្ស, ទំព័រ ៥០

[129] "វីរសមណៈខ្មែរក្រោម", ឯកសារ (PDF) ដែលបានរៀបរៀងដោយ លោក ថាច់ សេ ។

[130] "ខ្មែរណាមបូ" (Khmer Nam Bo) មានន័យថា "ខ្មែរភាគខាងត្បូង" នៃប្រទេសវៀតណាម ។ នេះជាឈ្មោះមួយដែលរបបយួនកុម្មុយនីស្ត សព្វថ្ងៃ ប្រើជាផ្លូវការសម្រាប់ហៅ "ខ្មែរក្រោម" នៅដែនដីកម្ពុជាក្រោម ។

ឡឹម តឿង (Lâm Tương) និង ចៅ ពុធ ។ ព្រះសង្ឃចាស់ទុំមួយចំនួន ដែលត្រូវបានយួនតែងតាំងឲ្យទទួលតំណែងធំៗនៅក្នុងបក្សកុម្មុនីស្តយួននោះ មានដូចជា ព្រះតេជព្រះគុណ សឺង វ៉ង់ បានទទួលមុខងារជា អនុប្រធានការពារសន្តិភាព និង ជាទីប្រឹក្សា នៃ "គណៈកម្មការរណសិរ្សមាតុភូមិជាតិ [យួន] រំដោះវៀតណាមខាងត្បូង" និង ព្រះតេជព្រះគុណ ហូវ ញ៉ែម បានទទួលមុខងារជា អនុប្រធាន "គ.រ.ម.ជ.រ.វ.ណ.ត." [131] ព្រះតេជព្រះគុណ ថាច់ សម បានទទួលមុខងារជា ប្រធាន "សមាគមព្រះសង្ឃសាមគ្គីស្នេហាជាតិ" [132] ប្រចាំតំបន់និរតីភាគខាងត្បូងវៀតណាម និង ព្រះតេជព្រះគុណ លុយ សារ៉ាត (Luy Sarat) បានទទួលមុខងារជាប្រធាន "រណសិរ្សជាតិ [យួន] រំដោះខេត្តត្រាវិញ" ។ បើតាមរបាយការណ៍នេះដដែលបានបញ្ជាក់ថា មេដឹកនាំកំពូលនៃលទ្ធិកុម្មុយនីស្តនៅក្នុងប្រទេសកម្ពុជា ក៏ជាមនុស្សដែលមានដើមកំណើតជាខ្មែរនៅដែនដីកម្ពុជាក្រោម ផងដែរ នោះគឺ សឺង ង៉ុក មិញ ឬ អាចារ្យ មៀន និង ទូ សាមុត ឬ អាចារ្យ សុខ ជាសហស្ថាបនិក នៃ គណបក្សបដិវត្តន៍ប្រជាជនខ្មែរ (Khmer People's Revolutionary Party) ។ គណបក្សនេះ បានបង្កើតឡើងនៅក្នុងខែសីហា ឆ្នាំ ១៩៥១ និងក្រោយមក បានក្លាយទៅជា គណបក្សប្រជាជនកម្ពុជា (CPP) នៃប្រទេសកម្ពុជាសព្វថ្ងៃ ។ សឺង ង៉ុក មិញ ឬ អាចារ្យ មៀន មានឈ្មោះជាភាសាយួនថា ផាម វ៉ាំង ហឿ (Phạm Văn Hứa) កើតឆ្នាំ ១៩២០ នៅខេត្តព្រះត្រពាំង ដែលមានឪពុកជាខ្មែរក្រោម និងម្តាយជាយួន ។ [133] របាយការណ៍ខាងលើដដែលបានបញ្ជាក់ថា នៅក្នុងសម័យសង្គ្រាម ទូទាំងកម្ពុជាក្រោម មានវត្តចំនួន ១១០ ត្រូវយៀកកុងយកធ្វើមូលដ្ឋានតស៊ូរបស់ខ្លួន និងខេត្តព្រះត្រពាំង មានពលរដ្ឋខ្មែរក្រោមជាសមាជិកបក្សកុម្មុយនីស្តយួន

[131] "គ.រ.ម.ជ.រ.វ.ណ.ត." អក្សរកាត់ "គណៈកម្មការរណសិរ្សមាតុភូមិជាតិរំដោះវៀតណាមខាងត្បូង" ។ ឈ្មោះដើមជាភាសាយួន "Mặt trận Dân tộc Giải phóng miền Nam Việt Nam" ជារណសិរ្សដែលបានបង្កើតដោយក្រុមយៀកកុងនៅកម្ពុជាក្រោម ដើម្បីប្រឆាំងនឹងរបបសាធារណរដ្ឋវៀតណាម និងទាហានសហរដ្ឋអាមេរិក នៅក្នុងសម័យសង្គ្រាមវៀតណាម ។

[132] "សមាគមព្រះសង្ឃសាមគ្គីស្នេហាជាតិ" ជាឈ្មោះសមាគមរបស់ព្រះសង្ឃខ្មែរនៅកម្ពុជាក្រោម ដែលរបបយួនកុម្មុយនីស្តសព្វថ្ងៃ ទទួលស្គាល់ជាផ្លូវការ និងអនុញ្ញាតឲ្យដំណើរការនៅក្រោមឆត្រ "សមាគមពុទ្ធសាសនាវៀតណាម" (Giáo hội Phật giáo Việt Nam) និង "រណសិរ្សមាតុភូមិវៀតណាម" (Mặt trận Tổ quốc Việt Nam) ។ នៅកម្ពុជាក្រោម សព្វថ្ងៃ គ្មានសមាគមសង្ឃឯករាជ្យដាច់ឡែករបស់ខ្លួនទេ ។

[133] Christopher E. Goscha, Thailand and the Southeast Asian Networks of the Vietnamese Revolution, 1885-1954, Routledge, 1999, ទំព័រ ៣៣៩

បានស្លាប់នៅក្នុងសមរភូមិចំនួន ១.២៤៧ នាក់ និងខេត្តលង់ហោរ ស្លាប់ចំនួន ១៤៧ នាក់ ដែលអ្នកទាំងនោះ ត្រូវបានរបបកុម្មុយនីស្តយួន សព្វថ្ងៃ ចាត់ទុកថាជាមនុស្ស ដែលបានពលីជីវិត ដើម្បីបុព្វហេតុជាតិរបស់គេ ។ [134]

**របបសាធារណរដ្ឋវៀតណាមត្រូវដួលរលំ ឆ្នាំ ១៩៧៥ របបយួនកុម្មុយនីស្តបន្តធ្វើអាណានិគមលើដែនដីកម្ពុជាក្រោម៖**

នៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៧៥ កងទ័ពយួនកុម្មុយនីស្ត [135] បានវាយសម្រុកចូលវិមានឯករាជ្យ (Dinh Độc Lập) ជាអគាររដ្ឋបាលរបស់រដ្ឋាភិបាលសាធារណរដ្ឋវៀតណាម ដែលមានទីតាំងនៅទីក្រុងព្រៃនគរ ហើយបានចាប់បង្ខំប្រធានាធិបតីយួនខាងត្បូង យឿង វ៉ាំង មិញ [136] ឲ្យប្រកាសចុះចាញ់ និងរំសាយរដ្ឋាភិបាលយួនខាងត្បូងដោយគ្មានលក្ខខណ្ឌ ក្នុងគោលបំណងអ្វីមួយដែលរបបយួនកុម្មុយនីស្តហៅថា "ដើម្បីបង្រួបបង្រួមជាតិ" និង "ជៀសវាងការបង្ហូរឈាម" រវាងយួននិងយួនគ្នាឯង ។ ពេលបានទទួលជ័យជម្នះភ្លាម ក្រុមយួនកុម្មុយនីស្តខាងត្បូងបានបង្កើតជារដ្ឋាភិបាលបណ្តោះអាសន្នមួយឈ្មោះថា "សាធារណរដ្ឋខាងត្បូងវៀតណាម" (Cộng hòa Miền Nam Việt Nam) ដែលមាន លោក ហ៊ិញ តឹង ផាត (Huỳnh Tấn Phát) ធ្វើជាប្រធានរដ្ឋបានមួយឆ្នាំ ។ នៅថ្ងៃទី ២ ខែកក្កដា ឆ្នាំ ១៩៧៦ របបយួនកុម្មុយនីស្តបានភ្ជាប់ទឹកដីកម្ពុជាក្រោមទៅនឹងទឹកដីយួនខាងជើងឲ្យរួមចូលគ្នាជាប្រទេសតែមួយដែលយួនហៅថា "ឯកភាពទឹកដី" (Thống nhất đất nước) និងបានបង្កើតជាប្រទេសយួនតែមួយមានឈ្មោះថា "សាធារណរដ្ឋសង្គមនិយមវៀតណាម" រហូតមកដល់ សព្វថ្ងៃ ។

---

[134] Sơn Phước Hoang, (2000). Vai trò của chùa đối với đời sống văn hóa của đồng bào Khmer Nam Bộ (ស្រង់ប្រភព៖ ០១ ធ្នូ ២០២០), https://bit.ly/33ClkDn

[135] កងទ័ពយួនកុម្មុយនីស្តដែលវាយចូលទីក្រុងព្រៃនគរផ្តួលរំលំរបបសាធារណរដ្ឋវៀតណាម នាពេលនោះ មាន ២ ក្រុម គឺ ទីមួយ "រណសិរ្សជាតិរំដោះវៀតណាមខាងត្បូង" (Mặt trận Dân tộc Giải phóng miền Nam Việt Nam) បានបង្កើតឡើងដោយក្រុមយៀកកុងដែលមានមូលដ្ឋាននៅកម្ពុជាក្រោម ឬ វៀតណាមខាងត្បូង និងទីពីរ "កងទ័ពប្រជាជនវៀតណាម" (Quân đội nhân dân Việt Nam) បានបង្កើតឡើងដោយរដ្ឋាភិបាលយួនកុម្មុយនីស្តខាងជើង "សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម" ។

[136] យឿង វ៉ាំង មិញ (Dương Văn Minh) ជាប្រធានាធិបតីចុងក្រោយបង្អស់ នៃរបបសាធារណរដ្ឋវៀតណាម ដែលបានឡើងកាន់តំណែងបានតែ ២ ថ្ងៃប៉ុណ្ណោះ គឺចាប់ពីថ្ងៃទី ២៨ ដល់ ៣០ ខែមេសា ឆ្នាំ ១៩៧៥ ។ ដោយសារចាញ់សង្គ្រាមជាបន្តបន្ទាប់ និងអាមេរិកលែងផ្តល់ជំនួយយោធាដល់របបសាធារណរដ្ឋវៀតណាម ប្រធានាធិបតី ង្វៀង វ៉ាំង ទេវ បានប្រកាសលាលែងពីតំណែងនៅថ្ងៃទី ២១ ខែមេសា ឆ្នាំ ១៩៧៥ ។

### ៤៥ ឆ្នាំ ក្រោមរបបយួនកុម្មុយនីស្ត (១៩៧៥ - បច្ចុប្បន្ន) ៖

របបសាធារណរដ្ឋវៀតណាមបានដួលរលំទៅ របបយួនកុម្មុយនីស្តបានចូលមកបន្តកាន់កាប់ និងធ្វើអាណានិគមលើដែនដីកម្ពុជាក្រោម នៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៧៥ ។ ចាប់តាំងពីពេលនោះមក ពលរដ្ឋនៅកម្ពុជាក្រោមបានចាប់ផ្តើមស្គាល់នូវរបបអាណានិគមថ្មីមួយទៀត នោះគឺ របបយួនកុម្មុយនីស្ត ដែលរដ្ឋាភិបាលមួយនេះបានដឹកនាំប្រទេសតាមរបៀបសង្គមនិយម ឬលទ្ធិកុម្មុយនីស្តម៉ាក្សឡេនីន ។ នៅទីសាធារណៈ និងទីប្រជុំរបស់រដ្ឋាភិបាល គេបានឃើញទង់ជាតិនៃរបបកុម្មុយនីស្តយួនពណ៌ក្រហមដែលមានផ្កាយពណ៌លឿង ទង់លទ្ធិកុម្មុយនីស្តពណ៌ក្រហមដែលមានសញ្ញាកណ្តៀវ និងញញួរ រូបមេលទ្ធិកុម្មុយនីស្តទាំងពីររូប គឺ កលម៉ាក្ស និង ឡេនីន ព្រមទាំងរូបមេដឹកនាំបក្សកុម្មុយនីស្តយួន ហូ ជី មិញ ។ ទីក្រុងព្រៃនគរ ដែលជនជាតិយួនធ្លាប់ហៅថា សាយហ្គន (Sài Gòn) ត្រូវរបបនេះប្តូរឈ្មោះទៅជាទីក្រុងហូជីមិញវិញ ផងដែរ ។

ពេលក្តាប់អំណាចបានពេញដៃហើយ របបយួនកុម្មុយនីស្តបានបោសសម្អាតនូវមនុស្សណាដែលជាប់ពាក់ព័ន្ធនឹងសង្គមចាស់ តាមរយៈការចាប់អ្នកទាំងនោះទៅធ្វើទារុណកម្មនៅក្នុងគុក ដែលភាសាយួនហៅថា “ឌីកាយតាវ” (Đi cải tạo) មានន័យថា “ទៅរៀនសូត្រ ឬទៅលត់ដំ” ។ ចំពោះខ្មែរក្រោមវិញ មុខព្រួញដែលរបបកុម្មុយនីស្តយួនត្រូវបោសសម្អាតនោះ រួមមាន មេដឹកនាំសង្ឃ, គ្រូបង្រៀនសាលាបាលីនៅតាមវត្តអារាម, អ្នកនយោបាយ, អ្នកធ្វើជារាជការ ឬជាទាហាននៅក្នុងរបបយួន ទេវ គី, អ្នកបង្កើតជាចលនាតស៊ូដើម្បីរំដោះទឹកដីកម្ពុជាក្រោម, អ្នកដែលហ៊ានចេញមុខធ្វើបាតុកម្ម និងបញ្ចេញមតិតាមអិនធើណែតអំពីបញ្ហាដែលរបបយួនកុម្មុយនីស្តរំលោភសិទ្ធិលើខ្មែរក្រោម ជាដើម ។ អ្នកដែលត្រូវរបបយួនកុម្មុយនីស្តចាប់ដាក់គុក និងត្រូវសម្លាប់នោះ មានដូចជា លោក សឺង ង៉ុក ថាញ់ ជាអ្នកនយោបាយដ៏ល្បីនៅកម្ពុជា ត្រូវចាប់ដាក់គុកជីហ្វា (Chí Hoà) ឆ្នាំ ១៩៧៥ និងត្រូវស្លាប់ឆ្នាំ ១៩៧៧, ព្រះតេជព្រះគុណ គឹម តុក ចើង ជាព្រះមេគណខេត្តព្រះត្រពាំង ត្រូវយួនធ្វើឃាតនៅក្នុងគុក ឆ្នាំ ១៩៨៦,

ព្រះតេជព្រះគុណ ថាច់ ស ជាព្រះឧបជ្ឈាយ៍វត្តកញ្ចោងកំពង់លាវ ត្រូវឃុំឃាំងនិងបង្គោលទង់នៅក្នុងវត្តនិងបាញ់សម្លាប់ ចោទពីបទជាប់ពាក់ព័ន្ធនឹងព្រឹត្តិការណ៍បះបោររំដោះទឹកដីកម្ពុជាក្រោម នៅក្នុងខេត្តព្រះត្រពាំងកាលពីឆ្នាំ ១៩៧៦, លោក ចៅ រៀប នៅខេត្តមាត់ជ្រូក ជាទាហានអាមេរិកក្នុងរបបសាធារណរដ្ឋវៀតណាម និងមានឋានៈជាអនុសេនីយ៍ឯក ត្រូវឃុំឃាំងចាប់ដាក់គុក និងធ្វើទារុណកម្ម ៧ ឆ្នាំ គឺចាប់ពីឆ្នាំ ១៩៧៥ ដល់ ១៩៨២ [137], លោក ថាច់ សេ (កាលនៅជាសង្ឃ) ជាអគ្គលេខាធិការសាលាគណ នៃគណៈពុទ្ធសាសនាថេរវាទខេត្តព្រះត្រពាំង និងជាសមណប្បាតុករ ធ្វើបាតុកម្មទាមទារឲ្យដោះលែងព្រះសង្ឃដែលត្រូវរបបឃុំឃាំង ទេវ គឺ ចាប់ទៅធ្វើជាទាហាននោះត្រូវរបបឃុំឃាំងកុម្មុយនីស្តចាប់ដាក់គុក ៥ ឆ្នាំ គឺចាប់ពីឆ្នាំ ១៩៧៥ ដល់ ១៩៨០ [138], ព្រះសង្ឃ ៥ អង្គ នៅខេត្តឃ្លាំង រួមមាន ភិក្ខុ គឹម មឿន, ភិក្ខុ យ៉ាញ តួន, ភិក្ខុ លី សឿង, ភិក្ខុ ថាច់ ធឿង និង ភិក្ខុ លី ហ្វាង ត្រូវរបបឃុំឃាំងចាប់ផ្សឹក និងដាក់គុកមួយអង្គៗពី ២ ទៅ ៤ ឆ្នាំ ជាប់ពាក់ព័ន្ធនឹងការធ្វើបាតុកម្មរបស់សមណសិស្សសាលាបាលីខេត្តឃ្លាំង ឆ្នាំ ២០០៧ [139] និង ព្រះតេជព្រះគុណ ទឹម សាខន ជាព្រះចៅអធិការវត្តភ្នំដិន នាស្រុកគិរីវង់ ខេត្តតាកែវ ដែលមានដើមកំណើតនៅខេត្តមាត់ជ្រូក ត្រូវមន្ត្រីសង្ឃខ្មែរនៃប្រទេសកម្ពុជា ចាប់ផ្សឹក និងបញ្ជូនទៅដាក់គុកឃុំឃាំងនៅដែនដីកម្ពុជាក្រោម នៅថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០០៧ និងបានដោះលែងឲ្យនៅក្រៅឃុំវិញនៅថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០០៨ [140] ។ ក្រៅពីនេះ មានមនុស្សជាច្រើនទៀត ត្រូវរងទារុណកម្មនៅក្នុងគុកឃុំឃាំង ដែលយើងមិនបានរៀបរាប់ឲ្យអស់នៅទីនេះ ។

តាំងពីឆ្នាំ ១៩៧៥ មកដល់ពេលបច្ចុប្បន្ននេះ ពលរដ្ឋខ្មែរក្រោមនៅតែបន្តភៀសខ្លួនចេញពីដែនដីកម្ពុជាក្រោមជាបន្តបន្ទាប់ ដើម្បីគេចចេញពីការធ្វើទុក្ខបុកម្នេញដោយរបបឃុំឃាំងកុម្មុយនីស្ត ។ ជនភៀសខ្លួនទាំងនោះ បានឧត្តមស្នងការអង្គការសហ

[137] ភិក្ខុ ថាច់ ប្រីជា គឿន (សុធម្មប្បញ្ញោ), (ព. ស. ២៥៦៤ - គ. ស. ២០២០), ជីវប្បវត្តិ លោក ចៅ រៀប ប្រធានសភាព្រឹទ្ធាចារ្យ នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម, សហរដ្ឋអាមេរិក, នាយកដ្ឋានព័ត៌មាន នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម, ទំព័រ ២១ - ២២

[138] ថាច់ សិរ, (១៩៩៧), ទុក្ខខ្មែរក្រោម, សហរដ្ឋអាមេរិក, មជ្ឈមណ្ឌលស្រាវជ្រាវ សឺង ង៉ុក ថាញ់, ក្របសៀវភៅខាងក្រោយ

[139], [140] ព្រះតេជព្រះគុណ សឺង យ៉ឹង រតនា, (ព. ស. ២៥៥៨ គ. ស. ២០១៤), ព្រឹត្តិបត្រ កម្ពុជាក្រោម, ឆ្នាំទី ១១ លេខពិសេស, សហរដ្ឋអាមេរិក, សហព័ន្ធខ្មែរកម្ពុជាក្រោម, ទំព័រ ៦១ - ៦៤, (ស្រង់ប្រភពៈ ៨ ធ្នូ ២០២០), http://bit.ly/3r1fcyx

ប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR) បញ្ជូនទៅតាំងទីលំនៅ នៅប្រទេសនានាក្នុងពិភពលោក ក្នុងនោះមាន សហរដ្ឋអាមេរិក, កាណាដា, អូស្ត្រាលី, អូទ្រីស, បារាំង, ដាណឺម៉ាក, អាល្លឺម៉ង់, អ៊ីតាលី, ជប៉ុន, ហុល្លង់, នូវែលសេឡង់, អង់គ្លេស, ស្វិស និងប្រទេសផ្សេងៗទៀត ។ [141] ក្រៅពីនេះ ក៏មានខ្មែរក្រោមជាច្រើន កំពុងតែរស់នៅស្របច្បាប់ក្នុងប្រទេសកម្ពុជា ផងដែរ ។ ពួកគាត់បានភៀសខ្លួនទៅប្រទេសកម្ពុជា ដោយមូលហេតុផ្សេងៗគ្នា ដូចជា គេចចេញពីការធ្វើទុក្ខបុកម្នេញដោយរបបយួនកុម្មុយនីស្តព្រោះបញ្ហានយោបាយ, ចង់កសាងជីវិតឲ្យប្រសើរឡើងនៅលើទឹកដីថ្មីព្រោះជីវភាពនៅស្រុកក្រីក្រ និងដើម្បីបន្តការសិក្សា ជាដើម ។ [142] នៅក្នុងខែធ្នូ ឆ្នាំ ២០២០ មានជនភៀសខ្លួនខ្មែរក្រោម នៅប្រទេសថៃ ប្រមាណ ៦៥ គ្រួសារ ដោយមានសមាជិកចំនួន ២០៧ នាក់ ដែលកំពុងតែស្វែងរកសិទ្ធិជ្រកកោននៅការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR) ។ [143]

ខែឧសភា ឆ្នាំ ១៩៧៥ មេដឹកនាំសង្ឃទាំងពីរគណៈគឺ ព្រះតេជព្រះគុណ ធម្មសាល ថាច់ រាជ ជាព្រះមេគណគណៈថេរវាទ ព្រះតេជព្រះគុណ ង៉ោ ស៊ីវ ជាព្រះមេគណគណៈខេមរនិកាយ ព្រះសង្ឃាធិបតី ថាច់ ងោស ព្រះមេគណរង ថាច់ ភឿន និង ព្រះអគ្គលេខាធិការ ថាច់ ហ្វាយ ត្រូវបានរដ្ឋាភិបាលបក្សកុម្មុយនីស្តយួនចាប់ដាក់គុកនិងធ្វើទារុណកម្ម ។ ក្រោយមក ពុទ្ធសាសនាទាំងពីរគណៈនេះ ត្រូវរបបយួនកុម្មុយនីស្តរំសាយចោល និងបានបង្កើតជានិកាយថ្មីមួយទៀតឈ្មោះថា “ពុទ្ធសាសនាគណៈមហានិកាយ” ដែលនិកាយមួយនេះ មានដំណើរការរហូតមកដល់សព្វថ្ងៃ ។ [144]

---

[141] សហព័ន្ធខ្មែរកម្ពុជាក្រោម, (៣ មករា ២០០៦), Khmer Krom People Statistics, (ស្រង់ប្រភព៖ ០៨ ធ្នូ ២០២០), https://bit.ly/2lx1Kkl

[142] គេនៅមិនទាន់បានឃើញសេចក្ដីរាយការណ៍ជាផ្លូវការណាមួយស្ដីពីចំនួនខ្មែរក្រោម ដែលរស់នៅក្នុងប្រទេសកម្ពុជានៅឡើយ ។ តាមការមើលឃើញជាក់ស្ដែង ខ្មែរក្រោមជាច្រើនតែងតែផ្លាស់ប្ដូរឈ្មោះ និងទីកន្លែងកំណើតរបស់ខ្លួន ដើម្បីសម្របខ្លួនឲ្យស្របតាមសង្គមខ្មែរ ពេលទៅរស់នៅក្នុងប្រទេសកម្ពុជា ។ បញ្ហានេះ នឹងធ្វើឲ្យពិបាកក្នុងការគណនាចំនួនខ្មែរក្រោមនៅកម្ពុជា ។ មូលហេតុនៃការភៀសខ្លួនរបស់ខ្មែរក្រោម បានមកពីការមើលឃើញជាក់ស្ដែង ។

[143] “ជនភៀសខ្លួនខ្មែរក្រោមបានទទួលអំណោយពីសប្បុរស”, Youtube, ផ្សព្វផ្សាយដោយ Voice of Kampuchea Krom, (០៨ ធ្នូ ២០២០), https://youtu.be/FZ2GyFUCu2k

[144] សហព័ន្ធខ្មែរកម្ពុជាក្រោម, (២០០៩), សៀវភៅមគ្គុទ្ទេសក៍ ផ្លូវទៅយកសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង, ទំព័រ ១៥៨

**ព្រឹត្តិការណ៍ ១៦ វិច្ឆិកា ១៩៧៦៖** [145]

នៅថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ១៩៧៦ "រណសិរ្សសេរីភាពជាតិរំដោះកម្ពុជាក្រោម" ដែលបានបង្កើតឡើងនៅខេត្តព្រះត្រពាំង ដោយ លោក សឺង ញ៉ុរ ហៅ នេន សុភី ជាប្រធាន និង លោក កៀង ហ៊ាន ជាអនុប្រធាន បានដឹកនាំសមាជិករបស់ខ្លួនក្រោកឡើងប្រយុទ្ធដោយកម្លាំងប្រដាប់អាវុធ ដើម្បីរំដោះកម្ពុជាក្រោមចេញពីនឹមអាណានិគមយួន ។ ការតស៊ូនេះ មិនបានជោគជ័យទេ ដោយសារកម្លាំងកងទ័ពរបស់រដ្ឋាភិបាលយួនច្រើនជាង ។ ទីបំផុត សមាជិកជាច្រើននៃរណសិរ្សនេះ ត្រូវរបបយួនកុម្មុយនីស្តចាប់ដាក់គុក កាត់ទោសប្រហារជីវិត និងធ្វើទារុណកម្មរហូតស្លាប់ក្នុងគុក ជាដើម ។ អ្នកដែលបានក្រោកឡើងប្រយុទ្ធជាមួយនឹងកងទ័ពយួន នាពេលនោះ ត្រូវបានខ្មែរក្រោមចាត់ទុកថាជា "វីរជនដែលបានបូជាជីវិតដើម្បីជាតិ" នៅដែនដីកម្ពុជាក្រោម ។ ខាងក្រោមនេះ ជាឆាកប្រយុទ្ធនានានៅក្នុងព្រឹត្តិការណ៍នេះ ។

**សមរភូមិនៅស្រុកកញ្ចោង (Tiểu Cần)៖**

ជាសមរភូមិមួយឈានមុខគេខាងក្លាហាន ដែលបានផ្ទុះអាវុធយ៉ាងសាហាវបំផុតវាយលុកលើកងទ័ពយួន ។ លោក ថាច់ ភី និងសមាជិកនៃរណសិរ្សសេរីភាពជាតិរំដោះកម្ពុជាក្រោម បានក្តាប់អាវុធបាញ់សំដៅទៅលើកងទ័ពយួននៅសាលាស្រុកកញ្ចោង បណ្តាលឲ្យកងទ័ពយួនស្លាប់ជាច្រើន កងទ័ពយួនខ្លះទៀតបានរត់ចេញមកក្រៅ ក៏ត្រូវសម្លាប់ដោយកាំបិត និងពូថៅ ។ លោក ថាច់ ភី និងសមាជិករបស់ខ្លួនពីររូបទៀតនៅលើស្ពែនទឹក (អាងស្តុបទឹក) ដែលមានអាវុធគ្រប់ធុន ដូចជា គ្រាប់បែក M79,12,8l បានបាញ់សំដៅចូលទៅសាលាស្រុក បណ្តាលឲ្យកម្មាភិបាលរបបយួនកុម្មុយនីស្តស្លាប់ និងរងរបួសជាច្រើន ។ ការផ្ទុះអាវុធចាប់ពីម៉ោង ៨ ព្រឹក ថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ១៩៧៦ លុះដល់ពេលរសៀល រដ្ឋាភិបាលបក្សកុម្មុយនីស្តយួន បាននាំកងទ័ពជំនួយរបស់ខ្លួនមកពីខេត្តលង់ហោរ (Vĩnh Long) ធ្វើអន្តរាគមន៍ មានទាំងរថក្រោះកាំភ្លើងធំមកផង ។ ពេលនោះ កម្លាំងតស៊ូរបស់ខ្មែរក្រោមមិនអាចទប់ទល់ នឹងកម្លាំងរបស់រដ្ឋាភិបាលយួន

[145] យោងតាមសៀវភៅ "កម្រងរឿងពិត នៃប្រវត្តិសាស្ត្រកម្ពុជាក្រោម ព្រឹត្តិការណ៍ ១៦ ខែវិច្ឆិកា ឆ្នាំ ១៩៧៦" ចងក្រងដោយ លោក កៀង ហ៊ាន ជាអនុប្រធាន នៃរណសិរ្សសេរីភាពជាតិរំដោះកម្ពុជាក្រោម ។

បានក៏នាំគ្នាដកថយ នៅសល់តែ ៣ នាក់ប៉ុណ្ណោះ ដែលនៅលើស្ពានទឹក ។ គ្រានោះ កងទ័ពយួនបានឡោមព័ទ្ធជុំវិញស្ពានទឹក ហើយបញ្ជាឲ្យរថក្រោះកាំភ្លើងធំបាញ់សម្រុក ចូលស្ពានទឹកធ្វើឲ្យ លោក ថាច់ ភី និងខ្មែរក្រោមពីររូបទៀតត្រូវស្លាប់នៅសមរភូមិ នេះ ។ ពេលបានឃើញរថក្រោះកំពុងតែបាញ់សម្រុកស្ពានទឹកដូច្នោះ លោក ថាច់ ភឿង និងកូនប្រុសរបស់គាត់ម្នាក់ទៀតឈ្មោះ ថាច់ ភឿន បានឱបគ្រាប់បែកលោត ឡើងលើរថក្រោះបោកធ្វើអត្តឃាត បណ្តាលឲ្យកងទ័ពយួនស្លាប់ជាច្រើន ។ អ្នកដែល បានស្លាប់នៅក្នុងសមរភូមិស្រុកកញ្ចោង មានជាង ៣០ អង្គ និង រូប ដែលមានរាយនាម ដូចតទៅះ

១. ព្រះតេជព្រះគុណ ថាច់ ស ជាព្រះចៅអធិការ និងព្រះឧបជ្ឈាយ៍ វត្តកញ្ចោង កំពង់លាវ ត្រូវយួនចងជាប់នឹងបង្គោលទង់ចំកណ្តាលវត្ត ហើយបាញ់ប្រហារជីវិត ។

២. ព្រះតេជព្រះគុណ គឹម ភិន

៣.លោក ថាច់ ភឿង

៤. លោក ថាច់ ភៀង

៥. លោក ថាច់ ភឿន (អ្នកទាំង ៣ នេះ ជាគ្រួសារតែមួយ គឺ ថាច់ ភឿង និង ថាច់ ភៀង ជាបងប្អូនបង្កើត ឯ លោក ថាច់ ភឿន ជាកូន របស់ ថាច់ ភឿង )

៦.លោក ថាច់ ភួង

៧.លោក ថាច់ ធី

៨.លោក ថាយ គី

៩.លោក ថាច់ ស

១០.លោក ថាច់ រើក

១១.លោក ថាច់ កេច

១២.លោក ថាច់ រ៉ង

១៣.លោក ត្រឹង ម៉ោ

១៤.លោក ថាច់ ថន

១៥.លោក ថាច់ អឹង

១៦.លោក ថាច់ ហឿង

១៧.កញ្ញា ឡឹម ធី ហាញ់

១៨.លោក ថាច់ ជ្រេង

១៩.លោក ថាច់ ង៉ុក ថាញ់

២០.លោក ថាច់ ផាន

២១.លោក ថាច់ ចយ

២២.លោក ថាច់ ខឿង

២៣.លោក ថាច់ នឹម

២៤.លោក ថាច់ ហែម

២៥.លោក តុង ជិន

២៦.លោក តុង តង

២៧.លោក ថាច់ អន

២៨. លោក ថាច់ ភី និងខ្មែរក្រោមពីររូបទៀត ត្រូវស្លាប់នៅលើអាងស្តុកទឹក ។

**សមរភូមិស្រុកចូវ (Trà Cú)៖**

លោក គឹម កែវ និង លោក គឹម គិន បានផ្តល់របាយការណ៍ពីសមរភូមិឃុំចុងព្រៃ ។ ឃុំចុងព្រៃជាឃុំមួយដែលទទួលរងគ្រោះធ្ងន់បំផុត ក្នុងចំណោម ឃុំផ្សេងទៀត នៅក្នុងស្រុកចូវ ។ អ្នកដែលបានស្លាប់នៅសមរភូមិ មានរាយនាមដូចខាងក្រោម៖

១.លោក គឹម សុខ (អាយុ ៦០ ឆ្នាំ)

២.លោក គឹម រី (ត្រូវជាកូនអាយុ ២១ ឆ្នាំ)

៣.លោក សឺន រាជ (អាយុ ៧១ ឆ្នាំ)

៤.លោក គឹម អាង (អាយុ ៥៤ ឆ្នាំ )

៥.លោក គឹម សាង (អាយុ ៥៣ ឆ្នាំ )

៦.លោក សឺន សេដ្ឋា (អាយុ ៥០ ឆ្នាំ)

៧.លោក គីម យ៉ង (អាយុ ៣៥ ឆ្នាំ )

៨.លោក គីម សាងតូច (អាយុ ៤៩ ឆ្នាំ)

៩.លោក ថាច់ ភឿង (អាយុ ៤៨ ឆ្នាំ)

១០.លោក ចន្ទ រង្សី (អាយុ ៥៤ ឆ្នាំ)

១១.លោក ថាច់ ហុង

១២.លោក ថាច់ សាង

១៣.លោក ធន សេរី

១៤.លោក ថាច់ សុខ

១៥.លោក ថាច់ រិន្ទ

១៦.លោក ថាច់ ឡឹង

១៧.លោក ថាច់ សេ

១៨.លោក ថាច់ ខ្លាំង

១៩.លោក ថាច់ ឃាង

២០.លោក ថាច់ ខ្មៅ ។ល។

**សមរភូមិទីរួមខេត្តព្រះត្រពាំងៈ**

លោក គីម ញ៉ បានជូនរបាយការណ៍ ពីសមរភូមិថា ចំនួនខ្មែរក្រោមដែលត្រូវកងទ័ពបក្សកុម្មុយនីសយួនសម្លាប់ដោយបាញ់ប្រហាររួមមានៈ

១. លោក គីម សាង វត្តកំពង់ជ្រៃ

២. លោក សឺន ហ្វួង វត្តកំពង់ជ្រៃ

៣. លោក គីម យ៉យ វត្តកំពង់ជ្រៃ

៤. កញ្ញា ត្រឿង តាន

៥. អ្នកនាង ផល្លា វត្តកំពង់ក្សាន្ត

៦. លោក ថាច់ ថា

៧. លោក សឺន ជុំ

៨. លោក ថាច់ ជ័រ (ស្លាប់ក្នុងគុក) វត្តកំពង់ជ្រៃ

៩. លោក ថាច់ ច្រើន

១០. លោក ថាច់ ចឹង

១១.លោក ថាច់ ហឿង វត្តពោធិសាលរាជ (កំពង់)

១២.លោក សឺន គក់ វត្តសិលាទ្រ (ថ្មទល់)

ក្រោយពីព្រឹត្តិការណ៍នេះ មេដឹកនាំនៃ រណសិរ្សសេរីភាពជាតិរំដោះកម្ពុជាក្រោម ត្រូវយួនចាប់ដាក់ពន្ធនាគារជាច្រើនរូប ។ បន្ទាប់ពីបានជាប់គុកអស់ ៤ ឆ្នាំ នៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៨០ របបយួនកុម្មុយនីស្តបានបញ្ជូនខ្មែរក្រោមចំនួន ២០ រូប ឡើងកាត់ទោសនៅទីរួមខេត្តព្រះត្រពាំង ។ អ្នកទាំងនោះរួមមានៈ

**កាត់ទោសប្រហារជីវិតៈ**

១.លោក ថាច់ គិន

២.លោក ថាច់ ឃាក

៣.លោក គឹម រី

**កាត់ទោសជាប់គុកមួយជីវិតៈ**

៤.លោក សឺន ញ៉ុរ

៥.លោក កៀង ហ៊ាន

៦.លោក កៀង ស្មុន

៧.លោក កៀង សឺង

៨.លោក ថាច់ ជេន

៩.លោក ថាច់ សិន

**កាត់ទោសជាប់គុក ២០ ឆ្នាំៈ**

១០.លោក យឿង បាន

១១.លោក ថាច់ លួត

១២.លោក គឹម អាន

**កាត់ទោសជាប់គុក ១៥ ឆ្នាំ៖**

១៣.លោក ថាច់ មុនី

១៤.លោក ថាច់ នឹម

១៥.លោក ថាច់ ប្រុស

១៦.លោក គឹម កែវ

១៧.លោក គឹម យ៉ឹង

**កាត់ទោសជាប់គុក ១៣ ឆ្នាំ៖**

១៨.លោក ថាច់ ម៉ារី

**កាត់ទោសជាប់គុក ៥ ឆ្នាំ៖**

១៩.លោក ថាច់ ឬទ្ធី

**កាត់ទោសជាប់គុក ៣ ឆ្នាំ៖**

២០.លោក ថាច់ សាម៉ន

ថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ១៩៨១ លោក ថាច់ គិន, ថាច់ ឃាក និង គឹម វី ដែលរបបយួនកុម្មុយនីស្តយួនកាត់ទោសប្រហារជីវិតនោះ បាននាំទៅបាញ់ប្រហារនៅព្រលានយន្តហោះខេត្តព្រះត្រពាំង ក្រោយពីត្រូវបានជាប់គុក និងបរិភោគបាយនឹងទឹកអំបិលអស់រយៈពេលជិត ២ ឆ្នាំ ។

**ករណី កាសេហាសិប (KC-50)**

នៅពាក់កណ្តាលទសវត្សរ៍ ឆ្នាំ ១៩៨០ រដ្ឋាភិបាលវៀតណាមបានអនុវត្តនូវគោលនយោបាយបង្ក្រាបលើពលរដ្ឋខ្មែរក្រោមដោយសង្ស័យថា មានទំនាក់ទំនងនឹងចលនាសម្ងាត់ដើម្បីផ្តួលរំលំរបបយួនកុម្មុយនីស្ត ។ បើតាមសាស្ត្រាចារ្យ Ian Harris ជាអ្នកសិក្សាអំពីពុទ្ធសាសនា និងភាសាសំស្ក្រឹត បានបញ្ជាក់នៅក្នុងសៀវភៅ “ពុទ្ធសាសនាក្រោមរបបប៉ុលពត” (Buddhism Under Pol Pot) ថា៖

*“នៅពេលនោះ ដើម្បីអាចនិមន្តទៅទីកន្លែងផ្សេងៗបាន ព្រះសង្ឃខ្មែរក្រោមត្រូវមានលិខិតសម្គាល់ខ្លួន ។ នៅឆ្នាំ ១៩៨៤ បណ្ណាល័យនៅ*

*តាមវត្តអារាមជាច្រើនត្រូវរឹបអូស និងព្រះសង្ឃដែលពាក់ព័ន្ធនឹងការបង្រៀន អំពីពុទ្ធសាសនា និងវប្បធម៌ខ្មែរត្រូវគេចាប់ដាក់គុក ។ វាហាក់ដូចជាជនជាតិ យួនជឿថា ខ្មែរក្រោមបានចូលរួមនៅក្នុងចលនាផ្តួលរំលំមួយ ដែលពួកគេ ហៅថា កាសេហាសិប (KC-50) ។ ចលនានេះត្រូវបានគេសន្មតថា មានការ គាំទ្រដោយសហរដ្ឋអាមេរិក និងមានគម្រោងបង្កើតឡើងវិញនូវរដ្ឋាភិបាលថ្មី មួយដែលមិនមែនកុម្មុយនីស្ត ...”* ។ [145]

របបយួនកុម្មុយនីស្តបានចោទ ព្រះតេជព្រះគុណ គឹម តុក ចើង (កន្តធម្មោ) ជាព្រះមេគណខេត្តព្រះត្រពាំងថា ជាមេខ្លោងនៅក្នុងព្រឹត្តិការណ៍ KC-50 និងបានចាប់ព្រះអង្គយកទៅធ្វើទារុណកម្មនៅក្នុងគុកអស់ ២ ឆ្នាំ ១ ខែ ៥ ថ្ងៃ រហូតដល់សុគតនៅក្នុងគុក នៅថ្ងៃព្រហស្បតិ៍ ២ រោច ខែមិគសិរ ឆ្នាំខាល អដ្ឋស័ក ព. ស. ២៥៣០ ត្រូវនឹងថ្ងៃទី ១៨ ខែធ្នូ គ. ស. ១៩៨៦ ក្នុងជន្មាយុ ៥១ ឆ្នាំ ។ ព្រះតេជព្រះគុណ គឹម តុក ចើង ប្រសូតនៅឆ្នាំ ១៩៣៥ នៅភូមិដំបងពាក់ ឃុំរំដួល ស្រុកចូវ ខេត្តព្រះត្រពាំង និងបានសាងផ្នួសនៅវត្តសុវណ្ណទេព្វឯករិមលារាម (ដំបងពាក់) ជាវត្តមួយឋិតនៅក្នុងភូមិកំណើតរបស់ព្រះអង្គ ។ ក្រោយឆ្នាំ ១៩៧៥ ក្នុងឋានៈជាព្រះមេគណខេត្តព្រះត្រពាំង ព្រះអង្គបានបំផុសគំនិត និងចលនាឲ្យព្រះសង្ឃគ្រប់វត្តអារាមទូទាំងខេត្ត បើកសាលារៀនផ្នែកពុទ្ធិកសិក្សា និងអក្សរសាស្ត្រខ្មែរមានការរីកចម្រើនគួរឲ្យកត់សម្គាល់ ដែលធ្វើឲ្យរបបយួនកុម្មុយនីស្តបង្កើតជាព្រឹត្តិការណ៍ KC-50 ដើម្បីបំផ្លិចបំផ្លាញនូវការអភិវឌ្ឍរបស់ខ្មែរក្រោម ។ [146] ពេលធ្វើឃាតរួច យួនបានបញ្ជូនសាកសព ព្រះតេជព្រះគុណ គឹម តុក ចើង សងមកគ្រួសារវិញ ដោយបានដាក់ចូលទៅក្នុងក្ដារមឈូសមួយ ដែលមានរចនាប័ទ្មបែបយួន និងបានបិទត្រាហាមបើកមើល តែក្រុមគ្រួសារ និងពលរដ្ឋខ្មែរក្រោមនៅតែជម្នះបើកមើលឲ្យទាល់តែបាន ។ ពលរដ្ឋខ្មែរក្រោមបានលើកឡើងថា យួនបានធ្វើឃាតព្រះអង្គដោយវិធីវះពោះ ។ [147]

[145], [147] HRW, On the Margins Rights Abuses of Ethnic Khmer in Vietnam’s Mekong Delta (2009), ទំព័រ ១៨

[146] ថាច់ ប្រីជា គឿន, (១៧ ធ្នូ ២០១៦), “ព្រះតេជព្រះគុណ គឹម តុក ចើង (កន្តធម្មោ) ដែលត្រូវយួនសម្លាប់ក្នុងគុក”, សំឡេងកម្ពុជាក្រោម (VOKK), (ស្រង់ប្រភព៖ ១០ ធ្នូ ២០២០), https://vokk.net/kim-toc-chon

វិធីដែលរបបយួនកុម្មុយនីស្តបានធ្វើទារុណកម្មលើខ្មែរក្រោមនៅក្នុងគុក ក្នុងករណី KC-50 នោះ រួមមាន៖

- ឆក់ខ្សែភ្លើង ។
- ចងជើងព្យួរឡើងលើ ក្បាលសំយុងចុះក្រោម ។
- ខ្នោះជើងដៃជាប់ ឲ្យមូសខាំ ។
- ច្រកគុកងងឹត និងគ្មានខ្យល់អាកាសចេញចូល (ក្លិនស្អុយតែលាមក) ។
- យកដបវាយឆ្អឹងខ្នង ដើមទ្រូង ហើយចាក់ទឹកត្រីចូលតាមរន្ធច្រមុះ ។
- ច្រកក្នុងធុងសាំង រួចយកដំបងវាយពីក្រៅ ។ល។

វិធីធ្វើទារុណកម្មបែបនេះ ដើម្បីបង្ខំឲ្យពលរដ្ឋខ្មែរក្រោមទទួលទោសថា ខ្លួនបានចូលរួមបង្កើតជា រណសិរ្សសាមគ្គីរំដោះកម្ពុជាក្រោម ។

អ្នកដទៃទៀត ដែលត្រូវរបបយួនកុម្មុយនីស្តសម្លាប់ និងធ្វើទារុណកម្មដោយវិធីប្រហាក់ប្រហែលគ្នានោះ រួមមាន ព្រះតេជព្រះគុណ គឹម សាង ព្រះតេជព្រះគុណ ថាច់ កា ព្រះតេជព្រះគុណ ថាច់ ចៀន និង លោក ថាច់ ភោគ ។ ក្រៅពីនេះ ក៏មានពលរដ្ឋខ្មែរក្រោមធ្វើជាកម្មាភិបាលក្នុងរបបយួនកុម្មុយនីស្តចំនួន ៧ រូបទៀត ដែលត្រូវយួនសម្លាប់ដែរនោះ រួមមាន លោក គឹម សុវណ្ណ លោក ថាច់ ជ័រ លោក ថាច់ ជុំ លោក ថាច់ គង់ លោក គឹម ថា លោក គឹម ផាង និង លោក គឹម កុង ។ [148]

លោក ថាច់ ភោគ ត្រូវចាប់ដាក់គុកជាលើកទី ២ ពីឆ្នាំ ១៩៨៥ ដល់ ១៩៨៧ និងត្រូវយួនធ្វើទារុណកម្មដោយវិធីចងជើងព្យួរឡើងលើ ក្បាលសំយុងចុះក្រោម និងវះពោះរហូតដល់ស្លាប់នៅក្នុងគុក ។ លោក ថាច់ ភោគ កើតនៅភូមិព្រៃកឈូក ស្រុកផ្សារថ្មី (Tam Binh) ខេត្តលង់ហោរ និងបានសាងផ្នួសនៅវត្តសាលវនឧទ្យាន (ព្រៃកឈូក) ជាវត្តមួយឋិតនៅក្នុងភូមិកំណើតរបស់ខ្លួន ។ ឆ្នាំ ១៩៧៤ កាលនៅជាសង្ឃ លោកបានទទួលឋានៈជានាយករងនៃគណៈពុទ្ធសាសនាថេរវាទ ដែលមានការិយាល័យនៅក្នុងវត្តចន្ទរង្សី ទីក្រុងព្រៃនគរ ។ លោកត្រូវរបបយួនកុម្មុយនីស្តចាប់ដាក់គុកលើកទីមួយចាប់ពីឆ្នាំ ១៩៧៥ ដល់ ១៩៨០ ។ ពេលបានចេញពីគុក លោកបានរៀបការជាមួយនឹង

[148] សហព័ន្ធខ្មែរកម្ពុជាក្រោម, (២០០៩), សៀវភៅមគ្គុទ្ទេសក៍ ផ្លូវទៅយកសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង, ទំព័រ ១៦៥ - ១៦៧

ស្ត្រីម្នាក់ឈ្មោះ ធីតា និងបានរស់នៅជាមួយគ្នាបានមួយរយៈខ្លី ក៏ត្រូវយួនចាប់ដាក់គុកជាលើកទីពីរ ។ [149]

ឆ្នាំ ១៩៨៥ របបយួនកុម្មុយនីស្តបានចាប់ ព្រះតេជព្រះគុណ ធម្មវិរិយោ គឹម សាង ដាក់គុកលើកទីពីរ និងបានដោះលែងវិញ នៅខែធ្នូ ឆ្នាំ ១៩៨៧ ។ ពេលបានចេញពីគុកមិនយូរប៉ុន្មាន ព្រះអង្គបានសុគតនៅក្នុងឆ្នាំ ១៩៨៨ ។ ព្រះអង្គជាសង្ឃនាយកនៃគណៈពុទ្ធសាសនាថេរវាទ ដែលមានការិយាល័យនៅវត្តចន្ទរង្សី នាទីក្រុងព្រៃនគរ ។ ព្រះអង្គប្រសូតនៅឆ្នាំ ១៩២២ និងបានសាងផ្នួសនៅវត្តពោធិវង្សកំពង់ដូង ជាវត្តមួយបិតនៅភូមិកំណើតរបស់ខ្លួន នៅស្រុកកញ្ជោង ខេត្តព្រះត្រពាំង ។ [150]

ក្រៅពីនេះ មានមនុស្សជាច្រើនទៀត ដែលរងគ្រោះនៅក្នុងព្រឹត្តិការណ៍ KC-50 ដែលយើងមិនបានចារឈ្មោះឲ្យអស់នៅទីនេះ ដោយអ្នកទាំងនោះ អ្នកខ្លះត្រូវស្លាប់ និងត្រូវរងទារុណកម្មនៅក្នុងគុក និងអ្នកខ្លះទៀត បានចេញពីគុកហើយ បានភៀសខ្លួនទៅនៅប្រទេសកម្ពុជា និងប្រទេសដទៃទៀត ។

បន្ទាប់ពីបានចាប់ព្រះសង្ឃ និងបញ្ញវន្តខ្មែរក្រោមដាក់គុក ធ្វើទារុណកម្ម និងសម្លាប់រួចហើយ របបយួនកុម្មុយនីស្តបានចេញមកបកស្រាយថា អំពើដែលខ្លួនបានធ្វើលើខ្មែរក្រោមនោះ គ្រាន់តែជាការយល់ច្រឡំតែប៉ុណ្ណោះ ។ ករណីជាក់ស្តែង ដូចជាការធ្វើឃាត ព្រះតេជព្រះគុណ គឹម តុក ចើង ជាដើម យួនបានបកស្រាយថា បក្សបានសម្លាប់ច្រឡំ និងបានសងប្រាក់ជំងឺចិត្តដល់គ្រួសាររបស់ព្រះអង្គចំនួន ២ លានដុង ។

ក្រោយមកទៀត ការិយាល័យស៊ើបអង្កេតជាន់ខ្ពស់ (Viện Kiểm Sát Nhân Dân Tối Cao) របស់របបយួនកុម្មុយនីស្តបានសើរើករណី KC-50 ឡើងវិញ និងបានបញ្ជាក់ថា ករណី KC-50 ដែលបានកើតឡើងនៅក្នុងខេត្តកូវឡុង (Cửu Long) [151] មានពលរដ្ឋខ្មែរក្រោមប្រមាណជិត ២០០ នាក់ ត្រូវចាប់ខ្លួនទាំងអយុត្តិធម៌ និងអ្នកទាំងនោះ

[149] "វីរសមណៈខ្មែរក្រោម", ឯកសារ (PDF) ជាភាសាអង់គ្លេសដែលបានរៀបរៀងដោយ លោក ថាច់ សេ ។

[150] "ជីវប្រវត្តិ ព្រះតេជព្រះគុណ គឹម សាង, ឯកសារ (PDF) រៀបរៀងដោយ លោក ថាច់ សេ

[151] Cửu Long ជាខេត្តមួយរួបរួមដោយ ខេត្តព្រះត្រពាំង និង ខេត្តលង់ហោរ ចូលគ្នា ដែលយួនបានបង្កើតឡើងក្រោយឆ្នាំ ១៩៧៥ និងក្រោយមក បានរំសាយចេញឲ្យនៅជា ២ ខេត្ត ដូចដើមវិញ ។

គ្មានទោសកំហុសអ្វីសោះឡើយ ។ [152]

របបយួនកុម្មុយនីស្តបានបង្កើតព្រឹត្តិការណ៍ KC-50 ដើម្បីសម្លាប់ខ្មែរក្រោមនោះ វាដូចជាការសាបព្រោះនូវពូជគំនិត និងស្មារតីនៃការស្អប់ខ្ពើមរបស់ខ្មែរក្រោម លើពូជអម្បូរយួន និងបក្សកុម្មុយនីស្តយួនកាន់តែខ្លាំងឡើងៗពីជំនាន់មួយទៅជំនាន់មួយមិនសាបសូន្យឡើយ ។ បើយោងតាមរបាយការណ៍មួយស្តីពី ជីវភាពរបស់ខ្មែរក្រោមនៅក្នុងខេត្តព្រះត្រពាំង ពីឆ្នាំ ១៩៩២ ដល់ ២០១០ ដោយ "គណៈកម្មការឃោសនាខេត្តត្រាវិញ" ជាស្ថាប័នមួយរបស់របបកុម្មុយនីស្តយួន បានបញ្ជាក់ថា៖

*" លទ្ធផលនៃករណី KC-50 និង 91/6B នៅតែបន្តជះឥទ្ធិពលអាក្រក់ដល់សតិអារម្មណ៍ និងស្មារតីរបស់ព្រះសង្ឃ, ប្រជាពលរដ្ឋ និងកម្មាភិបាលខ្មែរនៅក្នុងខេត្ត ។ ពួកគេនៅតែមិនយល់នូវគោលការណ៍, មាគ៌ារបស់បក្ស, គោលនយោបាយ និងច្បាប់របស់រដ្ឋអំពីបញ្ហាជនជាតិ ។ ក្រុមប្រតិកិរិយានៅក្នុង និងក្រៅប្រទេស នៅតែមិនបោះបង់នូវល្បិចកលពិសពុល ដើម្បីបំបែកសាមគ្គីភាពរវាងបក្ស, រដ្ឋាភិបាល, កម្មាភិបាល, ព្រះសង្ឃ និងជនជាតិខ្មែរជាមួយនឹងជនជាតិយួន (Kinh) ជាដើម ។.... ស្ថានភាពការធ្វើបាបប្រជាជននៅតែបន្តកើតឡើងដដែល"* ។ [153]

**ករណី រណសិរ្សតស៊ូខ្មែរកម្ពុជាក្រោម នៅខេត្តទឹកខ្មៅ៖**

នៅថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ ១៩៨៥ លោក ថាច់ ញ៉ កើតឆ្នាំ ១៩៥៩ នៅខេត្តទឹកខ្មៅ ជាប្រធានរណសិរ្សចលនាតស៊ូខ្មែរកម្ពុជាក្រោម ពីឆ្នាំ ១៩៧៥ ដល់ ១៩៨៥ ត្រូវរបបយួនកុម្មុយនីស្តកាត់ទោសឲ្យជាប់គុក ១៨ ឆ្នាំ តែជាប់បានតែ ១២ ឆ្នាំ ប៉ុណ្ណោះ ។ ពេលបានចេញពីគុក លោកបានភៀសខ្លួនទៅប្រទេសកម្ពុជា នៅឆ្នាំ ២០០០ ហើយបានសុំសិទ្ធិជ្រកកោននៅការិយាល័យ UNHCR នៅភ្នំពេញ នាឆ្នាំ ២០០៥ ។ [154]

---

[152] TRẦN HÙNG, (២០ មេសា ២០១៥), Bức cung nhục hình dẫn đến oan sai và món nợ của công lý, Hội Cựu Chiến Binh TP.HCM., (ស្រង់ប្រភព៖ ១១ ធ្នូ ២០២០), https://bit.ly/377gbW4

[153] Ban Tuyên giáo Tỉnh ủy Trà Vinh, (១៩ ឧសភា ២០១៦), "Đồng bào Khmer tỉnh Trà Vinh..." (1992 – 2010),(ស្រង់ប្រភព៖ ១១ ធ្នូ ២០២០), https://bit.ly/2KfU0nu

[154] សម្ភាសន៍ លោក ថាច់ ញ៉ នៅភ្នំពេញ កាលពីឆ្នាំ ២០០៥ ។

**ករណី ភិក្ខុ ថាច់ លីភោ នៅខេត្តព្រះត្រពាំង ឆ្នាំ ២០០៥៖**

យប់ថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០០៥ របបយួនកុម្មុយនីស្តបានចាប់ ភិក្ខុ **ថាច់ លី ភោ** (Thach Ly Pho) ផ្សឹក នៅវត្តនិគ្រោធកំពង់ក្សាន្ត នាទីរួមខេត្តព្រះត្រពាំង ចោទពីបទ "ធ្វើសកម្មភាពប្រឆាំងរដ្ឋាភិបាលយួន" និងបានបញ្ជូនទៅដាក់គុកអស់ ៣ ខែ ១៨ ថ្ងៃ ។ សកម្មភាពដែលរបបយួនកុម្មុយនីស្តចាត់ទុកថា "ប្រឆាំងរដ្ឋាភិបាល" នោះ ដោយសារ ភិក្ខុ ថាច់ លីភោ បានផ្សព្វផ្សាយ (ចែកចាយជាសម្ងាត់) នូវឯកសារមួយចំនួនដែលបាន ផលិតដោយ សហព័ន្ធខ្មែរកម្ពុជាក្រោម នៅក្រៅប្រទេស ក្នុងនោះ មានថតចម្លងនូវ សៀវភៅប្រវត្តិសាស្រ្តកម្ពុជាក្រោមដែលមានចំណងជើងថា "ទុក្ខខ្មែរក្រោម", ថាស់ ស៊ីឌី (CD) ចម្រៀងជាតិនិយមខ្មែរក្រោម និងវីស៊ីឌី (VCD) វីដេអូប្រណាំងទូក ង ដែល ក្រុមកីឡារបស់ សហព័ន្ធខ្មែរកម្ពុជាក្រោម បានចូលរួមប្រណាំងជាលក្ខណៈអន្តរជាតិ នៅទីក្រុង Philadelphia សហរដ្ឋអាមេរិក កាលពីឆ្នាំ ២០០១ ។

ពេលបានចេញពីគុក លោក ថាច់ លីភោ បានភៀសខ្លួនទៅប្រទេសកម្ពុជា និងបាន សាងផ្នួសឡើងវិញនៅក្នុងវត្តមួយនាទីក្រុងភ្នំពេញ ។ ក្រោយមក លោកបានបន្តភៀស ខ្លួនទៅប្រទេសថៃ នៅឆ្នាំ ២០០៧ និងបានឧត្តមស្នងការអង្គការសហប្រជាជាតិទទួល បន្ទុកជនភៀសខ្លួន (UNHCR) បញ្ជូនទៅតាំងទីលំនៅ នៅសហរដ្ឋអាមេរិក កាលពីឆ្នាំ ២០១២ ។ [155]

ករណី ភិក្ខុ ថាច់ លីភោ បានធ្វើឲ្យព្រះសង្ឃ និងពលរដ្ឋខ្មែរក្រោមមួយចំនួន ដែល ជាប់ពាក់ព័ន្ធ បានភៀសខ្លួនទៅប្រទេសកម្ពុជា ។ ថ្ងៃទី ០១ ខែសីហា ឆ្នាំ ២០០៥ ជន ភៀសខ្លួនខ្មែរក្រោមប្រមាណ ៨៧ រូប ក្នុងនោះ មានព្រះសង្ឃ ១៥ អង្គ និងគ្រហស្ថ ៧២ នាក់ ដែលស្នាក់នៅក្នុងវត្តសាមគ្គីរង្សី ក្នុងសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ ទីក្រុងភ្នំពេញ ដឹកនាំដោយ ភិក្ខុ ថាច់ ប្រីជា គឿន ជាប្រធានជនភៀសខ្លួន និង លោក ថៅ សំអឿន ជាអនុប្រធាន បានជួបជុំគ្នានៅលើចិញ្ចើមផ្លូវអស់ ១ យប់ ២ ថ្ងៃ នៅមុខ ទីស្នាក់ការ នៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR)

[155] ថាច់ ប្រីជា គឿន, (២០ សីហា ២០១២), 'លោក ថាច់ លីភោ បានចេញទៅតាំងទីលំនៅ នៅប្រទេសទី ៤', សំឡេងកម្ពុជាក្រោម, www.vokk.net/thach-ly-pho

ដើម្បីស្នើសុំឋានៈជាជនភៀសខ្លួន និងស្នើ UNHCR ផ្តល់ជម្រក (ជំរំជនភៀសខ្លួន) ឲ្យពួកគាត់បានស្នាក់នៅសមរម្យ ។

ដោយសារមានការតវ៉ាជាបន្តបន្ទាប់ពីជនភៀសខ្លួន ទើបនៅថ្ងៃទី ៤ ខែសីហា ឆ្នាំ ២០០៥ ការិយាល័យ UNHCR ប្រចាំទីក្រុងភ្នំពេញ បានចេញលិខិតមួយច្បាប់ ចុះលេខ CAM/PROT/05/134 ស្តីអំពី "**ការបិទនៃនីតិវិធីសុំសិទ្ធិជ្រកកោន**" ជាជនភៀសខ្លួនរបស់ពលរដ្ឋខ្មែរក្រោមនៅកម្ពុជា ។ ខ្លឹមសារនៃលិខិតនេះមានពីរភាសា (អង់គ្លេស-ខ្មែរ) មានសេចក្តីថា៖

*"UNHCR ត្រូវបានទទួលដំណឹងដោយរដ្ឋាភិបាលកម្ពុជាថា បងប្អូនខ្មែរកម្ពុជាក្រោមដែលបានមកពីប្រទេសវៀតណាម ត្រូវបានស្វាគមន៍ឲ្យស្នាក់នៅក្នុងប្រទេសកម្ពុជា និងត្រូវបានចាត់ទុកជាពលរដ្ឋកម្ពុជា ។ ដូច្នេះ បងប្អូនខ្មែរកម្ពុជាក្រោម ដែលបានចុះបញ្ជីដោយ UNHCR នឹងមិនឋិតនៅក្នុងអាណត្តិរបស់អង្គការនេះទៀតឡើយ ។ ចំពោះជំនួយតទៅមុខទៀត សូមធ្វើទំនាក់ទំនងផ្ទាល់ជាមួយអាជ្ញាធរកម្ពុជា"* ។[156]

ក្រុមជនភៀសខ្លួនខាងលើសុទ្ធតែបានលើកឡើងថា ពួកគាត់បានភៀសខ្លួនចេញពីកម្ពុជាក្រោម ដោយសាររបបឃុនកុម្មុយនីស្តស្វែងរកចាប់ខ្លួន ចោទពីបទចែកចាយ និងមើលនូវឯកសារដែលបានផលិតដោយ សហព័ន្ធខ្មែរកម្ពុជាក្រោម ។ ឯកសារទាំងនោះ រួមមាន ថាស់ស៊ីឌីចម្រៀងជាតិនិយមខ្មែរក្រោម, វីស៊ីឌី (VCD) វីដេអូប្រណាំងទូក-ង ដែលក្រុមកីឡាទូក-ង នៃសហព័ន្ធខ្មែរកម្ពុជាក្រោម បានប្រណាំងជាលក្ខណៈអន្តរជាតិនៅសហរដ្ឋអាមេរិក និងព្រឹត្តិបត្រ "កម្ពុជាក្រោម" ដែលបានបោះពុម្ពជារៀងរាល់ខែ ។[157]

### ចលនា "សម្ព័ន្ធជាតិនិយមខ្មែរកម្ពុជាក្រោម"៖

នៅថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០០៥ ព្រះសង្ឃមួយក្រុមនៅកម្ពុជាក្រោម និងកម្ពុជា បានរួបរួមគ្នាបង្កើតជាចលនាមួយឈ្មោះ "សម្ព័ន្ធជាតិនិយមខ្មែរកម្ពុជាក្រោម" ដើម្បីធ្វើ

[156] លិខិត 'ការបិទនៃនីតិវិធីសុំសិទ្ធិជ្រកកោន' របស់ UNHCR ចុះថ្ងៃទី ៤ ខែសីហា ឆ្នាំ ២០០៥ ជូនជនភៀសខ្លួនខ្មែរក្រោម ។
[157] 'លិខិតស្នើសុំឋានៈជាជនភៀសខ្លួន' ឆ្នាំ ២០០៥ ដែលជនភៀសខ្លួនខ្មែរក្រោមនៅភ្នំពេញបានដាក់ជូន UNHCR ។

សកម្មភាពគាំទ្រនូវការតស៊ូរបស់សហព័ន្ធខ្មែរកម្ពុជាក្រោម ។ នៅប្រទេសកម្ពុជា គណៈកម្មការនៃចលនានេះ ដឹកនាំដោយ ភិក្ខុ ថាច់ កុង ផួង ស្នាក់នៅវត្តទួលសង្កែ ជាប្រធាន និង ភិក្ខុ ថាច់ ប្រីជា គឿន ស្នាក់នៅវត្តសាមគ្គីរង្សី ជាអនុប្រធាន ។ ចំណែកនៅកម្ពុជាក្រោម ភិក្ខុ គឹម ស៊ីសំណា ស្នាក់នៅវត្តមុនីសាគរដើមអំពិល ខេត្តឃ្លាំង ធ្វើជាប្រធាន ។ ចលនានេះ ធ្វើសកម្មភាពនាំយកនូវឯកសារផ្សេងៗ ដែលបានផលិតដោយសហព័ន្ធខ្មែរកម្ពុជាក្រោម មាន ព្រឹត្តិបត្រ "កម្ពុជាក្រោម", ថាស់ស៊ីឌី (CD) និង វីស៊ីឌី (VCD) ជាដើម ពីប្រទេសកម្ពុជាទៅផ្សព្វផ្សាយនៅកម្ពុជាក្រោម ។ ក្រោយមក គណៈកម្មការនៃចលនានេះ បានប្រកាសរំសាយនូវរចនាសម្ព័ន្ធរបស់ខ្លួន នៅឆ្នាំ ២០០៧ នៅក្នុងកិច្ចប្រជុំសម្ងាត់មួយនៅក្នុងវត្តភ្នំជិនខាងជើង ស្រុកគិរីវង់ ខេត្តតាកែវ ដើម្បីចៀសវាងការចោទប្រកាន់ពីរដ្ឋាភិបាលនៃប្រទេសកម្ពុជាពីបទ "ប្រើប្រាស់ទឹកដីប្រឆាំងនឹងប្រទេសជិតខាង" ។

ព្រះតេជព្រះគុណ ថាច់ កុង ផួង (Thạch Cung Phuông) កើតថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៧៦ ជាកូនរបស់ លោក ថាច់ កុង និង អ្នកស្រី ថាច់ ធី ឡុង នៅភូមិស្វាយមីង ស្រុកកញ្ចោង ខេត្តព្រះត្រពាំង ។ មុនពេលភៀសខ្លួនទៅកម្ពុជា ព្រះអង្គជាចៅអធិការវត្តកញ្ចោងកំពង់លាវ ជាវត្តមួយឋិតនៅក្នុងស្រុកកំណើតរបស់ខ្លួន ។ បន្ទាប់ពីចលនា "សម្ព័ន្ធជាតិនិយមខ្មែរកម្ពុជាក្រោម" បានរំសាយ ព្រះតេជព្រះគុណ ថាច់ កុង ផួង បានបន្តភៀសខ្លួនទៅប្រទេសថៃ និងបានដាក់ពាក្យស្នើសុំឋានៈជាជនភៀសខ្លួននយោបាយនៅការិយាល័យ UNHCR ។ ក្រោយមក នៅថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០១៣ អាជ្ញាធរខ្មែរបានសហការជាមួយនឹងអាជ្ញាធរថៃ ទៅឡោមព័ទ្ធវត្តមួយឋិតនៅក្នុងខេត្តនន្ទបុរី ជាទីដែល ព្រះតេជព្រះគុណ ថាច់ កុង ផួង ស្នាក់នៅ និងបានចាប់បញ្ជូនទៅដាក់គុកនៅស្រុកខ្មែររហូតមកដល់សព្វថ្ងៃ ។ តុលាការខ្មែរបានចោទប្រកាន់ ព្រះតេជព្រះគុណ ថាច់ កុង ផួង ពីបទប្រឆាំង ឬប៉ុនប៉ងផ្តួលរំលំរដ្ឋាភិបាលកម្ពុជា តាមរយៈចលនាមួយឈ្មោះ "រណសិរ្សរំដោះជាតិខ្មែរ" ដែលមានមូលដ្ឋាននៅក្រៅប្រទេស ។ [158]

[158] វណ្ណ វិចារ, (១៦ មីនា ២០១៣), កម្ពុជាចាប់ជនភៀសខ្លួនខ្មែរនៅថៃ ៦ នាក់ ចោទប៉ុនប៉ងផ្តួលរំលំរដ្ឋាភិបាល, វិទ្យុអាស៊ីសេរី, (ស្រង់ប្រភព៖ ១៥ ធ្នូ ២០២០), https://bit.ly/3agsLUL

**ករណី ភិក្ខុ គឹម ស៊ីសំណា ឆ្នាំ ២០០៦៖**

នៅព្រឹកថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០០៦ របបយួនកុម្មុយនីស្តបានកោះហៅ ព្រះតេជព្រះគុណ គឹម ស៊ីសំណា ទៅសួរចម្លើយនៅមន្ទីរធម្មការខេត្តឃ្លាំង (Ban Tôn Giáo Tỉnh Sóc Trăng) អំពីចលនា “សម្ព័ន្ធជាតិនិយមខ្មែរកម្ពុជាក្រោម” ដែលបានបង្កើតឡើងនៅដែនដីកម្ពុជាក្រោម ។

វត្តមាននៃកម្មាភិបាលរបបយួនកុម្មុយនីស្តដែលបានសួរចម្លើយ ព្រះតេជព្រះគុណ គឹម ស៊ីសំណា រួមមាន លោក ឡឹម រ៉ែន (Lâm Ren) ជាប្រធានមន្ទីរធម្មការខេត្តឃ្លាំង, លោក សឺង ថាន់ (Sơn Thanh) ជាអ្នកទទួលបន្ទុកកិច្ចការសាសនា និង លោក ង្វៀង វ៉ាំង ហ៊ឹង (Nguyễn Văn Hưng) ជាតំណាងក្រសួងសាសនារបស់រដ្ឋាភិបាលយួន ។

នៅចំពោះមុខកម្មាភិបាលរបបយួនកុម្មុយនីស្ត ព្រះតេជព្រះគុណ គឹម ស៊ីសំណា បានលើកឡើងថា ព្រះអង្គមានបំណងចង់តំណាងពលរដ្ឋខ្មែរកម្ពុជាក្រោម បង្កើតជារដ្ឋាភិបាលមួយ “សម្រេចវាសនាខ្លួនដោយខ្លួនឯង” គ្របដណ្តប់ទូទាំង ២១ ខេត្តក្រុងនៅដែនដីកម្ពុជាក្រោម ។ ឆ្លើយតបនឹងសំណួរដែលកម្មាភិបាលយួនសួរថា តើចលនារបស់ព្រះអង្គមានឈ្មោះដូចម្តេចដែរ ? ព្រះតេជព្រះគុណ គឹម ស៊ីសំណា បានឆ្លើយថា ឈ្មោះ “សម្ព័ន្ធជាតិនិយមខ្មែរកម្ពុជាក្រោម” ជាភាសាយួនឈ្មោះ “Liên Hiệp Chủ Nghĩa Dân Tộc Khmer Kampuchea Krom” ។ ព្រះអង្គបានលើកឡើងទៀតថា ទោះបីច្បាប់នៅក្នុងប្រទេសវៀតណាមមិនអនុញ្ញាតឲ្យចលនានេះ ធ្វើសកម្មភាពយ៉ាងណាក៏ដោយ តែបើតាមច្បាប់អន្តរជាតិគ្មានខុសច្បាប់អ្វីឡើយ ។

ដោយសារមិនអាចទទួលបាននូវការធ្វើទុក្ខបុកម្នេញ បំបិទសិទ្ធិសេរីភាព និងគំរាមកំហែងពីរបបយួនកុម្មុយនីស្ត ព្រះតេជព្រះគុណ គឹម ស៊ីសំណា បានសម្រេចចិត្តភៀសខ្លួនទៅប្រទេសកម្ពុជា និងបានដាក់ពាក្យបណ្តឹងប្តឹងទៅការិយាល័យស្នងការជាន់ខ្ពស់នៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ប្រចាំកម្ពុជា នៅថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០០៦ អំពីករណីដែលរបបយួនបានរំលោភបំពានសិទ្ធិលើព្រះអង្គ ។ (159)

[159] ព្រឹត្តិបត្រស្រាវជ្រាវ គូស្រះស្រី, (ឆ្នាំទី ១ លេខ ៨, ខែធ្នូ ឆ្នាំ ២០០៦), កំណត់ហេតុ (Biên Bản Làm Việc) ជាភាសាយួន ដែលកម្មាភិបាលយួនសួរចម្លើយ ភិក្ខុ គឹម ស៊ីសំណា ថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០០៦, (ស្រង់ប្រភព៖ ១៥ ធ្នូ ២០២០), http://bit.ly/3oTXYRL

ព្រះតេជព្រះគុណ គឹម ស៊ីសំណា កើតនៅឆ្នាំ ១៩៨២ នៅភូមិស្វាយមីង ស្រុកកញ្ចោង ខេត្តព្រះត្រពាំង និងបានសាងផ្នួសនៅវត្តកញ្ចោងកំពង់លាវ ។ នៅឆ្នាំ ២០១២ ព្រះតេជព្រះគុណ គឹម ស៊ីសំណា បានលាចាកសិក្ខាបទ (សឹក) មកជាគ្រហស្ថវិញ និងសព្វថ្ងៃ កំពុងតែរស់នៅក្នុងប្រទេសកម្ពុជា ។

**ករណី ភិក្ខុ [160] ស៊ឺន ចែងចើន, ភិក្ខុ ថាច់ ធន និង ភិក្ខុ សឺន លំអាន ឆ្នាំ ២០០៧៖**

ថ្ងៃទី ១៧ ខែមករា ភិក្ខុ ថាច់ ធន ជាព្រះសង្ឃវត្តកញ្ចោងកំពង់លាវ ស្រុកកញ្ចោង ខេត្តព្រះត្រពាំង ត្រូវនគរបាលរបបយួនកុម្មុយនីស្ត ស្រុកកញ្ចោង ស្កាត់ចាប់តាមផ្លូវ ខណៈដែលលោកកំពុងជិះម៉ូតូនាំយក ព្រឹត្តិបត្រ “កម្ពុជាក្រោម” ចំនួន ៦០ ក្បាលដែលបានបោះពុម្ពដោយ សហព័ន្ធខ្មែរកម្ពុជាក្រោម ទៅចែកដល់ព្រះសង្ឃជាសម្ងាត់ ។

ដោយបានឃើញនគរបាលយួនចាប់ ភិក្ខុ ថាច់ ធន ដូច្នោះ ពីរថ្ងៃក្រោយមក គឺនៅថ្ងៃទី ១៩ ខែមករា ភិក្ខុ ស៊ឺន ចែងចើន (Sơn Cheng Chơn) បានដឹកនាំសមណសិស្សដែលកំពុងតែរៀនសាលាពុទ្ធិកអនុវិទ្យាល័យទី ៤ (បាលីរង) នៅវត្តកំពង់ជ្រៃ ចំនួន ៤០ អង្គ និងមានការចូលរួមពីព្រះសង្ឃវត្តផ្សេងៗមួយចំនួនទៀត ចេញដំណើរពីវត្តកំពង់ជ្រៃ ក្នុងស្រុកកំពង់ធំ (Châu Thành) ឆ្ពោះទៅសាលាស្រុកនៃស្រុកកញ្ចោង (Uỷ Ban Nhân Dân Huyện Tiểu Cần) ដើម្បីទាមទារឲ្យរបបយួនកុម្មុយនីស្តដោះលែង ភិក្ខុ ថាច់ ធន ហៅ ថាច់ ខែត្រ ឲ្យមានសេរីភាព តែយួនមិនព្រមដោះលែងឡើយ ។

ពេលបានទទួលដំណឹងនេះ ព្រះសង្ឃមួយក្រុមនៅភ្នំពេញ នៃប្រទេសកម្ពុជា បានសរសេរញត្តិ ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ ២០០៧ ក្នុងនាមតំណាងព្រះសង្ឃ និងពលរដ្ឋខ្មែរក្រោម ផ្ញើទៅសាលាក្រុងភ្នំពេញ ដើម្បីស្នើសុំធ្វើបាតុកម្មដោយអហិង្សានៅមុខស្ថានទូតយួន តែសំណើនេះមិនបានអនុញ្ញាតឡើយ ។ ទោះបីយ៉ាងនេះក្តី ក៏នៅថ្ងៃទី ២០ ខែមករា ព្រះសង្ឃចំនួន ៨ អង្គ ដែលស្នាក់នៅវត្តនានា ក្នុងទីក្រុងភ្នំពេញ បានទៅប្រមូលផ្តុំគ្នាតាមកាលកំណត់នៅមុខស្ថានទូតយួន និងបានផ្ញើញត្តិទៅរដ្ឋាភិបាលយួនតាមរយៈមន្ត្រីស្ថានទូត អំពាវនាវឲ្យរបបយួនឈប់ជាបន្ទាន់នូវការរំលោភសិទ្ធិមនុស្ស

[160] “ភិក្ខុ” អានថា “ភិក-ខុ” ឬ “ភិក” មានន័យថា សមណៈអ្នកសូម, សមណៈអ្នកខ្លាចភ័យក្នុងវដ្តសង្សារ, អ្នកខ្លាចបាបជានិច្ច, អ្នកមានព្យាយាមដុតបំផ្លាញអំពើអាក្រក់... ។ ជាពាក្យសម្រាប់ហៅចំពោះតែបុរសអ្នកបួសដែលមានភេទឧត្តមជាងសាមណេរ ។

លើជនជាតិដើមខ្មែរក្រោម ។

ញត្តិអំពាវនាវ ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ ២០០៧ ដែលមានចំណងជើងថា “*សេចក្តីអំពាវនាវរបស់ព្រះសង្ឃ និងប្រជាពលរដ្ឋខ្មែរក្រោមនៅប្រទេសកម្ពុជា ទៅរដ្ឋាភិបាលអាណានិគមវៀតណាម ឲ្យគោរពសិទ្ធិខ្មែរក្រោមម្ចាស់ស្រុក*” មានសេចក្តីថា៖

*“ក្នុងនាមព្រះសង្ឃ និងប្រជាពលរដ្ឋខ្មែរក្រោមដែលបានភៀសខ្លួនមកជ្រកកោនរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជានេះ សូមអំពាវនាវដល់រដ្ឋាភិបាល នៃប្រទេសសាធារណរដ្ឋសង្គមនិយមវៀតណាម ត្រូវតែបញ្ឈប់ជាបន្ទាន់នូវការរំលោភសិទ្ធិមនុស្សជាមូលដ្ឋានមកលើខ្មែរក្រោម មានដូចជា៖*

- *បញ្ឈប់ជាបន្ទាន់នូវការចាប់ខ្លួនព្រះសង្ឃ និងប្រជាពលរដ្ឋខ្មែរក្រោមយកទៅឃុំឃាំង និងសួរចម្លើយ ដោយគ្រាន់តែព្រះសង្ឃ និងពលរដ្ឋខ្មែរក្រោមទាំងនោះអាននូវប្រវត្តិសាស្ត្ររបស់ខ្លួនប៉ុណ្ណោះ ។*
- *ដោះលែងព្រះសង្ឃព្រះនាម ថាច់ ធន ដែលត្រូវបានចាប់ទៅឃុំឃាំងកាលពីវេលាម៉ោង ០៦ ល្ងាច ថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០០៧ កន្លងទៅនេះជាបន្ទាន់ ។*
- *សងមកវិញនូវឧបករណ៍ដូចជា ម៉ាស៊ីន Camera វីដេអូ ១ គ្រឿង និងម៉ាស៊ីន Camera ថតរូប ២ គ្រឿង ដែលរដ្ឋាភិបាលវៀតណាមបានរឹបអូសយកពីព្រះសង្ឃ ថាច់ ធន” ។*[161]

ទោះបីមានការតវ៉ាយ៉ាងនេះក្តី របបយួនកុម្មុយនីស្តនៅតែបង្ក្រាបដោយការចាប់ព្រះសង្ឃផ្សឹកជាបន្តបន្ទាប់ ។ ព្រះសង្ឃដែលត្រូវចាប់ផ្សឹកនោះ រួមមាន៖

១. ភិក្ខុ ថាច់ ធន វត្តកញ្ចោងកំពង់លាវ

២. ភិក្ខុ សឺន តឿង វត្តកញ្ចោងកំពង់លាវ

៣. សាមណេរ ថាច់ រតនា វត្តកញ្ចោងកំពង់លាវ

[161] ព្រឹត្តិបត្រស្រាវជ្រាវ គូស្រះស្រី, (ឆ្នាំទី ២ លេខ ១០, ខែមករា ឆ្នាំ ២០០៧), សេចក្តីអំពាវនាវរបស់ព្រះសង្ឃ និងពលរដ្ឋខ្មែរក្រោមនៅប្រទេសកម្ពុជា ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ ២០០៧, ទំព័រ ៨, (ស្រង់ប្រភព៖ ១៦ ធ្នូ ២០២០), http://bit.ly/3mqER0j

៤. ភិក្ខុ ស៊ីន លំអាន វត្តផ្ទៅសង្គ្រម ស្រុកកញ្ចោង ខេត្តព្រះត្រពាំង

៥. ភិក្ខុ ស៊ីន ចែងចើន វត្តផ្ទៅអណ្តែត ស្រុកកំពង់ធំ ខេត្តព្រះត្រពាំង ។

ភិក្ខុ ស៊ីន ចែងចើន ត្រូវចាប់ផ្សឹកនៅក្នុងវត្តផ្ទៅអណ្តែត នៅថ្ងៃទី ២២ ខែមេសា ឆ្នាំ ២០០៧ បន្ទាប់ពីអាជ្ញាធរយួនបានឃុំឃាំងព្រះអង្គឲ្យស្នាក់នៅក្នុងវត្តមួយអស់រយៈពេលជាង ៣ ខែ ក្រោមការឃ្លាំមើល និងតាមដានយ៉ាងតឹងរ៉ឹងពីនគរបាលយួន ។

នៅក្នុងកិច្ចប្រជុំវិនិច្ឆ័យទោសមួយដែលបានធ្វើនៅវត្តពោធិសាលរាជ (កំពង់) នៅថ្ងៃទី ២៩ ខែមីនា ឆ្នាំ ២០០៧ ក្រុមនគរបាលយួនបានលើកឡើងថា ភិក្ខុ ស៊ីន ចែងចើន អាចប្រឈមនឹងទោសជាប់គុកចំនួន ២០ ឆ្នាំ ពីបទ "ផ្សព្វផ្សាយនូវឯកសារដែលមានខ្លឹមសារប្រឆាំងនឹងរបបយួន ដូចជា និពន្ធជាកំណាព្យ សរសេរអត្ថបទ និងធ្វើបាតុកម្ម ជាដើម ។

ព្រះសង្ឃ និងកម្មាភិបាលនៃរបបយួនកុម្មុយនីស្ត ដែលបានចាប់បង្ខំ ភិក្ខុ ស៊ីន ចែងចើន ផ្សឹកនោះ រួមមាន ព្រះតេជព្រះគុណ ថាច់ សុខ សាន្ត, ថាច់ សាង ថឿង, ថាច់ ហ្វាយ, គឹម ថន, ថាច់ សួង, លោក ស៊ើង កាង, ស៊ើង សុង ស៊ើង, ឡឹម ភូ, ថាច់ មិញ ម៉ឹង, ហ៊ុញ ភឿក ឡុង និង ស៊ើង ហ៊ើន ។

ភិក្ខុ ស៊ីន ចែង ចើន កើតឆ្នាំ ១៩៨៥ នៅភូមិផ្ទៅអណ្តែត ឃុំកំពង់ទូក ស្រុកកំពង់ធំ ខេត្តព្រះត្រពាំង និងបានសាងផ្នួសនៅវត្តពោធិទេពចេតិយារាម (ផ្ទៅអណ្តែត) ជាវត្តមួយបិតនៅក្នុងភូមិកំណើត នៅក្នុងឆ្នាំ ២០០២ ។ [162]

ពីរខែបន្ទាប់ពីរបបយួនចាប់ផ្សឹក លោក ស៊ីន ចែងចើន បានភៀសខ្លួនទៅប្រទេសកម្ពុជា ហើយបានសាងផ្នួសឡើងវិញនៅវត្តអង្គតាមិញ នៅថ្ងៃទី ៩ ខែធ្នូ ឆ្នាំ ២០០៧ ។ ក្រោយមក លោកបានលាចាកសិក្ខាបទ (សឹក) មកជាគ្រហស្ថវិញ នៅថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ២០១២ ។ សព្វថ្ងៃ លោក ស៊ីន ចែងចើន មានតួនាទីជាចាងហ្វាង សារព័ត៌មានព្រៃនគរ ជាស្ថាប័នព័ត៌មានមួយស្តីពីខ្មែរក្រោមដែលមានមូលដ្ឋាននៅកម្ពុជា ។ [163]

[162] ស៊ីន ចែងចើន, (ព. ស. ២៥៥៨ - គ. ស. ២០១៤), "កំណត់ហេតុរបស់ លោក ស៊ីន ចែង ចើន ជាអតីតព្រះសង្ឃដែលត្រូវយួនចាប់ផ្សឹក", ព្រឹត្តិបត្រ កម្ពុជាក្រោម, ឆ្នាំទី ១១ លេខពិសេស, ទំព័រ ៦៧ - ៧៣, (ស្រង់ប្រភព៖ ១៦ ធ្នូ ២០២០), http://bit.ly/3r1fcyx

[163] "សារព័ត៌មាន ព្រៃនគរ" បានបង្កើតឡើងនៅថ្ងៃទី ១ ខែមករា ២០០៨ ដោយមាន ព្រះតេជព្រះគុណ សឺង យ៉ឹង រតនា ជាអភិបាល, លោក លី ឈួន ជាចាងហ្វាង (២០១០ - ២០១៤), លោក ស៊ីន ចែង ចើន ជាចាងហ្វាង (២០១៤ - បច្ចុប្បន្ន) ។ www.preynokornews.info

ថ្ងៃទី ៣០ ខែឧសភា ឆ្នាំ ២០០៦ ពលរដ្ឋខ្មែរក្រោមទាំង ៣ រូប គឺ លោក ថៅ សុខ, លោក ថៅ ចៀង, លោក ថៅ សៀម នៅភូមិពោធិ (Pothi) ស្រុកក្របៅ (Tịnh Biên) ខេត្តមាត់ជ្រូក (An Giang) ត្រូវអាជ្ញាធរយួនឃុំអាងគឺ ធ្វើទារុណកម្មរហូតដល់សន្លប់បាត់ស្មារតី ដោយចោទប្រកាន់ថា អ្នកទាំងនេះបានមើលនូវឯកសារវីស៊ីឌី (VCD) ដែលបានផលិតដោយផលិតកម្មខ្មែរក្រោមស្តីពី សហព័ន្ធខ្មែរកម្ពុជាក្រោម ចូលប្រជុំនៅក្នុងវេទិកាអចិន្ត្រៃយ៍ នៃអង្គការសហប្រជាជាតិស្តីពីបញ្ហាជនជាតិដើម (UNPFII) នៅការិយាល័យអង្គការសហប្រជាជាតិ នាទីក្រុង New York សហរដ្ឋអាមេរិក ។

**"ព្រឹត្តិការណ៍ ៨ កុម្ភៈ" ឆ្នាំ ២០០៧៖**

ថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ ២០០៧ សមណសិស្ស នៃសាលាបាលី [164] មួយ ដែលមានមូលដ្ឋាននៅក្នុងវត្តឃ្លាំងប្រមាណ ២០០ អង្គ បានចេញធ្វើបាតុកម្មនៅមុខការិយាល័យនគរបាលយួនខេត្តឃ្លាំង ដើម្បីទាមទារឲ្យរបបយួនកុម្មុយនីស្តគោរពសិទ្ធិខ្មែរក្រោមជាម្ចាស់ស្រុកនៃដែនដីកម្ពុជាក្រោម ។ មានការលើកឡើងថា មូលហេតុដែលនាំឲ្យមានបាតុកម្មនេះ ដោយសារនគរបាលចរាចរណ៍យួនបានឡោមព័ទ្ធវត្តឃ្លាំង និងហាមឃាត់ព្រះសង្ឃនិមន្តចេញទៅបិណ្ឌបាត ។ ក្រោយបាតុកម្ម ព្រះសង្ឃជាច្រើនត្រូវរបបយួនចាប់ផ្សឹក និងដាក់ពន្ធនាគារ ចោទពីបទ "ធ្វើឲ្យខូចសណ្តាប់ធ្នាប់ទីសាធារណៈ" ។ សព្វថ្ងៃ ព្រះសង្ឃដែលបានចូលរួមធ្វើបាតុកម្មនៅក្នុងព្រឹត្តិការណ៍នេះ ខ្លះកំពុងតែរស់នៅក្នុងស្រុក ខ្លះរស់នៅក្នុងប្រទេសកម្ពុជា ខ្លះនៅថៃ និងខ្លះទៀត បានឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR) បញ្ជូនទៅនៅបរទេស ។

ព្រះសង្ឃដែលត្រូវរបបយួនចាប់ផ្សឹកនោះ រួមមាន ភិក្ខុ លី សឿង ហៅ ធឿន, ភិក្ខុ ថាច់ ធឿង និង ភិក្ខុ លី ធន ស៊ួយ (វត្តទឹកប្រៃ), ភិក្ខុ គឹម មឿន និង ភិក្ខុ ថាច់ ឌើ (វត្តសិរីតាសេក), ភិក្ខុ ថាច់ ស្វឹង ហៀង និង ភិក្ខុ តាំង ថេន (វត្តសេរីតាម៉ឺន), ភិក្ខុ លី ហ្វាង និង លី តឹង ផុង (វត្តសំរោង) និង ភិក្ខុ យ៉ាញ តូន (វត្តការន្តចាស់) ។

---

[164] សាលានេះពីមុនឈ្មោះថា "សាលាបាលីជាន់ខ្ពស់ខេត្តឃ្លាំង" តែក្រោយមក បានប្តូរឈ្មោះទៅជា "សាលាមធ្យមសិក្សាបំពេញវិជ្ជាណាមបូ" (Trường Bổ Túc Văn Hóa Pali Trung Cấp Nam Bộ) ។ សាលានេះបានបង្កើតឡើងនៅថ្ងៃទី ៧ ខែធ្នូ ឆ្នាំ ១៩៩៤ ជារបៀបអន្តេវាសិកដ្ឋាន ដើម្បីឲ្យព្រះសង្ឃនិមន្តមកពីខេត្តនានាទូទាំងដែនដីកម្ពុជាក្រោមរៀនភាសាបាលី និងចំណេះវិជ្ជាចាប់ពីថ្នាក់ទី ៦ ដល់ ១២ ជាភាសាយួន ។

ក្រោយមក នៅថ្ងៃទី ១០ ខែឧសភា ឆ្នាំ ២០០៧ តុលាការនៃរបបយួនកុម្មុយនីស្ត បានផ្តន្ទាទោសព្រះសង្ឃ ៥ អង្គ ឲ្យជាប់ពន្ធនាគារមួយអង្គៗ ពី ២ ទៅ ៤ ឆ្នាំ ពីបទ “ធ្វើឲ្យខូចសណ្តាប់ធ្នាប់ទីសាធារណៈ” ។ ព្រះសង្ឃទាំង ៥ អង្គនោះ រួមមាន៖

១. ភិក្ខុ យ៉ញ តូន ៤ ឆ្នាំ (ដោះលែង ថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០០៩)

២. ភិក្ខុ គឹម មឿន ៤ ឆ្នាំ (ដោះលែង ថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០០៩)

៣. ភិក្ខុ ថាច់ ធឿង  ៣ ឆ្នាំ (ដោះលែង ថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០០៩)

៤. ភិក្ខុ លី ហ្វាង ២ ឆ្នាំ  (ដោះលែង ថ្ងៃទី ២០ ខែមករា ឆ្នាំ ២០០៩)

៥. ភិក្ខុ លី សឿង ហៅ ធឿន ២ ឆ្នាំ (ដោះលែង ថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០០៨) ។

ពេលបានចេញពីពន្ធនាគារ ព្រះសង្ឃទាំង ៥ នេះ បានភៀសខ្លួនទៅប្រទេសថៃ និងបានអង្គការ UNHCR បញ្ជូនទៅនៅបរទេស កាលពីឆ្នាំ ២០០៩ ។ [165]

ក្រៅពីនេះ  មានព្រះសង្ឃមួយចំនួនទៀត  ដែលបានភៀសខ្លួនចេញពីកម្ពុជាក្រោម ដោយសារ  “ព្រឹត្តិការណ៍  ៨  កុម្ភៈ”  និងបានសឹកទៅជាគ្រហស្ថ  ដែលកំពុងតែរស់នៅនិរទេសរហូតមកដល់សព្វថ្ងៃ  រួមមាន៖

១. ភិក្ខុ ថាច់ ឌើ (វត្តសិរីតាសេក) នៅប្រទេសអូស្ត្រាលី

២.ភិក្ខុ ភឿង សុង (តារា) (វត្តកោះទុង) នៅប្រទេសកម្ពុជា

៣. ភិក្ខុ ថាច់ ស្វឹង ហៀង (វត្តសេរីតាម៉ឺន) នៅសហរដ្ឋអាមេរិក

៤. ភិក្ខុ ថាច់ ស៊ីណាន (វត្តសង់ច្រវាថ្មី) នៅប្រទេសកម្ពុជា

៥. ភិក្ខុ ចៅ សុខ (វត្តពោធិ៍លាស់) នៅប្រទេសថៃ

៦. ភិក្ខុ ទ្រីវ មិញ ភូ (សួន បូរ៉ា) (វត្តដើមអម្ពិល) នៅសហរដ្ឋអាមេរិក

៧. ភិក្ខុ លី វ៉ាន (វត្តទឹកប្រៃ) នៅអូស្ត្រាលី ។ល។

**បាតុកម្មរបស់ខ្មែរក្រោមក្រៅប្រទេសថ្កោលទោសរបបយួន៖**

ក្រោយ “ព្រឹត្តិការណ៍ ៨ កុម្ភៈ” ព្រះសង្ឃ និងពលរដ្ឋខ្មែរក្រោមនៅប្រទេសកម្ពុជា និងបរទេសបានធ្វើបាតុកម្មជាបន្តបន្ទាប់ ដើម្បីថ្កោលទោសការរំលោភសិទ្ធិមនុស្សលើខ្មែរក្រោម ដូចជាការចាប់ព្រះសង្ឃផ្សឹក ជាដើម ។ នៅប្រទេសកម្ពុជា បាតុកម្មបានធ្វើ

[165] សហព័ន្ធខ្មែរកម្ពុជាក្រោម, (២០០៩), សៀវភៅមគ្គុទ្ទេសក៍ ផ្លូវទៅយកសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង, ទំព័រ ១៧៨ - ១៨០

នៅទីតាំងមួយចំនួន ក្នុងទីក្រុងភ្នំពេញ ដូចជាៈ

លើកទី ១ៈ មុខស្ថានទូតយួន ធ្វើនៅថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ ២០០៧ ។

លើកទី ២ៈ ក្នុងវត្តសាមគ្គីរង្សី ធ្វើនៅថ្ងៃទី ២ ខែមីនា ឆ្នាំ ២០០៧ ។

លើកទី ៣ៈ មុខស្ថានទូតយួន, មុខព្រះបរមរាជវាំង និងមុខស្ថានទូតអាមេរិក ធ្វើនៅថ្ងៃទី ២០ ខែមេសា ឆ្នាំ ២០០៧ ។

ញត្តិដែលព្រះសង្ឃ និងពលរដ្ឋខ្មែរក្រោម ជូនចំពោះស្ថានទូតយួន ស្ថាប័នព្រះមហាក្សត្រខ្មែរ មន្ត្រីស្ថានទូតសហរដ្ឋអាមេរិក និងអង្គការអន្តរជាតិនានា នៅក្នុងថ្ងៃបាតុកម្មលើកទីបី និងត្រូវបាន ភិក្ខុ ហ៊ុល ភិរម្យ អានជាសាធារណៈ នៅចំពោះមុខអ្នកកាសែតនោះ បានអំពាវនាវឲ្យរបបយួនបញ្ឈប់ជាបន្ទាន់ នូវទង្វើរំលោភសិទ្ធិមនុស្សលើខ្មែរក្រោម ចំនួន ៦ ចំណុច ក្នុងនោះរួមមាន ករណីចាប់ខ្លួន លោក ថៅ ធឿន នៅខេត្តមាត់ជ្រូក, លោក ឌិញ សុធី នៅខេត្តឃ្លាំង, នគរបាលយួនឡោមព័ទ្ធវត្តឃ្លាំង ហាមព្រះសង្ឃនិមន្តចេញទៅបិណ្ឌបាត នៅថ្ងៃទី ៨ ខែកុម្ភៈ, ចាប់ព្រះសង្ឃចំនួន ៩ អង្គផ្សឹកថ្ងៃទី ២២ ខែកុម្ភៈ, ចាប់បង្ខំឲ្យព្រះសង្ឃនៅខេត្តព្រះត្រពាំងចំនួន ៣ អង្គ គឺ ភិក្ខុ ថាច់ធន, ស៊ឺន ថែងចើន និង ស៊ឺន លំអាន ឲ្យលាចាកសិក្ខាបទដោយខ្លួនឯង និង ចាប់ផ្សឹកភិក្ខុ យ៉ាញ តូន នៅខេត្តព្រែកឫស្សី ។ [166]

នៅក្នុងព្រឹត្តិការណ៍បាតុកម្មទាំងបីលើកនេះ ភិក្ខុ អ៊ាង សុខ ធឿន ត្រូវសុគតដោយអាថ៌កំបាំងនៅវត្តទ្រទំជ្រឹង ។ មុនពេលសុគត ភិក្ខុ អ៊ាង សុខ ធឿន បាននិមន្តចូលរួមបាតុកម្មជាមួយព្រះសង្ឃនៅមុខស្ថានទូតយួន តែពេលព្រះអង្គនិមន្តត្រឡប់ទៅកាន់វត្តទ្រទំជ្រឹង ឋិតនៅក្នុងឃុំបឹងធំ ស្រុកអង្គស្នួល ខេត្តកណ្ដាល វិញ នៅថ្ងៃបន្ទាប់ មានព័ត៌មានពីអាជ្ញាធរខ្មែរ និងសមត្ថកិច្ចស្រុកអង្គស្នួលបញ្ជាក់ថា ព្រះអង្គបានធ្វើអត្តឃាតដោយអារកនៅយប់ថ្ងៃ ២៧ ខែកុម្ភៈ ឆ្នាំ ២០០៧ ។ អង្គការ និងសមាគមខ្មែរក្រោមដែលមានមូលដ្ឋាននៅកម្ពុជាសង្ស័យថា ការសុគតរបស់ ភិក្ខុ អ៊ាង សុខធឿន ជាករណីឃាតកម្មដោយមានជនដៃដល់សម្លាប់ ហើយបានស្នើទៅព្រះរាជអាជ្ញាតុលាការខេត្ត

[166] សហព័ន្ធខ្មែរកម្ពុជាក្រោម, (ខែឧសភា ឆ្នាំ ២០០៧), “ស្ថានទូតអាមេរិកស្វាគមន៍ញត្តិសមណបាតុករខ្មែរក្រោមនៅកម្ពុជា”, ព្រឹត្តិបត្រ កម្ពុជាក្រោម លេខ ៤១, ទំព័រ ៥ - ៦, (ស្រង់ប្រភពៈ ១៧ ធ្នូ ២០២០), https://is.gd/wMKWuk

កណ្ដាលឲ្យស៊ើបអង្កេតលើករណីនេះឡើងវិញ ដោយយកព្រះសពឡើងធ្វើកោសល្យវិច័យ តែត្រូវបដិសេធ ។ [167] ព្រះសពរបស់ ភិក្ខុ អ៊ាង សុខធឿន ត្រូវអាជ្ញាធរខ្មែរ និង គណៈកម្មការវត្តកប់ក្រោយរបងវត្តទ្រនំជ្រើង ដោយមិនបានអនុញ្ញាតឲ្យលើកសពឡើងបូជា ដើម្បីធ្វើបុណ្យតាមប្រពៃណីជាតិ និងសាសនាឡើយ ។ [168]

ភិក្ខុ អ៊ាង សុខធឿន ហៅ ទ្រីវ ធឿន កើតនៅឆ្នាំ ១៩៧៥ នៅភូមិជ្រោយទឹម ស្រុកបាយឆៅ ខេត្តឃ្លាំង [169] និងបានសាងផ្នួសនៅវត្តជ្រោយទឹម ជាវត្តមួយដែលឋិតនៅក្នុងភូមិកំណើតរបស់ព្រះអង្គ ។ នៅឆ្នាំ ១៩៩៧ ព្រះអង្គបាននិមន្តទៅនៅបន្តការសិក្សាប្រទេសកម្ពុជា ។[170]

នៅក្នុងព្រឹត្តិការណ៍បាតុកម្មទាំងបីលើកខាងលើ តែងតែត្រូវបង្ក្រាបដោយប៉ូលិសខ្មែរបណ្ដាលឲ្យព្រះសង្ឃខ្លះត្រូវរបួសស្រាលនិងធ្ងន់ ក្នុងនោះ មាន ភិក្ខុ ឡឹម យុត្តិជាដើម ជាព្រះសង្ឃគង់នៅវត្តសាមគ្គីរង្សី ត្រូវបុរសម្នាក់វាយបែកចិញ្ចើមនៅមុខវត្តឧណ្ណាលោម នៅថ្ងៃទី ១៧ ខែកុម្ភៈ ខណៈដែលក្បួនបាតុកម្មកំពុងតែដង្ហែចេញពីមុខព្រះបរមរាជវាំងឆ្ពោះទៅស្ថានទូតសហរដ្ឋអាមេរិក ។

ដោយសារបានឃើញព្រះសង្ឃខ្មែរក្រោមចេះតែធ្វើបាតុកម្មជាបន្តបន្ទាប់ ទើបនៅថ្ងៃទី ៨ ខែមិថុនា ឆ្នាំ ២០០៧ គណៈសង្ឃនាយក និង ក្រសួងធម្មការ និងសាសនា នៃប្រទេសកម្ពុជា បានចេញ “សង្ឃប្រកាស” បញ្ញាហាមព្រះសង្ឃទូទាំងប្រទេសកម្ពុជាធ្វើបាតុកម្មតាមគ្រប់រូបភាព ។ សង្ឃប្រកាសនេះក៏បានបកប្រែទៅជាភាសាយួន និងបានរដ្ឋាភិបាលវៀតណាមយកទៅផ្សព្វផ្សាយនៅដែនដីកម្ពុជាក្រោមផងដែរ ។ តាមមើលទៅ ប្រហែលជារដ្ឋាភិបាលយួនជាអ្នកបញ្ជាទៅ គណៈសង្ឃនាយក នៃប្រទេសកម្ពុជាឲ្យចេញសង្ឃប្រកាសនេះ ដើម្បីទប់ស្កាត់រលកនៃការធ្វើបាតុកម្មរបស់ព្រះសង្ឃ

[167] លិខិតរំឭករបស់អង្គការខ្មែរក្រោមចំនួន ៦ ជូន លោក ព្រះរាជអាជ្ញាតុលាការខេត្តកណ្ដាល ចុះថ្ងៃទី ៩ មីនា ២០០៧ ។

[168] លិខិតប្រគេនដំណឹង របស់ចៅអធិការវត្តទ្រនំជ្រើង ជូនតំណាងសមាគមព្រះសង្ឃខ្មែរកម្ពុជាក្រោម ចុះថ្ងៃទី ១៥ មីនា ២០០៧ ។

[169] អត្តសញ្ញាណប័ណ្ណ (Giấy Chứng Minh Nhân Dân), ផ្ដល់ដោយរដ្ឋាភិបាលវៀតណាម ចុះថ្ងៃទី ៨ ខែសីហា ឆ្នាំ ១៩៩១, បញ្ជាក់ថា ភិក្ខុ អ៊ាង សុខធឿន មានឈ្មោះដើមថា ទ្រីវ ធឿន (Triệu Thương) កើតឆ្នាំ ១៩៧៥ នៅភូមិជ្រោយទឹម ស្រុកបាយឆៅ ខេត្តឃ្លាំង (Đại Tâm, Mỹ Xuyên, Hậu Giang) ។

[170] ព្រឹត្តិបត្រស្រាវជ្រាវ គូស្រះស្រី, (ឆ្នាំទី ២ លេខ ១២ ខែមីនា ឆ្នាំ ២០០៧) ‘មរណភាពអាថ៌កំបាំងរបស់ព្រះសង្ឃខ្មែរក្រោម អ៊ាង សុខធឿន’, ទំព័រ ២២

ខ្មែរក្រោម ។

*“ ប្រការ ២៖ ហាមដាច់ខាតចំពោះ ភិក្ខុ - សាមណេរ ពុទ្ធសាសនាថេរវាទ ក្នុងព្រះរាជាណាចក្រកម្ពុជាទាំងអស់ ក្នុងការបង្កើត ឬចូលរួមធ្វើបាតុកម្ម កូដកម្ម កុបកម្ម និងយករូបភាពធម្មយាត្រា ដើម្បីដង្ហែក្បួននានា ធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈក្នុងសង្គម”* ។ [171]

**ករណី ព្រះតេជព្រះគុណ ទឹម សាខន (Tim Sakhorn)៖**

ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០០៧ ព្រះតេជព្រះគុណ **ទឹម សាខន** ជាព្រះចៅអធិការវត្តភ្នំដិនខាងជើង ស្រុកគិរីវង្ស ខេត្តតាកែវ ត្រូវសម្តេចសង្ឃ ទេព វង្ស និង នន្ទ ង៉ែត នៃប្រទេសកម្ពុជា បញ្ជាឲ្យមន្ត្រីសង្ឃខ្មែរចាប់ផ្សឹក ហើយបានបញ្ជូនទៅដាក់គុកយួននៅក្នុងខេត្តមាត់ជ្រូក ដោយចោទពីបទ “បំបែកបំបាក់មិត្តភាពយួនខ្មែរ”។

យោងតាមលិខិតចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០០៧ ដែល សម្តេចព្រះសង្ឃនាយក នន្ទ ង៉ែត ទូលថ្វាយចំពោះ សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី ទេព វង្ស ដើម្បីធ្វើ “សំណើព្រះរាជានុញ្ញាតផ្សឹក ភិក្ខុ ទឹម សាខន ជាព្រះចៅអធិការវត្តភ្នំដិនខាងជើង” បានបញ្ជាក់ថា៖

*“ភិក្ខុ ទឹម សាខន អង្គនេះ បានប្រព្រឹត្តខុសនឹងវិន័យព្រះពុទ្ធសាសនា ដែល ធ្វើឲ្យបែកបាក់សាមគ្គីជាតិ - អន្តរជាតិ ជាពិសេសរវាងប្រទេសទាំងពីរ កម្ពុជា - វៀតណាម យកទីអារាមវត្ត ធ្វើទីបញ្ជាការសម្រាប់បម្រើចលនាឃោសនាដែលធ្វើឲ្យប៉ះពាល់ដល់វិន័យ និងសេចក្តីថ្លៃថ្នូរព្រះពុទ្ធសាសនា”* ។ [172]

ក្រោយការចាប់ផ្សឹក ព្រះតេជព្រះគុណ ទឹម សាខន បានមួយថ្ងៃ គឺនៅថ្ងៃទី ១ ខែកក្កដា សមាគមខ្មែរកម្ពុជាក្រោម ចំនួន ១២ ដែលមានមូលដ្ឋាននៅកម្ពុជា បានចេញសេចក្តីថ្លែងការណ៍រួមមួយទាមទារឲ្យបំបួស ព្រះតេជព្រះគុណ ទឹម សាខន ឡើងវិញ

[171] សង្ឃប្រកាស នៃ គណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា លេខ ៤០៣/០៧ ស.ន.ក.ជ. ចុះហត្ថលេខាដោយសម្តេច ព្រះសង្ឃនាយក នន្ទ ង៉ែត និង ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ឃុន ហាំង ។

[172] លិខិត សម្តេចព្រះសង្ឃរាជ នន្ទ ង៉ែត ទូលថ្វាយ សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី ទេព វង្ស ដើម្បីផ្សឹក ភិក្ខុ ទឹម សាខន លេខ ៥០២/០៧ ស.ន.ក.ជ. និងមានការឯកភាពពី សម្តេចសង្ឃរាជ ទេព វង្ស ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០០៧ ។

ជាបន្ទាន់ ដោយអង្គការទាំងនោះបានលើកឡើងថា សេចក្ដីសម្រេចរបស់ គណៈសង្ឃនាយកនៃប្រទេសកម្ពុជា ផ្ទុយទាំងស្រុងទៅនឹងរដ្ឋធម្មនុញ្ញប្រទេសកម្ពុជា ត្រង់មាត្រា ៤៣ ដែលបានចែងថា "...*ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ...*" និង "*ព្រះវិន័យក្នុងពុទ្ធសាសនាបានចែងថា ព្រះសង្ឃនៅក្នុងពុទ្ធសាសនាដែលអាចចាប់ផ្សឹកបាន លុះត្រាណាតែសង្ឃអង្គនោះ បានប្រព្រឹត្តល្មើសសិក្ខាបទណាមួយក្នុងសិក្ខាបទទាំង ៤ នៃអាបត្តិបារាជិក* " តែព្រះតេជព្រះគុណ ទឹម សាខន មិនបានប្រព្រឹត្តល្មើស ឬ "*មិនបានស្ថិតនៅក្នុងសិក្ខាបទណាមួយនៃអាបត្តិបារាជិកទាំង ៤ នោះទេ*" ។ [173]

ប្រធានអង្គការខ្មែរកម្ពុជាក្រោមទាំង ១២ ដែលបានចុះហត្ថលេខាលើសេចក្ដីថ្លែងការណ៍នោះ រួមមាន៖

១. ព្រះមហា យឿង សិន (សមាគមព្រះសង្ឃខ្មែរកម្ពុជាក្រោម)

២. លោក ថាច់ សេដ្ឋា (សហគមន៍ខ្មែរកម្ពុជាក្រោម)

៣. លោក គឹម វណ្ណ ឆេង (គណៈកម្មការសម្របសម្រួលខ្មែរកម្ពុជាក្រោម)

៤. លោក អាង ច័ន្ទរិទ្ធ (អង្គការខ្មែរកម្ពុជាក្រោម ការពារសិទ្ធិមនុស្ស)

៥. ព្រះគ្រូ ចៅ សាង (សម្ព័ន្ធសមណនិស្សិត-និស្សិតខ្មែរកម្ពុជាក្រោម)

៦. លោក ស៊ឺន យឿង (សមាគមខ្មែរកម្ពុជាក្រោមដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍)

៧. លោក ថាច់ សាក់បូរ៉ា (អង្គការខ្មែរកម្ពុជាក្រោមដើម្បីកុមារ)

៨. លោក វ៉ា ប៊ុន យី (សមាគមខ្មែរកម្ពុជាក្រោម និងអភិវឌ្ឍន៍)

៩. អ្នកស្រី ព្រំ យ៉ាង (អង្គការស្ត្រីខ្មែរកម្ពុជាក្រោម)

១០. លោក យន្ត ថារូ (មូលនិធិសម្រាប់អ្នកក្រីក្រ)

១១. លោក លីវ អាន (សមាគមខ្មែរកម្ពុជាក្រោម)

១២. លោក ថាច់ សាង (មិត្តសមាគមខ្មែរកម្ពុជាក្រោម) ។

ក្រោយពីបាត់ព្រះកាយបីខែ តុលាការយួនបាននាំ ព្រះតេជព្រះគុណ **ទឹម សាខន** ចេញបង្ហាញខ្លួនក្នុងភាពជាគ្រហស្ថ និងបានកាត់ទោសនៅខេត្តមាត់ជ្រូក នៅថ្ងៃទី ០៨

[173] "សេចក្ដីថ្លែងការណ៍" ចុះថ្ងៃទី ១ ខែកក្កដា ឆ្នាំ ២០០៧ របស់ អង្គការ និងសមាគមខ្មែរកម្ពុជាក្រោម ទាំង ១២ ។ ព្រឹត្តិបត្រស្រាវជ្រាវ គូស្រះស្រី ឆ្នាំទី ២ លេខ ១៩ ខែមិថុនា ឆ្នាំ ២០០៧, ទំព័រ ១៦-១៧, https://is.gd/ZdV7o7

ខែវិច្ឆិកា ឲ្យជាប់គុក ១ ឆ្នាំ ពីបទ “បំផ្លាញសាមគ្គីជាតិ [យួន]” យោងតាមមាត្រា ៨៧ នៃក្រមព្រហ្មទណ្ឌ របស់ប្រទេសវៀតណាម ។

ព្រះតេជព្រះគុណ **ទឹម សាខន** ប្រសូតនៅឆ្នាំ ១៩៦៨ នៅស្រុកស្វាយទង ខេត្តមាត់ជ្រូក និងបានទៅនៅប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៧៨ ។ ឆ្នាំ ១៩៩៣ ព្រះអង្គបានតែងតាំងជាព្រះចៅអធិការវត្តភ្នំដិនខាងជើង រហូតដល់ថ្ងៃដែលត្រូវចាប់ផ្សឹក ។

ដោយសារ សហព័ន្ធខ្មែរកម្ពុជាក្រោម (KKF) បានដឹកនាំធ្វើបាតុកម្មនៅជុំវិញពិភពលោកថ្កោលទោសរបបយួនកុម្មុយនីស្ត និងបានអំពាវនាវដល់សហគមន៍អន្តរជាតិឲ្យជួយអន្តរាគមន៍នោះ តុលាការនៃរបបយួនបានសម្រេចដោះលែង ព្រះតេជព្រះគុណ ទឹម សាខន ឲ្យចេញពីពន្ធនាគារ ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០០៨ ហើយឋិតនៅក្រោមការតាមដានរបស់សមត្ថកិច្ច ។

ពេលបានចេញពីពន្ធនាគារ និងបានរស់នៅក្នុងភាពជាគ្រហស្ថនៅក្នុងខេត្តមាត់ជ្រូកជិតមួយឆ្នាំ នៅថ្ងៃទី ៤ ខែមេសា ឆ្នាំ ២០០៩ រដ្ឋាភិបាលយួនបានអនុញ្ញាតឲ្យលោកទៅសួរសុខទុក្ខគ្រួសាររបស់ខ្លួននៅឃុំភ្នំដិន ស្រុកគិរីវង់ ខេត្តតាកែវ ក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរ ។ ក្រោយមក លោក ទឹម សាខន បានភៀសខ្លួនទៅប្រទេសថៃ សុំសិទ្ធិជ្រកកោននៅ ការិយាល័យឧត្តមស្នងការ អ.ស.ប. ទទួលបន្ទុកជនភៀសខ្លួន (UNHCR) និងបានអង្គការនេះបញ្ជូនទៅនៅប្រទេសស៊ុយអែត ។

**ករណី លោក វិញ បា (Hùynh Ba) ខេត្តឃ្លាំង ឆ្នាំ ២០១០៖**

ថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០១០ លោក វិញ បា ត្រូវតុលាការយួនខេត្តឃ្លាំង ប្រកាសសាលក្រមឲ្យជាប់គុក ២ ឆ្នាំ ពីបទអ្វីមួយដែលរបបយួនកុម្មុយនីស្តហៅថា “កេងចំណេញលើសិទ្ធិសេរីភាព, លទ្ធិប្រជាធិបតេយ្យ, រំលោភលើផលប្រយោជន៍រដ្ឋ, សិទ្ធិ និងផលប្រយោជន៍របស់អង្គការចាត់តាំងវណ្ណៈកម្មករ និងកសិករ” តាមមាត្រា ២៥៨ នៃច្បាប់ព្រហ្មទណ្ឌរបស់រដ្ឋាភិបាលវៀតណាម ។ រដ្ឋាភិបាលយួនបានដោះលែងលោកឲ្យចេញពីគុកវិញ នៅថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ ២០១១ បន្ទាប់ពីលោកត្រូវជាប់គុកអស់រយៈពេល ២០ ខែ ។

លោក វិញ បា កើតនៅភូមិតឹងវីអា (Tân Quy A) ឃុំតឹងហឹង (Tân Hưng) ស្រុកអណ្តូងទឹក (Long Phú) ខេត្តឃ្លាំង (Sóc Trăng) ។ លោកត្រូវរបបយួនចាប់ខ្លួនដាក់គុកនៅខែឧសភា ឆ្នាំ ២០០៩ ដោយសារធ្វើការទាមទារដីស្រែចម្ការរបស់ខ្លួនជាច្រើនហិកតា ដែលត្រូវអាជ្ញាធរយួននៅស្រុកអណ្តូងទឹក រឹបយកទៅធ្វើជាកសិដ្ឋានរបស់រដ្ឋកាលពីឆ្នាំ ១៩៧៩ ។ [174]

**ករណី លោក ចៅ ហេន (Châu Hên) ខេត្តមាត់ជ្រូក ឆ្នាំ ២០១០៖**

លោក ចៅ ហេន កើតឆ្នាំ ១៩៥៤ ត្រូវនគរបាលយួនឡោមព័ទ្ធផ្ទះចាប់ខ្លួន នៅពេលដែលលោក និងអ្នកស្រី នាង ភឿន ជាភរិយា បានធ្វើមាតុភូមិនិវត្តន៍ពីប្រទេសថៃមកផ្ទះនៅខេត្តមាត់ជ្រូក វិញ នៅថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១០ ។

បន្ទាប់ពីដាក់គុកអស់បីខែ នៅថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០១១ លោកត្រូវតុលាការយួនប្រកាសសាលក្រមផ្តន្ទាទោសឲ្យជាប់គុក ២ ឆ្នាំ ពីបទ "បំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈ និងបង្កអសន្តិសុខទីសាធារណៈ" តាមមាត្រា ទី ១៤៣ និង ២៤៥ នៃក្រមព្រហ្មទណ្ឌរបស់ប្រទេសវៀតណាម ។

ការចោទប្រកាន់បែបនេះ ដោយសារ លោក ចៅ ហេន ធ្លាប់បានដឹកនាំប្រជាពលរដ្ឋខ្មែរក្រោមនៅខេត្តមាត់ជ្រូកជាង ៦០០ នាក់ ធ្វើបាតុកម្មជាបន្តបន្ទាប់នៅឆ្នាំ ២០០៨ ដើម្បីទាមទារដីស្រែចម្ការរបស់ខ្លួនដែលយួនបានរឹបយកក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ ។

ដោយការតវ៉ានៅកម្ពុជាក្រោមមិនបានទទួលជោគជ័យ លោក ចៅ ហេន បានឱបឯកសារសំណុំរឿងដីធ្លីភៀសខ្លួនទៅប្រទេសកម្ពុជា ដើម្បីប្តឹងអង្គការសិទ្ធិមនុស្សអន្តរជាតិនានាឲ្យជួយរកយុត្តិធម៌ និងបានបន្តភៀសខ្លួនទៅប្រទេសថៃសុំសិទ្ធិជ្រកកោន នៅការិយាល័យ UNHCR តែត្រូវអង្គការនេះបដិសេធនូវឋានៈជាជនភៀសខ្លួន បានធ្វើឲ្យលោកសម្រេចចិត្តធ្វើមាតុភូមិនិវត្តន៍មកស្រុកកំណើតវិញ ។

ពេលបានចេញពីគុក លោក ចៅ ហេន និងភរិយា បាននាំគ្នាភៀសខ្លួនទៅប្រទេសថៃជាលើកទីពីរ និងបានអង្គការ UNHCR ផ្តល់ឋានៈជាជនភៀសខ្លួន ប៉ុន្តែខណៈដែល

[174] ថាច់ ប្រីជា គឿន, (៧ មករា ២០១៧), 'សហព័ន្ធខ្មែរកម្ពុជាក្រោម ផ្តល់ពានរង្វាន់សិទ្ធិមនុស្សកម្ពុជាក្រោម ដល់សកម្មជនខ្មែរក្រោម ១៤ រូប', សំឡេងកម្ពុជាក្រោម (VOKK), (ស្រង់ប្រភព៖ ២១ ធ្នូ ២០២០), https://is.gd/INvayW

គ្រួសារលោកកំពុងតែរង់ចាំឱកាសចេញទៅនៅសហរដ្ឋអាមេរិក ភរិយារបស់លោកគឺអ្នកស្រី នាង ភឿន បានស្លាប់ដោយសារជំងឺ នៅក្នុងផ្ទះជួលមួយនៅខេត្តនន្ទបុរី ថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១៤ ។ ទីបំផុត UNHCR បានបញ្ជូន លោក ថៅ ហេន ឲ្យទៅតាំងទីលំនៅ នៅរដ្ឋ North Carolina សហរដ្ឋអាមេរិក តែម្នាក់ឯង នៅថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០១៤ ។ [175]

**ករណី ភិក្ខុ លី ចិន្តា ត្រូវយួនច្រកចូលបាវធ្វើទារុណកម្ម ឆ្នាំ ២០១៣៖**

នៅថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៣ អាជ្ញាធរយួនបានបញ្ជាឲ្យកងកម្លាំងសន្តិសុខរបស់ខ្លួនទៅវាយកម្ទេចទម្លុះជញ្ជាំងកុដិរបស់ ភិក្ខុ លី ចិន្តា នៅវត្តទេពារាមព្រៃជាប់បិតនៅក្នុងស្រុកជ្រោយញ ខេត្តឃ្លាំង ហើយបានញាត់លោកច្រកចូលបាវ យកទៅធ្វើទារុណកម្មយ៉ាងព្រៃផ្សៃ ។

ពលរដ្ឋខ្មែរក្រោម ៥ នាក់ទៀត ដែលបានចូលវត្តទូងស្គរ ស្រែកតវ៉ាចំពោះការចាប់ភិក្ខុ លី ចិន្តា ផ្សឹក ត្រូវតុលាការយួនកាត់ទោសឲ្យជាប់គុកម្នាក់ៗ ពី ១០ ខែដល់ ១ ឆ្នាំ ។

អ្នកទាំងនោះ រួមមាន៖

១. អ្នកស្រី លី ធី សាបុត (Lý Thị Sà Bột) ១ ឆ្នាំ

២. អ្នកស្រី លី ធី យន់ (Lý Thị Dạnh) ១ ឆ្នាំ

៣. អ្នកស្រី ឡឹម ធី ឡូង (Lâm Thị Loan) ១ ឆ្នាំ

៤. លោក លី មិន ហាយ (Lý Minh Hải) ១១ ខែ

៥. លោក តាំង ផល្លា (Tăng Pho La) ១០ ខែ ។

ក្រោយមក លោក លី ចិន្តា បានភៀសខ្លួនទៅប្រទេសថៃ សុំសិទ្ធិជ្រកកោននៅការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR) ហើយបានអង្គការនេះបញ្ជូនទៅនៅសហរដ្ឋអាមេរិក កាលពីឆ្នាំ ២០១៦ ។

**ករណី ភិក្ខុ ថាច់ ធឿន និង ភិក្ខុ លីវ នី នៅវត្តសិរីតាសេក ខេត្តឃ្លាំង ឆ្នាំ ២០១៣៖**

នៅថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ២០១៣ តុលាការយួនខេត្តឃ្លាំង បានប្រកាសសាលក្រម

[175] ថាច់ ប្រីជា គឿន, (ខែធ្នូ ២០១៤), 'ថៅ ហេន អ្នកធ្វើដំណើរចូលមាត់ខ្លាដើម្បីលាតត្រដាងការរំលោភសិទ្ធិលើខ្មែរក្រោម', ព្រឹត្តិបត្រ កម្ពុជាក្រោម ឆ្នាំ ១១, លេខ ៩៤, ទំព័រ ៦៥ - ៦៦, (ស្រង់ប្រភព៖ ២១ ធ្នូ ២០២០), https://is.gd/uuz3qV

ផ្តន្ទាទោសព្រះសង្ឃ ២ អង្គ និងបរិស័ទ ២ រូបឲ្យជាប់គុកពី ២ ទៅ ៦ ឆ្នាំ ពីបទអ្វីមួយដែលរបបយួនហៅថា “ប្រឆាំងរដ្ឋាភិបាល” ដោយអ្នកទាំងនោះ គ្រាន់តែទទួលប្រាក់ឧបត្ថម្ភពីខ្មែរក្រោមនៅបរទេស និងផ្តល់បទសម្ភាសន៍ដល់ វិទ្យុសំឡេងកម្ពុជាក្រោម (VOKK) និងវិទ្យុអាស៊ីសេរី (RFA) ដែលមានមូលដ្ឋាននៅបរទេស តែប៉ុណ្ណោះ ។

អ្នកដែលត្រូវរបបយួនផ្តន្ទាទោសនោះ រួមមាន៖

១. ភិក្ខុ ថាច់ធឿន (Thạch Thươl) ប្រសូត ឆ្នាំ ១៩៨៥ ជាគ្រូសូត្រវត្តសិរីតាសេក ត្រូវយួនចាប់ផ្សឹក និងកាត់ទោសឲ្យជាប់គុក ៦ ឆ្នាំ ។ លោកបានចេញពីគុកវិញ នៅថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០១៩ ។

២. ភិក្ខុ លីវ នី (Liêu Ny) ប្រសូត ឆ្នាំ ១៩៨៦ ជាព្រះចៅអធិការវត្តសេរីតាសេក ត្រូវយួនចាប់ផ្សឹក និងកាត់ទោសឲ្យជាប់គុក ៤ ឆ្នាំ ។ លោកបានចេញពីគុកវិញ នៅថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០១៧ ។

៣. លោក ថាច់ ភូមិឫទ្ធ (Thạch Phum Ních) កើតឆ្នាំ ១៩៨៩ ត្រូវរបបយួនកាត់ទោសឲ្យជាប់គុក ៣ ឆ្នាំ ។

៤. លោក ត្រា វណ្ណ ថា (Trà Quành Tha) ត្រូវជាប់គុក ២ ឆ្នាំ ។

បើយោងតាមសាលក្រមដែលតុលាការយួនបានប្រកាសនោះ សកម្មភាពអ្វីដែលរបបយួនចាត់ទុកថាជាទង្វើ “ប្រឆាំងរដ្ឋាភិបាល” នោះ ដោយសារព្រះសង្ឃ ២ អង្គ និងពលរដ្ឋខ្មែរក្រោម ២ រូប ខាងលើបានធ្វើសកម្មភាព៖

> *“ ដោយសារជឿតាមការឃោសនារបស់មនុស្សអាក្រក់នៅបរទេស ថាច់ ធឿន និង លីវ នី បានធ្វើសកម្មភាពឃោសនា បំផុសបំផុល និងបរិហារ ដើម្បីបំបែកបំបាក់នូវចំណងមហាសាមគ្គីភាពជាតិ ។ តាំងពីចុងឆ្នាំ ២០១០ រហូតដល់ពេលដែលត្រូវចាប់ខ្លួន ថាច់ ធឿន និង លីវ នី បានទទួលប្រាក់ចំនួន ១២ លើក ដែលមានទឹកប្រាក់ជាង ១១៨ លានដុង [ជាង ៨ ពាន់ដុល្លារអាមេរិក] ពីក្រុមប្រតិកិរិយា និងបានផ្តល់បទសម្ភាសន៍ចំនួន ២១ ដង ដល់វិទ្យុសំឡេងកម្ពុជាក្រោម (VOKK) និង វិទ្យុអាស៊ីសេរី*

*(RFA) ដែលមានខ្លឹមសារបរិហារកេរ្តិ៍រដ្ឋាភិបាលវៀតណាម* ” ។ [176]

តុលាការរបបយួនបានបញ្ជាក់អំពីហេតុការណ៍ចាប់ខ្លួន ភិក្ខុ ថាច់ ធឿន, ភិក្ខុ លីវ នី និង លោក ត្រា វណ្ណ ថា នៅខេត្តមាត់ជ្រូក នៅពេលដែលអ្នកខាងលើកំពុងតែលបរត់ភៀសខ្លួនចេញទៅប្រទេសកម្ពុជា ថា៖

“ *នៅថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០១៣ នៅវត្តសិរីតាសេក ឃុំវិញហាយ (Vĩnh Hải), ទីរួមស្រុកជ្រោយញ (Vĩnh Châu) ថាច់ ធឿន និង លីវ នី បានបញ្ជាឲ្យ លោក ថាច់ ភូមិបុទ្ធ ថតជាវីដេអូឃ្លីបដែលមានខ្លឹមសារបំផុសបំផុល និងបរិហារកេរ្តិ៍ រួចចម្លងដាក់ចូល USB ដើម្បីយកតាមខ្លួនលួចរត់ទៅប្រទេសកម្ពុជា ។ ក្រោយមក ថាច់ ធឿន, លីវ នី និង ថាច់ ភូមិបុទ្ធ បានពឹង លោក ត្រា វណ្ណ ថា ឲ្យនាំផ្លូវភៀសខ្លួនទៅកម្ពុជា ។ នៅពេល ថាច់ ធឿន, លីវ នី, ថាច់ ភូមិបុទ្ធ និង ត្រា វណ្ណ ថា កំពុងតែធ្វើដំណើរភៀសខ្លួនឆ្លងទៅប្រទេសកម្ពុជា ក៏ត្រូវនគរបាល [យួន] ឃុំខាន់បិន (Khánh Bình), ស្រុកអាងភូ (An Phú) នៃខេត្តមាត់ជ្រូក (An Giang) ឆែកឆេរ និងចាប់ខ្លួន* ” ។[177]

សព្វថ្ងៃ លោក ថាច់ ធឿន និង លីវ នី កំពុងតែរស់នៅក្នុងជីវភាពជាគ្រហស្ថនៅផ្ទះរបស់ខ្លួនបិតនៅក្នុងខេត្តឃ្លាំង ក្រោមការឃ្លាំមើល និងតាមដានយ៉ាងយកចិត្តទុកដាក់ពីអាជ្ញាធររបបយួន ។

**ករណី យួនដណ្តើមដីធ្លីនៅខេត្តក្រមួនស ឆ្នាំ ២០២០៖**

នៅថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ២០២០ តុលាការយួនស្រុកយ៉ាងថាញ់ (Giang Thành) នៃខេត្តក្រមួនស បានប្រកាសសាលក្រមផ្តន្ទាទោសកសិករខ្មែរក្រោម ជាជនរងគ្រោះនៃការបង្ខំបណ្តេញពីដីធ្លីស្រែចម្ការចំនួន ៤ នាក់ឲ្យជាប់គុកពី ៦ ខែទៅ ២ ឆ្នាំកន្លះ ពីបទប្រើអំពើហិង្សាលើកងកម្លាំងសមត្ថកិច្ច និងបទប្រឆាំងនឹងអាជ្ញាធរសាធារណៈ ។

អ្នកដែលត្រូវតុលាការយួនផ្តន្ទាទោសនោះ រួមមាន៖

[176], [177] Minh Trường, (២៧ កញ្ញា ២០១៣), ‘Xét xử vụ án "trốn đi nước ngoài nhằm chống chính quyền nhân dân’, Báo Nhân Dân, (ស្រង់ប្រភព៖ ២១ ធ្នូ ២០២០), https://is.gd/NRRDCg

១. លោក វិញ វ៉ាំង ដែប (Hùynh Văn Đẹp) អាយុ ៤១ ឆ្នាំ  ជាអ្នកស៊ីឈ្នួលបើកអេស្កាវ៉ាទ័រ ត្រូវកាត់ទោសឲ្យជាប់គុក ២ ឆ្នាំ ៦ ខែ ។

២. លោក តៀន ដាម (Tien Dam) អាយុ ២៨ ឆ្នាំ ត្រូវជាប់គុក ២ ឆ្នាំ ៣ ខែ

៣. លោក តៀន ណាម (Tien Nam) អាយុ ២៨ ឆ្នាំ ត្រូវជាប់គុក ១ ឆ្នាំ

៤. លោកយាយ ធី ពេជ្រ (Thi Pich) អាយុ ៧១ ឆ្នាំ ត្រូវជាប់គុក ១ ឆ្នាំ ។

របបយួនមិនបានដាក់អ្នកទាំងនេះចូលគុកភ្លាមៗទេ តែត្រូវដាក់ឲ្យស្ថិតក្នុងការព្យួរទោសនៅក្រៅឃុំដោយមានលក្ខខណ្ឌ ។

សូមបញ្ជាក់ថា នៅថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០២០ អាជ្ញាធររបបយួន រួមមានប៉ូលិស និងទាហាន ដែលប្រដាប់ដោយអាវុធ ប្រមាណជា ១០០ នាក់ បានចុះទៅរឹបយកដីជាង ៣.០០០ ហិតតា របស់ពលរដ្ឋខ្មែរក្រោមចំនួន ១៤៥ គ្រួសារ ធ្វើជាកម្មសិទ្ធិរបស់រដ្ឋ ។ ប្រជាពលរដ្ឋបានធ្វើការជំទាស់រហូតផ្ទុះជាអំពើហិង្សា បណ្ដាលឲ្យពលរដ្ឋខ្មែរក្រោមជាង ១០ នាក់រងរបួសធ្ងន់ និងស្រាល ។ ពលរដ្ឋខ្មែរក្រោមបបានលើកឡើងថា ពួកគាត់បានអាស្រ័យផលលើដីនោះតាំងពីអំឡុងឆ្នាំ ១៩៧៣ មកម្ល៉េះ ប៉ុន្តែរបបយួនមិនព្រមធ្វើប័ណ្ណកម្មសិទ្ធិឲ្យនោះទេ ។ [178]

[178] ស៊ីន ចែងចើន, (៦ ធ្នូ ២០២០), ‘តុលាការវៀតណាម នៅខេត្តក្រមួនសកាត់ទោសកសិករខ្មែរក្រោម ៤ នាក់ ឲ្យជាប់គុកពី ១ ឆ្នាំ ទៅ ២ ឆ្នាំកន្លះ ក្នុងសំណុំរឿងដីធ្លី‘, សំឡេងកម្ពុជាក្រោម (VOKK), (ស្រង់ប្រភព៖ ២១ ធ្នូ ២០២០), https://is.gd/O0qa98

# ឈ្មោះខេត្ត ក្រុង កោះ នៅដែនដីកម្ពុជាក្រោម [179]

| ល.រ. | ភាសាខ្មែរ | ឈ្មោះផ្សេងទៀត | ភាសាយួន | ទីក្រុងរណប | វត្តខ្មែរ |
|---|---|---|---|---|---|
| ១ | ទីក្រុង **ព្រៃនគរ** | ព្រៃគ, ផ្សារធំ, កំពង់កោះក្របី | Sài Gòn<br>Hồ Chí Minh | | ២ |
| ២ | **អូរកាប់** | ពាមជើងកញ្ជើ<br>Cap Saint-Jacques | Bà Rịa – Vũng Tàu | Bà Rịa | ២ |
| ៣ | **ព្រះសួគ៌ា** | បារាយណ៍ | | | |
| ៤ | **ទួលតាមោក** | ឈើទាលមួយដើម | Bình Dương | Thủ Dầu Một | ៥ |
| | | | Bình Phước | Đồng Xoài | |
| ៥ | **ត្រពាំងចង្វា** | ដូងណាយ (*)<br>វាលប្រើស<br>កំពប់ស្រកាត្រី<br>ពាមមេសែន<br>កង្ហារដាក់ពាង | Đồng Nai | Biên Hòa | ២ |
| ៦ | **រោងដំរី** | ភ្នំជើងមេដែង | Tây Ninh | Tây Ninh | ៦ |
| ៧ | **មាត់ជ្រូក** | ភ្នំស្វាម | An Giang | Châu Đốc | ៦៦ |
| ៨ | **បារាជ** | | | Long Xuyên | |
| ៩ | **ផ្សារដែក** | | Đồng Tháp | Sa Đéc | |
| ១០ | **ពលលាវ** | ពោធិ៍លើ | Bạc Liêu | Bạc Liêu | ២២ |
| ១១ | **កំពង់ឫស្សី** | ផ្សុំអំបើស | Bến Tre | Bến Tre | |
| ១២ | **ទឹកខ្មៅ** | | Cà Mau | Cà Mau | ៦ |
| ១៣ | **ព្រែកឫស្សី** | កំពូលមាស | Cần Thơ | Cần Thơ | ១២ |
| | | | Hậu Giang | Vị Thanh | ១៥ |

[179] Kennet T. So, (២០១៧), ‘The Khmer Kings and The History of Cambodia, Book II, 1595 to Contemporary Period’, ទំព័រ ១០២ - ១០៣ ។ (*) **ដូងណាយ** (ឡាតាំង៖ Daung-Nay, បារាំង៖ Coco Rejeté) យោងតាម អាដេម៉ារ ឡឺក្លែរ, (១៩១៤), Histoire Du Cambodge, ទំព័រ ៤៣៥-៤៣៦, https://is.gd/iqDqx4

| ល.រ. | ឈ្មោះភាសាខ្មែរ | ឈ្មោះផ្សេងទៀត | ឈ្មោះភាសាយួន | ទីក្រុងរណប | វត្តខ្មែរ |
|---|---|---|---|---|---|
| ១៤ | **ក្រមួនស** | រាជា | Kiên Giang | Rạch Giá | ៧៥ |
| ១៥ | **ពាម** | បន្ទាយមាស | | Hà Tiên | |
| ១៦ | **កំពង់គោ** | | Long An | Tân An | |
| ១៧ | **ឃ្លាំង** | ស្រុកទ្រាំង<br>ស្រុកបាសាក់<br>ស្រុកឃ្លាំង | Sóc Trăng | Sóc Trăng | ៩២ |
| ១៨ | **មេស** | | Tiền Giang | Mỹ Tho | |
| ១៩ | **កោះគង** | | | Gò Công | |
| ២០ | **ព្រះត្រពាំង** | | Trà Vinh | Trà Vinh | ១៤៣ |
| ២១ | **លង់ហោរ** | | Vĩnh Long | Vĩnh Long | ១៣ |
| ២២ | **កោះត្រល់** | | Phú Quốc | | ១ |
| ២៣ | **កោះត្រឡាច** | | Côn Đảo | | |
| **សរុបវត្តខ្មែរនៅកម្ពុជាក្រោម** | | | | | **៤៦២** |

កម្ពុជាក្រោម មាន ២១ ខេត្ត/ក្រុង និង កោះ ២ ប៉ុន្តែ សព្វថ្ងៃ របបអាណានិគមយួន បានបំបែក និងបូកបញ្ចូលខេត្តទាំងនោះ ឲ្យនៅសល់ត្រឹមតែ ១៩ ខេត្ត/ក្រុង និង កោះ ២ ប៉ុណ្ណោះ ។

# វគ្គទី ៣

# ប្រជុំអត្ថបទ

# ស្ដីពី

# ដែនដីកម្ពុជាក្រោម

# អត្ថន័យនៃសញ្ញា "រាហូចាប់ចន្ទ" នៅក្នុងសង្គមខ្មែរក្រោម

«រាហូចាប់ចន្ទ» ជានិមិត្តសញ្ញាជាតិរបស់ខ្មែរក្រោមទូទាំងពិភពលោក ។ ជានិមិត្តសញ្ញាជាតិនោះ ដោយសារវត្តអារាម អង្គការ សមាគម និង សហព័ន្ធខ្មែរកម្ពុជាក្រោមជាដើម បានយកសញ្ញា «រាហូចាប់ចន្ទ» នេះ មកធ្វើជាសញ្ញាសម្គាល់ ឬធ្វើជាត្រារបស់ខ្លួន ។ តើសញ្ញា «រាហូចាប់ចន្ទ» មានអត្ថន័យយ៉ាងណាក្នុងជំនឿរបស់ខ្មែរ និងខ្មែរក្រោម? តើពលរដ្ឋខ្មែរក្រោមបានយកសញ្ញានេះ មកធ្វើជានិមិត្តសញ្ញារបស់ខ្លួនតាំងពីពេលណាមក? ។

«រាហូចាប់ចន្ទ» ជារូបគំនូរ ឬ សញ្ញា (Logo) ដែលគេគូរ ឬរចនាមានរូបរាហូត្រឹមក្លៀកឡើងលើឲ្យឃើញច្បាស់តែដៃ ក្បាល មុខធំទូលាយមានឫទ្ធអំណាច និងបញ្ចេញធ្មេញស្វាញ ប្រឹងលេបព្រះចន្ទបានពាក់កណ្តាលចូលទៅក្នុងមាត់ ។ គំនិតនៃការបង្កើតជារូបគំនូរនេះ កើតចេញពីបាតុភូតធម្មជាតិមួយដែលខ្មែរហៅថា «ចន្ទគ្រាស» មានន័យថា ការចាប់ព្រះចន្ទនៃរាហូអសុរិន្ទ ។ ក្រោយមក អ្នកវិទ្យាសាស្ត្របានបញ្ជាក់អំពី «ចន្ទគ្រាស» ថា វាគ្រាន់តែជាបាតុភូតមួយកើតឡើង ដោយសារផែនដីបានបាំងពន្លឺព្រះអាទិត្យដែលជះមកលើព្រះចន្ទតែប៉ុណ្ណោះ ។

តាំងពីបុរាណកាលមក នៅដែនដីកម្ពុជាក្រោម គេតែងគូរ ឬឆ្លាក់រូប «រាហូចាប់ចន្ទ» នៅហោជាងព្រះវិហារ និងខ្លោងទ្វារចូលទៅវត្តនីមួយៗ ។ ចំណែកវត្តអារាម គេហដ្ឋាន ព្រះរាជវាំង និងប្រាសាទនៅក្នុងប្រទេសកម្ពុជា ក៏មានគូរ និងឆ្លាក់រូប «រាហូចាប់ចន្ទ» ដែរ ។ យោងតាមក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ដែលមានមូលដ្ឋាននៅប្រទេសកម្ពុជា បានបញ្ជាក់អំពីប្រយោជន៍នៃការដាក់រូប «រាហូចាប់ចន្ទ» ដើម្បីឲ្យគេដឹងថា «ជាអ្នកមានឫទ្ធិ, អ្នកខ្លាំងពូកែ, និងជាអ្នកធំ» ។

នៅឆ្នាំ ១៩៣៧ ឧកញ៉ា ឡាំ ឯម ជាអតីតអភិបាលខេត្តឃ្លាំង និងជាស្ថាបនិក «មិត្តសមាគមខ្មែរកម្ពុជាក្រោម» បានយកសញ្ញា «រាហូចាប់ចន្ទ» នេះ ទៅដាក់នៅខ្លោង

ទ្វារចូលទៅកាន់ទីស្នាក់ការនៃមិត្តសមាគមខ្មែរកម្ពុជាក្រោមប្រចាំខេត្តឃ្លាំង ហើយក្រោយមកសញ្ញានេះ បានក្លាយជានិមិត្តសញ្ញា (Logo) និងត្រាជាផ្លូវការនៃសមាគមមួយនេះតែម្តង ។

ពេលយួនកុម្មុយនីស្តចូលកាន់កាប់ទឹកដីកម្ពុជាក្រោម នៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៧៥ ពលរដ្ឋខ្មែរក្រោមជាច្រើន បានភៀសទៅក្រៅប្រទេស ហើយបានរួបរួមគ្នាបង្កើតជាចលនាតស៊ូទាមទារសិទ្ធិសេរីភាពជូនខ្មែរក្រោមនៅក្នុងស្រុក ។ ចលនាតស៊ូទាំងនោះ ដូចជា មិត្តសមាគមខ្មែរកម្ពុជាក្រោម, សមាគមខ្មែរកម្ពុជាក្រោម, សភាខ្មែរកម្ពុជាក្រោម និងសហព័ន្ធខ្មែរកម្ពុជាក្រោម ជាដើម ដែលមានមូលដ្ឋាននៅក្រៅប្រទេស សុទ្ធតែយករូប «រាហូចាប់ចន្ទ» មកធ្វើជានិមិត្តសញ្ញារបស់ខ្លួន ។

**អត្ថន័យជាផ្លូវការនៃនិមិត្តសញ្ញា «រាហូចាប់ចន្ទ» នៅក្នុងសង្គមខ្មែរក្រោមៈ**

សញ្ញា «រាហូចាប់ចន្ទ» មានអត្ថន័យយ៉ាងជ្រាលជ្រៅ តំណាងសាមគ្គីភាពដែលកើតចេញពីសេចក្តីស្រឡាញ់រាប់អានគ្នា ដូចជាបងប្អូនបង្កើតរបស់ពលរដ្ឋខ្មែរក្រោមនៅជុំវិញពិភពលោក ។ ព្រោះថា រាហូ តំណាងខ្មែរក្រោមនៅក្រៅស្រុក និង ចន្ទ តំណាងខ្មែរក្រោមនៅក្នុងស្រុកដែលព្រាត់ពីគ្នា ហើយយូរៗបានជួបគ្នាម្តង ក៏ចាប់គ្នាឱប ស្រឡាញ់គ្នារហូតដល់ចង់លេបទុក ជាដើម ។

យោងតាម ព្រឹត្តិបត្រ កម្ពុជាក្រោម លេខ ១ ចេញផ្សាយ ឆ្នាំ ១៩៨៤ ដោយសមាគមខ្មែរកម្ពុជាក្រោមនៅសហរដ្ឋអាមេរិក បានចុះផ្សាយនូវអត្ថន័យនៃសញ្ញា «រាហូចាប់ចន្ទ» ដែលបានទទួលស្គាល់ ដោយមហាសន្និបាតខ្មែរកម្ពុជាក្រោម ថ្ងៃទី ១១ ខែសីហា ឆ្នាំ ១៩៨៤ ថាៈ *"រូបសញ្ញានេះ យកតាមខ្លោងទ្វារចូលទៅកាន់ទីស្នាក់ការមិត្តសមាគមខ្មែរកម្ពុជាក្រោម ប្រចាំខេត្តឃ្លាំង"* ។

ខ្លឹមសារដើមនៃសេចក្តីអនុម័តនេះបានបញ្ជាក់ថាៈ *"រឿងព្រេងខ្មែរបានតំណាលថា រាហូ និង ចន្ទ ជាបងប្អូនបង្កើត តែត្រូវរស់នៅឆ្ងាយពីគ្នា ។ តាមការព្រាងទុក រាហូ និង ចន្ទ ត្រូវវិលជួបគ្នាក្នុងមួយឆ្នាំម្តង ។ ពេលជួបគ្នាម្តងៗ រាហូតែងតែចាប់ចន្ទមកញ៉ាំញីឱបរឹត ដើម្បីឲ្យស្បើយនូវការអាឡោះអាល័យ ហើយពេលខ្លះ រហូតដល់ចង់ចាប់ចន្ទ*

*មកលេបទុកទៀតផង ដោយហេតុមិនចង់ឲ្យបែកគ្នាតទៅទៀត ។*

***អធិប្បាយៈ***

***ចន្ទ៖*** *ជានិមិត្តរូបនៃខ្មែរកម្ពុជាក្រោមទាំងមូល ដែលមានរូបសម្ផស្សឆោមល្អភ្លឺត្រចះត្រចង់ខ្ពស់ត្រដែតធ្វើឲ្យជាតិសាសន៍ដទៃគោរពរាប់អាន ។*

***រាហូ៖*** *ជានិមិត្តរូបនៃខ្មែរកម្ពុជាក្រោម ដែលកំពុងរស់នៅបរទេសទាំងអស់ ហើយក៏ជានិមិត្តរូប នៃកម្លាំងសាមគ្គីមួយយ៉ាងមាំរបស់ខ្មែរកម្ពុជាក្រោមទូទៅ ហើយកំពុងចាប់ចន្ទ យកមកឱបថ្នាក់ថ្នមរក្សាតរៀងទៅ ។*

***រាហូចាប់ចន្ទ៖*** *គឺជានិមិត្តរូបនៃការស្រឡាញ់រាប់អានគ្នា ជិតស្និទ្ធនឹងគ្នាស្គាល់ធុរៈគ្នាលើកស្ទួយគ្នាគ្រប់កាលៈទេសៈ ជាពិសេស ក្នុងគ្រាមានអាសន្នហាក់បីដូចជាបងប្អូនបង្កើត" ៕*

សូមអាន «**ប្រវត្តិរបស់រាហូ**» និង «**ដើមកំណើតនៃរាហូ ព្រះអាទិត្យ និងព្រះចន្ទ**» នៅក្នុងសៀវភៅ «ប្រជុំរឿងព្រេងខ្មែរ ភាគ ៩» រៀបរៀងដោយក្រុមជំនុំទំនៀមទម្លាប់ខ្មែរ និងបានបោះពុម្ពផ្សាយនៅឆ្នាំ ១៩៧៤ ដោយពុទ្ធសាសនបណ្ឌិត្យ ត្រង់ទំព័រ ៧៦ ។

# ប្រវត្តិទង់ជាតិកម្ពុជាក្រោម



ទង់ជាតិកម្ពុជាក្រោម ត្រូវបានអនុម័តឲ្យប្រើជាផ្លូវការនៅឆ្នាំ ១៩៩២ នៅក្នុង «មហាសន្និបាតសាកលលើកទី ៤ នៃខ្មែរកម្ពុជាក្រោម» ដែលបានរៀបចំនៅទីក្រុង Philadelphia រដ្ឋ Pennsylvania សហរដ្ឋអាមេរិក ។ ទង់នេះជាតំណាង និងជានិមិត្តរូបនៃប្រជាជាតិខ្មែរក្រោមទូទាំងពិភពលោក និងដែនដីកម្ពុជាក្រោម ដែលកំពុងតែត្រូវរបបយួនធ្វើអាណានិគមសព្វថ្ងៃ ។ ទង់ជាតិកម្ពុជាក្រោម មានបីឆ្នូត ដែលមានទំហំស្មើគ្នា និងមាន ៣ ព័ណ៌ផ្សេងគ្នា គឺ ខៀវ លឿង និងក្រហម ហើយមានខ្នាតទទឹងពីរភាគបី និងបណ្តោយបីភាគបី ។

- **ឆ្នូតព័ណ៌ខៀវ** នៅខាងលើ ជានិមិត្តរូបនៃសិទ្ធិសេរីភាពនិងប្រជាធិបតេយ្យ ដែលជាសិទ្ធិខ្ពស់ជាងគេបំផុត ។
- **ឆ្នូតព័ណ៌លឿង** នៅចំកណ្តាល ជានិមិត្តរូបនៃជាតិសាសន៍របស់ខ្មែរក្រោម ដែលស្រឡាញ់សន្តិភាព និងយុត្តិធម៌ ។
- **ឆ្នូតព័ណ៌ក្រហម** នៅខាងក្រោម ជានិមិត្តរូប នៃវីរភាពអង់អាចក្លាហានរបស់វីរជនខ្មែរក្រោម ដែលហ៊ានបូជាជីវិតខ្លួនដើម្បីជាតិរស់ ។

លោក ថាច់ តាន់តារា ជាអតីតប្រធាន សហព័ន្ធខ្មែរកម្ពុជាក្រោម ក្នុងអាណត្តិកាលពីឆ្នាំ ១៩៩៦ ដល់ ២០០០ បានថ្លែងថា ទង់ជាតិកម្ពុជាក្រោម បានកើតឡើងដោយសភាខ្មែរកម្ពុជាក្រោម ដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិក ។

លោក ថាច់ តាន់តារា បានថ្លែងថា៖

*“ដល់ពេលធ្វើមហាសន្និបាតលើកទីបួន នៅទីក្រុងភីឡាដែលផ្យា ក៏បានប្តូរឈ្មោះឲ្យទៅជា «សភាខ្មែរកម្ពុជាក្រោម» ទៅវិញ ។ សភានេះក៏បានរៀបចំធម្មនុញ្ញសម្រាប់ឲ្យខ្មែរកម្ពុជាក្រោម សម្រាប់ឲ្យដែនដីកម្ពុជាក្រោម ដែលខំធ្វើបួនឆ្នាំ បានចេញទៅជាទង់ [ជាតិកម្ពុជាក្រោម]*

*ដែលយើងមានប្រើសព្វថ្ងៃ ទង់ដែលយើងពាក់សព្វថ្ងៃ ។ ទង់នេះហើយ ដែលជាស្នាដៃរបស់ សភាខ្មែរកម្ពុជាក្រោម យើង ដែលបង្កើតឡើង នៅទីក្រុងភីឡាដែលផ្យា ដែលមានខ្ញុំព្រះករុណា ខ្ញុំបាទ ធ្វើជាប្រធាន និងមានគណៈកម្មការយ៉ាងច្រើន មាន លោក ថាច់ ចាន់ និងអស់លោក មកពីស្រុកបារាំង មកពីស្រុកខ្មែរ បានរួបរួមគ្នា ធ្វើគ្រប់បែបយ៉ាង ដើម្បីឲ្យមានជាធម្មនុញ្ញមួយ ។ ដោយយើងយល់ថា បើយើងចង់មានទឹកដី យើងត្រូវចាប់ផ្ដើមឲ្យមានច្បាប់ដើម្បីគ្រប់គ្រងទឹកដីហ្នឹង ឬយ៉ាងតិចណាស់ ត្រូវប្រកាសប្រាប់គេឯងថា តើយើងជាខ្មែរកម្ពុជាក្រោមចង់បានហ្នឹង ចង់បានស្អី ហើយយើងដើរនយោបាយរបៀបណា”* ។ [1]

## កើតចេញពីទង់ពុទ្ធសាសនា៖

គំនិតនៃការបង្កើតទង់ជាតិកម្ពុជាក្រោម កើតចេញពីទង់ពុទ្ធសាសនា ដោយសារពលរដ្ឋខ្មែរក្រោមជាអ្នកគោរពប្រតិបត្តិតាមពុទ្ធសាសនាថេរវាទ តាំងពីយូរលង់ណាស់មកហើយ ។ ម្យ៉ាងទៀត ជីវិតរបស់ខ្មែរក្រោមម្នាក់ៗនៅដែនដីកម្ពុជាក្រោម តែងតែផ្សារភ្ជាប់នឹងទង់ពុទ្ធសាសនាយ៉ាងស្អិតរមួត ដោយសារទង់នេះ ត្រូវបានព្រះសង្ឃបង្ហូតឡើងនៅតាមវត្តអារាមនានាគ្រប់ពេលវេលា ។ ដើម្បីឲ្យទង់ជាតិកម្ពុជាក្រោមបង្កើតមក ត្រូវនឹងផ្នត់គំនិតរបស់ប្រជាជនខ្មែរក្រោម សភាខ្មែរកម្ពុជាក្រោម បានសម្រេចកាត់យក ៣ ព័ណ៌ត្រង់ភាគខាងលើនៃទង់ពុទ្ធសាសនាមកធ្វើជាទង់ជាតិរបស់ខ្លួន ។

ត្រង់ចំណុចនេះ ព្រះតេជព្រះគុណ ឡឹម ខៃ ជាព្រះសង្ឃដែលបានចូលរួមធ្វើដំណើរតស៊ូជាមួយនឹង សហព័ន្ធខ្មែរកម្ពុជាក្រោម តាំងពីដើមមកនោះ បានថ្លែងថា ការបង្កើតទង់ជាតិកម្ពុជាក្រោម ដែលមាន ៣ ព័ណ៌ គឺ ខៀវ លឿង និងក្រហម នោះ ពិតជាមានអត្ថន័យជ្រាលជ្រៅខ្លាំងណាស់សម្រាប់ប្រជាជាតិខ្មែរក្រោម ព្រោះនៅកម្ពុជាក្រោម ជាតិ និងសាសនា តែងតែនៅជាប់ជាមួយគ្នាជានិច្ច បានធ្វើឲ្យជាតិខ្មែរនៅគង់វង្សរហូតមកដល់សព្វថ្ងៃ ។ ដូច្នេះហើយ ទើបនៅក្នុងសង្គមខ្មែរក្រោម តែងតែឮគេថ្លែងនូវ

[1] To Kim Thong, (១០ សីហា ២០១៩), ‘វីដេអូផ្សាយនៅលើ Facebook ដែល លោក ថាច់ តាន់តារា ថ្លែងនៅក្នុងកិច្ចប្រជុំរបស់សហព័ន្ធខ្មែរកម្ពុជាក្រោម និយាយអំពីការបង្កើតជាទង់ជាតិកម្ពុជាក្រោម’, (ស្រង់ប្រភព៖ ១៣ កក្កដា ២០២០), https://is.gd/NT21SW

សុភាសិតមួយថា៖

“*សាសានារលត់ ជាតិរលាយ សាសនាពណ្ណរាយ ជាតិរុងរឿង*” ។

ព្រះតេជព្រះគុណ ឡឹម ខៃ បានមានព្រះបន្ទូលថា ទង់ជាតិកម្ពុជាក្រោម បង្កើតមកមានអត្ថន័យគ្របដណ្ដប់ទាំងជាតិ និងសាសនា ដោយព្រះអង្គបានបង្កើតជាពាក្យស្លោកមួយឃ្លាថា «**បត់ជាតិលាតសាសនា**» ។ ពាក្យនេះមានន័យថា កាលណាគេយកទង់ពុទ្ធសាសនាដែលមាន ៦ ព័ណ៌ មកបត់ជាពីរ នឹងកើតជាទង់ជាតិកម្ពុជាក្រោម ដែលមាន ៣ ព័ណ៌ គឺ ខៀវ លឿង និងក្រហម ទើបហៅថា «**បត់ជាតិ**» តែកាលណាលាតសន្ទឹងចេញមកវិញ នឹងកើតជាទង់ពុទ្ធសាសនា ទើបហៅថា «**លាតសាសនា**» ។



សូមបញ្ជាក់ថា ទង់ពុទ្ធសាសនា មាន ៦ ព័ណ៌ គឺ ខៀវ, លឿង, ក្រហម, ស, ហង្សបាទ និង ផ្លេក ។ នេះជាទង់តំណាង និងជានិមិត្តរូបនៃព្រះពុទ្ធសាសនា សម្រាប់ពុទ្ធសាសនិកប្រើទូទាំងពិភពលោក ។ ទង់នេះបានបង្កើតឡើងនៅឆ្នាំ ១៨៨៥ ដោយគណៈកម្មាធិការខូឡុមបូ (Colombo Committee) នៅទីក្រុង Colombo នៃប្រទេសសិរីលង្កា ។ ក្រោយមក លោក ហែនរី ស្ទិល អូលកត (Henry Steel Olcott) ជាអ្នកកាសែតជនជាតិអាមេរិក មានគំនិតថា ទ្រង់ទ្រាយទង់ជ័យនេះ មានលក្ខណៈវែង អាចនឹងមានបញ្ហាសម្រាប់ការប្រើប្រាស់ជាទូទៅ នាពេលអនាគត ។ លោកក៏បានសំណូមពរឲ្យគណៈកម្មការកែប្រែខ្នាត និងទ្រង់ទ្រាយ តាមបែបទង់ជាតិនៃប្រទេសនីមួយៗវិញ ។ នៅក្នុងមហាសន្និបាតពុទ្ធសាសនិកជនពិភពលោក នៅឆ្នាំ ១៩៥០ ទង់ព្រះពុទ្ធសាសនា ត្រូវបានអនុម័តជាផ្លូវការថាជា ទង់អន្តរជាតិសម្រាប់ពុទ្ធបរិស័ទទូទាំងពិភពលោក ។

ពណ៌ទាំង ៦ នៅក្នុងទង់ពុទ្ធសាសនា ត្រូវបានគេចាត់ទុកថា ជាតំណាងពណ៌ទាំង ៦ ឬឆព្វណ្ណរង្សី ដែលផ្សាយចេញពីព្រះកាយរបស់ព្រះពុទ្ធ ពេលដែលព្រះអង្គបានត្រាស់ជាព្រះពុទ្ធ ។ អត្ថន័យនៃព័ណ៌ទាំងនោះរួមមាន៖

- ♦ **ពណ៌ខៀវ** (នីលៈ) មានន័យថា ស្រឡាញ់សេចក្ដីល្អ ករុណាជាសកល ។

- ♦ **ពណ៌លឿង** (បិតៈ) មជ្ឈិមប្បដិបទា ឬផ្លូវកណ្ដាល វៀរចាកអំពើអាក្រក់ សូន្យសុង ឬ សុញ្ញតៈ ។
- ♦ **ពណ៌ក្រហម** (លោហិតៈ) សេចក្ដីចម្រើនដោយការប្រតិបត្តិ សេចក្ដីសម្រេច បញ្ញា គុណធម៌ ជោគលាភ និងសេចក្ដីថ្លៃថ្នូរ ។
- ♦ **ពណ៌ស** (ឱទាតៈ) ភាពបរិសុទ្ធនៃព្រះធម៌ ការនាំសត្វក្នុងត្រៃភពឲ្យរួចរដោះចាកទុក្ខ ។
- ♦ **ពណ៌ហង្សបាទ** (ស៊ីជម្ពូខ្ចីដូចជើងហង្ស) (មញ្ជេសតៈ) តំណាងពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ឬបញ្ញា ។
- ♦ **ពណ៌ផ្លេក** (បភស្សរៈ) គឺប្រជុំរស្មីទាំងអស់មក ។ [2]

**ទទួលស្គាល់ដោយអង្គការ UNPO៖**

នៅថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០១ បន្ទាប់ពី សហព័ន្ធខ្មែរកម្ពុជាក្រោម បានចូលជាសមាជិកពេញសិទ្ធិ នៃអង្គការប្រជាជាតិ និងប្រជាជនគ្មានតំណាង (UNPO) ទង់ជាតិកម្ពុជាក្រោម ត្រូវបានគេបង្ហូតឡើងនៅការិយាល័យកណ្ដាលរបស់ UNPO នៅទីក្រុងឡាអេ នៃប្រទេសហុល្លង់ ជាមួយនឹងទង់ជាតិនៃប្រជាជាតិនានាទាំង ៥២ ផ្សេងទៀត ដែលជាសមាជិករបស់ UNPO ។

ប្រធានអង្គការ UNPO លោក ចន នីមរ៉ូត (John Nimrod) បានថ្លែងទៅកាន់ថ្នាក់ដឹកនាំ ព្រះសង្ឃ និងសមាជិក នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម នៅក្នុងពិធីទទួលស្គាល់ខ្មែរក្រោមជាសមាជិកពេញសិទ្ធិនៃអង្គការ UNPO ដែលធ្វើនៅទីក្រុង Philadelphia រដ្ឋ Pennsylvania សហរដ្ឋអាមេរិក កាលពីឆ្នាំ ២០០១ ថា៖ *"អធិបតីរបស់អ្នក គឺលោក ថាច់ តាន់តារា បានផ្ញើទង់ជាតិមួយឲ្យខ្ញុំ ។ ខ្ញុំសូមជម្រាបជូនឲ្យលោកអ្នកឲ្យបានជ្រាបថា ឥឡូវនេះ ទង់ជាតិរបស់អ្នក ត្រូវបានបង្ហូតឡើងក្នុងចំណោមទង់ជាតិសមាជិកទាំង ៥២ ផ្សេងទៀត នៅក្នុងការិយាល័យកណ្ដាលរបស់យូអិនភីអូ"*។ [3]

សព្វថ្ងៃ ទង់ជាតិកម្ពុជាក្រោម ត្រូវបានពលរដ្ឋខ្មែរក្រោមលើកឡើងនៅតាមផ្ទះ និង

[2] Buddhist flag, (២៧ ធ្នូ ២០២០), Wikipedia, https://en.wikipedia.org/wiki/Buddhist_flag

[3] DVD ពិធីបុណ្យប្រណាំងទូក-ង អន្តរជាតិ នៅទីក្រុង Philadelphia លើកទី ៤ ថ្ងៃទី ១ - ៥ ខែសីហា ឆ្នាំ ២០០១, រៀបរៀងដោយ អ្នកស្រី កៀង សាខន, ផលិតដោយ ផលិតកម្មខ្មែរក្រោម, ផ្សព្វផ្សាយដោយ សហព័ន្ធខ្មែរកម្ពុជាក្រោម ឆ្នាំ ២០០១ ។

បង្ហួតឡើងនៅការិយាល័យសហព័ន្ធខ្មែរកម្ពុជាក្រោម អង្គការ សមាគម និងវត្តអារាម នានានៅជុំវិញពិភពលោក ដើម្បីបង្ហាញដល់មជ្ឈដ្ឋាននានាបានដឹងថា ខ្លួនជាខ្មែរក្រោម មកពីដែនដីកម្ពុជាក្រោម ៕

# ជំនោរសេរីភាព

នៅថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ ២០១៤ ជាថ្ងៃបុណ្យជាតិ ដើម្បីកត់សម្គាល់កំណើតរបស់សហរដ្ឋអាមេរិក ដែលកាលពី ២៣៨ ឆ្នាំមុន សហរដ្ឋអាមេរិក បានប្រកាសឯករាជ្យចេញពីអង់គ្លេស ។ នៅថ្ងៃនេះ រដ្ឋាភិបាល និងពលរដ្ឋអាមេរិកកាំង បានអបអរ «ទិវាឯករាជ្យ» របស់ខ្លួន ដោយមានការបាញ់កាំជ្រួចអបអរសាទរ និងអាំងសាច់នៅទីធ្លាក្រោយផ្ទះ គឺជាឱកាសមួយសម្រាប់ពលរដ្ឋអាមេរិកកាំង គិតពិចារណាលើតម្លៃនៃឯករាជភាព និងប្រព័ន្ធប្រជាធិបតេយ្យរបស់រដ្ឋាភិបាល ។ តម្លៃឯករាជភាពរបស់សហរដ្ឋអាមេរិកមិនត្រឹមតែបានធ្វើឲ្យប្រទេសមួយនេះមានភាពរីកចម្រើនរុងរឿង មានលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សដ៏កំពូលក្នុងលោកតែប៉ុណ្ណោះទេ វាបានរួមចំណែកដល់ការជម្រុញឲ្យមានសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យនៅជុំវិញពិភពលោកផងដែរ ។ ក្រោយមក «សេចក្តីប្រកាសឯករាជ្យ» របស់សហរដ្ឋអាមេរិក បានបំផុសគំនិតឲ្យបង្កើតជាសេចក្តីប្រកាសដ៏ល្បី ក្នុងដំណើរស្វែងរកនូវសេរីភាពរបស់មនុស្សជាច្រើន ដូចជា របស់ Martin Luther King Jr. និង Abraham Lincoln ។ សេចក្តីប្រកាសនេះក៏បានជះឥទ្ធិពលលើ «សេចក្តីប្រកាសឯករាជ្យ» របស់ប្រទេសមួយចំនួនក្នុងពិភពលោក ក្នុងនោះ មានប្រទេសវៀតណាម និងឆិមបាវ៉េ (Zimbabwe) ជាដើម ។ ចំពោះខ្មែរក្រោមនៅកម្ពុជាក្រោមវិញ មានឱកាសបានទទួលលម្ហើយដែលកើតចេញពីជំនោរសេរីភាពទាំងនោះដែរឬទេ ខណៈដែល «សេចក្តីប្រកាសឯករាជ្យ» របស់ប្រទេសវៀតណាម បានចម្លងតាមគំនិតរបស់សហរដ្ឋអាមេរិកដែរនោះ ។

ថ្ងៃទី ៤ ខែកក្កដា កាលពីឆ្នាំ ១៧៧៦ បិតាស្ថាបនិករបស់សហរដ្ឋអាមេរិកបានផ្លាស់ប្តូរប្រវត្តិសាស្ត្រដោយបង្កើតរដ្ឋថ្មី ដែលកើតចេញពីជំនឿជឿជាក់លើសេរីភាព និងគោលគំនិត *“មនុស្សទាំងអស់កើតមកស្មើភាពគ្នា ធម្មជាតិបានផ្តល់សិទ្ធិជាមូលដ្ឋានដល់មនុស្សដែលមិនអាចប៉ះពាល់បាន សិទ្ធិទាំងនោះ ដូចជា សិទ្ធិរស់រានមានជីវិត សេរីភាព និងសិទ្ធិស្វែងរកសុភមង្គល”* ។ គោលការណ៍ទាំងនេះ បានដឹកនាំសហរដ្ឋអាមេរិកឲ្យទទួលបានឥស្សរភាពពីចក្រភពអង់គ្លេស ហើយបានទ្រទ្រង់សហរដ្ឋអាមេរិកឲ្យ

ក្លាយជាពន្លឺភ្លើង នៃក្ដីសង្ឃឹមសម្រាប់ពលរដ្ឋអាមេរិកទាំងអស់ឲ្យទទួលបានភាពថ្លៃថ្នូរក្នុងសេរីភាព និងលទ្ធិប្រជាធិបតេយ្យរហូតមកដល់សព្វថ្ងៃ ។ ពន្លឺភ្លើងនោះបាន និងកំពុងតែបន្តបញ្ចេញរស្មីយ៉ាងភ្លឺត្រចះត្រចង់ទៅក្នុងប្រទេសនានាទូទាំងពិភពលោក ។

តម្លៃនៃ «ឯករាជ្យ» របស់សហរដ្ឋអាមេរិក ដែលពលរដ្ឋអាមេរិកទទួលបានថ្ងៃនេះ វាកើតឡើងក្នុងប្រវត្តិសាស្ត្រមួយត្រូវបានគេចងចាំថា មិនមែនជាមាគ៌ារលូន និងងាយស្រួលទេ ។ ប៉ុន្តែការរក្សានិងការពារ «ឯករាជ្យ» ដែលបានមកហើយនោះ រឹតតែពិបាកជាងនេះទៅទៀត ។ ដូចដែលប្រវត្តិសាស្ត្រសហរដ្ឋអាមេរិក បានបង្ហាញឲ្យឃើញស្រាប់ហើយ ការធានាឲ្យមានលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សដែលកើតចេញពី «សេចក្ដីប្រកាសឯករាជ្យ» របស់សហរដ្ឋអាមេរិកនោះ មិនមែនជាការស្រួលទេ វាទាមទារឲ្យមានការប្ដេជ្ញាចិត្ត និងការខិតខំច្រើនទាំងពីសំណាក់អ្នកដឹកនាំ ទាំងពីសំណាក់ប្រជាជន ។ គោលជំហរទាំងនេះហើយ ទើបអាចធ្វើឲ្យសហរដ្ឋអាមេរិកបានក្លាយជាអរិយប្រទេស និងបានបង្ហាញដល់ពិភពលោកថា វាពិតជាអាចបង្កើត និងរក្សាស្ថាប័នប្រជាធិបតេយ្យរឹងមាំលើកកម្ពស់សេរីភាព និងបានផ្ដល់ឱកាសសម្រាប់មនុស្សគ្រប់រូបក្នុងលោក ។

សម្រាប់វៀតណាមវិញ ហូ ជី មិញ បានប្រកាស «សេចក្ដីប្រកាសឯករាជ្យ» នៅថ្ងៃទី ២ ខែកញ្ញា ឆ្នាំ ១៩៤៥ នៅទីក្រុងហាណូយ ដើម្បីប្រកាសឯករាជ្យចេញពីអាណានិគមបារាំង ហើយបង្កើតជាប្រទេសថ្មីមួយ ។ «សេចក្ដីប្រកាសឯករាជ្យ» របស់វៀតណាម ត្រូវបានគេមើលឃើញថា វាបានទទួលឥទ្ធិពលពីសហរដ្ឋអាមេរិក ។ អ្វីដែលគេមើលឃើញនោះ គឺនៅក្នុង «សេចក្ដីប្រកាសឯករាជ្យ» របស់វៀតណាមបានចែងថា *“មនុស្សទាំងអស់កើតមកស្មើភាពគ្នា ធម្មជាតិបានផ្ដល់សិទ្ធិជាមូលដ្ឋានដល់មនុស្សដែលមិនអាចប៉ះពាល់បានសិទ្ធិទាំងនោះ ដូចជា សិទ្ធិរស់រានមានជីវិត សេរីភាព និង សិទ្ធិស្វែងរកសុភមង្គល”* ។ សម្ដីអមតៈនៅក្នុង «សេចក្ដីប្រកាសឯករាជ្យ» របស់សហរដ្ឋអាមេរិក កាលពីឆ្នាំ ១៧៧៦ នោះ មានន័យទូលំទូលាយណាស់ ឃ្លានេះមានន័យថា ជនជាតិទាំងអស់ក្នុងពិភពលោក កើតមកមានសិទ្ធិស្មើគ្នា ជនជាតិណាក៏មាន

សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានភាពសប្បាយរីករាយ និងសេរីភាព ។ ៣២ ឆ្នាំបន្ទាប់វៀតណាមបានប្រកាស «សេចក្តីប្រកាសឯករាជ្យ» នៅថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ១៩៧៧ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ បានទទួលស្គាល់វៀតណាម ជាសមាជិកទី ១៤៩ របស់អង្គការសហប្រជាជាតិ ។ កត្តានេះបង្ហាញឲ្យឃើញថា ជនជាតិយួនបានក្លាយជាប្រជាជាតិមួយ ដែលមានប្រទេស មានឯករាជ្យ និងសេរីភាព ដូចជាជនជាតិនានាក្នុងពិភពលោកដែរ តែវាមិនមែនជារបស់ប្រជាពលរដ្ឋខ្មែរក្រោម ដែលកំពុងតែរស់នៅកម្ពុជាក្រោម សព្វថ្ងៃ នោះទេ ។

ប្រាកដណាស់ ពលរដ្ឋខ្មែរក្រោម ជាមនុស្សមួយក្រុមដែល អ.ស.ប. ចាត់ទុកថាជា «ជនជាតិដើម» នៃដែនដីកម្ពុជាក្រោម ហើយត្រូវបានគាំពារដោយសេចក្តីប្រកាសរបស់ អ.ស.ប. ស្តីពីសិទ្ធិជនជាតិដើមថា “ជនជាតិដើមគ្រប់រូប មានសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង” ។ ប៉ុន្តែអ្វីៗទាំងអស់វាផ្ទុយពីនេះ ដោយមានសេចក្តីរាយការណ៍ជាហូរហែមកថា ខ្មែរក្រោមរងការធ្វើទុក្ខបុកម្នេញគ្រប់ពេលពីរបបអាណានិគមយួន ដែលកើតចេញពីគំនិតប្រកាន់ពូជសាសន៍ ហើយឈានទៅ អនុវត្តនូវគោលនយោបាយរំលាយពូជសាសន៍ខ្មែរក្រោម និងលុបបំបាត់ប្រវត្តិសាស្ត្រនៃកម្ពុជាក្រោមទៀតផង ។ កាលពីខែកញ្ញា ឆ្នាំ ២០១៣ រដ្ឋាភិបាលវៀតណាមបានចាប់ព្រះសង្ឃវត្តសេរីតាសេក ២ អង្គ និងអ្នកភូមិ ២ រូប ដាក់គុកពី ២ ឆ្នាំ ទៅ ៦ ឆ្នាំ ពីបទទាក់ទងនឹងសហព័ន្ធខ្មែរកម្ពុជាក្រោម នៅក្រៅប្រទេស និងពីបទ «រត់ចេញទៅក្រៅប្រទេសដើម្បីប្រឆាំងរដ្ឋាភិបាល»។ ក្រៅពីនេះ បានផ្តន្ទាទោសអ្នកភូមិព្រៃជាប់ នៃខេត្តឃ្លាំង ៥ រូបទៀតឲ្យជាប់គុកពី ១០ ខែទៅ ២ ឆ្នាំ ពីបទ «បង្កអសន្តិសុខទីសាធារណៈ» ដោយគ្រាន់តែអ្នកទាំងនេះបានទូងស្គរក្នុងវត្ត ដើម្បីជំទាស់នឹងការដែលអាជ្ញាធរយួនចូលមកវត្តចាប់ព្រះសង្ឃតែប៉ុណ្ណោះ ។ ពិធីបុណ្យចូលឆ្នាំរបស់ជនជាតិយួន រដ្ឋាភិបាលវៀតណាមបានអនុញ្ញាតឲ្យជនជាតិយួនឈប់សម្រាកកន្លះខែរៀងរាល់ឆ្នាំ ដែលវាផ្ទុយពីខ្មែរក្រោមម្ចាស់ស្រុកនៃដែនដីកម្ពុជាក្រោម វៀតណាមមិនបានអនុញ្ញាតឲ្យពួកគេឈប់សម្រាក ដើម្បីបានអបអរពិធីបុណ្យជាតិរបស់ខ្លួនឡើយ ។ ឈ្មោះភូមិស្រុក និងខេត្ត

នៃដែនដីកម្ពុជាក្រោមជាភាសាខ្មែរ ត្រូវរបបយួនលុបបំបាត់ដោយប្តូរឈ្មោះទៅជាភាសាយួនគ្មានសល់ និងអ្នកដែលហ៊ាននិយាយពីប្រវត្តិសាស្ត្រកម្ពុជាក្រោម និងនិយាយឈ្មោះភូមិសាស្ត្រដែនដីកម្ពុជាក្រោមជាភាសាខ្មែរ នឹងត្រូវរដ្ឋាភិបាលយួនចាត់ទុកថា ជាអ្នកប្រឆាំងហើយចាប់ដាក់គុកជាមិនខាន ។ នេះគ្រាន់តែលើកយកចំណុចតូចមួយ មកនិយាយតែប៉ុណ្ណោះ ក៏ល្មមបញ្ជាក់ឲ្យឃើញថា ជីវិតខ្មែរក្រោមរស់នៅក្រោមនឹមអាណានិគមយួន គ្មានសិទ្ធិអ្វីទាំងអស់ ក្រៅតែពីមានដង្ហើមរស់សម្រាប់កំដរផែនដីតែប៉ុណ្ណោះ ។ តើអ្វីទៅដែល «សេចក្តីប្រកាសឯករាជ្យ» របស់វៀតណាមថា *“ជនជាតិទាំងអស់ក្នុងពិភពលោកកើតមកមានសិទ្ធិស្មើគ្នា ជនជាតិណា ក៏មានសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានភាពសប្បាយរីករាយ និងសេរីភាព”* នោះ ?

ជំនោរសេរីភាពដែលកើតចេញពី «សេចក្តីប្រកាសឯករាជ្យ» របស់អាមេរិក និងរបស់ប្រទេសវៀតណាម និងជំនោរសេរីភាពដែលកើតចេញពី សេចក្តីប្រកាសរបស់ អ.ស.ប. ស្តីពីសិទ្ធិជនជាតិដើម នឹងបោកបក់ទៅគ្រប់ទីកន្លែងក្នុងពិភពលោក ប៉ុន្តែសម្រាប់ប្រជាជាតិខ្មែរក្រោម មិនទទួលបាននូវលម្ហើយដែលកើតចេញពីជំនោរសេរីភាពទាំងនោះសោះ ព្រោះមានជញ្ជាំងដ៏ក្រាស់នៃរបបទាំងពីរគឺ របបកុម្មុយនីស្ត និងរបបយួនមកបិទបាំង ។ តែនៅក្នុងសម័យបច្ចេកព័ត៌មានវិទ្យានេះ ពន្លឺនៃសេរីភាពនឹងថែងចាំងច្រាលចូលទៅក្នុងសត្យារម្មណ៍របស់ខ្មែរក្រោមគ្រប់រូប ឲ្យបានស្គាល់ពីតម្លៃនៃសិទ្ធិរបស់ខ្លួនក្នុងនាមជាម្ចាស់ស្រុកនៃកម្ពុជាក្រោមជាក់ជាមិនខាន ។ ទីបំផុត «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» នឹងមានសម្រាប់ខ្មែរក្រោម នៅពេលណាដែលខ្មែរក្រោមគ្រប់រូបចេះឆក់យកឱកាសប្រើប្រាស់នូវសិទ្ធិរបស់ខ្លួន ៕

អត្ថបទនេះ បានចុះផ្សាយនៅគេហទំព័រ សារព័ត៌មាន ព្រៃនគរ និង វិទ្យុសំឡេងកម្ពុជាក្រោម (VOKK)
នៅក្នុងទិវាបុណ្យឯករាជ្យជាតិ របស់សហរដ្ឋអាមេរិក នៅថ្ងៃទី ៤ ខែកក្កដា ឆ្នាំ ២០១៤ ។

# ខ្ញុំមានសុបិនមួយសម្រាប់ខ្មែរក្រោម

នៅថ្ងៃទី ២០ ខែមករា ជារៀងរាល់ឆ្នាំ គឺជាថ្ងៃឈប់សម្រាកផ្លូវការរបស់សហរដ្ឋអាមេរិក ដើម្បីរំឭកដល់ថ្ងៃខួបកំណើតរបស់ ម៉ាធីន លូធើឃីង ជាមេដឹកនាំចលនា «សិទ្ធិពលរដ្ឋ» របស់អាមេរិកស្បែកខ្មៅ ដែលគាត់បានកើតនៅថ្ងៃទី ១៥ ខែមករា ឆ្នាំ ១៩២៩ ។ នៅថ្ងៃចន្ទទី ២០ ខែមករា ឆ្នាំ ២០១៤ ជាខួប ៨៥ ឆ្នាំ នៃថ្ងៃកំណើតរបស់ ម៉ាធីន លូធើឃីង ។ កាលពី ៥០ ឆ្នាំមុន ម៉ាធិន លូធើឃីង បានអានន្ទូវសុន្ទរកថាដ៏ល្បីល្បាញមួយមានចំណងជើងថា «ខ្ញុំមានសុបិនមួយ» ដែលក្រោយមក សុន្ទរកថានេះបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ពលរដ្ឋអាមេរិកស្បែកខ្មៅ ហើយបាននាំឲ្យមានចលនាអហិង្សាទូទាំងប្រទេស ដើម្បីលុបបំបាត់ការប្រកាន់ពណ៌សម្បុរនៅសហរដ្ឋអាមេរិក ។ ៥០ ឆ្នាំក្រោយមក នៅថ្ងៃទី ២៨ ខែសីហា ឆ្នាំ ២០១៣ នៅក្នុងទិវាខួប ៥០ ឆ្នាំ នៃសុន្ទរកថា «ខ្ញុំមានសុបិនមួយ» របស់ ម៉ាធីន លូធើឃីង ប្រធានាធិបតីស្បែកខ្មៅរបស់សហរដ្ឋអាមេរិក លោក បារ៉ាក់ អូបាម៉ា បានបញ្ជាក់ថា៖ *“ដោយសារពួកគេបានធ្វើដំណើរ-យាត្រា សហរដ្ឋអាមេរិកបានផ្លាស់ប្ដូរ និងទីបំផុត សេតវិមានក៏បានផ្លាស់ប្ដូរដែរ”* ។

ប្រាកដណាស់ មកដល់ពេលនេះ សហរដ្ឋអាមេរិក មានការផ្លាស់ប្ដូរទាំងស្រុង គឺក្រុមជនជាតិដើមស្បែកក្រហម និងក្រុមអាមេរិកស្បែកខ្មៅ ត្រូវបានគេគោរពសិទ្ធិស្មើភាពគ្នា ដោយមិនមានការប្រកាន់ ឬរើសអើងទៀតឡើយ ។ កាលពី ៥០ ឆ្នាំមុន ជនជាតិអាមេរិកស្បែកខ្មៅ ត្រូវគេរើសអើងយ៉ាងខ្លាំង ដោយរដ្ឋាភិបាលបានបែងចែកដាច់ស្រឡះរវាងមនុស្សស្បែកស និងស្បែកខ្មៅ ដូចជា នៅទីសាធារណៈ ទឹកសម្រាប់មនុស្សស្បែកស គឺមនុស្សស្បែកខ្មៅមិនមានសិទ្ធិផឹកឡើយ នៅតាមឡានក្រុង ក្រុមមនុស្សស្បែកខ្មៅ ត្រូវគេបង្ខំឲ្យចូលឡានតាមទ្វារពីខាងក្រោយ ឬប្រសិនបើក្រុមមនុស្សស្បែកសខ្វះកៅអី គេមានសិទ្ធិដេញមនុស្សស្បែកខ្មៅឲ្យក្រោកចេញ ដើម្បីគេយកកៅអីមកអង្គុយជាដើម ។

ដោយមានសកម្មភាពប្រកាន់ពណ៌សម្បុរ និងរើសអើងពូជសាសន៍បែបនេះ ទើប ម៉ាធីន លូធើឃីង បានចេញមុខដឹកនាំធ្វើការតស៊ូដោយអហិង្សា ដើម្បីទាមទារនូវ

«សិទ្ធិស៊ីវិល ឬសិទ្ធិពលរដ្ឋ» យោងតាមសេចក្ដីប្រកាសឯករាជ្យរបស់អាមេរិក ដែលបានប្រកាសកាលពីឆ្នាំ ១៧៧៦ ថា៖ *"មនុស្សគ្រប់រូបកើតមកមានសិទ្ធិស្មើគ្នា ធម្មជាតិបានផ្ដល់ឲ្យពួកគេនូវសិទ្ធិដែលមិនអាចប៉ះពាល់បានឡើយ ។ នៅក្នុងសិទ្ធិនោះ មានសិទ្ធិរស់រានមានជីវិត សិទ្ធិសេរីភាព និងសិទ្ធិស្វែងរកសុភមង្គល"* ។ ម៉ាធីន លូធើ ឃីង បានបញ្ជាក់ថា មនុស្សគ្រប់រូបមិនថាស្បែកស ឬខ្មៅទេ ឲ្យតែជាពលរដ្ឋរបស់អាមេរិក ត្រូវតែទទួលបានផលប្រយោជន៍ពីកិច្ចសន្យារបស់សេចក្ដីប្រកាសឯករាជ្យនេះគ្រប់ៗគ្នា ។

នៅក្នុងខ្លឹមសារមួយនៃសុន្ទរកថា «ខ្ញុំមានសុបិនមួយ» ម៉ាធីន លូធើ ឃីង បានថ្លែងថា៖ *"ខ្ញុំមានសុបិនថា ថ្ងៃណាមួយ កូនរបស់ខ្ញុំទាំងបួននាក់ នឹងបានរស់នៅក្នុងប្រទេសមួយ ដែលពួកគេមិនត្រូវបានវាយតម្លៃដោយសម្បុរស្បែក តែដោយអាកប្បកិរិយារបស់ពួកគេ"* ។

ខណៈដែលសុបិនរបស់ ម៉ាធីន លូធើ ឃីង បានក្លាយជាការពិត តែយើងក្រឡេកមើលវាសនារបស់ខ្មែរក្រោម ដែលជាជនជាតិដើមនៃដែនដីកម្ពុជាក្រោមវិញ ពួកគេនៅតែត្រូវរងការរើសអើងពូជសាសន៍ពីរបបអាណានិគមវៀតណាម និងពីជនជាតិយួនដដែល ។

បន្ទាប់ពីបារាំងបានផ្ទេរដែនដីកូស័ងស៊ីន ឬកម្ពុជាក្រោម ឲ្យយួនបន្តត្រួតត្រានៅថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ១៩៤៩ មកដល់ឆ្នាំ ២០១៤ នេះ គឺមានរយៈពេល ៦៥ ឆ្នាំហើយ ដែលជនជាតិដើមខ្មែរក្រោម តែងតែត្រូវរដ្ឋាភិបាលយួនរើសអើងពូជសាសន៍ និងធ្វើទុក្ខបុកម្នេញជារៀងរាល់ថ្ងៃឥតស្រាកស្រាន្ត ។

ករណីដែលរដ្ឋាភិបាលវៀតណាម នៅតែប្រកាន់ពូជសាសន៍លើពលរដ្ឋខ្មែរក្រោមនោះ មានដូចជា ជនជាតិយួនមានសិទ្ធិផ្ដាច់មុខលើខ្មែរក្រោមម្ចាស់ស្រុកគ្រប់យ៉ាងទាំងអស់ ។ ឧទាហរណ៍ជាក់ស្ដែង ពិធីបុណ្យចូលឆ្នាំយួនរៀងរាល់ឆ្នាំ ពលរដ្ឋវៀតណាមទូទាំងប្រទេស ត្រូវបានរដ្ឋាភិបាលអនុម័តឲ្យឈប់សម្រាករយៈពេលកន្លះខែ តែសម្រាប់បុណ្យចូលឆ្នាំ និងបុណ្យសែនដូនតារបស់ខ្មែរក្រោមវិញ ក្នុងមួយឆ្នាំមានតែ ៤ ថ្ងៃប៉ុណ្ណោះ មិនត្រូវបានរបបអាណានិគមយួន ប្រកាសឲ្យមានថ្ងៃឈប់សម្រាកទូទាំង

កម្ពុជាក្រោមឡើយ ។ រដ្ឋាភិបាលវៀតណាមបានបើកសាលាឲ្យជនជាតិយួនរៀនទូទាំងប្រទេស លោកគ្រូ អ្នកគ្រូ មានប្រាក់ខែ តែមិនបានបើកសាលាកម្មវិធីជាខ្មែរសម្រាប់ខ្មែរក្រោមទូទាំងកម្ពុជាក្រោមបានរៀនឡើយ ។ ទង្វើនេះ នៅពេលអនាគត កូនចៅខ្មែរក្រោមនឹងក្លាយទៅជាជនជាតិយួនយ៉ាងពិតប្រាកដ ដោយសារពួកគេមិនបានចេះអក្សរសាស្ត្រជាតិរបស់ខ្លួន ព្រោះនាំគ្នារៀនតែភាសាយួននៅតាមសាលារដ្ឋយួន ។

នៅឆ្នាំ ២០១៣ រដ្ឋាភិបាលវៀតណាម បានបង្ក្រាបយ៉ាងឃោរឃៅទៅលើព្រះសង្ឃ និងពលរដ្ឋខ្មែរក្រោម ចំនួន ៨ អង្គ និង រូប ក្នុងនោះ បានចាប់ ព្រះតេជព្រះគុណ លី ចិន្តា នៃវត្តព្រៃជាប់ ច្រកចូលបារយកទៅធ្វើទារុណកម្ម ដោយចោទថា ព្រះសង្ឃអង្គនេះ បានទាក់ទងខ្មែរក្រោមនៅក្រៅប្រទេស ។ ចំណែក ព្រះតេជព្រះគុណ លីវ នី និង ព្រះតេជព្រះគុណ ថាច់ ធឿន ត្រូវចាប់ផ្សឹក និងដាក់គុក ៦ ឆ្នាំ ដោយគ្រាន់តែព្រះសង្ឃទាំង ២ អង្គនេះ បានផ្តល់បទសម្ភាសន៍តិចតួចដល់ វិទ្យុសំឡេងកម្ពុជាក្រោម និងវិទ្យុអាស៊ីសេរី ។ នៅមានករណីជាច្រើនទៀត ដែលរដ្ឋាភិបាលយួនបានរំលោភសិទ្ធិពលរដ្ឋខ្មែរក្រោម ដោយយើងមិនអាចរៀបរាប់ឲ្យអស់សេចក្តីនៅទីនេះបានឡើយ ។

«ខ្ញុំមានសុបិនមួយសម្រាប់ខ្មែរក្រោម» ថា ថ្ងៃណាមួយ ខ្មែរក្រោមនឹងមិនមានការរើសអើងពូជសាសន៍ពីរបបអាណានិគមយួន និងពីជនជាតិយួនទៀតឡើយ ។ ពលរដ្ឋខ្មែរក្រោមនឹងមានសិទ្ធិស្មើជនជាតិយួន ដោយពួកគេមានសាលារៀនកម្មវិធីខ្មែររបស់ខ្លួន និងរាល់ពេលបុណ្យជាតិរបស់ពួកគេ ត្រូវបានរដ្ឋាភិបាលប្រកាសឲ្យសាលារៀន ក្រុមហ៊ុនផ្សេងៗ និងគ្រប់ស្ថាប័នរដ្ឋនៅកម្ពុជាក្រោមត្រូវតែបិទទ្វារ ដើម្បីខ្មែរក្រោមគ្រប់រូបបានសម្រាកក្នុងថ្ងៃបុណ្យជាតិរបស់ខ្លួនគេដោយសេរី ។

«ខ្ញុំមានសុបិនមួយសម្រាប់ខ្មែរក្រោម» ថា ថ្ងៃណាមួយ ពលរដ្ឋខ្មែរក្រោមនឹងមាន «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» នៅកម្ពុជាក្រោមជាទឹកដីរបស់ខ្លួន ដោយមិនមានរដ្ឋាភិបាលយួនធ្វើអាណានិគម និងធ្វើទុក្ខបុកម្នេញទៀតឡើយ ៕

អត្ថបទនេះ បានចេញផ្សាយគេហទំព័រ វិទ្យុសំឡេងកម្ពុជាក្រោម (VOKK) សារព័ត៌មាន ព្រៃនគរ ឆ្នាំ ២០១៥ ។

# ចង់បានសិទ្ធិម្ចាស់ការលើទឹកដី ត្រូវមានសិទ្ធិម្ចាស់ការលើទឹកចិត្តជាមុន

ប្រជាជាតិខ្មែរក្រោមនៃដែនដីកម្ពុជាក្រោម មិនដែលទទួលបាននូវសិទ្ធិម្ចាស់ការនៅលើទឹកដីរបស់ខ្លួនទេ បើទោះបីមកដល់ឆ្នាំ ២០១១ នេះ មានរយៈពេល ៦៣ ឆ្នាំហើយ ដែល អ.ស.ប. បានចេញសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស សម្រាប់មនុស្សជាតិ នៅថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ១៩៤៨ ។ ក្នុងអំឡុង ៦៣ ឆ្នាំនេះ ពលរដ្ឋខ្មែរក្រោមនៅតែត្រូវរបបអាណានិគមយួនពីរបបមួយទៅរបបមួយ រំលោភបំពានសិទ្ធិឥតស្រាកស្រាន្ត ។ ការរើសអើងពូជសាសន៍ឈានទៅដល់ការជិះជាន់ និងសម្លាប់ជីវិតខ្មែរក្រោមពីសំណាក់របបអាណានិគមយួននោះ បានជំរុញឲ្យពលរដ្ឋខ្មែរក្រោមងើបឡើងតស៊ូដើម្បីសិទ្ធិម្ចាស់ការរបស់ខ្លួនជាបន្តបន្ទាប់ឥតឈប់ឈរ តែមិនទាន់បានជោគជ័យ ។ តាំងពីជនជាតិមួយដែលត្រូវគេបំភ្លេចចោល ហើយឈានទៅដល់ការបង្ហាញវត្តមានរបស់ខ្លួននៅលើឆាកអន្តរជាតិនាពេលបច្ចុប្បន្ន វាជាលទ្ធផលមួយបង្ហាញឲ្យឃើញថា «ខ្មែរក្រោមគ្រប់រូបមានសិទ្ធិម្ចាស់ការលើទឹកចិត្តខ្លួនជាមូលដ្ឋានហើយ ក្នុងការស្វែងរកសិទ្ធិម្ចាស់ការលើទឹកដីរបស់ខ្លួននាពេលអនាគត» ។ ដើម្បីឈានដល់ការទទួលបាននូវ «សិទ្ធិម្ចាស់ការ» ឬ “សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» កម្ពុជាក្រោម នោះតើខ្មែរក្រោមម្នាក់ៗក្នុងនាមជាសមាជិកសង្គមនៃប្រជាជាតិខ្មែរក្រោម ត្រូវត្រៀមខ្លួនយ៉ាងណាខ្លះ ?

## មានតែខ្លួនជាទីពឹងរបស់ខ្លួន

ជាការពិតណាស់ អ្វីដែលខ្មែរក្រោមមានវត្តមាននៅលើឆាកអន្តរជាតិ នាពេលនេះគឺមកពីការតស៊ូរបស់ខ្មែរក្រោមគ្រប់ជំនាន់ ដើម្បីរក្សានូវអត្តសញ្ញាណជាតិរបស់ខ្លួន និងប្រឆាំងជាដាច់ខាតរាល់ឧបាយកលក្នុងបំណងរំលាយពូជសាសន៍ ពីសំណាក់របបអាណានិគមយួន ដោយផ្អែកលើគោលការណ៍ «ខ្លួនទីពឹងខ្លួន» និងមានទិសដៅពិតប្រាកដមួយក្នុងការ «សម្រេចវាសនាខ្លួនដោយខ្លួនឯង» នៅលើទឹកដីកម្ពុជាក្រោម ក្នុងនាមជាប្រជាជាតិមួយនៃពិភពលោក ។

ដើម្បីបានឈានដល់ «សម្រេចវាសនាខ្លួនដោយខ្លួនឯង» នោះ ជាដំបូង ប្រជាជនខ្មែរក្រោមខ្លួនឯងត្រូវមានគោលការណ៍ «ខ្លួនជាទីពឹងរបស់ខ្លួន» ឲ្យបានច្បាស់លាស់សិន គឺខ្មែរក្រោមម្នាក់ៗទូទាំងពិភពលោក ត្រូវមានគោលបំណង ទិសដៅ និងសំឡេងឲ្យបានឯកភាពគ្នាជាធ្លុងមួយ ក្នុងការរំដោះខ្លួនចេញពីនឹមអាណានិគមយួន ។

ជាមេរៀនដ៏ជូរចត់មួយដែលបានបន្សល់ទុកមកឲ្យខ្មែរក្រោម នៅតែនៅក្រោមនឹមអាណានិគមយួនរហូតមកដល់សព្វថ្ងៃនោះ គឺដោយសារតែ «ការតស៊ូជ្រកក្រោមបដានយោបាយរបស់គេ» ហើយសង្ឃឹមថា «គេនឹងជួយខ្លួនពេលណាគេបានជោគជ័យ ឬបានទទួលលទ្ធផល» ។ នៅកម្ពុជាក្រោម ក្នុងសម័យសង្គ្រាមអាមេរិក មុនឆ្នាំ ១៩៧៥ ខ្មែរក្រោមខ្លះ រត់ចូលបម្រើអាមេរិក ខ្លះទៀតចូលបម្រើយួនកុម្មុយនីស្ត ដោយសង្ឃឹមថា ពេលភាគីម្ខាងៗបានជោគជ័យ គេនឹងជួយខ្មែរក្រោមឲ្យមានសិទ្ធិសេរីភាព ឬជួយអ្វីម្យ៉ាង ។ នៅប្រទេសកម្ពុជាវិញ ខ្មែរក្រោមខ្លះ ចូលបម្រើក្នុងក្រុមសាធារណរដ្ឋ ខ្លះចូលបម្រើស្ដេច និងខ្លះទៀតចូលបម្រើខ្មែរក្រហម ដោយសង្ឃឹមថា ពួកគេនឹងជួយរំដោះកម្ពុជាក្រោមចេញពីយួន ពេលណាគេបានជោគជ័យ ឬបានឡើងកាន់អំណាច ។ ក្ដីសង្ឃឹមដែលខ្មែរក្រោមបានបូជាជីវិតនោះ ជាលទ្ធផលគឺត្រូវគេបំភ្លេចចោលឲ្យនៅកំព្រារងាតែលតោល «ចុះទឹកក្រពើ ឡើងលើខ្លា» ទុក្ខឥតស្រាកស្រាន្ត ។

ដូច្នេះ បើទោះបី អ.ស.ប. បានចេញសេចក្ដីប្រកាសជាសកលស្ដីអំពីសិទ្ធិមនុស្ស ដើម្បីជំរុញឲ្យប្រទេសជាហត្ថលេខីគោរព នូវសិទ្ធិរបស់មនុស្សគ្រប់ជាតិសាសន៍នៅក្នុងពិភពលោកក្ដី និងបានចេញសេចក្ដីប្រកាសស្ដីអំពីសិទ្ធិជនជាតិដើម ដោយក្នុងនោះបានចែងថា “*ជនជាតិដើមគ្រប់រូបមានសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង*” ក៏ដោយ ប៉ុន្តែបើខ្មែរក្រោមគ្រប់រូបមិននាំគ្នាឆក់យកឱកាស ដើម្បីបានទទួលនូវសិទ្ធិទាំងនោះទេ វាពិតជាគ្មានទេវតា ឬបុគ្គលណាម្នាក់ក្រៅពីខ្លួនឯងនាំយកនូវសិទ្ធិទាំងនោះមកឲ្យខ្លួនឯងបានឡើយ ។

## ខ្មែរក្រោមម្នាក់ៗ ជាមន្ត្រីស្ថានទូតរបស់ខ្មែរក្រោម៖

បច្ចុប្បន្ន ខ្មែរក្រោម បានក្លាយទៅជាប្រជាជាតិមួយដែលមានទង់ជាតិដាច់ដោយ

ទ្បែករបស់ខ្លួន ហើយត្រូវបានទទួលស្គាល់ដោយ អង្គការប្រជាជាតិ និងប្រជាជនគ្មានតំណាង (Unrepresented Nations and Peoples Organization) បន្ទាប់ពី សហព័ន្ធខ្មែរកម្ពុជាក្រោម (KKF) បានចូលជាសមាជិកនៃអង្គការមួយនេះ នៅថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០១ មក ។

ពេលនេះ ប្រជាជាតិខ្មែរក្រោមមានទង់ជាគ្រឿងតំណាងជាតិរបស់ខ្លួន និងមានដែនដីកម្ពុជាក្រោម ជាទីតាំងសម្រាប់ប្រាប់ដល់ពិភពលោកថា ខ្លួនមកពីណាហើយ ដូច្នេះ ខ្មែរក្រោមម្នាក់ៗមានមោទនភាពណាស់ ក្នុងការឧទ្ទេសនាមខ្លួនដល់មនុស្សគ្រប់ជាតិសាសន៍ថា «ខ្ញុំជាខ្មែរក្រោម» ។

សម្រាប់ប្រទេសដែលមានឯករាជ្យដូចជា កម្ពុជា ថៃ លាវ វៀតណាម និងចិនជាដើម ដែលជាសមាជិកនៃ អ. ស. ប. ពលរដ្ឋរបស់គេពិតជាងាយស្រួលខ្លាំងណាស់ក្នុងការឧទ្ទេសនាម និងបង្ហួតខ្លួនគេដល់បរទេស ហើយប្រទេសនីមួយៗ គេតែងតែមានស្ថានទូតតំណាងនៅក្រៅប្រទេសជានិច្ច ប៉ុន្តែសម្រាប់ ពលរដ្ឋខ្មែរក្រោម ឬ ដែនដីកម្ពុជាក្រោមវិញ នៅមិនទាន់មានទេ ។ ដើម្បីឲ្យខ្មែរក្រោមមានស្ថានទូតដូចគេនោះ គឺខ្មែរក្រោមម្នាក់ៗ ចាប់តាំងពីបុគ្គល គ្រួសារ សមាគម អង្គការ និងវត្តអារាមនានា នៅក្នុងសកលលោក ត្រូវតែលើកទង់ជាតិកម្ពុជាក្រោម និងតាំងផែនទីដែនដីកម្ពុជាក្រោមនៅគ្រប់ទីកន្លែងរបស់ខ្លួន ហើយមានតួនាទី និងកាតព្វកិច្ចក្នុងការនាំសារប្រាប់ដល់ជនបរទេសដែលនៅជុំវិញខ្លួនឲ្យបានដឹងអំពី «ខ្មែរក្រោម» និងជួយធ្វើកិច្ចការដ៏សំខាន់មួយទៀតនោះ គឺត្រូវចេះគាំពារគ្នាប្រកបដោយព្រហ្មវិហារធម៌ឲ្យបានដូចជាមន្ត្រីស្ថានទូតការពារពលរដ្ឋរបស់ខ្លួន ។

ដូច្នេះ បើខ្មែរក្រោមទាំងអស់គ្នាចង់បាន «សិទ្ធិម្ចាស់ការ» ឬ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» នៅលើទឹកដីកម្ពុជាក្រោម នោះ ក្នុងនាមជាខ្មែរក្រោមម្នាក់ៗ ត្រូវមាន «គំនិតម្ចាស់ការ» ឬ «សម្រេចវាសនាខ្លួនដោយខ្លួនឯង» នៅលើទឹកចិត្តខ្លួនឯងជាមុនសិន ៕

អត្ថបទនេះ ចុះផ្សាយនៅលើទំព័រ កាសែត សារព័ត៌មាន ព្រៃនគរ លេខ ២៨ ឆ្នាំទី ២
ចេញផ្សាយថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១១

## ១៦ វិច្ឆិកា បង្ហាញពីទឹកចិត្តខ្មែរក្រោម «រស់ព្រោះហ៊ានស្លាប់»

នៅថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ២០១៣ ជាកំណត់សម្គាល់គម្រប់ ៣៧ ឆ្នាំ នៃការងើបឡើងរបស់ប្រជាជាតិខ្មែរក្រោមនៅដែនដីកម្ពុជាក្រោម ដើម្បីសិទ្ធិម្ចាស់ការរបស់ខ្លួនពីនឹមអាណានិគមយួន ។ ថ្ងៃនេះកាលពី ៣៧ ឆ្នាំមុន គឺនៅថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ១៩៧៦ ជាព្រឹត្តិការណ៍បង្ហូរឈាមមួយដែលបានកើតឡើងនៅខេត្តព្រះត្រពាំង រវាងយុទ្ធជនខ្មែរក្រោម និងកងទ័ពនៃរដ្ឋាភិបាលបក្សកុម្មុយនីស្តយួន បានបណ្តាលឲ្យយុទ្ធជនខ្មែរក្រោមទាំងព្រះសង្ឃ និងគ្រហស្ថជាច្រើនអង្គ និងរូប បានបូជាជីវិតក្នុងសមរភូមិ ហើយត្រូវអាជ្ញាធរបក្សកុម្មុយនីស្តយួនកាត់ទោសប្រហារជីវិត និងកាត់ទោសឲ្យជាប់គុកពី ៣ ឆ្នាំ រហូតដល់អស់មួយជីវិត ។

ការងើបឡើងដោយប្រើកម្លាំងប្រដាប់អាវុធរបស់ខ្មែរក្រោម នៃ «រណសិរ្សសេរីភាពជាតិរំដោះកម្ពុជាក្រោម» នាពេលនោះ ជាព្រឹត្តិការណ៍មួយបង្ហាញឲ្យឃើញនូវមេរៀនបរាជ័យមួយរបស់ប្រជាជាតិខ្មែរក្រោម ហើយរដ្ឋាភិបាលបក្សកុម្មុយនីស្តយួនបានឆ្លើយតបមកវិញ ដោយការសងសឹកជាទ្រង់ទ្រាយប្រកាន់ពូជសាសន៍ចំពោះអ្នកដែលហ៊ានងើបឡើងរំដោះជាតិចេញពីនឹមត្រួតត្រារបស់របបយួន ។ ការបាញ់ប្រហារ និងធ្វើទារុណកម្មលើអ្នកតស៊ូខ្មែរក្រោមនៅក្នុងព្រឹត្តិកាណ៍មួយនេះ ជាទារុណកម្មដ៏អាថ៌កំបាំងមួយមិនត្រូវបានពិភពលោកដឹងឮឡើយ ។ ផ្ទុយពីបរាជ័យក្នុងព្រឹត្តិការណ៍ ១៦ វិច្ឆិកា នេះ វាក៏បានឆ្លុះបញ្ចាំងឲ្យឃើញនូវទឹកចិត្តអង់អាចក្លាហានគ្មានអ្វីប្រៀបរបស់យុទ្ធជនខ្មែរក្រោមដែលហ៊ានងើបឡើង ដើម្បីអ្វីមួយដែលគេហៅថា «ការរំដោះខ្មែរក្រោមឲ្យចេញពីនឹមអាណានិគមយួន» និងចង់បញ្ជាក់ឲ្យពិភពលោកឃើញថា «ខ្មែរក្រោមស៊ូស្លាប់ឈរ តែមិនព្រមលុតជង្គង់ក្រោមការជិះជាន់របស់យួនឡើយ» ។

**ការយកពងមាន់ទៅជល់នឹងថ្ម៖**

មតិខ្លះបានលើកឡើងថា ការដែលយុទ្ធជនខ្មែរក្រោម នៃ «រណសិរ្សសេរីភាពជាតិរំដោះកម្ពុជាក្រោម ហ៊ានងើបឡើងតស៊ូប្រយុទ្ធជាមួយកងទ័ពរបបអាណានិគមយួននោះ វាជាការស្រមើស្រមៃមួយដែលមិនអាចយកជ័យជម្នះបានឡើយ ព្រោះថា បើ

គេប្រៀបធៀបកម្លាំងភាគីទាំងសងខាង ឃើញថា យួនមានកងទ័ព និងអាវុធដ៏ច្រើនសន្ធឹកសន្ធាប់ ឬអាចនិយាយបានថា កម្លាំងទ័ពរបស់យួនខ្លាំងក្លាមហិមារបស់ប្រទេសជាតិមួយ ។ ចំណែកខ្មែរក្រោមវិញមានកម្លាំងកងទ័ព និងប្រដាប់អាវុធតិចជាងយួន ព្រោះខ្មែរក្រោមនាពេលនោះ គ្រាន់តែជាចលនារណសិរ្សដ៏តូចមួយតែប៉ុណ្ណោះ ។ ហេតុនេះហើយ បានធ្វើឲ្យមតិខ្លះយល់ឃើញថា ការដែលក្រុមរណសិរ្សខ្មែរក្រោមមួយនេះហ៊ានងើបឡើងរំដោះខ្មែរក្រោម នាពេលនោះ វាប្រៀបបាននឹង «យកពងមាន់ទៅជល់នឹងថ្ម» ។

**រស់ព្រោះហ៊ានស្លាប់៖**

ជាការពិតណាស់ ព្រឹត្តិការណ៍ ១៦ វិច្ឆិកា ថ្វីដ្បិតតែពលរដ្ឋខ្មែរក្រោមមិនបានទទួលជ័យជម្នះទាំងស្រុង ក្នុងការនាំមកនូវភាពម្ចាស់ការជូនប្រជាជាតិខ្មែរក្រោមក្ដី ប៉ុន្តែវាល្មមឆ្លុះបញ្ចាំងឲ្យឃើញនូវទិដ្ឋភាពមួយ ដែលប្រជាជាតិខ្មែរក្រោមមិនអាចអត់ទ្រាំបាននូវការឈឺចាប់ ដែលកើតចេញពីការរើសអើងពូជសាសន៍ ឈានដល់ការជិះជាន់ និងធ្វើទុក្ខបុកម្នេញពីសំណាក់រដ្ឋការយួនគ្រប់របបនយោបាយ ។ ការបូជាជីវិតរបស់យុទ្ធជនខ្មែរក្រោមនៅក្នុងសមរភូមិនេះ អាចឆ្លុះបញ្ចាំងឲ្យឃើញថា ខ្មែរក្រោមមានទឹកចិត្តតស៊ូដ៏អង់អាចក្លាហានគ្មានអ្វីប្រៀបបាន ហើយពួកគាត់ចង់បញ្ជាក់ថា «ខ្មែរក្រោមស៊ូស្លាប់ឈរ តែមិនព្រមរស់ដោយលុតជង្គង់» ក្រោមការជិះជាន់ និងគាបសង្កត់គ្រប់សព្វបែបយ៉ាងតាមទំនើងចិត្តនៃរបបអាណានិគមយួនឡើយ ។

ទឹកចិត្តក្លាហានមុះមុតរបស់យុទ្ធជន ថាច់ ភី, ថាច់ ភឿង, ថាច់ ភឿន ដែលហ៊ានប្រយុទ្ធជាមួយកងទ័ពយួនដែលមានរថក្រោះ រហូតដល់ត្រូវពលីជីវិត និងយុទ្ធជន ៣ រូបទៀត គឺ យុវជន គឹម រី, ថាច់ គិន និង ថាច់ ឌាក ត្រូវរដ្ឋការយួនកាត់ទោសប្រហារជីវិតនាពេលនោះ គឺជាការ «ហ៊ានស្លាប់» ដើម្បីឲ្យឈាមក្រហមឆ្អៅរបស់ខ្លួនស្រោចលើប្រថពីកម្ពុជាក្រោម ដាស់ស្មារតីខ្មែរក្រោមគ្រប់រូបឲ្យភ្ញាក់ខ្លួនក្រោកឡើងប្រយុទ្ធតទៅមុខទៀតដើម្បី «ជាតិរស់» ។

## វត្តមាននៅក្នុងឆាកអន្តរជាតិៈ

ការបូជាជីវិតរបស់យុទ្ធជនខ្មែរក្រោម នៅក្នុង ព្រឹត្តិការណ៍ ១៦ វិច្ឆិកា នោះ វាជាការផុសឡើងនៃគំនិត និងស្មារតី សឺង គុយ យ៉ាងពិតប្រាកដ ដែលគេចាត់ទុកថា មាន សឺង គុយ រាប់ពាន់ រាប់ម៉ឺននាក់បានកើតឡើង ។ ការឈឺចាប់គ្មានព្រំដែន ព្រោះទឹកដីនៅក្រោមការជិះជាន់របស់អាណានិគមយួន ភាពឯកោ និងតែលតោលបាត់ភាពម្ចាស់ការនៅលើដែនដីរបស់ខ្លួន ដោយគ្មានបរទេសណាដឹងឮ សូម្បីតែខ្មែរជាតិសាសន៍តែមួយដែលមានព្រំដែនជាប់គ្នាជិតបង្កើយនោះ បានជំរុញឲ្យខ្មែរក្រោមសម្រេចថា «ធ្វើការតស៊ូដើម្បីសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ក្នុងនាមជាជនជាតិដើមមួយ នៃដែនដីកម្ពុជាក្រោម ។ ការសម្រេចចិត្តនេះ បានជំរុញឲ្យខ្មែរក្រោមទូទាំងពិភពលោកឯកភាពគ្នាបង្កើតជាទង់ជាតិរបស់ខ្លួនមួយដាច់ដោយឡែក ហើយត្រូវបានទទួលស្គាល់ដោយ អង្គការប្រជាជាតិ និងប្រជាជនគ្មានតំណាង បន្ទាប់ពី សហព័ន្ធខ្មែរកម្ពុជាក្រោម (KKF) បានចូលជាសមាជិកនៃអង្គការមួយនេះ នៅថ្ងៃ ១៥ ខែកក្កដា ឆ្នាំ ២០០១ ។ បន្ទាប់ពីបានចូលជាសមាជិក UNPO មក ខ្មែរក្រោមក៏បានបង្ហាញវត្តមានរបស់ខ្លួននៅក្នុង អ.ស.ប. នៅឆ្នាំ ២០០៤ ជាលើកដំបូង ។ ចាប់តាំងពីពេលនោះមក ជារៀងរាល់ឆ្នាំនៅក្នុងខែឧសភា សហព័ន្ធខ្មែរកម្ពុជាក្រោម តែងតែដឹកនាំប្រតិភូរបស់ខ្លួនចូលថ្លែងការណ៍នៅក្នុងវេទិកាអចិន្ត្រៃយ៍ នៃ អ.ស.ប. ស្តីអំពីបញ្ហាជនជាតិដើម (UNPFII) នៅការិយាល័យកណ្តាល នៃអង្គការសហប្រជាជាតិ នាបុរី New York សហរដ្ឋអាមេរិក ដើម្បីលាតត្រដាងការពិតនៅកម្ពុជាក្រោមឲ្យសហគមន៍អន្តរជាតិបានជ្រាប ។ រនាំងដែកដែលរបបអាណានិគមយួន ធ្លាប់តែបានបិទបាំងមិនឲ្យពិភពលោកខាងក្រៅមើលឃើញនិងដឹងឮថា «មានខ្មែរក្រោមនៅកម្ពុជាក្រោម» នោះ ត្រូវបានទម្លុះ ហើយបញ្ហារបស់ខ្មែរក្រោម ក៏ត្រូវបានសហគមន៍អន្តរជាតិចាប់អារម្មណ៍ និងដឹងឮជាសាធារណៈ ។

ក្រោយពី សហព័ន្ធខ្មែរកម្ពុជាក្រោម និងក្រុមជនជាតិដើមនានា ទូទាំងពិភពលោក ចូលថ្លែងការណ៍នៅក្នុង អ.ស.ប. ជារៀងរាល់ឆ្នាំមក នៅថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០០៧ អ.ស.ប. បានអនុម័តលើ «សេចក្តីប្រកាសស្តីពីសិទ្ធិជនជាតិដើម» (UNDRIP) ហើយ

របបអាណានិគមយួនក៏បានចុះហត្ថលេខាទទួលស្គាល់ផងដែរ ។ ក្នុងសេចក្តីប្រកាសនេះ មាត្រាទី ៣ បានចែងថា៖ “*ជនជាតិដើមគ្រប់រូបមានសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង*” និង មាត្រាទី ៤ បានចែងថា៖ “*ជនជាតិដើម ក្នុងការអនុវត្តនូវសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯងរបស់ពួកគេ [ពួកគេ] មានសិទ្ធិស្វយ័ត ឬស្វ័យគ្រប់គ្រងដោយខ្លួនឯង លើបញ្ហាទាំងឡាយដែលទាក់ទងនឹងកិច្ចការផ្ទៃក្នុង និងកិច្ចការនៅមូលដ្ឋានរបស់ពួកគេ ព្រមទាំងវិធីសាស្ត្រ និងមធ្យោបាយផ្សេងៗ សម្រាប់ផ្តល់ហិរញ្ញវត្ថុដល់ដំណើរការស្វយ័តរបស់ពួកគេ*”។

យោងតាមសេចក្តីប្រកាសនេះ ខ្មែរក្រោមជាជនជាតិដើម នៃដែនដីកម្ពុជាក្រោម មានសិទ្ធិពេញលេញក្នុងការបង្កើតជារដ្ឋាភិបាលមួយរបស់ខ្លួននៅកម្ពុជាក្រោម ដើម្បីគ្រប់គ្រងសង្គមជាតិដោយខ្លួនឯង ដោយរបបអាណានិគមយួនគ្មានសិទ្ធិលូកដៃចូលជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់ខ្មែរក្រោមឡើយ ៕

អត្ថបទនេះ បានចេញផ្សាយគេហទំព័រ វិទ្យុសំឡេងកម្ពុជាក្រោម (VOKK) សារព័ត៌មាន ព្រៃនគរ ឆ្នាំ ២០១៣ ។

# សេរីភាព និង សុភមង្គលគ្មានទេ បើគ្មានសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង

សាធារណរដ្ឋសង្គមនិយមវៀតណាម មានបាវចនាជាតិថា ឯករាជ្យ សេរីភាព និង សុភមង្គល ។ បាវចនាជាតិនេះ ត្រូវបានបក្សកុម្មុយនីស្តយួនយកទៅអនុវត្តបោកប្រាស់ខ្មែរក្រោមជាយូរមកហើយ ។ កាល ហូ ជី មិញ នៅរស់ គាត់តែងតែនិយាយជាញឹកញាប់ថា *"គ្មានអ្វីប្រសើរជាង ឯករាជ្យ និងសេរីភាពឡើយ"* ។ តាមការអំពាវនាវរបស់ ហូ ជី មិញ ថា ពេលណាគេធ្វើសង្គ្រាមបានឈ្នះបារាំង និងអាមេរិក ពលរដ្ឋគ្រប់រូបនឹងមានឯករាជ្យ សេរីភាព និងសុភមង្គល បានធ្វើឲ្យពលរដ្ឋខ្មែរក្រោមជាច្រើនបានចូលរួមធ្វើបដិវត្តជាមួយនឹងយួនក្រហម ដែលមាន ហូ ជី មិញ ជាមេដឹកនាំ ដើម្បីប្រឆាំងនឹងអាណានិគមនិយមបារាំង និងអាមេរិក ។ ជាលទ្ធផល ក្រោយថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៧៥ ពេលពួកយួនកុម្មុយនីស្តបានឈ្នះនោះ ឯករាជ្យ សេរីភាព និងសុភមង្គល ជាកម្មសិទ្ធិផ្តាច់មុខរបស់ជនជាតិយួន ហើយវាសនាដែនដីកម្ពុជាក្រោមត្រូវផ្លាស់ការគ្រប់គ្រងពីរបបយួនសេរីមកជារបបយួនកុម្មុយនីស្តយួនក្រហមវិញ ។

នៅពេលដែលរបបយួនក្រហមខាងជើង បានឈ្នះរបបសាធារណរដ្ឋវៀតណាមខាងត្បូង នៅថ្ងៃ ៣០ ខែមេសា ឆ្នាំ ១៩៧៥ ភ្លាម ពួកគេបានលើកទង់របស់ខ្លួនឡើងព្រោងព្រាតពេញទឹកដីកម្ពុជាក្រោម ដើម្បីអបអរសាទរទិវាជោគជ័យរបស់ខ្លួន ។ មិនយូរប៉ុន្មាន ទីក្រុងព្រៃនគរដែលជនជាតិយួនធ្លាប់បានហៅថាសាយហ្គននោះ បានប្តូរទៅជាទីក្រុង ហូ ជី មិញ វិញ ។

ស្ថិតក្នុងស្ថានភាពដ៏ខ្មៅងងឹតបែបនេះ ពលរដ្ឋខ្មែរក្រោមដែលធ្លាប់ចូលរួមធ្វើបដិវត្តជាមួយយួនកុម្មុយនីស្តនោះ ត្រូវខកបំណងយ៉ាងខ្លាំង ព្រោះត្រូវចាញ់បោកក្រុមយួនកុម្មុយនីស្ត ហើយវាសនារបស់ខ្លួនត្រូវធ្លាក់មកបិតនៅក្រោមនឹមអាណានិគមយួនកុម្មុយនីស្តមួយតម្រួតទៀត ។

ក្រោយពេលយួនកុម្មុយនីស្ត ចូលកាន់កាប់ដែនដីកម្ពុជាក្រោមនោះ គេមិនត្រឹមតែមិននឹកគុណដល់ពលិកម្មរបស់ខ្មែរក្រោមដែលបានពលីជីវិត នៅក្នុងសមរភូមិប៉ុណ្ណោះ

ទេ គឺថែមទាំងបានចាប់ព្រះសង្ឃ និងពលរដ្ឋខ្មែរក្រោមដាក់ពន្ធនាគារ និងយកទៅសម្លាប់ទៀតផង ដូចជាករណីកាសេហាសិប (KC-50) យួនបានចាប់ ព្រះតេជព្រះគុណ គឹម តុក ចើង និងបញ្ញវន្តខ្មែរក្រោមទៅដាក់គុក និងធ្វើឃាតជាដើម ។

សព្វថ្ងៃ ខ្មែរក្រោមកំពុងតែរស់នៅក្រោមរបបផ្តាច់ការយួន និងរបបកុម្មុយនីស្តកណ្តៀរញញួរ ។ របបទាំងពីរនេះ តែងតែសង្កត់សង្កិន ជិះជាន់ខ្មែរក្រោមមិនឲ្យងើបមុខទទួលបាននូវពន្លឺសេរីភាព និងសិទ្ធិមនុស្សឡើយ ។ ព្រះសង្ឃជាច្រើនអង្គត្រូវរដ្ឋាភិបាលយួនចាប់ផ្សឹក និងដាក់គុក ដោយគ្រាន់តែធ្វើបាតុកម្មស្នើឲ្យមានការគោរពសិទ្ធិខ្មែរក្រោម តែប៉ុណ្ណោះ ។ ពលរដ្ឋខ្មែរក្រោមជាច្រើនរូប ដែលប្រើប្រាស់បណ្តាញសង្គម Facebook និង ទាក់ទងអ្នកនៅក្រៅប្រទេស ក៏ត្រូវហៅទៅសួរចម្លើយ ដូចជាមនុស្សមានទោស ។ ចំណែកខ្មែរក្រោមដែលនៅក្រៅប្រទេសទៅលេងស្រុកកំណើត ក៏ត្រូវតាមដាន និងធ្វើទុក្ខបុកម្នេញឥតស្រាកស្រាន្ត ។ កសិករដែលតវ៉ាទាមទារដីកេរដូនតាដែលត្រូវគេរឹបយក ក៏ត្រូវប៉ូលិសយួនវាយសំពងបែកក្បាល និងដាក់ខ្នោះដៃជើង ហើយច្រកចូលគុកធ្វើទារុណកម្មយ៉ាងអយុត្តិធម៌ ។ល។

ដូច្នេះ ឯករាជ្យ សេរីភាព និងសុភមង្គល សព្វថ្ងៃ ជារបស់ជនជាតិយួនទេ មិនមែនជារបស់ខ្មែរក្រោមឡើយ ។ របបអាណានិគមយួនបានយកពាក្យនេះមកប្រើគ្រាន់តែជាការឡូប់ឡែ ដើម្បីត្រួតត្រាខ្មែរក្រោមជាជនជាតិដើមនៃដែនដីកម្ពុជាក្រោម និងជនជាតិភាគតិចផ្សេងៗទៀត នៅក្នុងប្រទេសវៀតណាម តែប៉ុណ្ណោះ ។ ដរាបណាពលរដ្ឋខ្មែរក្រោមមិនមានសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង ឬមិនមានភាពម្ចាស់ការលើខ្លួនឯងទេ ខ្មែរក្រោមនឹងមិនមានសេរីភាព និង សុភមង្គលឡើយ ៕

អត្ថបទនេះ បានចុះផ្សាយនៅលើទំព័រ កាសែត ព្រៃនគរ លេខ ២៩ ឆ្នាំ ២០១២ ចេញផ្សាយ ថ្ងៃទី ០១ ខែមករា ឆ្នាំ ២០១២ ។

## ការចាប់ លោក ចៅ ហេន ដាក់គុក ជាចន្លុះដុតបេះដូងខ្មែរក្រោម

នៅថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០១១ តុលាការបក្សកុម្មុយនីស្តយួន បានប្រកាសសាលក្រមផ្តន្ទាទោស លោក ចៅ ហេន ឲ្យជាប់គុក ២ ឆ្នាំ ពីបទអ្វីមួយដែលរបបនេះចោទថា លោក ចៅ ហេន «បានបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ និងបង្កឲ្យមានភាពចលាចលនៅទីសាធារណៈ» បន្ទាប់ពីនគរបាលយួនបានចាប់ខ្លួនគាត់ដាក់គុកអស់រយៈពេលជាង ៣ ខែកន្លងមក ។ របបអាណានិគមយួនតែងតែឃោសនាថា ខ្លួនជានិច្ចកាលតែងយកចិត្តទុកដាក់ដល់ជីវភាពរបស់ជនជាតិភាគតិចទាំង ៥៣ នៅក្នុងប្រទេស ក្នុងនោះ មានជនជាតិដើមខ្មែរក្រោម ផងដែរ ។ ប៉ុន្តែអ្វីៗវាផ្ទុយពីនេះ គ្រាន់តែ លោក ចៅ ហេន ចេញមុខទាមទារដីស្រែកេរដូនតា ដែលត្រូវរបបយួនកុម្មុយនីស្តរឹបយកនោះ ក៏ត្រូវអាជ្ញាធរចាប់ដាក់គុកទៅហើយ ។ នេះជាសកម្មភាពមួយ មិនត្រឹមតែរបបយួនមិនបានធ្វើតាមគោលនយោបាយ ដែលខ្លួនបានឃោសនានោះទេ តែថែមទាំងបានជិះជាន់ និងធ្វើទុក្ខបុកម្នេញលើជនជាតិដើមម្ចាស់ស្រុកទាំងភ្នែកស្រស់ ទៀតផង ។

លោក ចៅ ហេន កើតឆ្នាំ ១៩៥៤ នៅស្រុកស្វាយទង ខេត្តមាត់ជ្រូក ជាអ្នកដឹកនាំកសិករខ្មែរក្រោមនៅខេត្តមាត់ជ្រូកជាច្រើនគ្រួសារ ប្តឹងទៅអាជ្ញាធរយួនដើម្បីទាមទារយកដីស្រែកេរដូនតាមកវិញ បន្ទាប់ពីរបបកុម្មុយនីស្តយួនបានរឹបយកទៅចែកឲ្យជនជាតិយួនគ្នាគេ កាលពីឆ្នាំ ១៩៧៨ ។ ការរឹបយកនោះ របបយួនបានធ្វើនៅពេលដែលពលរដ្ឋខ្មែរក្រោមនៅខេត្តមាត់ជ្រូក ត្រូវជម្លៀសឲ្យទៅនៅខេត្តឃ្លាំង និងខេត្តផ្សេងៗទៀត ក្នុងគោលបំណងអ្វីមួយដែលរដ្ឋាភិបាលយួន កាលណោះ បានអះអាងថា គេចចេញពីការចូលលុកលុយឈ្លានពានរបស់កងទ័ពខ្មែរក្រហម នៅតាមបណ្តោយព្រំដែនខ្មែរ-យួន ។ ពេលពលរដ្ឋខ្មែរក្រោមត្រឡប់មកស្រុកកំណើតវិញ ស្រាប់តែដីកេរដូនតា និងផ្ទះសម្បែងរបស់ខ្លួន ត្រូវយួនរឹបយកទៅកាន់កាប់អស់គ្មានសល់ ។ របបយួនកាន់ជើងជនជាតិយួនរបស់ខ្លួន ដោយមិនបានដោះស្រាយ និងស្វែងរកយុត្តិធម៌ជូនពលរដ្ឋខ្មែរក្រោមម្ចាស់ដីឡើយ ។ ករណីនេះ អ្នកស្រុកបានធ្វើបាតុកម្មអូសបន្លាយជាច្រើនឆ្នាំ តែមិនមានលទ្ធផលអ្វីឡើយ ។ លទ្ធផលនៃការតវ៉ានេះ ត្រូវទទួលបញ្ច្រាស

មកវិញ គឺអ្នកដែលទាមទារត្រូវបានអាជ្ញាធរយួនតាមដាន ធ្វើទុក្ខបុកម្នេញ វាយដំច្រំធាក់ និងចាប់ដាក់គុក ជាដើម ។ ជនរងគ្រោះទាំងនោះ រួមមាន អ្នកស្រី នាង យ៉ុន និង នាង យ៉ន ត្រូវបានតុលាការយួនកាត់ទោសកាលពីឆ្នាំ ២០០៨ ឲ្យជាប់គុក ២ ឆ្នាំ កញ្ញា នាង សាវង្ស កូនស្រីរបស់ លោក ថៅ អិន ត្រូវនគរបាលយួនធ្វើទារុណកម្មរហូតដល់ស្លាប់ នៅថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០១០ ។ គ្រួសារ លោក ថៅ អុក និង លោក ថៅ ហេន បានភៀសខ្លួនទៅប្រទេសកម្ពុជា និងបន្តប្រទេសថៃ ដើម្បីសុំសិទ្ធិជ្រកកោននៅការិយាល័យអគ្គស្នងការនៃ អ.ស.ប. ទទួលបន្ទុកជនភៀសខ្លួន (UNHCR) ។

យោងតាមដីកាចាប់ខ្លួន លោក ថៅ ហេន ចេញថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១០ ដោយការិយាល័យនគរបាលយួនស្រុកស្វាយទង បានចោទប្រកាន់ លោក ថៅ ហេន ថា បាន «បំផ្លិចបំផ្លាញទ្រព្យសម្បត្តិ និងបង្កភាពចលាចលក្នុងទីសាធារណៈ» (Hủy họai tài sản – Gây rối trật tự công cộng ) តាមមាត្រាទី ១៤៣ និង ២៤៥ នៃច្បាប់ព្រហ្មទណ្ឌរបស់ប្រទេសសាធារណរដ្ឋសង្គមនិយមវៀតណាម ។ ការចាប់ខ្លួន លោក ថៅ ហេន បន្ទាប់ពីលោក និងអ្នកស្រី នាង ភឿន ជាភរិយា បានធ្វើមាតុភូមិនិវត្តន៍ពីប្រទេសថៃទៅផ្ទះរបស់ខ្លួនវិញ នៅថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១០ ដោយសារ UNHCR បដិសេធឋានៈជាជនភៀសខ្លួន ហើយមន្ត្រី UNHCR បានបញ្ជាក់ប្រាប់ថា គ្រួសារគាត់អាចធ្វើដំណើរត្រឡប់ទៅស្រុកកំណើតវិញ ដោយអាជ្ញាធរយួនមិនធ្វើទុក្ខបុកម្នេញអ្វីឡើយ ។

ករណីនេះ បានបញ្ជាក់ឲ្យឃើញថា វៀតណាមនៅតែរើសអើងពូជសាសន៍ និងរំលោភសិទ្ធិមនុស្សលើខ្មែរក្រោមដដែល ខណៈដែលខ្លួនជាប្រទេសហត្ថលេខីគាំទ្រចំពោះ សេចក្ដីប្រកាសស្ដីពីសិទ្ធិជនជាតិដើមរបស់ អ.ស.ប. (UNDRIP) ដែលបានអនុម័តកាលពីថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០០៧ ។

ទង្វើរំលោភសិទ្ធិមនុស្ស និងការជិះជាន់បែបអាណានិគមមកលើខ្មែរក្រោមម្ចាស់ដីនេះ មិនមែនជាមធ្យោបាយមួយសម្រាប់ការអភិវឌ្ឍប្រទេសរបស់ខ្លួនឡើយ ។ របបយួនកុម្មុយនីស្ដធ្វើបែបនេះ វាដូចជាខ្លួនឯងបានបង្កើតជាចន្លុះភ្លើងមួយសម្រាប់ដុតបេះដូងរបស់ពលរដ្ឋខ្មែរក្រោម ដែលកំពុងតែនៅក្ដៅរងំដោយកំហឹងប្រវត្តិសាស្ត្រ

«កុំរើប្រយ័ត្នកំពុបតែអុង» ឲ្យឆាបឆេះឡើងជាថ្មីម្តងទៀតនោះឡើយ ។

សម្រាប់ UNHCR ប្រចាំប្រទេសថៃវិញ ជាអង្គការមនុស្សធម៌ពិភពលោក តែមិនបានបំពេញកាតព្វកិច្ចឲ្យបានត្រឹមត្រូវតាមតួនាទីរបស់ខ្លួនទេ ។ ក្នុងនាមជា អ.ស.ប. តែខ្លួនមិនបានឈ្វេងយល់ឲ្យបានច្បាស់អំពីពុតរបស់របបយួនកុម្មុយនីស្តឡើយ ហើយហ៊ានបញ្ជាឲ្យ លោក ថៅ ហេន ត្រឡប់ទៅស្រុកចូលគុកយ៉ាងនេះ ? ។

ចំពោះពលរដ្ឋខ្មែរក្រោមនៅក្រៅប្រទេសវិញ គួរតែនាំគ្នាធ្វើអ្វីមួយសម្រាប់ជួយដល់ លោក ថៅ ហេន និងជនរងគ្រោះឯទៀតដែលកំពុងតែជាប់គុកនៅកម្ពុជាក្រោម ដោយនាំគ្នាធ្វើញត្តិប្តឹងទៅគ្រប់អង្គការជាតិ និងអន្តរជាតិ ព្រមទាំងធ្វើបាតុកម្មនៅមុខស្ថានទូតយួននៅតាមប្រទេសដែលខ្លួនកំពុងរស់នៅ ដើម្បីជំរុញឲ្យអាជ្ញាធរយួនដោះលែង លោក ថៅ ហេន ជាបន្ទាន់ ៕

អត្ថបទនេះ បានចុះផ្សាយនៅលើគេហទំព័រ វិទ្យុសំឡេងកម្ពុជាក្រោម (VOKK)
និង សារព័ត៌មាន ព្រៃនគរ នៅថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០១១

# វៀតណាមមិនអាចបិទបាំងនូវអំពើ
# រើសអើងពូជសាសន៍មកលើខ្មែរក្រោមបានទៀតទេ

មួយរយៈពេលចុងក្រោយនេះ របបយួនកុម្មុយនីស្តបានបង្ក្រាបទៅលើព្រះសង្ឃ និងពលរដ្ឋខ្មែរក្រោមជាបន្តបន្ទាប់ ដើម្បីឆ្លើយតបនឹងការដែលព្រះសង្ឃ និងពលរដ្ឋខ្មែរក្រោមទាំងនោះ គ្រាន់តែបានទាក់ទងខ្មែរក្រោមនៅក្រៅប្រទេស និងមានបំណងចង់បើកសាលារៀនអក្សរសាស្ត្រខ្មែរនៅក្នុងវត្ត ។

ទង្វើដែលរបបយួនកុម្មុយនីស្តនៅតែប្រកាន់ពូជសាសន៍លើខ្មែរក្រោមម្ចាស់ស្រុកនៅដែនដីកម្ពុជាក្រោមនោះ មានដូចជា ការចាប់ផ្សឹក និងធ្វើទារុណកម្ម ភិក្ខុ លី ចិន្ដា ជាព្រះសង្ឃគង់នៅវត្តព្រៃជាប់ នៅថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៣ ដោយគ្រាន់តែព្រះសង្ឃអង្គនេះចង់បង្កើតជាសាលារៀនអក្សរខ្មែរនៅក្នុងវត្ត ការយកកម្លាំងអាជ្ញាធរមកឡោមព័ទ្ធវត្តសិរីតាសេក ដើម្បីចាប់ ព្រះតេជព្រះគុណ លីវ នី និង ថាច់ ធឿន ផ្សឹក នៅពីថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០១៣ និងដាក់គុកដោយគ្រាន់តែព្រះសង្ឃទាំងនេះ មានទំនាក់ទំនងនឹងខ្មែរក្រោមនៅក្រៅប្រទេសជាដើម ។

ទង្វើរើសអើងពូជសាសន៍នៃរបបយួន បានធ្វើឲ្យពលរដ្ឋខ្មែរក្រោមទាំងនៅក្នុង និងក្រៅស្រុក ព្រមទាំងមជ្ឈដ្ឋាននានា មានអង្គការសិទ្ធិមនុស្ស, អ.ស.ប. និងរដ្ឋាភិបាលនៃប្រទេសមហាអំណាច បានដឹងកាន់តែច្បាស់តាមរយៈការធ្វើបាតុកម្ម និងការធ្វើសេចក្ដីរាយការណ៍ស្ដីអំពីបញ្ហាទាំងនេះ ដោយ សហព័ន្ធខ្មែរកម្ពុជាក្រោម ។

នៅថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ២០១៣ ព្រះតេជព្រះគុណ យ៉ាញ តូន ជាព្រះសង្ឃខ្មែរក្រោម ដែលធ្លាប់ត្រូវរបបយួនចាប់ដាក់គុកនៅឆ្នាំ ២០០៧ នោះ បានឡើងធ្វើជាសាក្សីឆ្លើយបំភ្លឺនៅក្នុងសវនាការសភាសហរដ្ឋអាមេរិកថា វៀតណាមនៅតែបន្តរើសអើង និងប្រកាន់ពូជសាសន៍មកលើខ្មែរក្រោម ដោយព្រះតេជព្រះគុណ យ៉ាញ តូន បានបញ្ជាក់ថា ព្រះសង្ឃខ្មែរក្រោមគ្រាន់តែបញ្ចេញមតិបន្តិចបន្តួច ក៏ត្រូវរបបយួនចាប់ផ្សឹក និងដាក់គុក ប៉ុន្តែសម្រាប់ព្រះសង្ឃជនជាតិយួនវិញ របបនេះមិនដែលបានចាប់ផ្សឹក និងដាក់គុកឡើយ ពេលដែលព្រះសង្ឃយួនទាំងនោះ ធ្វើការតវ៉ាចំពោះរដ្ឋាភិបាល

វៀតណាម ។

នៅថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ២០១៣ ដដែល សហព័ន្ធខ្មែរកម្ពុជាក្រោម បានចេញសេចក្តីថ្លែងការណ៍មួយជូនទៅគ្រប់ស្ថាប័នអង្គការសិទ្ធិមនុស្សអន្តរជាតិ និងស្ថានទូតនៃប្រទេសនានានៅក្នុងប្រទេសវៀតណាម ដើម្បីជម្រាបពីបញ្ហាដែលរបបយួនបានរំលោភបំពានលើព្រះសង្ឃ និងពលរដ្ឋខ្មែរក្រោម ។

សម្រាប់របបយួន នៅក្នុងសេចក្តីថ្លែងការណ៍នេះ សហព័ន្ធខ្មែរកម្ពុជាក្រោម បានរំឭកឡើងវិញនូវមាត្រាដែលរបបយួន បានរំលោភបំពានលើសេចក្តីប្រកាសជាសកលរបស់ អ.ស.ប. ស្តីពីសិទ្ធិមនុស្ស និងបានសំណូមពរដល់សហរដ្ឋអាមេរិក ឲ្យដាក់វៀតណាមចូលក្នុងបញ្ជីនៃប្រទេស ដែលរំលោភសិទ្ធិសេរីភាពសាសនាធ្ងន់ជាងគេក្នុងពិភពលោក ឬប្រទេសដែលមានក្តីកង្វល់ពិសេស (Country of Particular Concern) ដែលហៅកាត់ថា CPC ៕

អត្ថបទនេះ បានចុះផ្សាយនៅលើគេហទំព័រ វិទ្យុសំឡេងកម្ពុជាក្រោម (VOKK)
និង សារព័ត៌មាន ព្រៃនគរ នៅឆ្នាំ ២០១៣

# វៀតណាម
# សិទ្ធិជនជាតិដើមបែបជើងជាប់ខ្នោះ

នៅថ្ងៃទី ១៣ ខែកញ្ញា ជារៀងរាល់ឆ្នាំ សហព័ន្ធខ្មែរកម្ពុជាក្រោម ដែលមានមូលដ្ឋាននៅក្រៅស្រុក តែងតែប្រារព្ធពិធីអបអរសាទរដល់ថ្ងៃដែល អ.ស.ប. អនុម័តនូវសេចក្តីប្រកាសស្តីពីសិទ្ធិជនជាតិដើម នៅថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០០៧ ។ សេចក្តីប្រកាសនេះ បានទទួលស្គាល់នូវសិទ្ធិ និងសេរីភាពជាមូលដ្ឋានរបស់ជនជាតិដើមទាំងអស់ នៅគ្រប់ទីកន្លែងក្នុងពិភពលោក ដោយមិនមានការរើសអើងអ្វីទាំងអស់ ។ នៅក្នុងសេចក្តីប្រកាសនេះ ក៏មានចែងអំពី «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» របស់ជនជាតិដើម ផងដែរ ។ ចាប់តាំងពីបានអនុម័តមក សេចក្តីប្រកាសនេះ ត្រូវបានគេចាត់ទុកថាជា «ស្តង់ដាររួមមួយនៃសមិទ្ធផលរបស់ជនជាតិដើមគ្រប់ប្រជាជាតិទាំងអស់» នៅក្នុងពិភពលោក ដែលក្នុងនោះ ក៏មានខ្មែរក្រោមជាជនជាតិដើមនៅកម្ពុជាក្រោមផងដែរ ។

មកដល់ថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០១២ មានរយៈពេល ៥ ឆ្នាំហើយ ដែលរបបយួនជាប្រទេសហត្ថលេខីមួយក្នុងចំណោមប្រទេសទាំង ១៤៣ ដែលបានគ្រាំទ្រលើសេចក្តីអនុម័តនេះ តែយើងកត់សម្គាល់ឃើញថា មិនមានការរីកចម្រើនជាវិជ្ជមានណាមួយក្នុងការគោរព និងលើកស្ទួយដល់សិទ្ធិជនជាតិដើមខ្មែរក្រោមឡើយ ។ របបយួននៅតែរើសអើងពូជសាសន៍លើខ្មែរក្រោមម្ចាស់ស្រុកដដែល ដោយចាប់ខ្មែរក្រោមដាក់គុក រឹបអូសយកដីធ្លី ហាមមើលទូរទស្សន៍ខ្មែរផ្សាយចូលពីប្រទេសកម្ពុជា មិនអនុញ្ញាតឲ្យខ្មែរក្រោមសម្តែងមតិអំពីបញ្ហាខ្មែរក្រោមនៅទីសាធារណៈ ដូចជា ប្រារព្ធពិធីអបអរសាទរទិវាសិទ្ធិជនជាតិដើមនៅដែនដីកម្ពុជាក្រោម ជាដើម ។

នៅក្នុងខែកក្កដា ឆ្នាំ ២០១២ សមាគមព្រះពុទ្ធសាសនាវៀតណាម (Giáo Hội Phật Giáo Việt Nam) ដែលជាសមាគមសាសនាមួយបង្កើតដោយរបបយួនកុម្មុយនីស្តបានចេញលិខិតមួយច្បាប់បញ្ជាឲ្យចាប់ផ្សឹក ភិក្ខុ ថាច់ ធឿន ជាព្រះសង្ឃខ្មែរក្រោមគង់នៅវត្តសិរីតាសេក ដោយចោទព្រះសង្ឃអង្គនេះថា បានរំលោភបំពានលើធម្មនុញ្ញ

របស់សមាគមព្រះពុទ្ធសាសនាវៀតណាម ព្រោះមានទំនាក់ទំនងជាមួយនឹងព្រះសង្ឃ និងពលរដ្ឋខ្មែរក្រោមនៅក្រៅប្រទេស ។ សួរថា ចុះបើព្រះសង្ឃយួនទាក់ទងជនជាតិយួននៅក្រៅប្រទេសដែរនោះ របបយួនដែលចាប់ផ្សឹកដែរឬទេ?

ចំណែក លោក ថៅ ហេន នៅខេត្តមាត់ជ្រូក ត្រូវរបបយួនធ្វើទារុណកម្មនៅក្នុងគុករហូតដល់ធ្លាក់ខ្លួនឈឺ និយាយលែងចេញ និងបានដាក់ខ្នោះជើងគាត់យកទៅព្យាបាលជំងឺនៅមន្ទីរពេទ្យទាំងអយុត្តិធម៌ ។ លោក ថៅ ហេន គ្រាន់តែជាអ្នកទាមទារឲ្យរបបយួនសងដីកេរដូនតារបស់គាត់មកវិញតែប៉ុណ្ណោះ ។ រហូតមកទល់ពេលនេះ ការជាប់គុករបស់ លោក ថៅ ហេន ជិតផុតកំណត់ហើយ តែក្រុមគ្រួសារនៅមិនទាន់ទទួលបានដំណឹងអ្វីពីគាត់នៅឡើយ ។

ដើម្បីឆ្លើយតបទៅនឹងការប្ដេជ្ញាចិត្តរបស់របបយួន ដែលបានចុះហត្ថលេខាគាំទ្រចំពោះសេចក្ដីអនុម័តនេះ របបយួនត្រូវតែអនុវត្តទៅតាមសេចក្ដីប្រកាសស្ដីពីសិទ្ធិជនជាតិដើម ឲ្យមានប្រសិទ្ធភាពបំផុត ដើម្បីលើកស្ទួយជីវភាពពលរដ្ឋខ្មែរក្រោមជាម្ចាស់ស្រុកនៃដែនដីកម្ពុជាក្រោម និងជនជាតិភាគតិចទាំង ៥២ ដទៃទៀត នៅក្នុងប្រទេសវៀតណាមឲ្យមានការរីកចម្រើន ជាជាងខ្លួនប្រើអំណាចទៅគំរាមកំហែង និងរំលោភសិទ្ធិពួកគេ ព្រោះការគោរពសិទ្ធិជនជាតិដើម គឺជាការអភិវឌ្ឍប្រទេសវៀតណាមឲ្យមានការរីកចម្រើនគ្រប់វិស័យ ។

ជាអនុសាសន៍ យើងសូមឲ្យរបបអាណានិគមយួន ត្រូវតែអនុវត្តតាមសេចក្ដីប្រកាសស្ដីពីសិទ្ធិជនជាតិដើម (UNPFII) ឲ្យមានប្រសិទ្ធភាពបំផុត ហើយអំពាវនាវឲ្យមានការគោរពសិទ្ធិខ្មែរក្រោមដូចខាងក្រោមនេះ៖

♦ត្រូវដោះលែង លោក ថៅ ហេន នៅខេត្តមាត់ជ្រូក និងអ្នកស្រី ត្រឹង ធី ចូវ នៅខេត្តព្រះត្រពាំង ជាអ្នកតវ៉ាដីធ្លីដែលអាជ្ញាធរបានចាប់ដាក់គុកជិតពីរឆ្នាំមកហើយ ។

♦ត្រូវលុបចោលនូវការចោទប្រកាន់ទៅលើ ព្រះតេជព្រះគុណ ថាច់ ធឿន ព្រោះទង្វើ និងសកម្មភាពរបស់ព្រះអង្គ តាមអ្វីដែលរបបអាណានិគមយួន ចោទថា «ទាក់ទងខ្មែរក្រោមនៅក្រៅប្រទេស» នោះ មិនបានខុស ឬបំពានលើវិន័យព្រះពុទ្ធសាសនា

ឡើយ ។

♦ ត្រូវផ្សព្វផ្សាយនូវសេចក្ដីប្រកាសស្ដីពីសិទ្ធិជនជាតិដើម ដល់ពលរដ្ឋខ្មែរក្រោម បានជ្រួតជ្រាប ដើម្បីពួកគាត់បានដឹងអំពីសិទ្ធិរបស់ខ្លួន ។

♦ អនុញ្ញាតឲ្យពលរដ្ឋខ្មែរក្រោម ប្រារព្ធពិធីអបអរសាទរទិវាសិទ្ធិជនជាតិដើម ជាសាធារណៈ និងបញ្ចេញមតិដោយសេរី ។

♦ លុបបំបាត់ចោលការរើសអើងពូជសាសន៍ចំពោះខ្មែរក្រោម ដោយបង្កលក្ខណៈឲ្យពួកគេមានសិទ្ធិស្មើនឹងជនជាតិយួនដែលជាអាណានិគមជន ។

♦ បញ្ឈប់ជាបន្ទាន់ រាល់ការសួរចម្លើយ និងគំរាមកំហែងព្រះសង្ឃ និងពលរដ្ឋខ្មែរក្រោម ដែលធ្វើសកម្មភាពលើកស្ទួយវប្បធម៌ខ្មែរនៅកម្ពុជាក្រោម ។ល។

ចុងក្រោយ យើងចាត់ទុកថា ការដែលរបបអាណានិគមយួនត្បិតត្បៀត និងមានគំនិតចង្អៀតចង្អល់ ចំពោះការគោរពសិទ្ធិជាមូលដ្ឋានរបស់ខ្មែរក្រោមនោះ វាជាការធ្វើឲ្យប្រទេសវៀតណាមខ្លួនឯងក្លាយជាប្រទេសមួយមានដំណើរថយក្រោយគ្រប់វិស័យ និងវៀតណាមត្រូវបានសហគមន៍អន្តរជាតិកត់សម្គាល់ថា មិនគោរពនូវអ្វីដែលខ្លួនបានចុះសន្ធិសញ្ញាផ្សេងៗជាមួយនឹង អ.ស.ប. ។ សំខាន់ជាងនេះទៅទៀតនោះ គឺពលរដ្ឋខ្មែរក្រោមគ្រប់រូបនឹងបានយល់កាន់ច្បាស់ពីមួយថ្ងៃទៅមួយថ្ងៃ នូវអំពីពុតត្បុតដែលខ្លួនបានអនុវត្តចំពោះពួកគេ ពេលនោះ អ្វីៗដែលជាការឃោសនាលើបបូរមាត់របស់របបអាណានិគមយួន វាលែងមានប្រសិទ្ធភាពទៀតហើយ ៕

អត្ថបទនេះ បានចុះផ្សាយនៅលើគេហទំព័រ វិទ្យុសំឡេងកម្ពុជាក្រោម (VOKK)
និង សារព័ត៌មាន ព្រៃនគរ នៅឆ្នាំ ២០១៣

## របបកុម្មុយនីស្តយួននឹងត្រូវដួលរលំ ដោយសារចលនាជនជាតិដើម និង លទ្ធិប្រជាធិបតេយ្យ

ជនជាតិដើម ៤ ក្រុមធំៗ រួមមាន ខ្មែរក្រោម ចាម្ប៍ ម៉ុងតៃញ៉ា និង ម៉ុង នៅក្នុងប្រទេសវៀតណាម បានចាប់ផ្តើមក្រោកឡើងតស៊ូ ដើម្បីសិទ្ធិម្ចាស់ការរបស់ខ្លួនជាបន្តបន្ទាប់ ។ ចំណែកជនជាតិភាគតិចទាំង ៤៩ ផ្សេងទៀត និងជនជាតិយួន អ្នកដែលចង់បានលទ្ធិប្រជាធិបតេយ្យ ក៏បានក្រោកឡើងតស៊ូប្រឆាំងនឹងរបបយួនកុម្មុយនីស្ត ដើម្បីសិទ្ធិសេរីភាពរបស់ពួកគេគ្រប់ទិសទីផងដែរ ។ ការងើបឡើងតស៊ូរបស់ប្រជាជននៅក្នុងប្រទេសវៀតណាម រួមទាំងខ្មែរក្រោមនៅដែនដីកម្ពុជាក្រោម ផងនោះ ខណៈដែលប្រទេសវៀតណាមដឹកនាំដោយរបបកុម្មុយនីស្ត ចេះតែផ្តាច់ការទៅៗនិងមានការរើសអើងពូជសាសន៍ទៅលើក្រុមជនជាតិដើម និងជនជាតិភាគតិចយ៉ាងធ្ងន់ធ្ងរ ។

ជំនោរខ្យល់ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» និងលទ្ធិប្រជាធិបតេយ្យ បានបោកបក់មកលើប្រទេសវៀតណាម បានជំរុញឲ្យប្រជាជនងើបឡើងតស៊ូចំពោះរបបផ្តាច់ការកុម្មុយនីស្តយួនជាបន្តបន្ទាប់ នាពេលបច្ចុប្បន្ន ។ ការងើបឡើងតស៊ូទាំងនេះ អាចបញ្ជាក់ឲ្យឃើញ តាមរយៈសកម្មភាពផ្តាច់ការរបស់រដ្ឋការក្រុងហាណូយ សព្វថ្ងៃមានការចាប់ព្រះសង្ឃខ្មែរក្រោមផ្សឹកដាក់គុក និងការចាប់ខ្លួនក្រុមជនជាតិយួនដែលបញ្ចេញយោបល់ខ្វែងគំនិតដាក់គុកទាំងអយុត្តិធម៌ ជាដើម ។

**ចលនាទាមទារ សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង របស់ប្រជាជាតិខ្មែរក្រោម៖**

ប្រជាជាតិខ្មែរក្រោមនៅដែនកម្ពុជាក្រោម សព្វថ្ងៃ មានប្រមាណ ៧ លាននាក់ ទាំងព្រះសង្ឃ និងគ្រហស្ថ បានងើបឡើងតវ៉ាចំពោះការរំលោភសិទ្ធិមនុស្សពីសំណាក់របបអាណានិគមយួនជាបន្តបន្ទាប់ នៅក្នុងអំឡុងប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ បើទោះបីការតវ៉ានោះ ត្រូវរដ្ឋការក្រុងហាណូយ ធ្វើទុក្ខបុកម្នេញយ៉ាងណាក៏ដោយ ព្រោះពួកគាត់មិនអាចអត់ទ្រាំបាននឹងការជិះជាន់ពីសំណាក់របបផ្តាច់ការយួនមួយនេះ ។

នៅថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ ២០០៧ សមណសិស្សនៃសាលាបាលីជាន់ខ្ពស់ខេត្តឃ្លាំង បានក្រោកឡើងតវ៉ាចំពោះអាជ្ញាធរអាណានិគមយួន នៅមុខការិយាល័យនគរបាល

ខេត្តដើម្បីទាមទារឲ្យអាជ្ញាធរយួនគោរពសិទ្ធិរបស់ខ្មែរក្រោមម្ចាស់ស្រុក ។

មូលហេតុដែលនាំឲ្យមានការធ្វើបាតុកម្មនេះ ដោយសារនគរយួនបានហាមព្រះសង្ឃនៃសាលាបាលីមួយនេះនិមន្តចេញបិណ្ឌបាត ។ ក្រោយពីការធ្វើបាតុកម្មដោយសន្តិវិធីនោះ អាជ្ញាធរអាណានិគមយួនបានចាប់ព្រះសង្ឃផ្សឹកជាច្រើនអង្គ ។ ចំពោះព្រះសង្ឃអង្គណាដែលអាជ្ញាធរយួនចាត់ទុកថា ជាមេបាតុករត្រូវបានចាប់ដាក់គុកតាមលំដាប់លំដោយ ។

ព្រះសង្ឃទាំង ៥ អង្គ ដែលរបបអាណានិគមយួនចាប់ដាក់គុកនៅខេត្តឃ្លាំង ទាក់ទិនការធ្វើបាតុកម្មនោះ ត្រូវបានរបបយួនដោះលែងវិញ បន្ទាប់ពីត្រូវជាប់គុកម្នាក់ៗជាងពីរឆ្នាំ ។ ការដោះលែងព្រះសង្ឃឲ្យចេញពីគុកនោះ ដោយសារមានការធ្វើបាតុកម្ម និងប្តឹងទៅសហគមន៍អន្តរជាតិ ពីសំណាក់ខ្មែរក្រោមនៅបរទេសដើម្បីដាក់គំនាបលើរបបយួន ។

ក្រៅពីនេះ ខ្មែរក្រោមនៅខេត្តនានា បានក្រោកឡើងជាបន្តបន្ទាប់ ផងដែរ ដើម្បីទាមទារដីកេររបស់ខ្លួនដែលត្រូវរបបយួនរឹបយកទៅចែកឲ្យជនជាតិយួន ហើយត្រូវអាជ្ញាធរយួនចាប់ខ្លួនទាំងអយុត្តិធម៌ ។

ថ្មីៗនេះ នៅថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១០ លោក ថៅ ហេន ជាជនភៀសខ្លួនខ្មែរក្រោមនៅប្រទេសថៃ បានត្រឡប់មកស្រុកកំណើត នៅខេត្តមាត់ជ្រូក ត្រូវបានអាជ្ញាធរយួនចាប់ដាក់គុក ផងដែរ ។ល។

**ចលនានៃជនជាតិ Degar-Montagnards នៅតំបន់ខ្ពង់រាបះ**

ជនជាតិម៉ុងតែញ៉ា (Degar-Montagnards ) បានក្រោកឡើងតវ៉ាជាបន្តបន្ទាប់ដូចខ្មែរក្រោមដែរ ចាប់តាំងពីឆ្នាំ ២000 មក ។ ការរើសអើងពូជសាសន៍ និងការរំលោភសិទ្ធិមនុស្សពីរបបអាណានិគមយួននៅតំបន់ខ្ពង់រាប ភាគកណ្តាលវៀតណាម បានធ្វើឲ្យក្រុមកុលសម្ព័ន្ធជនជាតិតំបន់ភ្នំទាំងនោះ ងើបឡើងតវ៉ាជាលក្ខណៈទ្រង់ទ្រាយធំដើម្បីប្តូរយកសិទ្ធិសេរីភាពរបស់ពួកគេ ។

ការទាមទាររបស់ក្រុមជនជាតិនេះ ត្រូវបានអាជ្ញាធរយួនចាប់ដាក់គុក និងមានសេច

ក្ដីរាយការណ៍ថា មានមនុស្សតវ៉ាជាច្រើន ត្រូវបានបាត់ខ្លួន ហើយពួកគេភាគច្រើនបាននាំគ្នាភៀសខ្លួនរត់ចូលព្រៃឆ្លងកាត់ព្រំដែនចូលប្រទេសកម្ពុជាតាមខេត្តរតនគិរី និងខេត្តមណ្ឌលគិរី ដើម្បីរួចផុតពីការចាប់ខ្លួនធ្វើទារុណកម្មរបស់រដ្ឋការក្រុងហាណូយ ។

ក្រុមកុលសម្ព័ន្ធភ្នំនៃតំបន់ខ្ពង់រាបទាំងនេះ មានប្រជាជនប្រមាណពី ១ ទៅ ២ លាននាក់ ជាអ្នកកាន់សាសនាគ្រិស្ត ក្នុងនោះមានក្រុមជនជាតិ Jarai, Rhade, Bahnar, Koho, Mnong និង Stieng រស់នៅលើផ្ទៃដីប្រមាណ ៥៥.000 គីឡូម៉ែត្រការ៉េ ។ នេះបើយោងតាមរបាយការណ៍ស្ដីអំពីជនជាតិដើម Degar-Montagnards របស់អង្គការ UNPO ។

## ចលនាផ្ដាច់ខ្លួនបង្កើតព្រះរាជាណាចក្រ Hmong នៅភាគខាងជើងវៀតណាមៈ

នៅក្នុងខែឧសភា ឆ្នាំ ២០១១ ក្រុមជនជាតិ Hmong នៅស្រុកមឿងញ៉ែ (Muong Nhe ) ខេត្តដៀងបៀង (Dien Bien) ភាគខាងជើងប្រទេសវៀតណាម បាននាំគ្នាក្រោកឡើង ទាមទារផ្ដាច់ខ្លួនចេញពីប្រទេសវៀតណាម ហើយគ្រោងបង្កើតជាព្រះរាជាណាចក្រមួយរបស់ខ្លួន ។ ការក្រោកឡើង ដែលមានមនុស្សចូលរួមប្រមាណជាង ៥.000 នាក់នេះ ត្រូវអាជ្ញាធរយួនបង្ក្រាបដោយប្រើឧទ្ធម្ភាគចក្រ បណ្ដាលឲ្យមនុស្សចំនួន ៦៣ នាក់បាត់បង់ជីវិត ។ នេះបើយោងតាមរបាយការណ៍របស់មជ្ឈមណ្ឌលវិភាគគោលនយោបាយសាធារណៈហៅកាត់ថា CPPA និងក្រុមជនជាតិ Hmong Advance មានមូលដ្ឋាននៅសហរដ្ឋអាមេរិក បានរាយការណ៍ កាលពីខែឧសភា ឆ្នាំ ២០១១ ។

ជនជាតិ Hmong នៅជុំវិញពិភពលោកមាន ៣២០.000 នាក់ និងបច្ចុប្បន្ន ជនជាតិមួយនេះ មានអង្គការសម្ព័ន្ធរដ្ឋចៅហ្វា (ChaoFa Federated State ) ជាសមាជិកនៃអង្គការ UNPO ។ យោងតាមគេហទំព័រ Wikipedia ជនជាតិ Hmong នៅក្នុងប្រទេសវៀតណាមមានប្រមាណ ៧៨៧.៦០៤ នាក់ ។

## ចលនាក្រុមជនជាតិចាម្ប៍ភាគកណ្ដាលវៀតណាមៈ

ជនជាតិចាម្ប៍ នៃអាណាចក្រចម្ប៉ា ឬភាគកណ្ដាលនៃប្រទេសវៀតណាម សព្វថ្ងៃនៅមិនទាន់ឃើញមានការងើបតវ៉ាធំដុំនៅឡើយ តែពួកគេកំពុងតែឱបកំហឹងរាល់ថ្ងៃ

ចំពោះការបាត់បង់ព្រះរាជាណាចក្ររបស់ខ្លួនទៅដៃយួនកាលពីអតីតកាល ដែលព្រឹត្តិការណ៍មួយនេះ ជនជាតិចាម្ប៍គ្រប់រូបនៅតែចាត់ទុកថាជា «កំហឹងជាតិ» របស់ខ្លួនជានិច្ច ។

នគរចម្ប៉ា បានធ្លាក់ចូលក្នុងកណ្តាប់ដៃយួន បន្ទាប់ពីស្តេចយួនឈ្មោះ ត្រឹង ញឹង តុង បានលើកកូនស្រីរបស់ខ្លួនម្នាក់ឈ្មោះ ហៀង ត្រឹង ( Huyền Trân) ឲ្យទៅស្តេចនគរចម្ប៉ា ព្រះនាម ជយសិង្ហវរ្ម័ន ទី ៣ នា ឆ្នាំ ១៣០៦ ។

ប្រវត្តិជ័យជម្នះដណ្តើមបាននគរចម្ប៉ានេះ សព្វថ្ងៃ របបអាណានិគមយួន បានសាងបូជនីយស្ថានមួយនៅទីក្រុងហ្វេ (Hue) សម្រាប់តាំងរូបសំណាកនាង ហៀង ត្រឹង ដើម្បីសម្តែងការដឹងគុណ ដោយជនជាតិយួនចាត់ទុកថា ដោយសារគុណបំណាច់របស់នាងនេះហើយ បានធ្វើឲ្យជនជាតិយួនដណ្តើមយកបាននគរចាម្ប៉ា នាពេលនោះ ។

ជនជាតិចាម្ប៍ចាត់ទុកការបាត់នគររបស់ខ្លួនថាជា «ព្រឹត្តិការណ៍កំហឹងជាតិ» ហើយពួកគេកំពុងតែឱបទុក្ខរាល់ថ្ងៃ ចាំតែមានឱកាសអាលនឹងដណ្តើមយកនគររបស់ខ្លួនមកវិញ ។ អ្វីដែលឈឺចាប់ជាងនេះទៅទៀតសម្រាប់ជនជាតិចាម្ប៍នោះគឺ នៅក្នុងបូជនីយស្ថាននោះ របបយួនបានចារជាផ្ទាំងសិលាចារឹកមួយយ៉ាងធំ ដែលវាហាក់ដូចជាការចំអកឡកឡើយដល់ជនជាតិចាម្ប៍ថា នាង ហៀង ត្រឹង ជាវីរនារីជាតិ ដែលបានធ្វើឲ្យជនជាតិយួនដណ្តើមយកបាននគរចាម្ប៉ាក្នុងអតីតកាល ។

**ចលនាទាមទារលទ្ធិប្រជាធិបតេយ្យរបស់ជនជាតិយួនះ**

ថ្ងៃទី ០២ ខែសីហា ឆ្នាំ ២០១១ រដ្ឋការក្រុងហាណូយបានបើកសាលាឧទ្ធរណ៍ក្តីលោក កូវ ហ៊ី ហា វ៉ៅ ជាមេធាវីជនជាតិយួនម្នាក់ ដែលត្រូវបានអាជ្ញាធរយួនចោទប្រកាន់ពីបទ «ឃោសនាប្រឆាំងរដ្ឋាភិបាលយួន» ។ ក្រៅពីនេះ សកម្មជនតស៊ូមតិ និងអ្នកបញ្ចេញយោបល់ខ្វែងគំនិតជនជាតិយួនជាច្រើនរូបទៀត កំពុងតែជាប់នៅក្នុងគុកកុម្មុយនីស្តយួន ដោយសារតែពួកគេនិយាយការពិតដែលកើតឡើងអយុត្តិធម៌នៅក្នុងសង្គមនៃរបបកុម្មុយនីស្តយួន ។ អ្នកប្រជាធិបតេយ្យយួនទាំងនេះចង់ឲ្យវៀតណាមក្លាយទៅជាប្រទេសមាននីតិរដ្ឋ គោរពសិទ្ធិមនុស្ស មានលទ្ធិប្រជាធិបតេយ្យ និងប្តូរ

របបពីកុម្មុយនីស្តទៅជារបបសេរីពហុបក្ស ។

អំពើផ្តាច់ការរបស់រដ្ឋការក្រុងហាណូយពីមួយថ្ងៃទៅមួយថ្ងៃ ត្រូវបានប្រជាពលរដ្ឋវៀតណាម និងជនជាតិដើមនៅក្នុងប្រទេសមើលឃើញកាន់តែច្បាស់ ។ ការយល់ដឹងរបស់ប្រជាជនគ្រប់ស្រទាប់វណ្ណៈ អំពីពុតរបស់បក្សកុម្មុយនីស្តយួន និងការឈឺចាប់ដែលកើតចេញពីការជិះជាន់ វានឹងជំរុញឲ្យរបបកុម្មុយនីស្តផ្តាច់ការមួយនេះ នឹងត្រូវដួលរលំនៅពេលអនាគតខាងមុខនេះជាមិនខាន ៕

បទបរិយាយរបស់ កាសែត ព្រៃនគរ លេខ ២៤ ឆ្នាំទី ២ ចេញផ្សាយថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១១

# ធ្វើយ៉ាងណាទើបអាចដឹងថា នរណាជាខ្មែរក្រោម នរណាជាយួន?

**អត្ថន័យពាក្យ «យួន»៖**

ដើម្បីបានជ្រាបច្បាស់ថា នរណាជាជនជាតិយួន និងនរណាជាខ្មែរក្រោម ដែលកំពុងតែរស់នៅក្នុងប្រទេសកម្ពុជានោះ យើងអាចសង្កេតមើល និងប្រៀបធៀបរវាងខ្មែរក្រោម និងជនជាតិយួនលើកគ្គាមួយចំនួនដូចជា យីហោហាងរបស់ជនជាតិយួន ភាសា ឈ្មោះនាមត្រកូល សាសនា ទីកន្លែងកំណើត និងចិត្តគំនិត ដូចខាងក្រោម៖

**អំពីជនជាតិយួននៅកម្ពុជា៖**

ជនជាតិយួនទោះបីទៅដល់ទីកន្លែងណាដ៏ដោយ គេមិនដែលបោះបង់ចោលអត្តសញ្ញាណរបស់ខ្លួនទេ គឺគេតែងតែបង្ហាញឲ្យមនុស្សម្នាមើលឃើញថា ខ្លួនគេជាជនជាតិយួនយ៉ាងពិតប្រាកដ ដែលសកម្មភាពនេះហើយ អាចធ្វើឲ្យយើងសង្កេតដឹងបានថា ពួកគេជាជនជាតិយួន ។

**យីហោ៖** ជនជាតិយួននៅកម្ពុជា តាំងពីមុខរបរខ្នាតតូចដល់ធំ ពួកគេតែងតែបង្ហាញឲ្យមនុស្សម្នាឃើញថា ខ្លួនគេជាយួនជានិច្ច ។ កន្លែងលក់ដូរណាដែលជារបស់ជនជាតិយួន គេតែងតែដាក់យីហោជាអក្សរយួនធំៗ ជាសញ្ញាសម្គាល់ដូចជា «ហាងផើ» ជាប្រភេទទឹកស៊ុបម្យ៉ាងរបស់ជនជាតិយួន គេដាក់ជាអក្សរយួនធំៗថា «Phở» ហាងកាត់សក់ គេដាក់ថា «ហ៊ើកតុក» (Hớt Tóc) និងហាងលក់មាសដាក់ថា «ទេមវ៉ាង» (Tiệm Vàng ) ជាដើម ។

**ភាសា៖** សម្រាប់ជនជាតិយួនដែលនៅស្រុកខ្មែរយូរឆ្នាំ ហើយអាចនិយាយភាសាខ្មែរបានយ៉ាងណាក៏ដោយ តែគេនៅតែលៀនកន្ទុយចំណុចខ្សោយរបស់ខ្លួនមកដដែល គឺជនជាតិយួនភាគច្រើននិយាយភាសាខ្មែរដែលមានស័ព្ទប្រកបនឹងព្យញ្ជនៈ «ល» នៅពីមុខមិនបានទេ ។ ដូចពាក្យថា «កាល» ជនជាតិយួននិយាយបន្លំៗថា «ការ», ពាក្យថា «ស្រួល» និយាយថា «ស្រួរ» ជាដើម ។ សម្រាប់អ្នកនិយាយមិនច្បាស់វិញ យើងអាចនិយាយបានថា ពួកគេនិយាយដូចតារាកំប្លែង វ៉ាង ឌឿ ដែលធ្លាប់និយាយត្រាប់សំឡេង

យួនដូចជា «ស្រទឡាញ់» ថា «ស្រទឡាន់», ឆ្ងាញ់ ថា «ស្ងាន់» ជាដើម ។

**ឈ្មោះនិងត្រកូលៈ** ជនជាតិយួនមានឈ្មោះនិងត្រកូលសុទ្ធតែជាភាសាយួន ដែលត្រកូលទាំងនោះ មានដូចជា ង្វៀង (Nguyễn), ផាម (Phạm), ឡេ (Lê), វ៉ឺ (Võ), ផាង (Phan), ដោ (Đỗ), ហោ (Hồ), ប៊ូយ (Bùi), និង ដាំង (Đặng) ។

អត្តសញ្ញាណប័ណ្ណសញ្ជាតិវៀតណាម ចេញដោយរដ្ឋាភិបាលវៀតណាម សព្វថ្ងៃផ្តល់ដល់ជនជាតិយួននៅក្នុងស្រុក មានចំណុច ៣ សំខាន់ ដែលអាចកំណត់ដឹងបានថា គេជាជនជាតិយួន នោះគឺៈ

ទីមួយៈ **សញ្ជាតិ** (Quốc tịch) គេដាក់ថា វៀតណាម (Việt Nam)

ទីពីរៈ **ជនជាតិ** (Dân tộc) គេដាក់ថា កិញ (Kinh)

ទីបីៈ **ត្រកូល** និង **ឈ្មោះ** (Họ và Tên) គេដាក់តាមត្រកូលដែលមានខាងលើ ។

**សាសនាៈ** ជនជាតិយួនគោរពប្រតិបត្តិតាមពុទ្ធសាសនាមហាយាន តែដល់សម័យអាណានិគមនិយមបារាំង ពួកគេខ្លះ ក៏បានប្តូរពីពុទ្ធសាសនាមហាយានទៅជា សាសនាយេស៊ូវិញ ។

ដូចនេះ នៅតាមផ្ទះរបស់ជនជាតិយួននីមួយៗ តែងតែមានតាំងរូបព្រះ Guanyin ឬជនជាតិយួន ហៅថា ព្រះក្វាងថេអាំ (Quán Thế Âm) នៅលើអាសនៈសម្រាប់គោរពបូជា ។ កត្តានេះហើយ ជនជាតិយួនមិនដែលនាំគ្នាទៅធ្វើបុណ្យតាមវត្តអារាមព្រះពុទ្ធសាសនាថេរវាទខ្មែរទេ គឺគេតែងតែនាំគ្នាទៅធ្វើបុណ្យ នៅតាមវត្តព្រះពុទ្ធសាសនាមហាយានរបស់ព្រះសង្ឃយួនដែលបានកសាងនៅក្នុងស្រុកខ្មែរ ។

**កន្លែងកំណើតៈ** សម្រាប់ជនជាតិយួន ដែលបានមករស់នៅស្រុកខ្មែរ ហើយយើងបានដឹងថា ពួកគេមានកន្លែងកំណើតឋិតនៅក្នុងខេត្តណាមួយនៃភាគកណ្តាល (Miền Trung ឬ Huế) និងភាគខាងជើង (Miền bắc ឬ Hà Nội) នៃប្រទេសវៀតណាម គឺជាជនជាតិយួនសុទ្ធសាធ ឬជាជនជាតិភាគតិចណាមួយ មិនមែនជាខ្មែរក្រោមទេ ព្រោះថាខ្មែរក្រោមមិនដែលមានកន្លែងកំណើតនៅតំបន់ទាំងពីរខាងលើឡើយ ។ សម្រាប់ជនជាតិយួនដែលមានទីកន្លែងកំណើតនៅកម្ពុជាក្រោម ឬភាគខាងត្បូងនៃវៀតណាម

វិញ ប្រសិនបើមានករណីគេអះអាងថាគេជា «ខ្មែរក្រោម» នោះ យើងគ្រាន់តែសួរគេថា «គេនៅជិតវត្តខ្មែរណាមួយនៅដែនដីកម្ពុជាក្រោម?» ជនជាតិយួនពិតជាឆ្លើយសំណួរនេះមិនចេញទេ ។

**ចិត្តគំនិតៈ** ជនជាតិយួនដែលចូលមកនៅស្រុកខ្មែរ ពួកគេគិតអំពីបញ្ហាសេដ្ឋកិច្ចជាធំ ដោយពួកគេយកគណបក្សមានអំណាច ឬគណបក្សនយោបាយណាដែលគាំទ្ររដ្ឋាភិបាលវៀតណាមធ្វើជាម្លប់សម្រាប់សម្រួលដល់ជីវភាពរបស់ពួកគេទាំងស្របច្បាប់ និងខុសច្បាប់ ។ ពួកជនជាតិយួននៅប្រទេសកម្ពុជា មិនចូលចិត្តខ្មែរក្រោម និងគណបក្សនយោបាយណា ដែលរិះគន់រដ្ឋាភិបាលវៀតណាម និងកម្ពុជា ឡើយ ។

**អំពីខ្មែរក្រោមនៅកម្ពុជាៈ**

មូលហេតុដែលនាំឲ្យមានវត្តមានខ្មែរក្រោមនៅប្រទេសកម្ពុជានោះ មកពីកត្តាមួយចំនួន ដូចជា ពួកគាត់រត់ចេញពីកម្ពុជាក្រោម ដោយសារការរើសអើងពូជសាសន៍ពីរបបគ្រប់គ្រងយួន ការរំលោភសិទ្ធិមនុស្ស រដ្ឋការយួនដេញចាប់ទាក់ទិននយោបាយមកបន្តការសិក្សា និងបញ្ហាសេដ្ឋកិច្ច ជាដើម ។

ប្រជាជាតិខ្មែរក្រោមនៅកម្ពុជាមិនមានអ្វីប្លែកនិងខុសពីពលរដ្ឋខ្មែរនោះទេ ទាំងពីឈាមជ័រ សាសនា ភាសា និងចិត្តគំនិត ។ អ្វីដែលខ្មែរក្រោមប្លែកនិងខុសពីពលរដ្ឋខ្មែរនៅកម្ពុជានោះ គឺពួកគាត់មានត្រកូល និងមានទីកន្លែងកំណើតនៅកម្ពុជាក្រោម ។

ចំពោះអត្តសញ្ញាណប័ណ្ណសញ្ជាតិវៀតណាម ចេញដោយរដ្ឋាភិបាលយួន ផ្តល់ដល់ខ្មែរក្រោមនៅកម្ពុជាក្រោម វិញមានចំណុច ៣ យ៉ាងសំខាន់ ដែលអាចកំណត់ដឹងបានថា ពួកគាត់ជាខ្មែរក្រោម គឺៈ

ទីមួយៈ **សញ្ជាតិ** (Quốc tịch) គេដាក់ថា វៀតណាម (Việt Nam)

ទីពីរៈ **ជនជាតិ** (Dân tộc) គេដាក់ថា ខ្មែរ (Khmer ឬ Khơme)

ទីបីៈ **ត្រកូល** និង **ឈ្មោះ** (Họ và Tên) គេដាក់តាមត្រកូលរបស់ខ្មែរក្រោម មានត្រកូល ថាច់ (Thạch), សឺង (Sơn), កៀង (Kien), គឹម (Kim), យ័ញ ឬ ដាញ់ (Danh), ដាវ (Dao), តាំង (Tang), ឡឹម (Lam), ចៅ (Chau), លី (Ly), តោ (To), ត្រឹង (Tran),

និង យឿង (Duong) ជាដើម ។

ម៉្យាងទៀត ខ្មែរក្រោមដែលធំដឹងក្តីនៅកម្ពុជាក្រោម ពួកគាត់និយាយភាសាខ្មែរទៅតាមក្រាមភាសា ដែលមានសំនៀងធូន់ជាងភាសាខ្មែរនៅប្រទេសកម្ពុជា ។ ខ្មែរក្រោមនិយាយភាសាខ្មែរមានលក្ខណៈធូន់ ឬអាចនិយាយថា ពួកគាត់និយាយភាសាខ្មែរ មានលក្ខណៈរដឺន តែមិនមែនប៉ៃឡាំទេ ។

ប្រសិនបើ អ្នកចង់ដឹងថា នរណាម្នាក់ពិតជាខ្មែរក្រោមមកពីកម្ពុជាក្រោមនោះ ចូរសួរថា ផ្ទះពួកគាត់នៅក្នុងចំណុះជើងវត្តណាមួយនៅកម្ពុជាក្រោម? ពួកគាត់នឹងឆ្លើយបានយ៉ាងលឿនថា ពួកគាត់នៅក្នុងចំណុះជើងវត្តណាមួយ ដោយឥតទើសទាក់អ្វីឡើយ ព្រោះវត្តអារាមនីមួយៗនៅកម្ពុជាក្រោម ជាទីកន្លែងផ្សារភ្ជាប់ខ្សែជីវិតរបស់ខ្មែរក្រោមតាំងពីកើតរហូតដល់ស្លាប់ ៕

អត្ថបទចុះផ្សាយនៅលើទំព័រ កាសែត ព្រៃនគរ លេខ ២៤ ឆ្នាំទី ២ ចេញផ្សាយថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១១

# មើលទង់ជ័យពុទ្ធសាសនា
# ឃើញទង់ជាតិកម្ពុជាក្រោម

នៅថ្ងៃទី ៧, ៨ និងទី ៩ ខែកុម្ភៈ ឆ្នាំ ២០១៧ គណៈមន្ត្រីសង្ឃខេត្តព្រះត្រពាំង បានចាត់តាំងកម្មវិធីប្រឡងរួមខេត្ត បញ្ចប់ថ្នាក់ពុទ្ធិកសិក្សាបឋមភូមិ និងទុតិយភូមិ នាវត្តតាលភេរីឧត្តុង្គមានជ័យសេរីវង្សារាម (វំដួល) ឋិតនៅក្នុងស្រុកថ្កូវ ខេត្តព្រះត្រពាំង ។ ឆ្នាំសិក្សាពុទ្ធសករាជ ២៥៦០ គ្រិស្តសករាជ ២០១៦ - ២០១៧ វត្តវំដួលបានធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំមណ្ឌលប្រឡងសម្រាប់ទទួលសមណសិស្ស និងសិស្សានុសិស្សមកពីចំណុះជើងវត្តនានានៅក្នុងខេត្តព្រះត្រពាំង ។ កម្មវិធីនេះ គណៈកម្មការរៀបចំមណ្ឌលប្រឡងបានរៀបចំវេទិកាប្រកាសលទ្ធផលយ៉ាងស្រស់ស្អាត ប្រកបលក្ខណៈជាតិ និងសាសនាដែលមានទ្រង់ទ្រាយជាប្រាសាទបន្ទាយស្រី ហើយមានដាក់ទង់ពុទ្ធសាសនានៅចំកណ្ដាលវេទិកា បានធ្វើឲ្យរំលេចនូវពណ៌ខៀវ លឿង ក្រហម ដែលជាពណ៌នៃទង់ជាតិកម្ពុជាក្រោមយ៉ាងច្បាស់ក្រឡែតគួរជាទីមោទនៈពន់ពេក ។ ពេលបានឃើញរូបភាពនៃវេទិកាប្រកាសលទ្ធផល មនុស្សម្នារំភើបចិត្តគ្រប់គ្នា ប៉ុន្តែក្រោយមក មានព័ត៌មានតាមបណ្ដាញសង្គម Facebook ផ្សាយថា មានគេឲ្យរុះរើចេញដោយសារវេទិកានេះ មើលទៅឃើញទង់ជាតិកម្ពុជាក្រោមច្បាស់ពេក បណ្ដាលឲ្យមន្ត្រីសង្ឃគ្រប់អង្គមិនហ៊ានឡើងគង់នៅលើវេទិកានេះ ហើយនាំគ្នាគង់នៅខាងក្រោមមុខវេទិកាវិញ ព្រោះខ្លាចរបបយួនចោទប្រកាន់បញ្ហាផ្សេងៗជាដើម ។ ក្រោយមក គណៈកម្មការរៀបចំបានរើតុផ្កាសម្រាប់តម្កល់ពុទ្ធបដិមាចេញពីមុខទង់ជ័យពុទ្ធសាសនា ដើម្បីឲ្យមើលឃើញច្បាស់ពណ៌ទាំង ៦ នៃទង់ជ័យពុទ្ធសាសនា គឺ ខៀវ លឿង ក្រហម សហង្សបាទ និងពណ៌ភ្លឺផ្លេក ទើបមន្ត្រីសង្ឃហ៊ានឡើងគង់លើវេទិកានោះ ។

តើការណ៍ដែលគណៈមន្ត្រីសង្ឃខ្លាចពណ៌ខៀវ លឿង ក្រហម នេះ វាមានអត្ថន័យយ៉ាងណាសម្រាប់ "សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង" របស់ប្រជាជាតិខ្មែរក្រោមនៅដែនដីកម្ពុជាក្រោម នាពេលបច្ចុប្បន្ន និងអនាគត ?

## ខ្មែរក្រោមនៅមិនទាន់មានសិទ្ធិពេញលេញក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួនៈ

ទង់ជាតិកម្ពុជាក្រោម មានការទទួលស្គាល់ពីខ្មែរក្រោមទូទាំងពិភពលោក និងពីអង្គការប្រជាជាតិ និងប្រជាជនគ្មានតំណាង (UNPO) ។ សព្វថ្ងៃ ពលរដ្ឋខ្មែរក្រោមនៅក្រៅប្រទេសមានសិទ្ធិពេញលេញក្នុងការលើកទង់ជាតិកម្ពុជាក្រោមជាផ្លូវការ ដោយមិនមានរដ្ឋាភិបាល ឬបុគ្គលណាម្នាក់ហាមឃាត់ឡើយ តែនៅកម្ពុជាក្រោមបែរជាគ្មានសិទ្ធិទៅវិញ ។ ម្យ៉ាងទៀត សូម្បីតែទង់ជ័យពុទ្ធសាសនាសោះ ដែលមានពណ៌ខៀវលឿង និង ក្រហម ជាពណ៌នៃទង់ជាតិកម្ពុជាក្រោម ក៏បានធ្វើឲ្យគណៈមន្ត្រីសង្ឃខ្មែរខ្លះនៅខេត្តព្រះត្រពាំង ខ្លាចផងដែរ ។ នេះឆ្លុះបញ្ចាំងឲ្យឃើញថា ទម្ងន់នៃការគាបសង្កត់នៃរបបអាណានិគមយួនលើខ្មែរក្រោមនៅតែធ្ងន់សាហាវយង់ឃ្នងដដែល ។

ដោយសារទ្រាំលែងបាននឹងការឈឺចាប់ ព្រោះបានឃើញខ្មែរក្រោមកំពុងតែរស់នៅក្នុងភាពភ័យខ្លាច រងទុក្ខខ្លោចផ្សានៅក្រោមនឹមអាណានិគមយួននោះ ព្រះសង្ឃមួយអង្គបានសរសេរកំណាព្យមួយមានចំណងជើងថា «វេទិកាអភ័ព្វ» ហើយបង្ហោះនៅលើបណ្ដាញសង្គម Facebook ដើម្បីសម្ដែងពីព្រះទ័យព្រួយបារម្ភរបស់ព្រះអង្គចំពោះទង្វើដែលបុគ្គលមន្ត្រីសង្ឃខេត្តអង្គខ្លះ បានបញ្ជាឲ្យរុះរើនូវវេទិកានោះចេញ ។ កំណាព្យនោះមានសេចក្ដីថាៈ

*“វេទិកាល្អស្រស់សម្រស់មានជ័យ តែបាត់សេរីអប្រិយកំព្រា*
*ពណ៌ស្រស់ឆើតឆាយប្រាយប្រាប់រាល់គ្នា វេទិការងាមានពៀរនឹងពណ៌ ។*
*ខៀវលឿងក្រហមសហង្សបាទនិងផ្លេក តែអ្នកមានភ្នែកមើលខ្មៅជាស*
*ឃើញបានតែបីនាំឲ្យរឹករវ ថាទង់មិនល្អថាខុសអាស្នា ។*
*វេទិកាបានគេតុបតែងចែងចាំងសមរម្យ តែទាស់អ្នកធំឲ្យរើឲ្យសា*
*កន្លែងឲ្យគង់ទ្រង់មិនជ្រះថ្លា បែរយកហេតុការណ៍ថាលើក្ដៅពេក ។*
*នាំគ្នាចុះគង់ខាងក្រោមទាំងអស់ ចោលវេទិកាស្រស់ច្រាល់ពណ៌ភ្លឺផ្លេក*
*កូនចៅបៀមមាត់សង្កត់ទឹកភ្នែក បេះដូងស្ទើរបែកស្ដាយខ្លួនជាខ្មែរ ។*
*វេទិកាអូនអើយកុំឡើយសោកា កុំយំជីវ៉ាបាស្ងួនមាសស្នេហ៍*

*គេស្អប់អ្នកហើយត្រាណត្រើយមាសមេ អភ័ព្វម្ល៉េះទេវេទិការំដួល"* ។

រដ្ឋាភិបាលយួនជាប្រទេសហត្ថលេខីមួយ បានចុះហត្ថលេខាលើសេចក្ដីប្រកាសរបស់ អ.ស.ប. ស្ដីពីសិទ្ធិជនជាតិដើម (UNDRIP) ដោយបានសន្យាថា នឹងផ្ដល់សិទ្ធិដល់ជនជាតិដើមនៅក្នុងប្រទេសវៀតណាម ក្នុងនោះមានខ្មែរក្រោមនៅកម្ពុជាក្រោម ផងដែរ ឲ្យបានទទួលនូវសិទ្ធិជាមូលដ្ឋានរបស់ខ្លួន ដោយគ្មានការគំរាមកំហែង ។ ផ្ទុយទៅវិញ របបអាណានិគមយួនមិនបានអនុវត្តតាមកិច្ចសន្យាឡើយ តែបែរជាគំរាមកំហែងនិងធ្វើទុក្ខបុកម្នេញលើជនជាតិដើមខ្មែរក្រោម កាន់តែខ្លាំងជាងមុន ទៅវិញ ។

**ខ្យល់ "សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង" បានបក់ដល់កម្ពុជាក្រោមៈ**

ទោះបី គណៈមន្ត្រីសង្ឃនៅកម្ពុជាក្រោម និងពលរដ្ឋខ្មែរក្រោមខ្លះនៅមានការខ្លាចចំពោះទង់ជាតិកម្ពុជាក្រោម យ៉ាងណាក៏ដោយ តែវាជាចំណុចវិជ្ជមានមួយនៃការតស៊ូមតិរបស់ សហព័ន្ធខ្មែរកម្ពុជាក្រោម នៅក្រៅប្រទេសអស់រយៈពេល ២០ ឆ្នាំកន្លងមកនេះ បានធ្វើឲ្យអន្តរជាតិ ខ្មែរនៅប្រទេសកម្ពុជា និងខ្មែរក្រោមនៅកម្ពុជាក្រោម បានដឹងយ៉ាងច្បាស់អំពីទង់ជាតិរបស់ខ្លួន ។

នៅថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០១ អង្គការប្រជាជាតិ និងប្រជាជនគ្មានតំណាង (UNPO) បានទទួលស្គាល់ទង់ជាតិកម្ពុជាក្រោមជាផ្លូវការ ស្របពេលដែលអង្គការនេះបានទទួលស្គាល់សហព័ន្ធខ្មែរកម្ពុជាក្រោម ជាសមាជិកពេញសិទ្ធិរបស់ខ្លួន នាទីក្រុង Philadelphia សហរដ្ឋអាមេរិក ។ ដំបូងឡើយ មិនសូវមាននរណាបានដឹងថា ពលរដ្ឋខ្មែរក្រោមមានទង់ជាតិរបស់ខ្លួនឡើយ តែបន្ទាប់ពី សហព័ន្ធខ្មែរកម្ពុជាក្រោម ធ្វើការតស៊ូមតិនៅលើឆាកអន្តរជាតិ និងព្យាយាមផ្សព្វផ្សាយនូវសកម្មភាពរបស់ខ្លួនតាមរយៈវិទ្យុ ទូរទស្សន៍ ព្រឹត្តិបត្រ កាសែត ស៊ីឌី (CD) ចម្រៀងជាតិនិយម ល្ខោននិយាយរឿងចៅហ្វាយ គុយ វីស៊ីឌី (VCD) និង ឌីវីឌី (DVD) ទៅដល់ដែនដីកម្ពុជាក្រោមជាបន្តបន្ទាប់ ហើយប្រជាពលរដ្ឋខ្មែរក្រោមបាននាំគ្នាគាំទ្រជ្រោងទង់ជាតិរបស់ខ្លួនឡើង នៅគ្រប់ទីកន្លែងក្នុងពិភពលោក ក្នុងនោះ មានការធ្វើបាតុកម្មជាដើម បានធ្វើឲ្យពលរដ្ឋខ្មែរក្រោមនៅក្នុងស្រុក បានស្គាល់នូវទង់ជាតិរបស់ខ្លួន បានឮពាក្យ «សិទ្ធិមនុស្ស» និងជាពិសេស

បានពួពាក្យ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ជាគោលដៅមួយដែល សហព័ន្ធខ្មែរកម្ពុជាក្រោម កំពុងតែធ្វើដំណើរឆ្ពោះទៅកាន់មាតុភូមិកម្ពុជាក្រោម ។ ពីមុន ពេលដែលខ្មែរក្រោមនៅក្នុងស្រុកមិនទាន់មានអិនធើណិតនោះ សហព័ន្ធខ្មែរកម្ពុជាក្រោមបានព្យាយាមរកគ្រប់មធ្យោបាយក្នុងការបញ្ជូនព័ត៌មានរបស់ខ្លួនទៅដែនដីកម្ពុជាក្រោមតាមរយៈច្រកព្រំដែននៃប្រទេសកម្ពុជា ។ មកដល់ឆ្នាំ ២០១៧ លទ្ធផលនៃការតស៊ូនោះទទួលបានផ្លែផ្កាគួរឲ្យកត់សម្គាល់ ។ ផ្លែផ្កាដែលយើងបាន និងកំពុងតែមើលឃើញនោះគឺប៉ុន្មានឆ្នាំចុងក្រោយនេះ រដ្ឋាភិបាលយួនបានចាប់ផ្តើមផ្អើលនឹងពណ៌**ខៀវ លឿង** និង**ក្រហម** ហើយដើរគំរាមព្រះសង្ឃខ្មែរក្រោមគ្រប់ទីកន្លែង ។ ម៉្យាងទៀត ការណ៍ដែលគណៈមន្ត្រីសង្ឃបាននាំគ្នាចុះពីវេទិកាដោយសារផ្អើលនឹងពណ៌ខៀវ លឿង និងក្រហមនោះ មានន័យថា មន្ត្រីសង្ឃទាំងនោះបានដឹងហើយថា ខ្មែរក្រោមខ្លួនឯងមានទង់ជាតិនឹងគេដែរ គឺមិនមែនទង់ពណ៌ក្រហមផ្កាយលឿងរបស់យួននោះទេ ។ ទោះបីពេលនេះពលរដ្ឋនៅក្នុងស្រុកខ្លះ នៅផ្អើលនឹងទង់ជាតិរបស់ខ្លួនយ៉ាងណាក៏ដោយ តែសហព័ន្ធខ្មែរកម្ពុជាក្រោម បានទទួលជោគជ័យនៅលើដំណាក់កាលមួយ គឺបានធ្វើឲ្យពលរដ្ឋខ្មែរក្រោមក្នុងស្រុកបានដឹងអំពីអ្វីដែលជាតិរបស់ខ្លួនចង់បាននាពេលអនាគតហើយ ។

ធម្មតា ការធ្វើបដិវត្តដើម្បីផ្តួលរំលំរបបផ្តាច់ការអ្វីមួយ ឬការតស៊ូមតិដើម្បីផ្លាស់ប្តូរសង្គមណាមួយ ឬក៏ការធ្វើចលនាដើម្បីផ្លាស់ប្តូរផ្នត់គំនិតអ្វីមួយ វាត្រូវចំណាយពេលវេលាយូរណាស់ ។ ដូចជាស្ថានភាពកម្ពុជាក្រោមជាដើម ខ្មែរក្រោមកំពុងតែនៅក្រោមនឹមត្រួតត្រារបស់យួន ហើយរបបយួនកំពុងតែលាងខួរក្បាលយុវជនខ្មែរក្រោមឲ្យភ្លេចនូវប្រវត្តិរបស់ខ្លួនតាមរយៈការសិក្សានៅតាមសាលារៀនយួន ដើម្បីធ្វើឲ្យកូនចៅខ្មែរក្រោមជំនាន់ក្រោយក្លាយទៅជាយួនតាមគំនិតរបស់ ហូ ជី មិញ ថា «ដប់ឆ្នាំដាំដើមឈើ មួយរយឆ្នាំដាំមនុស្ស» ។ ដូច្នេះ ដើម្បីបានដល់គោលដៅ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» នោះ គឺយើងត្រូវការប្រើពេលវេលាមួយ ដើម្បីធ្វើបដិវត្តផ្លាស់ប្តូរផ្នត់គំនិតរបស់ខ្មែរក្រោមគ្រប់រូប ឲ្យប្តូរគំនិតពីការភ័យខ្លាចទៅជាក្លាហាន ក្នុងការប្រើប្រាស់នូវសិទ្ធិជាមូលដ្ឋានរបស់ខ្លួន ជាមុនសិន ។ ពេលដែលពលរដ្ឋខ្មែរក្រោម

ម្នាក់ៗបានស្គាល់នូវសិទ្ធិ និងពង្សាវតាររបស់ខ្លួនហើយ ពួកគាត់នឹងហ៊ានធ្វើអ្វីគ្រប់យ៉ាង ដើម្បីបុព្វហេតុការពារនូវជាតិរបស់ខ្លួនឲ្យបានគង់វង្ស ដោយមិនមានអំណាចអ្វីមកទប់ស្កាត់បានឡើយ ៕

អត្ថបទនេះ បានចុះផ្សាយនៅលើគេហទំព័រ វិទ្យុ សំឡេងកម្ពុជាក្រោម (VOKK)
និង សារព័ត៌មាន ព្រៃនគរ ចេញផ្សាយថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០១៧

# កូស័ងស៊ីន មិនមែនមានន័យថា "នាងទីប្រាំបួនសុំ" ទេ

«កូស័ងស៊ីន» នៅក្នុងភាសាបារាំង ជានាមសព្ទដែលគេហៅសំដៅលើឈ្មោះនៃ «ដែនដីកម្ពុជាក្រោម» នោះ ត្រូវបានជនជាតិយួនហៅផ្តួលទៅជាសំនៀងភាសាយួនថា «កូជិនសិន» ហើយត្រូវបានពលរដ្ឋខ្មែរក្រោមប្រែមកពីភាសាយួនជាខ្មែរថា «នាងទីប្រាំបួនសុំ» គេចង់សំដៅថា ដែនដីកម្ពុជាក្រោម ជាអំណោយដែលជនជាតិយួនបានមកដោយមហេសីយួនសុំពីព្រះរាជាខ្មែរ ។ តើអត្ថន័យពិតនៃពាក្យ «កូស័ងស៊ីន» មានន័យយ៉ាងណាដែរ?

ដែនដីកម្ពុជាក្រោម ត្រូវបានជនជាតិយួនហៅតាមភាសាយួនថា «ណាមគី» (Nam Kỳ) ឬណាមបូ (Nam Bộ) ដែលមានន័យជាភាសាខ្មែរថា «ភាគខាងត្បូង» និងត្រូវបានបារាំង និងពួកបស្ចិមប្រទេសហៅថា «កូស័ងស៊ីន» ឬ «កូស័ងឆៃណា» (Cochin China) ។ ក្រោយមក ជនជាតិយួនមួយចំនួនហៅផ្តួលសំនៀងពាក្យ កូស័ងស៊ីន ទៅជាភាសាយួនថា «កូជិនសិន» (Cô Chín Xin) ដែលមានន័យជាភាសាខ្មែរថា «នាងទីប្រាំបួនសុំ» ដើម្បីបង្វែរដានខ្មែរក្រោមឲ្យយល់ច្រឡំថា ដែនដីកម្ពុជាក្រោមជាកម្មសិទ្ធិរបស់ជនជាតិយួន ដោយសារ ព្រះនាង ង៉ុក វ៉ាំង (Ngọc Vạn) ដែលមហេសី បានសុំពីព្រះបាទ ជ័យជេដ្ឋា ទី ២ ជាព្រះស្វាមីរួចហើយ ។

ខាងក្រោមនេះជាហេតុផលមួយចំនួន ដែលបញ្ជាក់ឲ្យឃើញថា «កូស័ងស៊ីន» មិនមែនមានន័យថា «នាងទីប្រាំបួនសុំ» ដូចយួនថា «កូជិនសិន» នោះទេ ។

**ប្រភពពាក្យ «កូស័ងស៊ីន» (Cochin China)៖**

ពាក្យ «កូស័ងស៊ីន» នៅក្នុងភាសាអង់គ្លេស កាត់ចេញជាពីរសព្ទដាច់ដោយឡែកពីគ្នា គឺ កូស័ង (Cochin) និង ឆៃណា (China) ។ ពាក្យ «កូស័ង» (Cochin) ជាឈ្មោះទីក្រុងកំពង់ផែមួយនៅភាគខាងត្បូងនៃប្រទេសឥណ្ឌា ដែលពួកបស្ចិមប្រទេស ហៅថា Cochin India ។ ជ្រោយនេះ មានទ្រង់ទ្រាយស្រដៀងនឹងជ្រោយទឹកខ្មៅនៃដែនដីកម្ពុជាក្រោមដែរ ។ ចំណែកពាក្យ «ស៊ីន» ឬ «ឆៃណា» (China) វិញ សំដៅលើប្រទេសចិន ។ ពេលពួកបារាំងចុះមកធ្វើអាណានិគមនៅកម្ពុជាក្រោម ពួកគេបានដាក់

ឈ្មោះ កម្ពុជាក្រោមថា «កូស័ងស៊ីន» ឬ «កូស័ងឆៃណា» ដែលមានន័យថា «កូស័ង» ជាប់នឹងប្រទេសចិន ដើម្បីបែងចែកកុំឲ្យច្រឡំគ្នានឹងជ្រោយ «កូស័ងឥណ្ឌា» (Cochin India) ។

**«កូស័ងស៊ីន» ឈ្មោះមានមុនស្តេចខ្មែររៀបអភិសេកជាមួយនឹងស្រីយួនៈ**

យោងតាមផែនទីអាស៊ីអាគ្នេយ៍ដែលបានគូរដោយ លោក ឈើរ៉ាឌូស មើខាតធើ (Gerardus Mercator) ទស្សនវិទូ និងជា គណិតវិទូជនជាតិអាល្លឺម៉ង់ និង លោក ឆែន ហាន់ឌូស (Jan Hondius) នៅឆ្នាំ ១៦០៩ ឃើញថា ពាក្យ កូស័ងស៊ីន (Cochin China) ត្រូវបានគេហៅសំដៅនៅតំបន់តុងកឹង គឺហាណូយភាគខាងជើងប្រទេសវៀតណាមសព្វថ្ងៃ មិនមែនសំដៅលើតំបន់ដែនដីកម្ពុជាក្រោមទេ ។ ម្យ៉ាងទៀត ព្រះបាទជ័យជេដ្ឋា ទី ២ ព្រះមហាក្សត្រខ្មែរ បានរៀបអភិសេកជាមួយនឹងព្រះនាង ង្វៀង ផុក ង៉ុក វ៉ាង (Công nữ Ngọc Vạn) ជាបុត្រីទី ២ របស់ស្តេចយួន ង្វៀង ផុក ង្វៀង ( Nguyễn Phúc Nguyên) នៅក្នុងឆ្នាំ ១៦១៨ ដែលបញ្ជាក់ឲ្យឃើញថា ឈ្មោះ កូស័ងស៊ីន មានមកមុនស្តេចខ្មែររៀបអភិសេកបុត្រីយួនទៅទៀត ។ កត្តានេះ វាផ្ទុយនឹងអ្វីដែលជនជាតិយួនលើកឡើងក្រៅផ្លូវការថា បារាំងបានដាក់ឈ្មោះកម្ពុជាក្រោមថា “កូស័ងស៊ីន” ដើម្បីតបស្នងសងគុណដល់ “នាងទីប្រាំបួន” ដែលបានសុំដែនដីម្តុំនេះពីស្តេចខ្មែរ ។

**នាង ង៉ុក វ៉ាង ជាបុត្រីទី ២ របស់ស្តេចយួន មិនមែនទី ៩ ទេៈ**

យោងតាមប្រវត្តិព្រះនាង ង្វៀង ផុក ង៉ុក វ៉ាង បានបញ្ជាក់ថា ព្រះនាងជាបុត្រីទី ២ របស់ស្តេចយួន ង្វៀង ផុក ង្វៀង មិនមែនជាបុត្រីទី ៩ ទេ ។ យោងតាមសៀវភៅប្រវត្តិព្រះរាជាណាចក្រកម្ពុជាជាភាសាបារាំងឈ្មោះ ហ្វយុាំ ឌូ ខាំបោជហ្គ៍ (Royaume du Cambodge) នៅខែមីនា ឆ្នាំ ១៦១៨ ព្រះបាទ ជ័យចេស្តា ឬ ព្រះបាទ ជ័យជេដ្ឋា ទី ២ ត្រូវបានគេប្រទានព្រះគោរម្យងារជា សម្តេចព្រះជ័យ ចេស្តាធិរាជរាមាធិបតី បរមបពិត្រ ។ ពេលនោះ ស្តេចយួនអាណ្ណាម ក៏បានលើក ព្រះនាង ង៉ុក វ៉ាង ជាបុត្រីរបស់ខ្លួនឲ្យស្តេចខ្មែរ ហើយត្រូវបានគេប្រទានព្រះគោរម្យងារថា សម្តេចព្រះរាជវតីព្រះវររាជក្សត្រី ។

**ពាក្យ «China» ឬ «Chine» មិនមែនប្រែថា «ស៊ុំ» ទេ៖**

យោងតាមអក្សរ «ស៊ុំ» ក្នុងភាសាយួនគេសរសេរថា «Xin» ផ្សំពីតួអក្សរ «X-I-N» មិនមែនជា «China» ឬ «Chine» ដែលសំដៅលើប្រទេស «ចិន» ដូចសព្ទដើមរបស់ពាក្យ «Cochin China» នោះទេ ។ ដូច្នេះ ពាក្យកូសាំងស៊ីន ឬ កូសាំងឆៃណា មានន័យថា «ជ្រោយកូសាំង» នៅជាប់នឹង «ប្រទេសចិន» មិនមែនមានន័យថា ដែនដីដែល «នាងទីប្រាំបួនស៊ុំ» ទេ ។

**កូសាំងស៊ីន ឈ្មោះបារាំងដាក់ឲ្យ៖**

ខ្មែរក្រោមហៅដែនដីតំបន់នេះថា កម្ពុជាក្រោម ចំណែក ជនជាតិយួនហៅជាផ្លូវការថា ណាមគី (Nam Ky) ឬ ណាមបូ (Nam Bo) ខណៈ ពាក្យ «កូសាំងស៊ីន» ត្រូវបានពួកបស្ចិមប្រទេសហៅសំដៅតំបន់តុងកឹង ឬហាណូយ ភាគខាងជើងវៀតណាមបច្ចុប្បន្ន ទៅវិញ ។ ក្រោយមក ពេលបារាំងបានធ្វើអាណានិគមទាំងស្រុងនៅដែនដីកម្ពុជាក្រោម នាឆ្នាំ ១៨៦៧ ពួកគេបានហៅដែនដីកម្ពុជាក្រោម ជាភាសាបារាំងថា «កូសាំងស៊ីន» (Cochin China) ហើយហៅតំបន់អតីតនគរចម្ប៉ា ឬ ភាគកណ្ដាល នៃប្រទេសវៀតណាមបច្ចុប្បន្នថា អាណ្ណាម និង តំបន់ហាណូយ ហៅថា តុងកឹង វិញ ៕

អត្ថបទនេះ បានចុះផ្សាយនៅលើគេហទំព័រ វិទ្យុ សំឡេងកម្ពុជាក្រោម (VOKK)
និង សារព័ត៌មាន ព្រៃនគរ ចេញផ្សាយ នៅឆ្នាំ ២០១៤



UNPFII, NEW YORK, 2019

ភិក្ខុ ថាច់ ប្រីជា គឿន (សុធម្មប្បញ្ញោ) ប្រសូតនៅ ថ្ងៃសៅរ៍ ១៥ កើត ខែបុស្ស ឆ្នាំរកា ត្រីស័ក ព. ស. ២៥២៥ ត្រូវនឹងថ្ងៃទី ២០ ខែមករា គ. ស. ១៩៨១ នៅភូមិផ្តោឈើទាល ឃុំក្រសាំង ស្រុកកំពង់ស្ពាន ខេត្តព្រះត្រពាំង និងបានសាងផ្នួសនៅ វត្តមជ្ឈិមារាម (កណ្តាល) ស្រុកកំពង់ស្ពាន ខេត្តព្រះត្រពាំង តាំងពីឆ្នាំ ១៩៩៨ រហូតមកដល់ សព្វថ្ងៃ ។

ឆ្នាំ ២០០៥ ព្រះអង្គបានភៀសខ្លួនចេញពីស្រុកកំណើត ទៅប្រទេសកម្ពុជា ឆ្នាំ ២០១០ ព្រះអង្គបានភៀសខ្លួនបន្តទៅប្រទេសថៃ និងឆ្នាំ ២០១៣ បានទៅរស់នៅសហរដ្ឋអាមេរិក ។

ព្រះអង្គជា និពន្ធនាយក នៃ សារព័ត៌មាន ព្រៃនគរ តាំងពីឆ្នាំ ២០០៨ មក ។ ពេលបំពេញតួនាទីនៅក្នុងបណ្តាញ សារព័ត៌មាន ព្រៃនគរ ព្រះអង្គជាអ្នកសរសេរព័ត៌មាន រៀបរៀងជាកាសែត និងផលិតជាកម្មវិធីទូរទស្សន៍អនឡាញ ផ្សព្វផ្សាយឲ្យមជ្ឈដ្ឋាននានាបានដឹងអំពីស្ថានភាព និងរឿងរ៉ាវនៅដែនដីកម្ពុជាក្រោម ។

ISBN-13: 978-9924-9321-1-6
9 789924 932116 >